WORLD ANTI-DOPING AGENCY
play true



# ក្រម

# ប្រឆាំងដូប៉ាពិភពលោក

2021

## មាតិកា


គោលបំណង វិសាលភាព និងការរៀបចំកម្មវិធីប្រឆាំងដូប៉ាពិភពលោក និង *ក្រុម*....................11

ក្រុម 11

ហេតុផលសំខាន់សម្រាប់ក្រុមប្រឆាំងដូប៉ាពិភពលោក .................... 14

ប្រការ 1៖ និយមន័យនៃដូប៉ា .................... 18

ប្រការ 2៖ ការបំពានវិធានប្រឆាំងដូប៉ា.................... 18

2.1 វត្តមាននៃ*សារធាតុហាមឃាត់* ឬ*សារធាតុមេតាបូលីល* ឬ*សារធាតុបិទបាំង*នៅក្នុង*សំណាក*របស់*អត្តពលិក*19

2.2 *ការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់សារធាតុហាមឃាត់* ឬ*វិធីសាស្រ្តហាមឃាត់*ដោយ*អត្តពលិក* .......... 19

2.3 ការគេចវេស ការបដិសេធ ឬការខកខានក្នុងការផ្តល់*សំណាក*របស់*អត្តពលិក* .................... 20

2.4 ការខកខានមិនបានផ្តល់ព័ត៌មានអំពីទីសំចតដោយ*អត្តពលិក*.................... 20

2.5 *ការធ្វើឱ្យខូចដំណើរការ* ឬ*ប៉ុនប៉ងរំខាន*ទៅលើផ្នែកណាមួយនៃដំណើរការត្រួតពិនិត្យសារធាតុដូប៉ាដោយ*អត្តពលិក* ឬបុគ្គលផ្សេងទៀត .................... 20

2.6 *ការកាន់កាប់សារធាតុហាមឃាត់* និង*វិធីសាស្រ្តហាមឃាត់*ដោយ*អត្តពលិក* ឬ*អ្នកគាំពារអត្តពលិក*.......... 20

2.7 *ការជួញដូរ* ឬ*ការប៉ុនប៉ងជួញដូរ សារធាតុហាមឃាត់* ឬ*វិធីសាស្រ្តហាមឃាត់*ណាមួយ ដោយ*អត្តពលិក* ឬបុគ្គលផ្សេងទៀត .................... 21

2.8 *ការផ្តល់*ឬ*ការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់* ឬ*វិធីសាស្រ្តហាមឃាត់*ដោយ*អត្តពលិក*ឬបុគ្គលផ្សេងទៀតទៅឱ្យ*អត្តពលិក ក្នុងការប្រកួត* ឬ*ការផ្តល់* ឬ*ការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់* ឬ*វិធីសាស្រ្តហាមឃាត់*ទៅឱ្យ*អត្តពលិក* *ក្រៅការប្រកួត* ដែលត្រូវបានហាមឃាត់នៅ*ក្រៅការប្រកួត*។ .................... 21

2.9 ការរួមគំនិត ឬ*ការប៉ុនប៉ង*រួមគំនិតដោយ*អត្តពលិក* ឬបុគ្គលផ្សេងទៀត.................... 21

2.10 ទំនាក់ទំនងដែលត្រូវបានហាមឃាត់របស់*អត្តពលិក* ឬបុគ្គលផ្សេងទៀត.................... 21

2.11 សកម្មភាពរបស់*អត្តពលិក* ឬបុគ្គលផ្សេងទៀតក្នុងការរារាំង ឬសងសឹកចំពោះការរាយការណ៍ទៅអាជ្ញាធរ 22

ប្រការ 3៖ ការបង្ហាញភស្តុតាងនៃសារធាតុដូប៉ា .................... 22

3.1. បន្ទុក និងស្តង់ដារនៃការបង្ហាញភស្តុតាង.................... 22

3.1.1. *វិធីសាស្រ្ត*នៃការបង្កើតអង្គហេតុ និងការសន្មតទុកជាមុន.................... 23

ប្រការ 4៖ *បញ្ជីហាមឃាត់*.................... 26

4.1. ការបោះពុម្ពផ្សាយ និងការកែសម្រួល*បញ្ជីហាមឃាត់*.................... 26

4.2 *សារធាតុហាមឃាត់* និង*វិធីសាស្រ្តហាមឃាត់* ដែលត្រូវបានកំណត់នៅក្នុង*បញ្ជីហាមឃាត់*.................... 26

4.3 លក្ខណៈវិនិច្ឆ័យសម្រាប់ការរួមបញ្ចូលសារធាតុ និងវិធីសាស្រ្តក្នុង*បញ្ជីហាមឃាត់*.................... 27

4.4 ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល 28

ប្រការ 5៖ *ការធ្វើតេស្ត* និងការស៊ើបអង្កេត 33

5.1 គោរបំណងនៃ *ការធ្វើតេស្ត* និងការស៊ើបអង្កេត 33

5.2 អាជ្ញាធរធ្វើតេស្ត 33

*5.3 ការធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍កីឡា* 34

5.4 លក្ខខណ្ឌតម្រូវនៃ *ការធ្វើតេស្ត* 35

5.5 ព័ត៌មានអំពីទីសំចតរបស់ *អត្តពលិក* 35

5.6 អត្តពលិកចូលនិវត្តន៍ដែលត្រឡប់មកប្រកួតវិញ 36

ប្រការ 6៖ ការវិភាគ *សំណាក* 37

6.1 ការប្រើប្រាស់មន្ទីរពិសោធន៍ដែលត្រូវបានទទួលស្គាល់ និងទទួលសិទ្ធិ និងមន្ទីរពិសោធន៍ផ្សេងទៀត 37

6.2 គោលបំណងនៃការវិភាគ *សំណាក* និងទិន្នន័យ 37

6.3 ការស្រាវជ្រាវលើ *សំណាក* និងទិន្នន័យ 38

6.4 ស្តង់ដារសម្រាប់ការវិភាគ *សំណាក* និងការរាយការណ៍ 38

6.5 ការវិភាគបន្ថែមទៀតលើ *សំណាក* មុនពេល ឬក្នុងអំឡុងពេលនៃ *ដោះស្រាយវិវាទដូប៉ា* ឬដំណើការសវនាការ 38

6.6 ការវិភាគបន្ថែមលើ *សំណាក*ណាមួយ បន្ទាប់ពីវាត្រូវបានគេរាយការណ៍ថា វិជ្ជមាន ឬមិនមានលទ្ធផលក្នុងការចោទប្រកាន់ពីការបំពានវិធានប្រឆាំងដូប៉ា 39

6.7 ការបែងចែក *សំណាក* (ក) ឬ *សំណាក* (ខ) 39

6.8 សិទ្ធិរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ក្នុងការកាន់កាប់ *សំណាក* និងទិន្នន័យ 39

ប្រការ 7៖ ........ *ការដោះស្រាយវិវាទដូប៉ា* ការទទួលខុសត្រូវ ការត្រួតពិនិត្យបឋម ការជូនដំណឹង និងការព្យួរសិទ្ធិបណ្តោះអាសន្ន 40

7.1 ទំនួលខុសត្រូវក្នុងការអនុវត្ត *ការដោះស្រាយវិវាទដូប៉ា* 40

7.2 ការពិនិត្យឡើងវិញ និងការជូនដំណឹងទាក់ទងនឹងការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាសក្តានុពល 42

7.3 ការកំណត់អត្តសញ្ញាណនៃការបំពានវិធានប្រឆាំងដូប៉ា 42

7.4 គោលការណ៍ដែលអនុវត្តចំពោះការព្យួរសិទ្ធិបណ្តោះអាសន្ន 43

7.5 សេចក្តីសម្រេចស្តីពី *ការដោះស្រាយវិវាទដូប៉ា* 45

7.6 ការជូនដំណឹងអំពីសេចក្តីសម្រេចលើ *ការដោះស្រាយវិវាទដូប៉ា* 46

7.7 ការចូលនិវត្តន៍ពីកីឡា 46

ប្រការ 8៖ *ការដោះស្រាយវិវាទដូប៉ា*៖ សិទ្ធិទទួលបានសវនាការយុត្តិធម៌ និងការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់សវនាការ ........ 46

8.1 សវនាការយុត្តិធម៌ ........ 46

8.2 សវនាការ*ព្រឹត្តិការណ៍* ........ 47

8.3 ការបោះបង់សិទ្ធិទទួលបានសវនាការ ........ 47

8.4 ការជូនដំណឹងស្ដីពីការសេចក្ដីសម្រេច ........ 47

8.5 សវនាការតែមួយលើកនៅចំពោមុខមជ្ឈត្តកម្មកីឡា ........ 47

ប្រការ 9៖ ការ*ដកសិទ្ធិ*ដោយស្វ័យប្រវត្តិនៃលទ្ធផលឯកត្តជន ........ 47

ប្រការ 10៖ ការដាក់ទណ្ឌកម្មលើឯកត្តជន ........ 48

10.1 *ដកសិទ្ធិ*នៃលទ្ធផលនៅក្នុង*ព្រឹត្តិការណ៍*ដែលមានការបំពានវិធានប្រឆាំងដូប៉ា ........ 48

10.2 ការ*ព្យួរសិទ្ធិ* ចំពោះវត្តមាន *ការប្រើប្រាស់*ឬប៉ុនប៉ងប្រើប្រាស់ឬ*ការកាន់កាប់ សារធាតុហាមឃាត់*ឬ*វិធីសាស្រ្តហាមឃាត់* ........ 48

10.3 ការ*ព្យួរសិទ្ធិ*សម្រាប់ការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត ........ 50

10.4 *ស្ថានទម្ងន់ទោស*ដែលអាចបង្កើនរយៈពេលនៃការ*ព្យួរសិទ្ធិ* ........ 51

10.5 ការដករយៈពេលនៃការ*ព្យួរសិទ្ធិ*ក្នុងករណីដែលគ្មាន*កំហុស*ឬការ*ធ្វេសប្រហែស* ........ 52

10.6 ការកាត់បន្ថយរយៈពេលនៃការ*ព្យួរសិទ្ធិ*ផ្អែកលើការគ្មាន*កំហុស* ឬការ*ធ្វេសប្រហែស* ........ 52

10.7 ការដក ការកាត់បន្ថយ ឬផ្អាករយៈពេលនៃការ*ព្យួរសិទ្ធិ* ឬ*ផលវិបាក*ផ្សេងសម្រាប់ហេតុផលក្រៅពីកំហុស 53

10.8 កិច្ចព្រមព្រៀង*ការដោះស្រាយវិវាទដូប៉ា* ........ 56

10.9 ការបំពានជាច្រើនដង ........ 58

10.10 ការ*ដកសិទ្ធិ*នៃលទ្ធផលនៅការប្រកួត បន្ទាប់ពីការប្រមូល*សំណាក*ឬការប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា . 60

10.11 ប្រាក់រង្វាន់ដែលត្រូវបានដកយកវិញ ........ 60

10.12 *ផលវិបាក*ហិរញ្ញវត្ថុ ........ 60

10.13 ការចាប់ផ្ដើមនៃរយៈពេល*ព្យួរសិទ្ធិ* ........ 60

10.14 ស្ថានភាពក្នុងកំឡុងពេលនៃការ*ព្យួរសិទ្ធិ*ឬការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* ........ 62

10.15 ការផ្សព្វផ្សាយទណ្ឌកម្មដោយស្វ័យប្រវត្តិ ........ 64

ប្រការ11៖ *ផលវិបាក*សម្រាប់ក្រុម ........ 64

11.1 ការ*ធ្វើតេស្ត*សម្រាប់*កីឡាជាក្រុម* ........ 64

11.2 *ផលវិបាក*សម្រាប់កីឡាជាក្រុម ........ 64

11.3 ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍* ឬសហព័ន្ធអន្តរជាតិអាចបន្ថែម*ផលវិបាក*តឹងរ៉ឹងសម្រាប់កីឡាជាក្រុម ......... **64**

ប្រការ12៖ ការដាក់ទណ្ឌកម្មដោយ*ស្ថាប័នហត្ថលេខី*លើស្ថាប័នកីឡាផ្សេងទៀត .......................................... 65

ប្រការ 13៖ *ការដោះស្រាយវិវាទដូប៉ា*៖ បណ្ដឹងជំទាស់ ........................................................................ 65

13.1 *ការដោះស្រាយវិវាទដូប៉ា* ៖ ប្ដឹងជំទាស់ ............................................................................ **65**

13.2 ការប្ដឹងជំទាស់សេចក្ដីសម្រេចទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា *ផលវិបាក ការព្យួរសិទ្ធិបណ្ដោះអាសន្ន* ការអនុវត្តសេចក្ដីសម្រេច និងសិទ្ធិអំណាច ........................................................................ **67**

13.3. ការខកខានក្នុងការផ្ដល់សេចក្ដីសម្រេចឱ្យបានទាន់ពេលវេលាដោយ*អង្គការប្រឆាំងដូប៉ា* ..................... **70**

13.4. ការប្ដឹងជំទាស់ទាក់ទងនឹង*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ............................................ **70**

13.5. ការជូនដំណឹងអំពីសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ............................................................ **71**

13.6. ការប្ដឹងជំទាស់សេចក្ដីសម្រេចតាមប្រការ 24.1 ..................................................................... **71**

13.7. បណ្ដឹងជំទាស់ពីសេចក្ដីសម្រេចផ្អាក ឬដកហូតការទទួលស្គាល់គុណភាពពិសោធន៍ ............................ **71**

ប្រការ 14៖ ការរក្សាការសម្ងាត់ និងការរាយការណ៍ .............................................................................. 71

14.1 ព័ត៌មានទាក់ទងនឹងលទ្ធផលវិភាគវិជ្ជមាន លទ្ធផលមិនធម្មតា និងការបំពានវិធានប្រឆាំងការប្រើសារធាតុដូប៉ាដែលបានបញ្ជាក់ផ្សេងទៀត ................................................................................ **71**

14.2 ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ឬការបំពានលើសេចក្ដីសម្រេច*ព្យួរសិទ្ធិ* ឬសេចក្ដីសម្រេច*ព្យួរសិទ្ធិបណ្ដោះអាសន្ន* និងការស្នើសុំឯកសារ ..................................................................... **72**

14.3 ការ*ផ្សព្វផ្សាយជាសាធារណៈ* ............................................................................................ **73**

14.4 របាយការណ៍ស្ថិតិ .......................................................................................................... **74**

14.5 មូលដ្ឋានទិន្នន័យនៃការ*ត្រួតពិនិត្យដូប៉ា* និងការត្រួតពិនិត្យអនុលោមភាព ..................................... **74**

14.6 ភាពឯកជននៃទិន្នន័យ ..................................................................................................... **76**

ប្រការ 15៖ ការអនុវត្តសេចក្ដីសម្រេច ................................................................................................ 76

15.1. ផលប៉ះពាល់នៃសេចក្ដីសម្រេចដែលភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិរបស់*អង្គការប្រឆាំងដូប៉ា*ដែលជា*ស្ថាប័នហត្ថលេខី* **76**

15.2 ការអនុវត្តសេចក្ដីសម្រេចផ្សេងទៀតដោយ*អង្គការប្រឆាំងដូប៉ា* .................................................. **77**

15.3 ការអនុវត្តសេចក្ដីសម្រេចដោយស្ថាប័នដែលមិនមែន*ស្ថាប័នហត្ថលេខី* ........................................... **78**

ប្រការ 16 ការ*ត្រួតពិនិត្យដូប៉ា* សម្រាប់ការប្រកួតកីឡាសត្វ ........................................................................ 78

16.1. នៅក្នុងកីឡាណាមួយដែលរួមបញ្ចូលសត្វនៅ*ក្នុងការប្រកួត* សហព័ន្ធអន្តរជាតិសម្រាប់កីឡានោះត្រូវ បង្កើត និងអនុវត្តវិធានប្រឆាំងដូប៉ាចំពោះសត្វដែលមាននៅក្នុងកីឡានោះ។ វិធានប្រឆាំងដូប៉ាត្រូវរួមបញ្ចូល*បញ្ជីសារធាតុហាមឃាត់* នីតិវិធី*ធ្វើតេស្ត* សមស្រប និងបញ្ជីឈ្មោះមន្ទីរពិសោធន៍ដែលបានអនុម័តសម្រាប់ការវិភាគ*សំណាក*។ ............. **78**

16.2. ទាក់ទងទៅនឹងការកំណត់ការបំពានលើវិធានប្រឆាំងដូប៉ា*ការដោះស្រាយវិវាទដូប៉ា* សវនាការដោយយុត្តិធម៌ *ផលវិបាក* និងការប្តឹងជំទាស់ចំពោះសត្វដែលពាក់ព័ន្ធនឹងកីឡាសហព័ន្ធអន្តរជាតិសម្រាប់កីឡានោះត្រូវបង្កើត និងអនុវត្តវិធានដែលជាទូទៅស្របនឹង ប្រការ 1 , 2 , 3 , 9 , 10 , 11 , 13 និង 17 នៃ*ក្រម*នេះ។ ..... 78

ប្រការ 17៖ ច្បាប់អាជ្ញាយុកាល ..... 79

ប្រការ 18៖ ការអប់រំ ..... 81

18.1. គោលការណ៍ ..... 81

18.2. កម្មវិធី និងផែនការអប់រំដោយស្ថាប័នហត្ថលេខី ..... 81

ប្រការ 19៖ ការស្រាវជ្រាវ ..... 83

19.1 គោលដៅ និងគោលបំណងនៃការស្រាវជ្រាវប្រឆាំងដូប៉ា ..... 83

19.2 ប្រភេទនៃការស្រាវជ្រាវ ..... 83

19.3 ការសម្របសម្រួលការស្រាវជ្រាវ និងការចែករំលែកលទ្ធផល ..... 84

19.4 ការអនុវត្តការស្រាវជ្រាវ ..... 84

19.5 ការស្រាវជ្រាវដោយប្រើ *សារធាតុហាមឃាត់* និងវិធីសាស្ត្រហាមឃាត់ ..... 84

19.6 ការប្រើប្រាស់លទ្ធផលមិនត្រឹមត្រូវ ..... 84

ប្រការ20 តួនាទី និងការទទួលខុសត្រូវបន្ថែមរបស់*ស្ថាប័នហត្ថលេខី* និង *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ..... 86

20.1 តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ ..... 86

20.2 តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ ..... 87

20.3 តួនាទី និងការទទួលខុសត្រូវរបស់សហព័ន្ធអន្តរជាតិ ..... 89

20.4 តួនាទី និងការទទួលខុសត្រូវរបស់ *គណៈកម្មាធិការជាតិអូឡាំពិក* និងគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកជាតិ. ..... 91

20.5 តួនាទី និងការទទួលខុសត្រូវរបស់*អង្គការជាតិប្រឆាំងដូប៉ា* ..... 93

20.6 តួនាទី និងការទទួលខុសត្រូវរបស់*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ..... 95

20.7 តួនាទី និងភារកិច្ចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ..... 96

20.8 កិច្ចសហប្រតិបត្តិការទាក់ទងនឹងបទបញ្ញារបស់ភាគីទីបី ..... 97

ប្រការ21៖ តួនាទី និងការទទួលខុសត្រូវបន្ថែមរបស់អត្តពលិក និងបុគ្គលផ្សេងទៀត ..... 98

21.1 តួនាទី និងការទទួលខុសត្រូវរបស់អត្តពលិក ..... 98

21.1.1 ដើម្បីឱ្យមានចំណេះដឹង និងគោរពតាមគោលនយោបាយ និងវិធានប្រឆាំងដូប៉ាដែលអាចអនុវត្តបានទាំងអស់ដែលបានអនុវត្តតាម *ក្រម* នេះ។ ..... 98

21.1.2 ត្រូវអាចរកឃើញសម្រាប់ការប្រមូល*សំណាក* គ្រប់ពេល។ ..... 98

21.1.3 ត្រូវទទួលខុសត្រូវក្នុងបរិបទនៃការប្រឆាំងដូប៉ាំចំពោះអ្វីដែលពួកគេបានលេបចូល និងប្រើប្រាស់។ ........98

21.1.4 ត្រូវជូនដំណឹងដល់បុគ្គលិកពេទ្យអំពីកាតព្វកិច្ចរបស់ពួកគេក្នុងការមិន *ប្រើប្រាស់ សារធាតុហាមឃាត់* និង *វិធីសាស្ត្រហាមឃាត់* និងក្នុងការទទួលខុសត្រូវដើម្បីធ្វើឱ្យប្រាកដថា ការព្យាបាលណាមួយមិនត្រូវបំពានវិធានប្រឆាំងដូប៉ាំទេ។ ........98

21.1.5 ត្រូវបង្ហាញដល់*អង្គការជាតិប្រឆាំងដូប៉ាំ* និងសហព័ន្ធកីឡាអន្តរជាតិរបស់ពួកគេនូវសេចក្ដីសម្រេចណាមួយដោយស្ថាប័នមិនមែនជា*ស្ថាប័នហត្ថលេខី* ដែលរកឃើញថា*អត្តពលិក*បាន ប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ាំក្នុងរយៈពេលដប់ (10) ឆ្នាំកន្លងមក។ ........98

21.1.6 ត្រូវសហការជាមួយ*អង្គការប្រឆាំងដូប៉ាំ*ដែលស៊ើបអង្កេតការបំពានវិធានប្រឆាំងដូប៉ាំ។ ........98

21.1.7 ដើម្បីបង្ហាញពីអត្តសញ្ញាណ *អ្នកគាំពារអត្តពលិក* របស់ពួកគេតាមការស្នើសុំពី *អង្គការប្រឆាំងដូប៉ាំដែល* មានសិទ្ធិអំណាចលើ *អត្តពលិក។* ........98

21.2 តួនាទី និងការទទួលខុសត្រូវរបស់ *អ្នកគាំពារអត្តពលិក* ........98

21.3 តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលផ្សេងទៀតដែលស្ថិតនៅក្រោម*ក្រម*នេះ ........99

21.4 តួនាទី និងការទទួលខុសត្រូវរបស់*អង្គការប្រឆាំងដូប៉ាំ* ........99

ប្រការ 22៖ ការចូលរួមរបស់រដ្ឋាភិបាល ........99

22.1 រដ្ឋាភិបាលនីមួយៗគួរតែចាត់វិធានការ និងវិធានការទាំងអស់ដែលចាំបាច់ដើម្បីអនុលោមតាមអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ។* ........101

22.2. រដ្ឋាភិបាលនីមួយៗគួរតែដាក់ចេញនូវច្បាប់បទបញ្ញាគោលនយោបាយ ឬការអនុវត្តរដ្ឋបាលសម្រាប់៖ កិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មានជាមួយ *អង្គការប្រឆាំងដូប៉ាំ។* ការចែករំលែកទិន្នន័យក្នុងចំណោម *អង្គការប្រឆាំងដូប៉ាំ* ដូចមានចែងក្នុង*ក្រម* ការដឹកជញ្ជូនទឹកនោម និងឈាមដោយគ្មានការហាមឃាត់ *សំណាក* ក្នុងលក្ខណៈដែលរក្សាសន្តិសុខ និងសុចរិតភាពរបស់ពួកគេ។ ការចូល និងចេញដោយគ្មានការដាក់កំហិតរបស់ *មន្ត្រីត្រួតពិនិត្យសារធាតុដូប៉ាំ* និងការចូលដោយគ្មានការដាក់កំហិតចំពោះ *មន្ត្រីត្រួតពិនិត្យដូប៉ាំ* ទៅកាន់គ្រប់តំបន់ដែល *មានអត្តពលិកកម្រិតអន្តរជាតិ* ឬ*អត្តពលិកកម្រិតជាតិ*ហ្វឹកហាត់ ឬបណ្ដុះបណ្ដាលដើម្បីមិនមានការជូនដំណឹងជាមុនអំពីការ *ធ្វើតេស្ត* ដោយ មានការត្រួតពិនិត្យតាមព្រំដែនការធ្វើអន្តោប្រវេសន៍ និងតម្រូវការ និងបទប្បញ្ញត្តិ។ ........101

22.3. រដ្ឋាភិបាលនីមួយៗគួរតែប្រកាន់យកនូវវិធានបទបញ្ញា ឬគោលការណ៍ដាក់វិន័យដល់មន្ត្រី និងនិយោជិតដែលជាប់ពាក់ព័ន្ធក្នុង *ការត្រួតពិនិត្យសារធាតុដូប៉ាំការ* សម្ដែងកីឡា ឬការថែទាំសុខភាពនៅក្នុងការរៀបចំកីឡារួមទាំងសមត្ថភាពត្រួតពិនិត្យសម្រាប់ការចូលរួមក្នុងសកម្មភាពដែលអាចជាការបំពានប្រឆាំងនឹងសារធាតុហាមឃាត់ ច្បាប់ប្រសិនបើវិធានដែលអនុលោមតាម*ក្រម* ត្រូវបានអនុវត្តចំពោះ *បុគ្គលបែបនេះ។* ........101

22.4. រដ្ឋាភិបាលនីមួយមិនគួរអនុញ្ញាតឱ្យ*បុគ្គល*ណាមួយដែលនឹងត្រូវបានចូលរួម នៅក្នុងទីតាំងណាដែលពាក់ព័ន្ធនឹងការ*ត្រួតពិនិត្យដូប៉ាំ* ការសម្ដែងកីឡា ឬការថែទាំវេជ្ជសាស្ត្រនៅក្នុងការកំណត់កីឡារួមទាំងសមត្ថភាពគ្រប់គ្រងមួយដែល*បុគ្គល*ដូច ៖ ........101

(i) ត្រូវបានបម្រើរយៈពេលនៃការ*ព្យួរសិទ្ធិ*មួយសម្រាប់ បំពានវិធានប្រឆាំងដូប៉ាំក្រោម *ក្រម* ឬ ........101

(ii) ប្រសិនបើមិនស្ថិតនៅក្រោមអំណាចរបស់*អង្គការប្រឆាំងដូប៉ាំ* និងក្នុងករណីដែល*ព្យួរសិទ្ធិ* មិនត្រូវបានដោះ

ស្រាយនៅក្នុងដំណើរ*ការដោះស្រាយវិវាទដូប៉ា* យោងតាម *ក្រម* នោះត្រូវបានផ្តន្ទាទោស ឬរកឃើញនៅក្នុងបទឧក្រិដ្ឋវិន័យ ឬនីតិវិធីដែលមានជំនាញវិជ្ជាជីវៈដើម្បីចូលរួមនៅក្នុងការប្រព្រឹត្តដែលបាននឹងបានបង្កើតដែលបំពានវិធានការប្រឆាំងដូប៉ាប្រសិនបើក្រម បានអនុវត្តចំពោះបុគ្គលបែបនេះក្នុងករណីដែលស្ថានភាពគត់នៃបុគ្គលបែបនោះគួរតែនៅក្នុងកម្លាំងសម្រាប់យូរជាងប្រាំមួយ (6) ឆ្នាំចាប់ពីសេចក្តីសម្រេចព្រហ្ម ទណ្ឌវិជ្ជាជីវៈ ឬវិន័យ ឬរយៈពេលនៃការដាក់ទណ្ឌកម្មព្រហ្មទណ្ឌវិន័យ ឬវិជ្ជាជីវៈ។ **101**

22.5. រដ្ឋាភិបាលនីមួយៗគួរតែលើកទឹកចិត្តកិច្ចសហប្រតិបត្តិការរវាងសេវាកម្មសាធារណៈ ឬទីភ្នាក់ងារទាំងអស់របស់ខ្លួន និង*អង្គការប្រឆាំងដូប៉ា* ដើម្បីចែករំលែកព័ត៌មានទាន់ពេលវេលាជាមួយ*អង្គការប្រឆាំងដូប៉ា* ដែលនឹងមានប្រយោជន៍ក្នុងការប្រយុទ្ធប្រឆាំងដូប៉ា ឬបើមិនដូច្នោះទេ ការធ្វើដូចនេះនឹងត្រូវបានហាមឃាត់ដោយច្បាប់។ **101**

22.6. រដ្ឋាភិបាលនីមួយៗគួរតែគោរពមជ្ឈត្តកម្មជាមធ្យោបាយដែលពេញចិត្តក្នុងការដោះស្រាយវិវាទទាក់ទងនឹងសារធាតុដូប៉ាដែលជាកម្មវត្ថុនៃសិទ្ធិមនុស្ស និងមូលដ្ឋាន និងច្បាប់ជាតិដែលអាចអនុវត្តបាន។ **101**

22.7. រដ្ឋាភិបាលនីមួយៗ ដែលមិនមាន*អង្គការជាតិប្រឆាំងដូប៉ា* នៅក្នុងប្រទេសរបស់ខ្លួនគួរតែធ្វើការជាមួយ *គណៈកម្មាធិការជាតិអូឡាំពិក* របស់ខ្លួនដើម្បីបង្កើត។ **101**

22.8. រដ្ឋាភិបាលនីមួយៗគួរតែគោរពស្វ័យភាពរបស់*អង្គការជាតិប្រឆាំងដូប៉ា* នៅក្នុងប្រទេសរបស់ខ្លួន ឬ*អង្គការតំបន់ប្រឆាំងដូប៉ា* ដែលប្រទេសរបស់ខ្លួនជាកម្មសិទ្ធិ និងមន្ទីរពិសោធន៍ដែលបានទទួលស្គាល់ ឬអនុម័តដោយ*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*នៅក្នុងប្រទេសរបស់ខ្លួនហើយមិនជ្រៀតជ្រែកក្នុងការធ្វើសេចក្តីសម្រេច ប្រតិបត្តិការ និងសកម្មភាពរបស់ពួកគេឡើយ ។ **102**

22.9. រដ្ឋាភិបាលនីមួយមិនគួរកំណត់ ឬដាក់កម្រិតការចូលដំណើរការទៅកាន់*សំណាក* ឬកំណត់ត្រា ឬព័ត៌មាន នៃប្រឆាំងដូប៉ា ប្រព្រឹត្ត ឬត្រួតពិនិត្យ ដោយ*ស្ថាប័នហត្ថលេខី* សមាជិកនៃ*ស្ថាប័នហត្ថលេខី*មួយ ឬមន្ទីរពិសោធន៍ទទួលដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ **102**

22.10. ការខកខានដោយរដ្ឋាភិបាលក្នុងការផ្តល់សច្ចាប័នការទទួលយកការយល់ព្រម ឬការយល់ព្រមចំពោះអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ* អាចបណ្តាលឱ្យការប្រជែងសិទ្ធិក្នុងការដេញថ្លៃ និង/ ឬធ្វើជាម្ចាស់ផ្ទះ *ព្រឹត្តិការណ៍* ដូចមានចែងក្នុង ប្រការ 20.1.11 , 20.3.14 និង 20.6.9 និងការបរាជ័យរបស់រដ្ឋាភិបាល ការគោរពតាមអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ*ក្រោយមកដូចដែលបានកំណត់ដោយអង្គការយូណេស្កូ, អាចបណ្តាលអង្គការ*យូណេស្កូ* ផលវិបាកមានអត្ថន័យដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដូចដែលបានកំណត់ និងដោយអង្គការនីមួយ។ **102**

ប្រការ 23 ការទទួលយក និងការអនុវត្ត 103

23.1. ការទទួលយក*ក្រម* **104**

23.2 ការអនុវត្តក្រម **104**

23.3 ការអនុវត្តកម្មវិធីប្រឆាំងដូប៉ា **105**

ប្រការ 24៖ អ្នកឃ្លាំមើល និងការអនុវត្តការអនុលោមតាម*ក្រម* និងអនុសញ្ញាអន្តរជាតិរបស់អង្គការ *យូណេស្កូ* 106

24.1 ការត្រួតពិនិត្យ និងការអនុវត្តការអនុលោមតាម*ក្រម* **106**

24.1 ការត្រួតពិនិត្យការអនុលោមតាមអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ* **113**

ប្រការ 25 ការកែប្រែ និងការដកចេញ 113

25.1. ការកែប្រែ ..... 113

25.2 ការដកការទទួលយកក្រម ..... 114

ប្រការ 26៖ ការបកស្រាយក្រម ..... 114

26.1. អត្ថបទផ្លូវការនៃក្រមនេះនឹងត្រូវបានរក្សាទុកដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ហើយនឹងត្រូវបោះពុម្ពផ្សាយជាភាសាអង់គ្លេស និងបារាំង។ ក្នុងករណីមានភាពខុសគ្នាណាមួយរវាងអត្ថបទជាភាសាអង់គ្លេស និងភាសាបារាំង ត្រូវយកភាសាអង់គ្លេសជាគោល។ ..... 114

26.2. មតិយោបល់ដែលផ្តល់សេចក្តីអធិប្បាយលើបទប្បញ្ញត្តិផ្សេងៗនៃក្រមនេះ ត្រូវយកមកប្រើដើម្បីបកស្រាយ *ក្រម*នេះ ។ ..... 114

26.3. *ក្រម*នេះត្រូវបានបកស្រាយជាអត្ថបទឯករាជ្យ និងស្វយ័ត ហើយមិនយោងទៅលើច្បាប់ ឬលក្ខន្តិកៈដែលមានស្រាប់របស់ស្ថាប័នហត្ថលេខី ឬរដ្ឋាភិបាលនោះទេ។ ..... 114

26.4. ចំណងជើងដែលប្រើសម្រាប់ផ្នែក និងប្រការផ្សេងៗនៃក្រមនេះ គឺសម្រាប់តែភាពងាយស្រួលយល់ប៉ុណ្ណោះ ហើយមិនត្រូវចាត់ទុកថាជាផ្នែកនៃខ្លឹមសាររបស់ *ក្រម*នេះ ឬប៉ះពាល់ដល់ភាសា តាមរបៀបណាមួយ នៃបទប្បញ្ញត្តិដែលចំណងជើងសំដៅលើនោះទេ។ ..... 114

22.1 នៅពេលដែលពាក្យ "ថ្ងៃ" ត្រូវបានប្រើប្រាស់ក្នុង*ក្រម* ឬ*ស្តង់ដារអន្តរជាតិ* វាមានន័យថាជាថ្ងៃប្រតិទិន លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ ..... 114

22.1 *ក្រម*នេះ នឹងមិនត្រូវអនុវត្តចំពោះបញ្ហាដែលមិនទាន់សម្រេចក្នុងលក្ខណៈប្រតិសកម្មមុនកាលបរិច្ឆេទដែលក្រមនេះត្រូវបានទទួលយកដោយស្ថាប័នស្ថាប័នហត្ថលេខី និងអនុវត្តក្នុងវិធានរបស់ខ្លួនឡើយ។ ទោះយ៉ាងណាក៏ដោយ ការបំពានវិធានប្រឆាំងដូប៉ាមុនការទទួលយកក្រម នឹងបន្តរាប់ជា "ការបំពានលើកទីមួយ" ឬ "ការបំពានលើកទីពីរ" ក្នុងគោលបំណងកំណត់ការដាក់ទណ្ឌកម្មតាមប្រការ 10 ចំពោះការបំពាន ក្រោយការទទួលយកក្រមនេះ។ ..... 114

22.1 គោលបំណង វិសាលភាព និងការរៀបចំកម្មវិធីប្រឆាំងដូប៉ាពិភពលោក និង ក្រម និងឧបសម្ព័ន្ធទី 1 និយមន័យ និងឧបសម្ព័ន្ធទី 2 ឧទាហរណ៍នៃការអនុវត្តប្រការ 10 ត្រូវចាត់ទុកជាផ្នែកសំខាន់នៃក្រមនេះ ។ ..... 114

ប្រការ 27៖ អន្តរប្បញ្ញត្តិ ..... 114

27.1 ការអនុវត្តទូទៅនៃក្រម 2021 ..... 114

27.2 មិនមានលក្ខខណៈប្រតិសកម្មទេ លើកលែងតែ ប្រការ 10.9.4 និងប្រការ 17 ឬលុះត្រាតែគោលការណ៍ "Lex Miltor " ត្រូវបានអនុវត្ត ..... 115

27.3 ការដាក់ពាក្យសុំសេចក្តីសម្រេចដែលបានផ្តល់ឱ្យមុនក្រម 2021 ..... 115

27.4 ការបំពានជាច្រើនដែលការបំពានដំបូងកើតឡើងមុនថ្ងៃទី 1 ខែមករាឆ្នាំ 2021 ..... 115

27.5 ការកែប្រែក្រមបន្ថែម ..... 115

27.6 ការផ្លាស់ប្តូរ*បញ្ជីហាមឃាត់* ..... 116

និយមន័យ ..... 117

និយមន័យជាក់លាក់ចំពោះប្រការ 24.1 .................................................................................... **127**

## គោលបំណង វិសាលភាព និងការរៀបចំកម្មវិធីប្រឆាំងដូប៉ាពិភពលោក និង *ក្រម*

គោលបំណងនៃក្រម និងកម្មវិធីប្រឆាំងដូប៉ាពិភពលោកដែលក្រមគាំពារគឺៈ

- ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់អត្តពលិកក្នុងការចូលរួមការប្រកួតកីឡាដែលគ្មានសារធាតុដូប៉ា ហើយក៏ដើម្បីលើកកម្ពស់សុខភាព យុត្តិធម៌ និងសមភាពសម្រាប់ *អត្តពលិក* ទូទាំងពិភពលោក និង

- ដើម្បីធានាឱ្យបាននូវកម្មវិធីប្រឆាំងដូប៉ាដែលមានភាពសុខដុម សម្របសម្រួល និងមានប្រសិទ្ធភាពនៅកម្រិតអន្តរជាតិ និងកម្រិតជាតិ ទាក់ទងនឹងការទប់ស្កាត់ដូប៉ា ដែលរួមមានៈ

*ការអប់រំ* - ដើម្បីលើកកម្ពស់ការយល់ដឹង ជូនដំណឹង ទំនាក់ទំនង ដើម្បីបង្កើនគុណតម្លៃ អភិវឌ្ឍបំណិនជីវិត និងសមត្ថភាពធ្វើសេចក្តីសម្រេច ដើម្បីទប់ស្កាត់ការប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ាទាំងដោយចេតនា និងដោយអចេតនា។

ការធ្វើឱ្យឈប់-ដើម្បីបង្វែរអ្នកប្រើប្រាស់សារធាតុដូប៉ាសក្តានុពល ដោយធានាថាមានប្រព័ន្ធច្បាប់ និងទណ្ឌកម្មរឹងមាំ និងជាក់ស្តែងសម្រាប់អ្នកពាក់ព័ន្ធទាំងអស់។

ការស្វែងរក-ប្រព័ន្ធធ្វើតេស្ត និងការស៊ើបអង្កេតដែលមានប្រសិទ្ធភាព មិនត្រឹមតែបង្កើនប្រសិទ្ធភាពរាំងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានប្រសិទ្ធភាពក្នុងការការពារអត្តពលិកដែលស្អាតស្អំ និងការពារស្មារតីកីឡា ដោយស្វែងរកអ្នកដែលបំពានវិធានប្រឆាំងដូប៉ា ព្រមទាំងជួយបញ្ឈប់បុគ្គលដែលចូលរួមក្នុងដូប៉ា។

ការអនុវត្ត-ដើម្បីវិនិច្ឆ័យ និងដាក់ទណ្ឌកម្មអ្នកដែលត្រូវបានរកឃើញថា បានបំពានវិធានប្រឆាំងដូប៉ា។

នីតិរដ្ឋ-ដើម្បីធានាថា ភាគីពាក់ព័ន្ធទាំងអស់បានយល់ព្រមគោរពតាម *ក្រម* និង *ស្តង់ដារអន្តរជាតិ* ហើយរាល់វិធានការដែលអនុវត្តចំពោះកម្មវិធីប្រឆាំងដូប៉ារបស់ពួកគេគោរព *ក្រម ស្តង់ដារអន្តរជាតិ* និងគោលការណ៍សមាមាត្រ និងសិទ្ធិមនុស្ស។

### ក្រម

*ក្រម* នេះគឺជាឯកសារជាមូលដ្ឋាន និងជាសកលដែលកម្មវិធីប្រឆាំងដូប៉ាពិភពលោកលើវិស័យកីឡាត្រូវយោង។ គោលបំណងនៃក្រមនេះគឺដើម្បីជំរុញកិច្ចប្រឹងប្រែងប្រឆាំងដូប៉ា តាមរយៈការធ្វើសុខដុមនីយកម្មជាសកលនៃធាតុផ្សំសំខាន់នៃសារធាតុដូប៉ា។ វាមានគោលបំណងធ្វើឱ្យជាក់លាក់គ្រប់គ្រាន់ ដើម្បីសម្រេចបាននូវសុខដុមនីយកម្មពេញលេញលើបញ្ហាដែលទាមទារឱ្យមានលក្ខណៈតែមួយ ប៉ុន្តែមានលក្ខណៈទូទៅគ្រប់គ្រាន់នៅក្នុងផ្នែកផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យមានភាពបត់បែនលើរបៀបដែលគោលការណ៍ប្រឆាំងការប្រើសារធាតុហាមឃាត់ត្រូវបានអនុវត្ត។ *ក្រម*នេះត្រូវបានព្រាងឡើងដោយពិចារណាលើគោលការណ៍សមាមាត្រ និងសិទ្ធិមនុស្ស។[1]

### កម្មវិធីប្រឆាំងដូប៉ាពិភពលោក

កម្មវិធីប្រឆាំងដូប៉ាពិភពលោករួមបញ្ចូលនូវធាតុទាំងអស់ដែលចាំបាច់ ដើម្បីធានាបាននូវសុខដុមនីយកម្ម និងឧត្តមានុវត្ត

1 *[សេចក្តីអធិប្បាយៈ ធម្មនុញ្ញអូឡាំពិក និងអនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ាក្នុងវិស័យកីឡា ឆ្នាំ2005 អនុម័តនៅទីក្រុងប៉ារីស នាថ្ងៃទី 19 ខែតុលា ឆ្នាំ2005 ("អនុសញ្ញាយូណេស្កូ") ទទួលស្គាល់ទាំងការការពារ និងប្រឆាំងដូប៉ាក្នុងវិស័យកីឡា ដែលជាផ្នែកមួយដ៏សំខាន់នៃបេសកកម្មរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ និងអង្គការយូណេស្កូ ព្រមទាំងទទួលស្គាល់តួនាទីជាមូលដ្ឋានរបស់ក្រមនេះ។ ]*

នៅក្នុងកម្មវិធីប្រឆាំងដូប៉ាអន្តរជាតិ និងជាតិ។ ជំហានសំខាន់ៗមាន៖

**កម្រិតទី 1៖** *ក្រម*

**កម្រិតទី 2៖** *ស្តង់ដារអន្តរជាតិ* និង *ឯកសារបច្ចេកទេស*

**កម្រិតទី 3៖** គំរូឧត្តមានុវត្ត និងគោលការណ៍ណែនាំ

*ស្តង់ដារអន្តរជាតិ*

*ស្តង់ដារអន្តរជាតិ* សម្រាប់ផ្នែកបច្ចេកទេស និងប្រតិបត្តិការផ្សេងៗ នៅក្នុងកម្មវិធីប្រឆាំងដូប៉ាត្រូវបាន ហើយនឹងត្រូវបានបង្កើតឡើង ដោយមានការពិគ្រោះយោបល់ជាមួយ *ស្ថាប័នហត្ថលេខី* និងរដ្ឋាភិបាល និងអនុម័តដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ គោលបំណងនៃ *ស្តង់ដារអន្តរជាតិ* គឺសុខដុមនីយកម្មក្នុងចំណោម *អង្គការប្រឆាំងដូប៉ា* ដែលទទួលខុសត្រូវចំពោះផ្នែកបច្ចេកទេស និងប្រតិបត្តិការជាក់លាក់នៃកម្មវិធីប្រឆាំងដូប៉ា។ ការប្រកាន់ខ្ជាប់តាម *ស្តង់ដារអន្តរជាតិ* គឺជាកាតព្វកិច្ចសម្រាប់ការអនុលោមតាម *ក្រមនេះ*។ *ស្តង់ដារអន្តរជាតិ* អាចត្រូវបានកែសម្រួលនៅពេលណាមួយ ដោយគណៈកម្មាធិការប្រតិបត្តិនៃ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* បន្ទាប់ពីមានការពិគ្រោះយោបល់ដោយសមហេតុផលជាមួយ *ស្ថាប័នហត្ថលេខី* រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត។

*ស្តង់ដារអន្តរជាតិ* និងការកែប្រែទាំងអស់នឹងត្រូវបោះពុម្ពផ្សាយនៅលើ គេហទំព័ររបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ហើយនឹងចាប់ផ្តើមមានប្រសិទ្ធភាពនៅថ្ងៃដូចដែលបានបញ្ជាក់នៅក្នុង *ស្តង់ដារអន្តរជាតិ* ឬការកែប្រែ។[2]

## ឯកសារបច្ចេកទេស

ឯកសារបច្ចេកទេសទាក់ទងទៅនឹងតម្រូវការចាំបាច់ផ្នែកបច្ចេកទេសសម្រាប់ការអនុវត្តស្តង់ដារអន្តរជាតិ អាចត្រូវបានអនុម័ត និងចុះផ្សាយ នៅពេលណាមួយ ដោយគណៈកម្មាធិការប្រតិបត្តិរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។ ការប្រកាន់ខ្ជាប់ទៅនឹង ឯកសារបច្ចេកទេស គឺជាកាតព្វកិច្ចសម្រាប់ការអនុលោមតាម ក្រមនេះ។ ក្នុងករណីដែលការអនុវត្តឯកសារបច្ចេកទេសថ្មី ឬដែលត្រូវបានកែសម្រួលនេះ មិនមានបញ្ហាទាក់ទងនឹងពេលវេលានោះ គណៈកម្មាធិការប្រតិបត្តិនៃទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកត្រូវអនុញ្ញាតឱ្យមានការពិគ្រោះយោបល់ដោយសមហេតុផលជាមួយ ស្ថាប័នហត្ថលេខី រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត។ ឯកសារបច្ចេកទេស នឹងចាប់ផ្តើមមានប្រសិទ្ធភាពភ្លាមៗ នៅពេលបោះពុម្ពផ្សាយនៅលើគេហទំព័ររបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក លុះត្រាតែមានការបញ្ជាក់ថា នឹងមានប្រសិទ្ធភាពនៅពេលក្រោយ។[3]

គំរូនៃឧត្តមានុវត្ត និងគោលការណ៍ណែនាំ

គំរូនៃឧត្តមានុវត្ត និងគោលការណ៍ណែនាំដែលផ្អែកលើ *ក្រម* និង *ស្តង់ដារអន្តរជាតិ* ត្រូវបាន និងនឹងត្រូវបានបង្កើតឡើង ដើម្បីផ្តល់នូវដំណោះស្រាយនៅក្នុងទិដ្ឋភាពផ្សេងៗនៃការប្រឆាំងដូប៉ា។ គំរូ និងគោលការណ៍ណែនាំនឹងត្រូវបានផ្តល់ជូនដោយ *ទីភ្នាក់*

---

*2 [សេចក្តីអត្ថាធិប្បាយ៖ ស្តង់ដារអន្តរជាតិមានសេចក្តីលម្អិតបច្ចេកទេសជាច្រើនដែលចាំបាច់សម្រាប់ការអនុវត្តក្រមនេះ។ ក្រោមការពិគ្រោះយោបល់ជាមួយស្ថាប័នហត្ថលេខី រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ស្តង់ដារអន្តរជាតិនឹងត្រូវបានបង្កើតឡើងដោយអ្នកជំនាញ និងមានចែងនៅក្នុងឯកសារដាច់ដោយឡែក។ វាជាការសំខាន់ដែលគណៈកម្មាធិការប្រតិបត្តិរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចធ្វើការកែសម្រួលស្តង់ដារអន្តរជាតិបានទាន់ពេលវេលា ដោយមិនតម្រូវឱ្យមានការធ្វើវិសោធនកម្មក្រមនេះឡើយ។]*

*3 [សេចក្តីអធិប្បាយ៖ ឧទាហរណ៍ ក្នុងករណីដែលត្រូវការនីតិវិធីវិភាគបន្ថែមមុនពេលរាយការណ៍សំណាកមួយថាជាលទ្ធផលវិភាគវិជ្ជមាន នីតិវិធីនោះនឹងត្រូវបានកំណត់នៅក្នុងឯកសារបច្ចេកទេស ដែលចេញដោយគណៈកម្មាធិការប្រតិបត្តិរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកភ្លាមៗ។]*

*ងារប្រឆាំងដូប៉ាពិភពលោក* និងផ្តល់ជូនដល់ *ស្ថាប័នហត្ថលេខី* និងអ្នកពាក់ព័ន្ធដទៃទៀត។ បន្ថែមពីលើការផ្តល់នូវគំរូនៃឯកសារប្រឆាំងដូប៉ា *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក៏នឹងផ្តល់ជំនួយបណ្តុះបណ្តាលខ្លះដល់ *ស្ថាប័នហត្ថលេខីដែរ*។ [4]

4 *[សេចក្តីអត្ថាធិប្បាយ៖ ឯកសារគំរូទាំងនេះអាចផ្តល់នូវជម្រើសសម្រាប់ភាគីពាក់ព័ន្ធជ្រើសរើស។ ភាគីពាក់ព័ន្ធខ្លះអាចជ្រើសរើសយកវិធានគំរូ និងគំរូផ្សេងទៀតនៃការអនុវត្តល្អបំផុតគ្រប់ពាក្យទាំងស្រុងបាន។ ភាគីផ្សេងទៀតអាចសម្រេចយកគំរូដោយធ្វើការកែសម្រួល។ ភាគីពាក់ព័ន្ធដទៃទៀតអាចជ្រើសរើសបង្កើតវិធានផ្ទាល់ខ្លួនរបស់ពួកគេស្របតាមគោលការណ៍ទូទៅ និងតម្រូវការដាក់លាក់ដែលមានចែងក្នុងក្រមនេះ។*

ឯកសារគំរូ ឬគោលការណ៍ណែនាំសម្រាប់ផ្នែកជាក់លាក់នៃការងារប្រឆាំង *ដូប៉ា* ត្រូវបានបង្កើត ហើយអាចត្រូវបានបន្តអភិវឌ្ឍន៍ ដោយផ្អែកលើតម្រូវការ និងការរំពឹងទុករបស់ភាគីពាក់ព័ន្ធដែលត្រូវបានទទួលស្គាល់ជាទូទៅ។ ]

## ហេតុផលសំខាន់សម្រាប់ក្រមប្រឆាំងដូប៉ាពិភពលោក

កម្មវិធីប្រឆាំងដូប៉ាត្រូវបានបង្កើតឡើងជាគុណតម្លៃភ្ជាប់នឹងកីឡា។ គុណតម្លៃនេះត្រូវបានហៅថា "ស្មារតីកីឡា"៖ ការខិតខំប្រឹងប្រែងប្រកបដោយវិជ្ជាជីវៈ ដើម្បីសម្រេចបាននូវឧត្តមភាពរបស់មនុស្សតាមរយៈភាពឥតខ្ចោះនៃទេពកោសល្យធម្មជាតិរបស់*អត្តពលិក* នីមួយៗ។

កម្មវិធីប្រឆាំងដូប៉ាមានបំណងការពារសុខភាពរបស់អត្តពលិក និងផ្តល់ឱកាសដល់អត្តពលិកក្នុងឱ្យសម្រេចបាននូវឧត្តមភាពរបស់មនុស្ស ដោយគ្មានការប្រើប្រាស់សារធាតុ និងវិធីសាស្ត្រដែលត្រូវបានហាមឃាត់។

កម្មវិធីប្រឆាំងដូប៉ាក៏មានបំណងការពារសុចរិតភាពកីឡាតាមរយៈការគោរពច្បាប់ ការគោរពគូប្រកួតផ្សេងទៀត ការប្រកួតដោយយុត្តិធម៌ក្នុងមូលដ្ឋានស្មើគ្នា និងគុណតម្លៃនៃកីឡាដែលមានភាពស្អាតស្អំសម្រាប់ពិភពលោក។

ស្មារតីកីឡាគឺជាការសាទរស្មារតី រាងកាយ និងសតិបញ្ញារបស់មនុស្សជាតិ។ វាជាស្នូលនៃកីឡាអូឡាំពិក ហើយដែលត្រូវបានឆ្លុះបញ្ចាំងក្នុងគុណតម្លៃដែលយើងឃើញនៅក្នុងកីឡា និងតាមរយៈកីឡាដូចមានរៀបរាប់ខាងក្រោម៖

- សុខភាព
- សីលធម៌ ការប្រកួតដោយយុត្តិធម៌ និងភាពស្មោះត្រង់
- សិទ្ធិរបស់អត្តពលិកដូចបានកំណត់ក្នុងក្រមប្រឆាំងដូប៉ាពិភពលោក
- ឧត្តមភាពនៃសមត្ថភាព
- ចរិតលក្ខណៈ និងការអប់រំ
- ភាពសប្បាយរីករាយ និងសេចក្តីត្រេកអរ
- ការងារជាក្រុម
- ការលះបង់ និងការប្តេជ្ញាចិត្ត
- ការគោរពច្បាប់ និងបទប្បញ្ញត្តិ
- ការគោរពចំពោះខ្លួនឯង និង អ្នកចូលរួមដទៃទៀត
- ភាពក្លាហាន
- សហគម និងសាមគ្គីភាព

ស្មារតីកីឡាត្រូវបានបង្ហាញនៅក្នុងរបៀបនៃការប្រកួតកីឡាដោយត្រឹមត្រូវ។

ការប្រើប្រាស់សារធាតុគឺផ្ទុយទាំងស្រុងទៅនឹងស្មារតីកីឡា។

ផ្នែកទីមួយ

# ការត្រួតពិនិត្យដូប៉ា

## សេចក្តីផ្តើម

ផ្នែកទី1 នៃក្រមនេះចែងអំពីវិធាន និងគោលការណ៍ប្រឆាំងដូប៉ាជាក់លាក់ ដែលត្រូវអនុវត្តដោយអង្គការដែលទទួលខុសត្រូវក្នុងការអនុម័ត អនុវត្ត ឬពង្រឹងវិធានប្រឆាំងដូប៉ានៅក្នុងសិទ្ធិអំណាចរបស់ខ្លួន ឧទាហរណ៍៖ គណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ សហព័ន្ធកីឡាអន្តរជាតិ *គណៈកម្មាធិការជាតិអូឡាំពិក* និងគណៈកម្មាធិការប៉ារ៉ាឡាំពិក *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* និង*អង្គការជាតិប្រឆាំងដូប៉ា*។ ស្ថាប័នទាំងអស់នេះត្រូវបានហៅជារួមថាជា *អង្គការប្រឆាំងដូប៉ា* ។

បទប្បញ្ញត្តិទាំងអស់នៃក្រមនេះគឺជាលក្ខណ្ឌចាំបាច់ ហើយត្រូវតែអនុវត្តតាម តាមករណីដែលអាចអនុវត្តបានដោយ*អង្គការប្រឆាំងដូប៉ា* និង *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀត។ ទោះយ៉ាងណាក៏ដោយ ក្រមនេះមិនជំនួស ឬលុបបំបាត់តម្រូវការវិធានប្រឆាំងដូប៉ាដ៏ទូលំទូលាយ ដែលត្រូវបានអនុម័តដោយ *អង្គការប្រឆាំងដូប៉ា* នីមួយៗឡើយ។ ខណៈដែលបទប្បញ្ញត្តិមួយចំនួននៃក្រមនេះ ត្រូវតែដាក់បញ្ចូលដោយគ្មានការផ្លាស់ប្តូរសំខាន់ ដោយ *អង្គការប្រឆាំងដូប៉ា* នីមួយៗ ទៅក្នុងវិធានប្រឆាំងដូប៉ារបស់ខ្លួនក៏ដោយ បទប្បញ្ញត្តិផ្សេងទៀតនៃក្រមនេះ បង្កើតគោលការណ៍ណែនាំចាំបាច់ដែលអនុញ្ញាតឱ្យមានភាពបត់បែន ក្នុងការបង្កើតវិធាន ដោយ*អង្គការប្រឆាំងដូប៉ា*នីមួយៗ ឬបង្កើតតម្រូវការដែលត្រូវតែអនុវត្តតាម ដោយ*អង្គការប្រឆាំងដូប៉ា* នីមួយៗ ប៉ុន្តែមិនចាំបាច់ធ្វើឡើងវិញនៅក្នុងវិធានប្រឆាំងដូប៉ាផ្ទាល់ខ្លួនម្តងទៀតឡើយ។[5]

ដូចវិធានស្តីពីការប្រកួតដែរ វិធានប្រឆាំងដូប៉ាជាវិធានកីឡាដែលគ្រប់គ្រងលក្ខខណ្ឌនៃការលេងកីឡា។ *អ្នកគាំពារអត្តពលិក អត្តពលិក ឬ បុគ្គល* ផ្សេងទៀត (រួមទាំងសមាជិកក្រុមប្រឹក្សាភិបាល នាយក មន្ត្រី និងបុគ្គលិកជាក់លាក់ និង *ភាគីទីបី*ដែលបានចាត់តាំង និងបុគ្គលិករបស់ពួកគេ) យល់ព្រមអនុវត្តតាមវិធានទាំងនេះជាលក្ខខណ្ឌនៃការចូលរួម ឬការចូលប្រកួតកីឡា ហើយត្រូវស្ថិតក្នុងវិសាលភាពនៃវិធានទាំងនេះ។[6] ស្ថាប័នហត្ថលេខីនីមួយៗត្រូវបង្កើតវិធាន និងនីតិវិធី ដើម្បីធានាថា *អត្តពលិក*ទាំងអស់ *អ្នកគាំពារអត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនៅក្រោមអំណាចនៃ*ស្ថាប័នហត្ថលេខី*នោះ និងអង្គការជាសមាជិករបស់ខ្លួនត្រូវបានជូនដំណឹង និងយល់ព្រមអនុវត្តតាមវិធានប្រឆាំងដូប៉ាជាធរមានរបស់អង្គការប្រឆាំងដូប៉ា

---

*5 [សេចក្តីអត្ថាធិប្បាយ៖ ប្រការនៃក្រមទាំងនោះ ដែលតម្រូវឱ្យបញ្ចូលទៅក្នុងវិធានរបស់អង្គការប្រឆាំងដូប៉ានីមួយៗដោយគ្មានការផ្លាស់ប្តូរធំដុំ ត្រូវបានកំណត់ក្នុងប្រការ 23.2.2 ។ ឧទាហរណ៍៖ សម្រាប់គោលបំណងនៃការធ្វើសុខដុមនីយកម្ម វាមានសារៈសំខាន់ណាស់ដែលស្ថាប័នហត្ថលេខីទាំងអស់ធ្វើការសម្រេចចិត្តរបស់ខ្លួនដោយផ្អែកលើបញ្ជីដូចគ្នានៃការបំពានលើវិធានប្រឆាំងដូប៉ា បន្ទុកភស្តុតាងដូចគ្នា និងដាក់ទណ្ឌកម្មដូចគ្នា ចំពោះការបំពានលើវិធានប្រឆាំងដូប៉ាដូចគ្នា។ វិធានទាំងនេះត្រូវតែដូចគ្នា មិនថាសវនាការត្រូវបានធ្វើឡើងនៅចំពោះមុខសហព័ន្ធអន្តរជាតិ នៅថ្នាក់ជាតិ ឬនៅចំពោះមុខតុលាការមជ្ឈត្តកម្មកីឡាឡើយ។*

បទប្បញ្ញត្តិនៃក្រមដែលមិនមានរៀបរាប់នៅក្នុងប្រការ 23.2.2 នៅតែជាកាតព្វកិច្ច ទោះបីជា*អង្គការប្រឆាំង*ការប្រើប្រាស់សារធាតុដូប៉ាមិនតម្រូវឱ្យបញ្ចូលវាគ្រប់ពាក្យទាំងស្រុងក៏ដោយ។ បទប្បញ្ញត្តិទាំង នោះជាទូទៅមានពីរប្រភេទ។ ទី1 បទប្បញ្ញត្តិមួយចំនួនណែនាំ*អង្គការប្រឆាំងដូប៉ា*ឱ្យធ្វើសកម្មភាពជាក់លាក់ ប៉ុន្តែមិនចាំបាច់កំណត់ឡើងវិញនូវបទប្បញ្ញត្តិនៅក្នុងវិធានប្រឆាំង*ដូប៉ា*ផ្ទាល់ខ្លួនរបស់*អង្គការប្រឆាំងដូប៉ា*ឡើយ។ ឧទាហរណ៍៖ *អង្គការប្រឆាំងដូប៉ា*នីមួយៗត្រូវរៀបចំផែនការ និងធ្វើតេស្ត ដូចដែលបានតម្រូវក្នុងប្រការ 5 ប៉ុន្តែការណែនាំទៅកាន់ស្ថាប័នប្រឆាំង*ដូប៉ា*មិនចាំបាច់ធ្វើឡើងវិញនៅក្នុងវិធានផ្ទាល់របស់*អង្គការប្រឆាំងដូប៉ា*ម្តងទៀតឡើយ។ ទី2 បទប្បញ្ញត្តិមួយចំនួនមានលក្ខណៈចាំបាច់ ប៉ុន្តែផ្តល់ឱ្យ*អង្គការប្រឆាំងដូប៉ា*នីមួយៗ នូវភាពបត់បែនក្នុងការអនុវត្តគោលការណ៍ដែលមានចែងក្នុងបទប្បញ្ញត្តិនេះ។ ជាឧទាហរណ៍ វាមិនចាំបាច់តម្រូវឱ្យមានសុខដុមនីយកម្មប្រកបដោយប្រសិទ្ធភាព ដើម្បីបង្ខំឱ្យស្ថាប័នហត្ថលេខីទាំងអស់ប្រើប្រាស់ដំណើរ*ការដោះស្រាយវិវាទដូប៉ា*តែមួយនោះទេ ដរាបណាដំណើរការដែលបានប្រើប្រាស់បំពេញតាមតម្រូវការដែលមានចែងក្នុងក្រម និងស្តង់ដារអន្តរជាតិ សម្រាប់*ការដោះស្រាយវិវាទដូប៉ា*។ ]

*6 [សេចក្តីអត្ថាធិប្បាយ៖ ក្នុងករណីដែលក្រមតម្រូវឱ្យបុគ្គលម្នាក់ ដែលមិនមែនជាអត្តពលិក ឬអ្នកគាំពារអត្តពលិក អនុវត្តតាមក្រម បុគ្គលនោះនឹងមិនមែនជាកម្មវត្ថុនៃការប្រមូលសំណាក ឬការធ្វើតេស្តទេ ហើយនឹងមិនត្រូវបានចោទប្រកាន់ពីបទបំពានលើវិធានប្រឆាំងដូប៉ា ក្រោមក្រមនេះឡើយ ចំពោះការប្រើប្រាស់ ឬការកាន់កាប់សារធាតុហាមឃាត់ ឬវិធីហាមឃាត់។ ផ្ទុយទៅវិញ បុគ្គលបែបនេះនឹងត្រូវដាក់វិន័យចំពោះការបំពានប្រការ 2.5 (ការធ្វើឱ្យខូចដំណើរការ) 2.7 (ការជួញដូរ) 2.8 (ការចាក់ចូល) 2.9 (ការសមគំនិត) 2.10 (ទំនាក់ទំនងដែលត្រូវបានហាមឃាត់) និង 2.11 (ការសងសឹក) ។ លើសពីនេះ បុគ្គលនោះត្រូវស្ថិតនៅក្រោមតួនាទី និងការទទួលខុសត្រូវបន្ថែម យោងតាមប្រការ 21.3។ ដូចគ្នានេះដែរ កាតព្វកិច្ចដែលតម្រូវឱ្យបុគ្គលិកម្នាក់អនុវត្តតាមក្រមនេះគឺស្ថិតនៅក្រោមច្បាប់ជាធរមាន។ ]*

ដែលពាក់ព័ន្ធ។

*ស្ថាប័នហត្ថលេខី* នីមួយៗត្រូវបង្កើតវិធាន និងនីតិវិធី ដើម្បីធានាថា *អត្តពលិក អ្នកគាំពារអត្តពលិក ឬបុគ្គល* ផ្សេងទៀត ដែលស្ថិតនៅក្រោមអំណាចរបស់ *ស្ថាប័នហត្ថលេខី* និងអង្គការសមាជិករបស់ខ្លួនត្រូវបានជូនដំណឹងអំពីការផ្សព្វផ្សាយទិន្នន័យឯកជនរបស់ពួកគេ តាមការតម្រូវ ឬតាមការអនុញ្ញាតដោយ *ក្រមនេះ* ហើយត្រូវបានកំណត់ដោយ និងអនុលោមតាមវិធានប្រឆាំងដូប៉ាដែលមាននៅក្នុង *ក្រមនេះ* ហើយថា *ទណ្ឌកម្ម* សមស្របត្រូវបានកំណត់ចំពោះ *អត្តពលិក ឬ បុគ្គល* ផ្សេងទៀតដែលបំពានច្បាប់ទាំងនោះ។ វិធាន និងនីតិវិធីជាក់លាក់នៃកីឡាទាំងនេះ ដែលមានគោលបំណងពង្រឹងវិធានប្រឆាំងដូប៉ា ជាលក្ខណៈសកល និងសុខដុមនីយកម្ម មានលក្ខណៈដោយឡែកពីនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ វាមិនមែនសម្រាប់ជាកម្មវត្ថុ ឬត្រូវបានកំហិតដោយលក្ខខណ្ឌតម្រូវ និងបទដ្ឋានគតិយុត្តរបស់ជាតិ ដែលត្រូវដាក់ឱ្យអនុវត្តចំពោះនីតិវិធីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទេ ទោះបីជាគោលបំណងរបស់វាគឺដើម្បីអនុវត្តតាមរបៀបដែលគោរពគោលការណ៍សមាមាត្រ និងសិទ្ធិមនុស្ស នៅពេលដែលធ្វើការពិនិត្យអង្គហេតុ និងអង្គច្បាប់នៃករណីជាក់លាក់ណាមួយ គ្រប់តុលាការ ក្រុមប្រឹក្សាមជ្ឈតកម្ម និងស្ថាប័នវិនិច្ឆ័យផ្សេងទៀតត្រូវយល់ដឹង និងគោរពលក្ខណៈពិសេសដោយឡែកនៃវិធានប្រឆាំងដូប៉ានៅក្នុង*ក្រម* ព្រមទាំងការពិតដែលថា វិធានទាំងនេះតំណាងឱ្យការព្រមព្រៀងទាំងអស់គ្នារបស់ភាគីពាក់ព័ន្ធ នៅទូទាំងពិភពលោក លើអ្វីដែលជាតម្រូវការចាំបាច់ដើម្បីឱ្យមានការគោរព និងធានាបាននូវការលេងកីឡាដោយយុត្តិធម៌។

ដូចអ្វីដែលមានចែងក្នុងក្រម ទីភ្នាក់ងារប្រឆាំងដូប៉ានីមួយៗត្រូវទទួលខុសត្រូវលើគ្រប់ទិដ្ឋភាពនៃការត្រួតពិនិត្យដូប៉ា។ ទិដ្ឋភាពណាមួយនៃការអប់រំអំពីការត្រួតពិនិត្យសារធាតុដូប៉ា ឬប្រឆាំង*ការប្រើប្រាស់*សារធាតុដូប៉ា អាចត្រូវបានផ្តល់ជូនដោយអង្គភាពប្រឆាំងដូប៉ាទៅជាភាគីទីបី។ ទោះជាយ៉ាងណាក៏ដោយ ការផ្ទេរសិទ្ធិអង្គការប្រឆាំងដូប៉ា តម្រូវឱ្យភាគីទីបីដែលទទួលសិទ្ធិនោះ អនុវត្តទិដ្ឋភាពសំខាន់ៗដែលអនុលោមតាមក្រម និងស្តង់ដារអន្តរជាតិ ហើយអង្គការប្រឆាំងដូប៉ានឹងនៅតែទទួលខុសត្រូវទាំងស្រុងក្នុងការធានាថា រាល់ទិដ្ឋភាពដែលត្រូវបានផ្ទេរឱ្យអនុវត្ត ត្រូវបានអនុវត្តដោយអនុលោមតាមក្រម ។

## ប្រការ 1៖ និយមន័យនៃដូប៉ា

ដូប៉ាត្រូវបានផ្តល់និយមន័យថា ជាការបំពានវិធានប្រឆាំងដូប៉ាមួយ ឬច្រើន ដូចដែលបានចែងក្នុងប្រការ 2.1 រហូតដល់ប្រការ 2.11 នៃ*ក្រម*នេះ។

## ប្រការ 2៖ ការបំពានវិធានប្រឆាំងដូប៉ា

គោលបំណងនៃប្រការ 2 គឺដើម្បីកំណត់ស្ថានភាព និងការអនុវត្ត ដែលត្រូវបានចាត់ទុកថាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា។ សវនាការក្នុងសំណុំរឿងសារធាតុដូប៉ាត្រូវផ្អែកទៅលើការបង្ហាញថាមានការប្រព្រឹត្តិបំពានវិធានជាក់លាក់មួយ ឬច្រើន។

*អត្តពលិក* និងបុគ្គលផ្សេងទៀត ត្រូវទទួលខុសត្រូវស្វែងយល់អំពីថាតើអ្វីដែលត្រូវបានចាត់ទុកថាជាសកម្មភាពបំពានវិធានប្រឆាំងដូប៉ានេះ ព្រមទាំងស្វែងយល់ពីសារធាតុ ឬវិធីសាស្ត្រហាមឃាត់ ដូចដែលមានចែងក្នុង*បញ្ជីសារធាតុហាមឃាត់*។

លក្ខខណ្ឌខាងក្រោមត្រូវបានចាត់ទុកថាជាការប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ា៖

## 2.1 វត្តមាននៃ *សារធាតុហាមឃាត់* ឬ *សារធាតុមេតាបូលីល* ឬ *សារធាតុបិទបាំង*នៅក្នុង *សំណាក*របស់ *អត្តពលិក*

2.1.1 វាជាភារកិច្ចផ្ទាល់ខ្លួនរបស់*អត្តពលិក*ម្នាក់ៗ ដែលត្រូវធានាថា ក្នុងខ្លួនរបស់គេម្នាក់ៗ មិនមាន*សារធាតុហាមឃាត់*។ *អត្តពលិក*ម្នាក់ៗ ត្រូវទទួលខុសត្រូវលើ*សារធាតុហាមឃាត់* ឬ*សារធាតុមេតាបូលីល* ឬ*សារធាតុបិទបាំង* នៅក្នុង*សំណាក*របស់ខ្លួន។ ដូច្នេះ វាមិនសំខាន់ថាតើ វាជាការប្រព្រឹត្តិដោយចេតនា ជា*កំហុស* ឬការធ្វេសប្រហែសនោះទេ ឱ្យតែរកឃើញថា មានសារធាតុហាមឃាត់នៅក្នុង*សំណាក*របស់អត្តពលិកនោះ វានឹងត្រូវបានចាត់ទុកថា ជាការប្រព្រឹត្តបំពានក្រោមប្រការ 2.1 នៃវិធានប្រឆាំងដូប៉ា។[7]

2.1.2 ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា ក្រោមប្រការ 2.1 នេះ ត្រូវបានកំណត់ដោយលក្ខខណ្ឌណាមួយខាងក្រោម៖ មានវត្តមាននៃ*សារធាតុហាមឃាត់* ឬ*សារធាតុមេតាបូលីស* ឬ*សារធាតុបិទបាំង*នៅក្នុង*សំណាក* (ក) របស់*អត្តពលិក* ក្នុងករណីដែលអត្តពលិកបោះបង់ការវិភាគ*សំណាក* (ខ) ហើយ*សំណាក* (ខ) មិនត្រូវបានវិភាគ ឬក្នុងករណីដែល*សំណាក* (ខ) របស់*អត្តពលិក*ត្រូវបានវិភាគ ហើយលទ្ធផលនៃ*សំណាក* (ខ) នោះបញ្ជាក់ពីវត្តមាននៃ*សារធាតុហាមឃាត់* *សារធាតុមេតាបូលីស* ឬ*សារធាតុបិទបាំង* ដែលបានរកឃើញនៅក្នុង*សំណាក* (ក) របស់*អត្តពលិក* ឬក្នុងករណីដែល*សំណាក* (ក) និង*សំណាក* (ខ) របស់*អត្តពលិក*ត្រូវបានបែងចែកជាពីរផ្នែក ហើយលទ្ធផលនៃការវិភាគបំណែកណាមួយបញ្ជាក់ថា មានវត្តមាននៃ*សារធាតុហាមឃាត់* *សារធាតុមេតាបូលីស* ឬ*សារធាតុបិទបាំង* ដែលត្រូវបានរកឃើញនៅក្នុងបំណែកទីមួយនៃសំណាកនោះ ឬ*អត្តពលិក*បោះបង់ការវិភាគបំណែកនៃ*សំណាក*ដែលបានបែងចែកនោះ។[8]

2.1.3 ការលើកលែងចំពោះសារធាតុដែលត្រូវ*កម្រិតនៃសេចក្ដីសម្រេច*ត្រូវបានបញ្ជាក់ជាក់លាក់ក្នុង*បញ្ជីសារធាតុហាមឃាត់* ឬ*ឯកសារបច្ចេកទេស* វត្តមាននៃ*សារធាតុហាមឃាត់* ឬ*សារធាតុមេតាបូលីស* ឬ*សារធាតុបិទបាំង* ក្នុង*សំណាក*របស់*អត្តលិក*ដែលចាត់ទុកថា ជាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា។

2.1.4 ជាការលើកលែងចំពោះវិធានទូទៅនៃប្រការ 2.1 *បញ្ជីសារធាតុហាមឃាត់* *ស្តង់ដារអន្តរជាតិ* ឬ*ឯកសារបច្ចេកទេស*អាចបង្កើត លក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ការរាយការណ៍ ឬការវាយតម្លៃលើ*សារធាតុហាមឃាត់ជាក់លាក់*។

## 2.2 *ការប្រើប្រាស់* ឬ*ការប៉ុនប៉ងប្រើប្រាស់សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ដោយ *អត្តពលិក*[9]

2.2.1 វាជាភារកិច្ចផ្ទាល់ខ្លួនរបស់*អត្តពលិក*ម្នាក់ៗ ដែលត្រូវធ្វើឱ្យប្រាកដថាគ្មាន*សារធាតុហាមឃាត់*នៅក្នុងខ្លួន និងគ្មាន*វិធីសាស្ត្រហាមឃាត់*ណាមួយដែលខ្លួនបានប្រើប្រាស់ឡើយ។ ដូច្នេះ វាមិនសំខាន់ទេថា តើវាជាចេតនា *កំហុស* *ការធ្វេសប្រហែស* ឬជា*ការប្រើប្រាស់*ដោយដឹងមុនរបស់*អត្តពលិក* ដរាបណាមានការបង្ហាញថាមានការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា ចំពោះការ*ប្រើប្រាស់សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*។

2.2.2 វាមិនសំខាន់ទេថា តើ*ការប្រើប្រាស់* ឬ*ការប៉ុនប៉ងប្រើប្រាស់* *សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់* ទទួលបានជោគជ័យ ឬមិនជោគជ័យនោះ។ វាមានភាពគ្រប់គ្រាន់ហើយដែល*សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ត្រូវបាន*ប្រើប្រាស់* ឬ*ប៉ុនប៉ងប្រើប្រាស់* សម្រាប់កំណត់ថាមានការបំពានវិធានប្រឆាំងដូប៉ានោះ។[10]

### 2.3 ការគេចវេស ការបដិសេធ ឬការខកខានក្នុងការផ្តល់*សំណាក*របស់*អត្តពលិក*

ការគេចវេសពីការប្រមូល*សំណាក* ឬការបដិសេធ ឬការខកខានមិនបានផ្តល់*សំណាក*របស់*អត្តពលិក*ដោយមិនបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ បន្ទាប់ពីការជូនដំណឹងដោយបុគ្គលដែលមានសមត្ថកិច្ច ក្នុងការប្រមូល*សំណាក*។[11]

### 2.4 ការខកខានមិនបានផ្តល់ព័ត៌មានអំពីទីសំចតដោយ*អត្តពលិក*

កត្តារួមផ្សំណាមួយនៃការខកខានមិនបានធ្វើតេស្តចំនួន និង/ឬមិនបានបំពេញព័ត៌មានត្រឹមត្រូវ 03 (បី) ដង ដូចដែលបានកំណត់ក្នុង*ស្តង់ដារអន្តរជាតិស្តីពីដោះស្រាយវិវាទដូប៉ា* ក្នុងរយៈពេល 12 (ដប់ពីរ)ខែ ដោយ*អត្តពលិក*ដែលមានឈ្មោះក្នុង*បញ្ជីឈ្មោះធ្វើតេស្ត*។

### 2.5 *ការធ្វើឱ្យខូចដំណើរការ* ឬប៉ុនប៉ង*រំខាន*ទៅលើផ្នែកណាមួយនៃដំណើរការត្រួតពិនិត្យសារធាតុដូប៉ាដោយ*អត្តពលិក* ឬបុគ្គលផ្សេងទៀត

### 2.6 *ការកាន់កាប់សារធាតុហាមឃាត់* និង*វិធីសាស្ត្រហាមឃាត់*ដោយ*អត្តពលិក* ឬ*អ្នកគាំពារអត្តពលិក*

2.6.1 *ការកាន់កាប់សារធាតុហាមឃាត់* ឬប្រើប្រាស់*វិធីសាស្ត្រហាមឃាត់*ណាមួយដោយ*អត្តពលិក*នៅ*ក្នុងការប្រកួត* ឬ*ការកាន់កាប់សារធាតុហាមឃាត់* ឬប្រើប្រាស់*វិធីសាស្ត្រហាមឃាត់*ណាមួយដោយអត្តពលិកនៅ*ក្រៅការប្រកួត* លើកលែងតែ*អត្តពលិក*នោះបង្ហាញថា ការកាន់កាប់នោះស្របតាម*ការលើកលែងឱ្យប្រើប្រាស់ជាថ្នាំព្យាបាល*ដែលអនុញ្ញាតដោយប្រការ 4.4 ឬហេតុផលផ្សេងទៀតដែលអាចទទួលយកបាន។[12]

2.6.2 *ការកាន់កាប់សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ណាមួយដោយ*អ្នកគាំពារអត្តពលិក*នៅ*ក្នុងការប្រកួត* ឬ*ការកាន់កាប់សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ណាមួយដោយ*អ្នកគាំពារអត្តពលិក* នៅ*ក្រៅការប្រកួត* ដែលត្រូវបានហាមឃាត់*នៅក្រៅការប្រកួត* ពាក់ព័ន្ធនឹង*អត្តពលិក* *ការប្រកួត* ឬការហ្វឹកហាត់ លើកលែងតែ*អ្នកគាំពារអត្តពលិក*បង្ហាញថា ការកាន់កាប់នោះ ស្របតាម*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*ដែលអនុញ្ញាតសម្រាប់អត្តពលិកក្រោមប្រការ 4.4 ឬហេតុផលផ្សេងទៀតដែលអាចទទួលយកបាន។[13]

---

*11 [សេចក្តីអធិប្បាយចំពោះប្រការ 2.3 ៖ ឧទាហរណ៍៖ វានឹងជាការបំពានវិធានប្រឆាំងដូប៉ាដែលថា "ការគេចវេសពីការប្រមូលសំណាក" ប្រសិនបើគេអាចបង្ហាញថា អត្តពលិកម្នាក់មានចេតនាគេចវេសពីមន្ត្រីត្រួតពិនិត្យសារធាតុដូប៉ា ដើម្បីគេចពីការទទួលការជូនដំណឹង ឬការធ្វើតេស្ត។ ការបំពានដោយសារ "ការខកខានក្នុងការសហការប្រមូលសំណាក" អាចផ្អែកលើការប្រព្រឹត្តិដោយចេតនា ឬការធ្វេសប្រហែសរបស់អត្តពលិក ខណៈពេលដែល "ការគេចខ្លួន" ឬ "ការបដិសេធ" មិនសហការក្នុងការប្រមូលសំណាក ត្រូវបានចាត់ទុកថាការប្រព្រឹត្តដោយចេតនារបស់អត្តពលិក។]*

*12 [សេចក្តីអធិប្បាយចំពោះប្រការ 2.6.1 និង 2.6.2៖ យុត្តិកម្មដែលអាចទទួលយកបាននឹងមិនរាប់បញ្ចូលហេតុផលដូចជាការទិញ ឬការកាន់កាប់សារធាតុហាមឃាត់ក្នុងគោលបំណងផ្តល់ឱ្យមិត្តភក្តិ ឬសាច់ញាតិឡើយ លើកលែងតែស្ថិតក្រោមកាលៈទេសៈវេជ្ជសាស្ត្រសមហេតុផល ដែលថាបុគ្គលនោះមានវេជ្ជបញ្ជា ឧទាហរណ៍ឱ្យទិញអាំងស៊ុយលីនសម្រាប់កុមារដែលមានជំងឺទឹកនោមផ្អែម។]*

*13 [សេចក្តីអធិប្បាយចំពោះប្រការ 2.6.1 និង 2.6.2៖ យុត្តិកម្មដែលអាចទទួលយកបានអាចរួមបញ្ចូលហេតុផលដូចជា (ក) អត្តពលិក ឬវេជ្ជបណ្ឌិតរបស់ក្រុមកាន់កាប់សារធាតុហាមឃាត់ ឬវិធីហាមឃាត់ ក្នុងបំណងគ្រប់គ្រងស្ថានភាពធ្ងន់ធ្ងរ និងបន្ទាន់ (ឧ. ឧបករណ៍ចាក់បញ្ចូលអេភីនហ្វីនស្វ័យប្រវត្តិ) ឬ (ខ) អត្តពលិកដែលមានសារធាតុហាមឃាត់ន ឬវិធីហាមឃាត់សម្រាប់ហេតុផលព្យាបាលភ្លាមៗ មុនពេលដាក់ពាក្យសុំ និងទទួលបានការកំណត់ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល។*

2.7 *ការជួញដូរ* ឬ*ការប៉ុនប៉ងជួញដូរ សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ណាមួយ ដោយ*អត្តពលិក* ឬបុគ្គលផ្សេងទៀត

2.8 *ការផ្តល់*ឬ*ការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់*ឬ*វិធីសាស្ត្រហាមឃាត់*ដោយ*អត្តពលិក*ឬបុគ្គលផ្សេងទៀតទៅឱ្យ*អត្តពលិក* *ក្នុងការប្រកួត* ឬ *ការផ្តល់* ឬ *ការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់* ឬ *វិធីសាស្ត្រហាមឃាត់*ទៅឱ្យ*អត្តពលិក* *ក្រៅការប្រកួត* ដែលត្រូវបានហាមឃាត់នៅ*ក្រៅការប្រកួត*។

2.9 ការរួមគំនិត ឬ*ការប៉ុនប៉ង*រួមគំនិតដោយ*អត្តពលិក* ឬបុគ្គលផ្សេងទៀត

ការជ្រោមជ្រែង ការលើកទឹកចិត្ត ការគាំទ្រ ការញុះញង់ ការរួមគំនិត ការបិទបាំង ឬការរួមគំនិតដោយចេតនា ឬការ*ប៉ុនប៉ង*រួមគំនិត ទាក់ទងនឹងការប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា *ការប៉ុនប៉ង*ប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា ឬការប្រព្រឹត្តិបំពាននឹងប្រការ 10.14.1 ដោយបុគ្គលណាមួយផ្សេងទៀត។[14]

2.10 ទំនាក់ទំនងដែលត្រូវបានហាមឃាត់របស់*អត្តពលិក* ឬបុគ្គលផ្សេងទៀត

2.10.1 ក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ ឬក្របខ័ណ្ឌកីឡា ទំនាក់ទំនងរបស់*អត្តពលិក* ឬបុគ្គលផ្សេងទៀត ត្រូវស្ថិតក្រោមសិទ្ធិអំណាចរបស់អង្គការប្រឆាំងដូប៉ា សម្រាប់ទំនាក់ទំនងរបស់ពួកគេជាមួយនឹង*អ្នកគាំពារអត្តពលិក* ដែល៖

2.10.1.1 ប្រសិនបើស្ថិតក្រោមសិទ្ធិអំណាចរបស់*អង្គការប្រឆាំងដូប៉ា* កំពុងអនុវត្ត*ការព្យួរសិទ្ធិ* ឬ

2.10.1.2 ប្រសិនបើវាមិនស្ថិតក្រោមសិទ្ធិអំណាចរបស់*អង្គការប្រឆាំងដូប៉ា* ហើយប្រសិនបើ*ការព្យួរសិទ្ធិ* មិនត្រូវបានដោះស្រាយក្នុងដំណើរ*ការដោះស្រាយវិវាទដូប៉ា* ស្របតាមក្រមទេនោះ ឬប្រសិនបើត្រូវបានកាត់ឱ្យជាប់ទោសព្រហ្មទណ្ឌ ឬត្រូវបានរកឃើញក្នុងនីតិវិធីព្រហ្មទណ្ឌ វិន័យ ឬវិជ្ជាជីវៈ ថាមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបំពានវិធានឆាំងដូប៉ា ប្រសិនបើវិធានដែលអនុលោមតាម *ក្រម* ត្រូវបានអនុវត្តចំពោះបុគ្គលនោះ។ ស្ថានភាពនៃការដកសិទ្ធិលើបុគ្គលបែបនេះ នឹងត្រូវមានសុពលភាពសម្រាប់រយៈពេលរហូតដល់ 6(ប្រាំមួយ)ឆ្នាំ ចាប់ពីពេលដែលមានសេចក្តីសម្រេចស្តីពីនីតិវិធីព្រហ្មទណ្ឌ នីតិវិធីវិន័យ ឬវិជ្ជាជីវៈនោះ ឬសម្រាប់រយៈពេលអនុវត្តទោសព្រហ្មទណ្ឌ ទណ្ឌកម្មវិន័យ ឬវិជ្ជាជីវៈនោះ ឬ

2.10.1.3 ដើរតួជាបុគ្គលជួរមុខ ឬអន្តរការី សម្រាប់បុគ្គល ដូចដែលមានចែងក្នុងប្រការ 2.10.1.1 ឬប្រការ 2.10.1.2 ។

2.10.2 ដើម្បីកំណត់ពីការប្រព្រឹត្តិបំពានប្រការ 2.10 *អង្គការប្រឆាំងដូប៉ា* ត្រូវកំណត់ថា*អត្តលិក* ឬបុគ្គលផ្សេងទៀត យល់ដឹងពីស្ថានភាពនៃការដកសិទ្ធិរបស់*អ្នកគាំពារអត្តពលិក*នោះ។

14 *[សេចក្តីអធិប្បាយចំពោះប្រការ 2.9៖ ការសមគំនិត ឬការប៉ុនប៉ងសមគំនិតអាចរួមបញ្ចូលទាំងជំនួយផ្នែករាងកាយ ឬផ្លូវចិត្ត។ ]*

បន្ទុកត្រូវស្ថិតនៅលើ*អត្តពលិក* និង*បុគ្គល*ផ្សេងទៀតដែលត្រូវកំណត់ថា ទំនាក់ទំនងណាមួយជាមួយ*អ្នកគាំពារអត្តពលិក* ដែលមានចែងក្នុងប្រការ 2.10.1.1 ឬប្រការ 2.10.1.2 គឺមិនមែនក្នុងក្របខ័ណ្ឌអាជីព ឬទាក់ទងនឹងកីឡា និង/ឬទំនាក់ទំនងបែបនោះជាទំនាក់ទំនងមិនអាចចៀសបាន ដោយហេតុផលសមរម្យ។

*អង្គការប្រឆាំងដូប៉ា* ដែលបានមានព័ត៌មានអំពី*អ្នកគាំពារអត្តពលិក* ដូចដែលបានរៀបរាប់នៅក្នុងប្រការ 2.10.1.1 ប្រការ 2.10.1.2 ឬប្រការ 2.10.1.3 ត្រូវផ្តល់ព័ត៌មាននោះទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ។[15]

### 2.11 សកម្មភាពរបស់*អត្តពលិក* ឬបុគ្គលផ្សេងទៀតក្នុងការរារាំង ឬសងសឹកចំពោះការរាយការណ៍ទៅអាជ្ញាធរ

ក្នុងករណីដែលការប្រព្រឹត្តិនោះមិនត្រូវបានចាត់ទុកថាជាការបំពានប្រឆាំងដូប៉ាក្នុងប្រការ 2.5៖

2.11.1 អំពើដែលគំរាមគំហែង ឬព្យាយាមបំភិតបំភ័យដល់បុគ្គលណាម្នាក់ ក្នុងបំណងរារាំង បុគ្គលនោះមិនឱ្យរាយការណ៍ដោយស្មោះត្រង់ នូវព័ត៌មានដែលជាប់ទាក់ទងនៃការបំពានវិធានប្រឆាំងដូប៉ា ឬការចោទប្រកាន់ថា មិនបានគោរពតាមក្រម ទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬ*អង្គការប្រឆាំងដូប៉ា* មន្ត្រីអនុវត្តច្បាប់ ស្ថាប័នច្បាប់ វិជ្ជាជីវៈ ឬវិន័យ ក្រុមប្រឹក្សាសវនាការ ឬបុគ្គលដែលធ្វើការស៊ើបអង្កេតរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬ*អង្គការប្រឆាំងដូប៉ា*។

2.11.2 ការសងសឹកប្រឆាំងបុគ្គលណាម្នាក់ដែល ក្នុងបំណងសុចរិត បានផ្តល់នូវភស្តុតាង ឬព័ត៌មានទាក់ទងទៅនឹងការចោទប្រកាន់ថាមានការបំពានវិធានប្រឆាំងដូប៉ា ឬការចោទប្រកាន់ថាមានការមិនអនុវត្តតាម *ក្រម* ឱ្យទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អង្គការប្រឆាំងដូប៉ា* មន្ត្រីអនុវត្តច្បាប់ ស្ថាប័នអនុវត្តច្បាប់ ស្ថាប័នដាក់ទណ្ឌកម្មវិជ្ជាជីវៈ ឬវិន័យ ក្រុមប្រឹក្សាសវនាការ ឬបុគ្គលដែលធ្វើការស៊ើបអង្កេតរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬ*អង្គការប្រឆាំងដូប៉ាជាតិ*។[16]

សម្រាប់គោលបំណងនៃប្រការ 2.11 ការសងសឹក ការគំរាមគំហែង ឬការបំភិតបំភ័យ រួមបញ្ចូលទាំងសកម្មភាពដែលធ្វើឡើងប្រឆាំងបុគ្គលណាម្នាក់ ទោះដោយមូលហេតុដែលថាការរាយការណ៍នោះខ្វះមូលដ្ឋាននៃភាពសុចរិត ឬជាការឆ្លើយតបដែលមិនសមាមាត្រ។[17]

---

## ប្រការ 3៖ ការបង្ហាញភស្តុតាងនៃសារធាតុដូប៉ា

### 3.1. បន្ទុក និងស្តង់ដារនៃការបង្ហាញភស្តុតាង

*អង្គការប្រឆាំងដូប៉ា* ត្រូវមានកាតព្វកិច្ចបង្ហាញថា ការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាបានកើតឡើង។ ស្តង់ដារនៃការ

---

15 *[សេចក្តីអធិប្បាយចំពោះប្រការ 2.10៖ អត្តពលិក និងបុគ្គលផ្សេងទៀតមិនត្រូវធ្វើការជាមួយគ្រូបង្វឹក អ្នកបណ្តុះបណ្តាល គ្រូពេទ្យ ឬបុគ្គលិកគាំទ្រអត្តពលិកផ្សេងទៀត ដែលត្រូវបានព្យួរសិទ្ធិ ក្រោមវិធានប្រឆាំងដូប៉ា ឬអ្នកដែលត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ ឬវិន័យវិជ្ជាជីវៈទាក់ទងនឹងការប្រើសារធាតុដូប៉ាឡើយ។ ចំណុចនេះក៏ហាមឃាត់ទំនាក់ទំនងជាមួយអត្តពលិកដទៃទៀត ដែលបំពេញតួនាទីជាគ្រូបង្វឹក ឬអ្នកគាំទ្រអត្តពលិកដែលកំពុងអនុវត្តការព្យួរសិទ្ធិដែរ។ ឧទាហរណ៍មួយចំនួននៃប្រភេទទំនាក់ទំនងដែលត្រូវបានហាមឃាត់រួមមាន៖ ការទទួលការបណ្តុះបណ្តាល យុទ្ធសាស្ត្រ បច្ចេកទេស អាហារូបត្ថម្ភ ឬដំបូន្មានវេជ្ជសាស្ត្រ, ការទទួលឱ្យសថ ការព្យាបាល ឬវេជ្ជបញ្ជា, ការផ្តល់ផលិតផលជំនួយរាងកាយណាមួយសម្រាប់ការវិភាគ, ឬការអនុញ្ញាតឱ្យបុគ្គលគាំទ្រអត្តពលិកធ្វើជាភ្នាក់ងារ ឬអ្នកតំណាង។ ទំនាក់ទំនងដែលត្រូវបានហាមឃាត់មិនត្រូវការពាក់ព័ន្ធនឹងទម្រង់នៃការផ្តល់សំណងណាមួយឡើយ។ ខណៈដែលប្រការ* 2.10 មិនតម្រូវឱ្យ*អង្គការប្រឆាំងដូប៉ា*ជូនដំណឹងដល់អត្តពលិក ឬបុគ្គលផ្សេងទៀតអំពីស្ថានភាពនៃការបាត់បង់សិទ្ធិរបស់អ្នកគាំទ្រអត្តពលិក ការជូនដំណឹងបែបនេះ ប្រសិនបើត្រូវបានផ្តល់ នឹងក្លាយជាភស្តុតាងសំខាន់ ដើម្បីបញ្ជាក់ថា អត្តពលិក ឬបុគ្គលផ្សេងទៀតដឹងពីស្ថានភាពនៃការបាត់បង់សិទ្ធិរបស់បុគ្គលគាំទ្រអត្តពលិក។ ]

បង្ហាញភស្តុតាងនេះគឺអាចថា *អង្គការប្រឆាំងដូប៉ា* ត្រូវបង្ហាញថាមានការប្រព្រឹត្តិបំពានកើតឡើងដែល ក្រុមប្រឹក្សាជំនុំជម្រះអាចជឿជាក់បាន ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃការចោទប្រកាន់។ ស្តង់ដារនៃការបង្ហាញភស្តុតាងនៅក្នុងគ្រប់ករណី គឺប្រសើរជាងការដែលគ្រាន់តែបង្ហាញតុល្យការនៃលទ្ធភាពដែលអាចកើតមាន ប៉ុន្តែនៅមានទម្ងន់តិចជាងភស្តុតាងលើសពីវិមតិសង្ស័យ។[18] ក្នុងករណីដែលវិធានប្រឆាំងដូប៉ា ដាក់បន្ទុកនៃការបង្ហាញភស្តុតាងលើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា ដើម្បីបដិសេធការសន្មតជាមុន ឬបង្កើតអង្គហេតុ ឬកាលៈទេសៈជាក់លាក់ លើកលែងតែដូចអ្វីដែលមានចែងក្នុងប្រការ 3.2.2 និង 3.2.3 ស្តង់ដារនៃការបង្ហាញភស្តុតាងត្រូវផ្អែកលើតុល្យការនៃភាពដែលអាចកើតឡើង។

## 3.2. វិធីសាស្ត្រនៃការបង្កើតអង្គហេតុ និងការសន្មតទុកជាមុន

អង្គហេតុដែលទាក់ទងការបំពានវិធានប្រឆាំងដូប៉ា អាចត្រូវបានបង្កើតឡើង ដោយមធ្យោបាយដែលគួរឱ្យជឿជាក់ណាមួយ ព្រមទាំងការសារភាព។[19] ខាងក្រោមនេះជាវិធានបង្ហាញភស្តុតាងដែលត្រូវអនុវត្តចំពោះសំណុំរឿងសារធាតុដូប៉ា ៖

3.2.1 វិធីសាស្ត្រនៃការវិភាគ ឬ*កម្រិតនៃសេចក្តីសម្រេច*ដែលអនុម័តដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* បន្ទាប់ពីការប្រឹក្សាយោបល់នៅក្នុងសហគមន៍វិទ្យាសាស្ត្រពាក់ព័ន្ធ ឬដែលជាកម្មវត្ថុនៃការពិនិត្យឡើងវិញដោយសហការីក្នុងវិស័យ ត្រូវបានសន្មតទុកជាមុនថា ត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ។ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដែលជំទាស់នឹងលក្ខខណ្ឌនៃការសន្មតទុកជាមុននេះ ឬបដិសេធសុពលភាព បែបវិទ្យាសាស្ត្រនៃការសន្មតទុកជាមុននេះ តាមលក្ខខណ្ឌតម្រូវជាមុនសម្រាប់ការជំទាស់បែបនេះ ត្រូវជូនដំណឹងទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ជាមុនអំពីការជំទាស់ និងមូលដ្ឋាននៃការជំទាស់នោះ។ ស្ថាប័នសវនាការបឋម ស្ថាប័នបណ្តឹងជំទាស់ ឬ*មជ្ឈត្តកម្មកីឡា* ក្រោមគំនិតផ្តួចផ្តើមរបស់ខ្លួន អាចផ្តល់ព័ត៌មានទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អំពីការជំទាស់ណាមួយ។ នៅក្នុងរយៈពេល 10 (ដប់)ថ្ងៃ បន្ទាប់ពី *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ទទួលការជូនដំណឹង និងសំណុំរឿងពាក់ព័ន្ធនឹងការជំទាស់នេះ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងមានសិទ្ធិធ្វើអន្តរាគមន៍ក្នុងនាមជាភាគីមួយ ដោយដើរតួជាអ្នកជូនយោបល់តុលាការ ឬក៏ផ្តល់ភស្តុតាងផ្សេងក្នុងនីតិវិធីតុលាការ។ ក្នុងសំណុំរឿងនៅចំពោះមុខមជ្ឈត្តកម្មកីឡា តាមការស្នើសុំរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មជ្ឈត្តកម្មកីឡា* ដែលត្រូវបានតែងតាំងអ្នកជំនាញវិទ្យាសាស្ត្រសមស្រប ដើម្បីជាជំនួយ

16 *[សេចក្តីអធិប្បាយចំពោះប្រការ 2.11.2៖ ប្រការនេះមានបំណងការពារបុគ្គលដែលរាយការណ៍ដោយស្មោះត្រង់ និងមិនការពារបុគ្គលដែលរាយការណ៍មិនពិតដោយចេតនា។ ]*

17 *[សេចក្តីអធិប្បាយចំពោះប្រការ 2.11.2 ៖ ការសងសឹករួមបញ្ចូលទាំងសកម្មភាពដែលគំរាមកំហែងដល់សុខុមាលភាពរាងកាយ ឬផ្លូវចិត្ត ឬផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នករាយការណ៍ គ្រួសារ ឬសហការីរបស់ពួកគេ។ ការសងសឹកមិនរាប់បញ្ចូលស្ថានភាពដែលអង្គការប្រឆាំងដូប៉ាកំណត់ ដោយស្មោះត្រង់ ថាជាការបំពានលើវិធានប្រឆាំងសារធាតុហាមឃាត់ប្រឆាំងនឹងបុគ្គលរាយការណ៍នោះទេ។ សម្រាប់គោលបំណងនៃប្រការ 2.11 របាយការណ៍មិនត្រូវបានធ្វើឡើងដោយស្មោះត្រង់ទេ ប្រសិនបើបុគ្គលរាយការណ៍ដឹងថារបាយការណ៍នោះមិនពិត។ ]*

18 *[សេចក្តីអធិប្បាយចំពោះប្រការ 3.1៖ ស្តង់ដារភស្តុតាងដែលតម្រូវឱ្យបំពេញដោយអង្គការប្រឆាំងដូប៉ាអាចប្រៀបធៀបទៅនឹងស្តង់ដារដែលត្រូវបានអនុវត្តនៅក្នុងប្រទេសភាគច្រើន ចំពោះករណីពាក់ព័ន្ធនឹងការប្រព្រឹត្តខុសវិជ្ជាជីវៈ។ ]*

19 *[សេចក្តីអធិប្បាយចំពោះប្រការ 3.2៖ ឧទាហរណ៍៖ អង្គការប្រឆាំងដូប៉ាអាចបង្ហាញថាមានការបំពានលើវិធានប្រឆាំងសារធាតុហាមឃាត់ក្រោមប្រការ 2.2 ដោយផ្អែកលើការសារភាពរបស់អត្តពលិក ការផ្តល់សក្ខីកម្មគួរឱ្យទុកចិត្តរបស់បុគ្គលទីបី ភស្តុតាងឯកសារដែលអាចទុកចិត្តបាន ទិន្នន័យវិភាគដែលអាចជឿទុកចិត្តបានពីសំណាក ក ឬសំណាក ខ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីអធិប្បាយចំពោះប្រការ 2.2 ឬសេចក្តីសន្និដ្ឋានដែលដកស្រង់ចេញពីប្រវត្តិរូបឈាម ឬទឹកនោមរបស់អត្តពលិក ដូចជាទិន្នន័យពីប្រវត្តិជីវសាស្ត្រអត្តពលិកជាដើម។ ]*

ដល់ក្រុមប្រឹក្សាក្នុងការវាយតម្លៃនៃសំណុំរឿងរបស់ខ្លួនចំពោះការជំទាស់នោះ។[20]

3.2.2 មន្ទីរពិសោធន៍ដែលទទួលស្គាល់គុណភាពដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលអនុម័តដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវបានសន្មតថាបានធ្វើវិភាគ*សំណាក* និងអនុវត្តនីតិវិធីចាំបាច់ ដោយអនុលោមតាម*ស្តង់ដារអន្តរជាតិ*ស្តីពីមន្ទីរពិសោធន៍អន្តរជាតិ។ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត អាចបដិសេធការសន្មតជាមុននេះ ដោយបង្ហាញថា មានការអនុវត្តប្រាសចាកពី*ស្តង់ដារអន្តរជាតិ*ស្តីពីមន្ទីរពិសោធន៍អន្តរជាតិ បានកើតឡើងដែលអាចបណ្តាលឱ្យមាន*លទ្ធផលវិភាគអវិជ្ជមាន*។

ប្រសិនបើ*អត្តពលិក* ឬ*បុគ្គល*ដទៃទៀត បដិសេធការសន្មតជាមុន ដោយបង្ហាញថា មានការអនុវត្តប្រាសចាកពី*ស្តង់ដារអន្តរជាតិ*ស្តីពីមន្ទីរពិសោធន៍ ដែលអាចបណ្តាលឱ្យមាន*លទ្ធផលវិភាគវិជ្ជមាន* នោះ*អង្គការប្រឆាំងដូប៉ា*មានភារកិច្ចទទួលបន្ទុកបង្ហាញថា ការប្រាសចាកនោះមិនបង្កឱ្យមាន*លទ្ធផលវិភាគវិជ្ជមាន*ទេ។ ដែលមិនបានបង្កមកពី*លទ្ធផលវិភាគវិជ្ជមាន*នោះទេ។[21]

3.2.3 ការប្រាសចាកពី*ស្តង់ដារអន្តរជាតិ*ណាមួយ ឬវិធានប្រឆាំងដូប៉ា ឬគោលនយោបាយ ដូចដែលមានចែងនៅក្នុង*ក្រម* ឬវិធានប្រឆាំងដូប៉ាទាំងនេះ នឹងមិនមោឃភាពលើលទ្ធផលវិភាគ ឬភស្តុតាងផ្សេងទៀតនៃការបំពានវិធានប្រឆាំងដូប៉ាទេ និងមិនត្រូវបានយកជាសំអាងហេតុ ចំពោះការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ានេះឡើយ [22]ទោះបីក្នុងករណីដែលថា *អត្តពលិក* ឬ*អ្នកគាំពារអត្តពលិ*កបង្ហាញថា មានការប្រាសចាកពីបទប្បញ្ញត្តិនៃ*ស្តង់ដារអន្តរជាតិ*ជាក់លាក់ណាមួយខាងក្រោមក្នុងហេតុផលសមស្រប បានបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើ*លទ្ធផលវិភាគវិជ្ជមាន* ឬការខកខានមិនបានផ្តល់ព័ត៌មានអំពីទីសំចតនោះ *អង្គការប្រឆាំងដូប៉ា*ត្រូវទទួលបន្ទុកបង្ហាញថា ការប្រាសចាកពីស្តង់ដារនោះ មិនបង្កជាមូលហេតុនៃ*លទ្ធផលវិភាគវិជ្ជមាន*ទេ ឬការខកខានក្នុងផ្តល់ព័ត៌មានអំពីអំពីទីសំចត ទេ៖

(i) ការប្រាសចាកពី*ស្តង់ដារអន្តរជាតិ*ស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត ដែលទាក់ទងនឹងការប្រមូល

20 *[សេចក្តីអធិប្បាយចំពោះប្រការ 3.2.1៖ ចំពោះសារធាតុហាមឃាត់មួយចំនួន ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចណែនាំមន្ទីរពិសោធន៍ដែលខ្លួនទទួលស្គាល់មិនឱ្យរាយការណ៍អំពីសំណាកថាជាលទ្ធផលវិភាគវិជ្ជមាន ប្រសិនបើកំហាប់ប៉ាន់ស្មាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាបូលី ឬសារធាតុបិទបាំងរបស់វាស្ថិតនៅក្រោមកម្រិតរាយការណ៍អប្បបរមា។ សេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងការកំណត់ដែលថា តើកម្រិតរាយការណ៍អប្បបរមា ឬសារធាតុហាមឃាត់ណាគួរស្ថិតក្រោមកម្រិតរាយការណ៍អប្បបរមា មិនអាចត្រូវបានយកជាកម្មវត្ថុនៃការជំទាស់ឡើយ។ លើសពីនេះ កំហាប់ប៉ាន់ស្មានរបស់មន្ទីរពិសោធន៍អំពីសារធាតុហាមឃាត់នៅក្នុងសំណាកមួយអាចគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ គ្មានករណីណាដែលលទ្ធភាពកំហាប់ជាក់លាក់នៃសារធាតុហាមឃាត់នៅក្នុងសំណាកអាចទាបជាងកម្រិតរាយការណ៍អប្បបរមា អាចត្រូវបានយកជាអំណះអំណាងការពារចំពោះការបំពានលើវិធានប្រឆាំងដូប៉ា ដោយផ្អែកលើវត្តមាននៃសារធាតុហាមឃាត់នៅក្នុងសំណាកនោះទេ។ ]*

21 *[សេចក្តីអធិប្បាយចំពោះប្រការ 3.2.2 ៖ បន្ទុកគឺស្ថិតនៅលើអត្តពលិក ឬបុគ្គលផ្សេងទៀត ដើម្បីបង្ហាញ តាមលទ្ធភាពដែលថាការប្រាសចាកពីស្តង់ដារអន្តរជាតិសម្រាប់មន្ទីរពិសោធន៍ទំនងជាកើតឡើង ដែលអាចបង្កឱ្យមានការរកឃើញការវិភាគវិជ្ជមាន។ ដូច្នេះ នៅពេលអត្តពលិក ឬបុគ្គលផ្សេងទៀតអាចបង្ហាញតាមលទ្ធភាពការប្រាសចាក អាចកើតឡើង បន្ទុករបស់អត្តពលិក ឬបុគ្គលផ្សេងទៀតលើបុព្វហេតុនោះគឺជាស្តង់ដារភស្តុតាងទាបជាង "លទ្ធភាពដែលបានកើតឡើងដោយសមគួរ"។ ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតបំពេញតាមស្តង់ដារនេះ បន្ទុកត្រូវប្តូរទៅអង្គការប្រឆាំងដូប៉ា ដើម្បីបញ្ជាក់ពីការពេញចិត្តនៃក្រុមប្រឹក្សាជំនុំជម្រះ ដែលថាការប្រាសចាកនេះមិនបានបណ្តាលឱ្យមានការរកឃើញការវិភាគវិជ្ជមានទេ។ ]*

22 *[សេចក្តីអធិប្បាយចំពោះប្រការ 3.2.3៖ ការប្រាសចាកពីស្តង់ដារអន្តរជាតិ ឬវិធានផ្សេងទៀត ដែលមិនទាក់ទងទៅនឹងការប្រមូល ឬការយកសំណាក លទ្ធផលប្រវត្តិជីវសាស្ត្រវិជ្ជមាន ឬការខកខានក្នុងការផ្តល់ព័ត៌មានអំពីកន្លែងស្នាក់របស់អត្តពលិក ឬការបើកសំណាក ខ ឧទាហរណ៍ - ស្តង់ដារអន្តរជាតិសម្រាប់ការអប់រំស្តង់ដារអន្តរជាតិសម្រាប់ការការពារឯកជនភាព និងព័ត៌មានផ្ទាល់ខ្លួន ឬស្តង់ដារអន្តរជាតិសម្រាប់ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល អាចបណ្តាលឱ្យមានដំណើរការនីតិវិធីស្តីពីអនុលោមភាព ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ប៉ុន្តែមិនមែនជាអំណះអំណាងការពារនៅក្នុងនីតិវិធីស្តីពីការបំពានវិធានប្រឆាំងដូប៉ាទេ និងក៏មិនពាក់ព័ន្ធនឹងបញ្ហាថាតើអត្តពលិកបានប្រព្រឹត្តិបំពានលើវិធានប្រឆាំងដូប៉ា ឬអត់ដែរ។ ស្រដៀងគ្នានេះដែរ ការបំពានលើឯកសាររបស់អង្គការប្រឆាំងដូប៉ា ដូចមានចែងក្នុងប្រការ 20.7.7 នឹងមិនអាចត្រូវបានយកជាអំណះអំណាងការពារចំពោះការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុឡើយ។ ]*

*សំណាក* ឬការគ្រប់គ្រង*សំណាក* ដែលអាចជាមូលហេតុបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ាផ្អែកលើ*លទ្ធផលវិភាគវិជ្ជមាន* ដែលក្នុងករណីនេះ *អង្គការប្រឆាំងដូប៉ា* ត្រូវទទួលបង្ហាញថាការប្រាសចាកពីស្តង់ដារនោះ មិនបង្កជាមូលហេតុនៃ*លទ្ធផលវិភាគវិជ្ជមាន*ទេ។

(ii) ការប្រាសចាកពី*ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទ*ដូប៉ា ឬ*ស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត* និងការស៊ើបអង្កេត ដែលទាក់ទងនឹង*លទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ* ដែលជាមូលហេតុបង្កឱ្យមានលើការបំពានវិធានប្រឆាំងដូប៉ា ដែលក្នុងករណីនេះ *អង្គការប្រឆាំងដូប៉ា* ត្រូវទទួលបន្ទុកបង្ហាញថាការប្រាសចាកពីស្តង់ដារនោះ មិនបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ាទេ។

(iii) ការប្រាសចាកពី*ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទ* ដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃការផ្តល់ការជូនដំណឹងទៅអត្តពលិកអំពីការបើក*សំណាក* (ខ) ដែលក្នុងហេតុផលសមស្រប បង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើ*លទ្ធផលវិភាគវិជ្ជមាន*ដែលក្នុងករណីនេះ *អង្គការប្រឆាំងដូប៉ា* ត្រូវទទួលបន្ទុកបង្ហាញថា ការប្រាសចាកពីស្តង់ដារនោះ មិនបង្កជាមូលហេតុនៃ*លទ្ធផលវិភាគវិជ្ជមាន*ទេ។ [23]

(iv) ការប្រាសចាកពី*ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា* ដែលក្នុងហេតុផលសមស្រប អាចបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើការខកខាន មិនបានផ្តល់ព័ត៌មានអំពីកន្លែងស្នាក់របស់អត្តពលិក ដែលក្នុងករណីនេះ អង្គការប្រឆាំងដូប៉ា ត្រូវទទួលបន្ទុកបង្ហាញថា ការប្រាសចាកនោះមិនបង្កឱ្យមានការខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចតរបស់អត្តពលិកទេ។

3.2.4 អង្គហេតុដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់តុលាការ ឬសាលាវិនិច្ឆ័យដែលសមត្ថកិច្ច ដែលមិនមែនជាកម្មវត្ថុនៃបណ្តឹងជំទាស់ដែលកំពុងដំណើរការ គឺជាភស្តុតាងមិនអាចបដិសេធបានប្រឆាំងនឹងអត្ត ពលិក ឬបុគ្គលដទៃទៀត សម្រាប់អ្នកដែលសេចក្តីសម្រេចពាក់ព័ន្ធនឹងអង្គហេតុនោះ លើកលែងតែ*អត្តពលិក* ឬ*បុគ្គល*ដទៃទៀត បង្ហាញថាសេចក្តីសម្រេចនោះបានបំពានលើគោលការណ៍យុត្តិធម៌។

3.2.5 ក្រុមប្រឹក្សាជំនុំជម្រះនៅក្នុងពេលសវនាការ លើករណីបំពានវិធានប្រឆាំងដូប៉ា អាចទាញសេចក្តីសន្និដ្ឋានវិជ្ជមានចំពោះ*អត្តពលិក* ឬ*បុគ្គល*ដទៃទៀត ដែលត្រូវបានអះអាងថាបានបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើការបដិសេធរបស់*អត្តពលិក* ឬ*បុគ្គល*ដទៃទៀត បន្ទាប់ពីទទួលបានសំណើក្នុងរយៈពេលសមស្របមុនពេលសវនាការ ដើម្បីបង្ហាញខ្លួននៅក្នុងសវនាការនោះ (ទាំងបង្ហាញខ្លួនដោយផ្ទាល់ ឬតាមទូរស័ព្ទ តាមការបង្គាប់ដោយក្រុមប្រឹក្សាជំនុំជម្រះ) ព្រមទាំងឆ្លើយសំនួររបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គការប្រឆាំងដូប៉ា។

23 *[សេចក្តីអធិប្បាយចំពោះប្រការ 3.2.3 (iii)៖ អង្គការប្រឆាំងដូប៉ានឹងបំពេញភារកិច្ចរបស់ខ្លួនដើម្បីកំណត់ថា ការប្រាសចាកបែបនេះមិនបណ្តាលឱ្យមានលទ្ធផលវិភាគវិជ្ជមានទេ ដោយបង្ហាញថា ឧទាហរណ៍ ការបើក និងវិភាគសំណាក ខ ត្រូវបានពិនិត្យដោយសាក្សីឯករាជ្យ ហើយគ្មានភាពមិនប្រក្រតីណាមួយត្រូវបានគេសង្កេតឃើញទេ។ ]*

## ប្រការ 4៖ *បញ្ជីហាមឃាត់*

### 4.1. ការបោះពុម្ពផ្សាយ និងការកែសម្រួល *បញ្ជីហាមឃាត់*

*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ត្រូវមានភាពចាំបាច់ និងមិនតិចជាងរៀងរាល់ឆ្នាំជារៀងរាល់ឆ្នាំក្នុងការបោះពុម្ពផ្សាយ *បញ្ជីហាមឃាត់*ជា*ស្តង់ដារអន្តរជាតិ*។ ខ្លឹមសារដែលបានស្នើនៃ *បញ្ជីហាមឃាត់* និងការកែប្រែទាំងអស់ត្រូវផ្តល់ជូនជាលាយលក្ខណ៍អក្សរភ្លាមៗដល់ស្ថាប័នហត្ថលេខី និងរដ្ឋាភិបាលទាំងអស់ដើម្បី ផ្តល់យោបល់ និងពិគ្រោះយោបល់។ កំណែប្រចាំឆ្នាំនៃ*បញ្ជីហាមឃាត់* ហើយការកែប្រែទាំងអស់នឹងត្រូវបានចែកចាយភ្លាមដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ជូនហត្ថលេខីនីមួយៗ មន្ទីរពិសោធនទ៍ស្គាល់ ឬអនុម័តដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* និងរដ្ឋាភិបាល ហើយនឹងត្រូវបានចេញផ្សាយនៅលើគេហទំព័ររបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និងស្ថាប័នហត្ថលេខីនឹងចាត់វិធានការសមស្របដើម្បីចែកបញ្ជីហាមឃាត់ដល់សមាជិក និងសមាសភាពរបស់ខ្លួន។ វិធានរបស់អង្គការប្រឆាំងដូប៉ានីមួយៗ ត្រូវបញ្ជាក់ថា លុះត្រាតែមានចែងផ្សេងពីនេះនៅក្នុង*បញ្ជីហាមឃាត់* ឬការពិនិត្យឡើងវិញ *បញ្ជីហាមឃាត់* និងការកែប្រែ នឹងត្រូវចូលជាធរមានតាមច្បាប់របស់អង្គការប្រឆាំងដូប៉ា ក្នុងរយៈពេលបី (បី) ខែបន្ទាប់ពីការបោះពុម្ពផ្សាយ *បញ្ជីហាមឃាត់* ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដោយមិនតម្រូវឱ្យមានសកម្មភាពណាមួយបន្ថែមទៀត ដោយអង្គការប្រឆាំងដូប៉ា។[24]

### 4.2 *សារធាតុហាមឃាត់* និង *វិធីសាស្ត្រហាមឃាត់* ដែលត្រូវបានកំណត់នៅក្នុង *បញ្ជីហាមឃាត់*

#### 4.2.1 *សារធាតុហាមឃាត់* និង *វិធីសាស្ត្រហាមឃាត់*

*បញ្ជីហាមឃាត់*ត្រូវកំណត់អត្តសញ្ញាណនៃ *សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់* ដែលត្រូវបានហាមឃាត់ថាជាសារធាតុដូប៉ាគ្រប់ពេលវេលា (ទាំង*ក្នុងការប្រកួត* និង *ក្រៅការប្រកួត*) ដោយសារឥទ្ធិពលរបស់វាក្នុងការបង្កើនកម្លាំងរបស់*អត្តពលិក* ពេល*ប្រកួតនា*ពេលអនាគត ឬឥទ្ធិពលបិទបាំងរបស់វា ព្រមទាំងសារធាតុ និងវិធីសាស្ត្រ ដែលត្រូវបានហាមឃាត់សម្រាប់តែ*ក្នុងការប្រកួត*។ *បញ្ជីហាមឃាត់*អាចត្រូវបានកែសម្រួលដោយ *ទីភ្នាក់ងារប្រឆាំងនឹងដូប៉ាពិភពលោក* សម្រាប់ប្រភេទកីឡាជាក់លាក់។ *សារធាតុហាមឃាត់* និង*វិធីសាស្ត្រហាមឃាត់*អាចត្រូវបានបញ្ចូលក្នុង *បញ្ជីហាមឃាត់*តាមប្រភេទទូទៅ (ឧទាហរណ៍៖ សារធាតុអាណាបូលីស) ឬសម្រាប់សារធាតុ និងវិធី សាស្ត្រជាក់លាក់ណាមួយ។[25]

#### 4.2.2 *សារធាតុជាក់លាក់ ឬវិធីសាស្ត្រជាក់លាក់*

សម្រាប់គោលបំណងនៃការអនុវត្តប្រការ 10 រាល់*សារធាតុហាមឃាត់*ទាំងអស់ ត្រូវជាសារធាតុជាក់លាក់ លើកលែងដូចអ្វីដែលត្រូវបានកំណត់នៅក្នុង *បញ្ជីហាមឃាត់*។ គ្មាន*វិធីសាស្ត្រហាមឃាត់*ណាជា*វិធីសាស្ត្រ*

---

*24 [សេចក្តីអធិប្បាយចំពោះប្រការ 4.1៖ បញ្ជីហាមឃាត់នឹងត្រូវបានកែសម្រួល និងបោះផ្សាយតាមពេលវេលាកំណត់នៅពេលមានតម្រូវការ។ ទោះយ៉ាងណាក៏ដោយ ដើម្បីជាផលប្រយោជន៍ដល់ការព្យាករណ៍ បញ្ជីហាមឃាត់ថ្មីមួយនឹងត្រូវបោះផ្សាយជារៀងរាល់ឆ្នាំ ទោះបីមាន ឬគ្មានការផ្លាស់ប្តូរក៏ដោយ។ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនឹងរក្សាបញ្ជីហាមឃាត់ចុងក្រោយបំផុតគ្រប់ពេល ដែលត្រូវបានបោះផ្សាយនៅលើគេហទំព័ររបស់ខ្លួន។ បញ្ជីហាមឃាត់គឺជាផ្នែកសំខាន់មួយនៃអនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ាក្នុងវិស័យកីឡា។ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនឹងជូនដំណឹងដល់អគ្គនាយកអង្គការយូណេស្កូអំពីការផ្លាស់ប្តូរណាមួយចំពោះបញ្ជីហាមឃាត់។]*

*25 [សេចក្តីអធិប្បាយចំពោះប្រការ 4.2.1 ៖ ការប្រើប្រាស់ក្រៅការប្រកួតនូវសារធាតុដែលត្រូវបានហាមឃាត់តែនៅក្នុងការប្រកួត មិនមែនជាការបំពានវិធានប្រឆាំងដូប៉ាទេ លុះត្រាតែមានលទ្ធផលវិភាគវិជ្ជមានចំពោះសារធាតុ ឬសារធាតុមេតាប៉ូលី ឬសារធាតុបិទបាំងរបស់វាពីសំណាកដែលប្រមូលបានក្នុងការប្រកួត។]*

*ដាក់លាក់*ទ លើកលែងតែមានការកំណត់ច្បាស់លាស់ថា វាជាវិធីសាស្ត្រដាក់លាក់នៅក្នុង *បញ្ជីហាមឃាត់*។[26]

4.2.3 *សារធាតុបំពាន*

សម្រាប់គោលបំណងនៃការអនុវត្តប្រការ 10 រាល់ *សារធាតុបំពាន*ទាំងអស់ត្រូវរាប់បញ្ចូលទាំង *សារធាតុហាមឃាត់*ដែលត្រូវបានកំណត់ដាក់លាក់ ថាជា *សារធាតុបំពាន*នៅក្នុង *បញ្ជីហាមឃាត់* ព្រោះសារធាតុបែបនេះជាញឹកញាប់ ត្រូវបានប្រើដោយបំពាននៅក្នុងសង្គម ក្រៅពីបរិបទរបស់កីឡា។

4.2.4 ចំណាត់ថ្នាក់ថ្មីនៃ *សារធាតុហាមឃាត់* ឬ *វិធីសាស្ត្រហាមឃាត់*

នៅក្នុងព្រឹត្តិការណ៍ដែល *ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក* ពង្រីក *បញ្ជីហាមឃាត់* ដោយបន្ថែមថ្នាក់ថ្មីនៃ *សារធាតុហាមឃាត់* ឬ *វិធីសាស្ត្រហាមឃាត់* យោងតាម ប្រការ 4.1 គណៈកម្មា ធិការប្រតិបត្តិរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក*ត្រូវកំណត់ថា តើ *សារធាតុហាមឃាត់* ឬ *វិធីសាស្ត្រហាមឃាត់ណាមួយ* នៅក្នុងថ្នាក់ថ្មីត្រូវចាត់ទុកថាជា *សារធាតុដាក់លាក់* ឬ *វិធីសាស្ត្រហាមឃាត់* ប្រការ 4.2.2 ឬ *សារធាតុបំពាន* ក្រោម ប្រការ 4.2.3 ។

## 4.3 លក្ខណៈវិនិច្ឆ័យសម្រាប់ការរួមបញ្ចូលសារធាតុ និងវិធីសាស្ត្រក្នុង *បញ្ជីហាមឃាត់*

*ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក* ត្រូវពិចារណាលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមក្នុងការសម្រេចថា តើត្រូវបញ្ចូលសារធាតុ ឬវិធីសាស្ត្រក្នុង *បញ្ជីហាមឃាត់* ៖

4.3.1 សារធាតុ ឬវិធីសាស្ត្រមួយដែលត្រូវយកមកពិចារណាក្នុងការដាក់បញ្ចូលក្នុង *បញ្ជីហាមឃាត់* ប្រសិនបើ *ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក* តាមឆន្ទានុសិទ្ធិរបស់ខ្លួនកំណត់ថា សារធាតុ ឬវិធីសាស្ត្រនោះបំពេញតាមលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងពីរខាងក្រោម៖

4.3.1.1 ភស្តុតាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រផ្សេងទៀតឥទ្ធិពលឱសថសាស្ត្រ ឬបទពិសោធន៍ដែលសារធាតុ ឬវិធីសាស្ត្រតែម្នាក់ឯង ឬរួមបញ្ចូលគ្នាជាមួយសារធាតុ ឬវិធីសាស្ត្រផ្សេងទៀតមានសក្តានុពលក្នុងការលើកកម្ពស់ ឬបង្កើនសមត្ថភាពកីឡា។[27]

4.3.1.2 ភស្តុតាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រផ្សេងទៀត ឥទ្ធិពលឱសថសាស្ត្រ ឬបទពិសោធន៍ដែលការ*ប្រើប្រាស់*សារធាតុ ឬវិធីសាស្ត្របង្ហាញពីហានិភ័យសុខភាពជាក់ស្តែង ឬសក្តានុពលចំពោះ*អត្តពលិក*។

4.3.1.3 ការប្តេជ្ញាចិត្តរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក* ថាការ*ប្រើប្រាស់* សារធាតុ ឬវិធីសាស្ត្របំពាន

---

*26 [សេចក្តីអធិប្បាយចំពោះប្រការ 4.2.2៖ សារធាតុដែលបានកំណត់ និងវិធីសាស្ត្រដាក់លាក់ដែលបានកំណត់ក្នុងប្រការ 4.2.2 មិនគួរត្រូវបានចាត់ទុកថាមានសារៈសំខាន់ ឬគ្រោះថ្នាក់តិចជាងវិធី ឬសារធាតុដូប៉ាំផ្សេងទៀតឡើយ។ ផ្ទុយទៅវិញ វាគ្រាន់តែជាសារធាតុ និងវិធីសាស្ត្រដែលទំនងជាត្រូវបានប្រើប្រាស់ ឬប្រើប្រាស់ដោយអត្តពលិកម្នាក់ ក្នុងគោលបំណងផ្សេងក្រៅពីការពង្រឹងសមត្ថភាពកីឡា។ ]*

*27 [សេចក្តីអធិប្បាយចំពោះប្រការ 4.3.1.1៖ ប្រការនេះរំពឹងទុកថា អាចមានសារធាតុ ដែលនៅពេលប្រើតែវាមួយមុខ មិនត្រូវបានហាមឃាត់ទេ ប៉ុន្តែត្រូវហាមឃាត់ប្រសិនបើប្រើរួមគ្នាជាមួយសារធាតុផ្សេងទៀត។ សារធាតុមួយដែលត្រូវបានបញ្ចូលទៅក្នុងបញ្ជីហាមឃាត់ ព្រោះវាមានសក្តានុពលក្នុងការពង្រឹងសមត្ថភាព តែក្នុងករណីដែលប្រើរួមផ្សំជាមួយសារធាតុផ្សេងទៀត គួរត្រូវបានសម្គាល់ទុក ហើយត្រូវហាមឃាត់ លុះត្រាតែមានភស្តុតាងបង្ហាញថាមានការប្រើសារធាតុទាំងពីរនេះរួមបញ្ចូលគ្នា។ ]*

លើស្មារតីនៃកីឡាដែលបានពិពណ៌នានៅក្នុងសេចក្តីណែនាំនៃ *ក្រម* នេះ ។

4.3.2 សារធាតុ ឬវិធីសាស្ត្រ ក៏ត្រូវបញ្ចូលក្នុង *បញ្ជីហាមឃាត់* ផងដែរ ប្រសិនបើ *ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក* កំណត់ថា មានភស្តុតាងផ្នែកវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រផ្សេងទៀត ផលប៉ះពាល់ឱសថ ឬបទពិសោធន៍ដែល សារធាតុ ឬវិធីសាស្ត្រមានសក្តានុពលក្នុងការបិទបាំងការ *ប្រើប្រាស់សារធាតុហាមឃាត់* ឬ *វិធីសាស្ត្រហាមឃាត់* ផ្សេងទៀត។[28]

4.3.3 ការកំណត់សារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់របស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោក* ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុង *បញ្ជីហាមឃាត់* ការកំណត់ចំណាត់ថ្នាក់សារធាតុនៅក្នុង *បញ្ជីហាមឃាត់* ការកំណត់ចំណាត់ថ្នាក់សារធាតុមួយថាជាសារធាតុហាមឃាត់ គ្រប់ពេលវេលា ឬសារធាតុហាមឃាត់សម្រាប់តែ *ក្នុងការប្រកួត* ការកំណត់ចំណាត់ថ្នាក់នៃសារធាតុ ឬវិធីសាស្ត្រថាជា *សារធាតុជាក់លាក់ វិធីសាស្ត្រជាក់លាក់* ឬ *សារធាតុបំពាន* គឺជាការសម្រេច/កំណត់ចុងក្រោយ និងមិនអាចត្រូវបានជំទាស់ដោយ *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀតណាម្នាក់ឡើយ រួមបញ្ចូលទាំងការជំទាស់ផ្អែកលើទឡ្ហីករណ៍ដែលថាសារធាតុ ឬវិធីសាស្ត្រនោះមិនមែនជាសារធាតុបិទបាំង ឬមិនមានសក្តានុពលបង្កើនកម្លាំងអត្តពលិក នាំឱ្យមានហានិភ័យសុខភាព ឬបំពានលើស្មារតីកីឡាបានទេ។

## 4.4 ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

4.4.1 វត្តមាននៃ *សារធាតុហាមឃាត់* ឬ *សារធាតុមេតាបូលីស* ឬ *សារធាតុបិទបាំង* និង/ឬការ *ប្រើប្រាស់* ឬការ *ប៉ុនប៉ងប្រើប្រាស់ ការកាន់កាប់* ឬ *ការផ្តល់* ឬ *ការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់* ឬ *វិធីសាស្ត្រហាមឃាត់* មិនត្រូវបានចាត់ទុកថា ជាការបំពានវិធានប្រឆាំងដូប៉ាំឡើយ ប្រសិនបើវាស្របនឹងបទប្បញ្ញត្តិនៃ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ដែលអនុលោមតាម *ស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*។

4.4.2 *អត្តពលិក* ដែលមិនមែនជា *អត្តពលិកកម្រិតអន្តរជាតិ* ត្រូវដាក់ពាក្យសុំទៅ *អង្គការជាតិប្រឆាំងដូប៉ាំ* របស់ពួកគេសម្រាប់ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*។ ប្រសិនបើ *អង្គការជាតិប្រឆាំងដូប៉ាំ* បដិសេធការស្នើសុំនេះ *អត្តពលិក* អាចប្តឹងជំទាស់ទៅស្ថាប័នជំទាស់ដែលមានចែងក្នុងប្រការ 13.2.2 ។

4.4.3 *អត្តពលិក* ដែលជា *អត្តពលិកកម្រិតអន្តរជាតិ* ត្រូវដាក់ពាក្យទៅសហព័ន្ធអន្តរជាតិរបស់ខ្លួន។[29]

4.4.3.1 ក្នុងករណីដែល *អត្តពលិក ទទួលបានការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* រួចទៅហើយពី

---

28 *[សេចក្តីអធិប្បាយចំពោះប្រការ 4.3.2៖ ជាផ្នែកមួយនៃដំណើរការជារៀងរាល់ឆ្នាំ ស្ថាប័នហត្ថលេខី រដ្ឋាភិបាល និងបុគ្គលដែលមានចំណាប់អារម្មណ៍ផ្សេងទៀតត្រូវបានអញ្ជើញឱ្យផ្តល់មតិយោបល់ដល់ទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោកលើខ្លឹមសារនៃបញ្ជីហាមឃាត់។ ]*

29 *[សេចក្តីអធិប្បាយចំពោះប្រការ 4.4.3៖ ប្រសិនបើសហព័ន្ធអន្តរជាតិបដិសេធមិនទទួលស្គាល់ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល ដែលផ្តល់ដោយស្ថាប័នជាតិប្រឆាំងដូប៉ាំ ព្រោះបាត់កំណត់ត្រាវេជ្ជសាស្ត្រ ឬព័ត៌មានផ្សេងទៀតដែលត្រូវការ ដើម្បីបង្ហាញពីការពេញចិត្តជាមួយនឹងលក្ខណៈវិនិច្ឆ័យនៅក្នុងស្តង់ដារអន្តរជាតិ សម្រាប់ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល បញ្ហានេះមិនគួរត្រូវបានបញ្ជូនទៅទីភ្នាក់ងារប្រឆាំងដូប៉ាំពិភពលោកទេ។ ផ្ទុយទៅវិញ ឯកសារនេះគួរតែត្រូវបានបញ្ចប់ ហើយបញ្ជូនទៅសហព័ន្ធអន្តរជាតិវិញ។*

ប្រសិនបើសហព័ន្ធអន្តរជាតិជ្រើសរើសធ្វើតេស្តអត្តពលិកណាម្នាក់ ដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ស្ថាប័ននោះត្រូវទទួលស្គាល់ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល ដែលផ្តល់ដោយស្ថាប័នជាតិប្រឆាំង *ដូប៉ាំ* របស់អត្តពលិកនោះ។ ]

*អង្គការជាតិប្រឆាំងដូប៉ា*សស់ពួកគេ ចំពោះសារធាតុ ឬវិធីសាស្ត្រ ដែលមានការចោទសួរ ប្រសិនបើ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* បំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុង *ស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* នោះសហព័ន្ធអន្តរជាតិត្រូវតែទទួលស្គាល់។ ប្រសិនបើសហព័ន្ធអន្តរជាតិចាត់ទុកថា *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* មិនបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនោះទេ ហើយដូច្នេះបដិសេធមិនទទួលស្គាល់វា ត្រូវតែជូនដំណឹងដល់*អត្តពលិក* និង*អង្គការជាតិប្រឆាំងដូប៉ារបស់អត្តពលិក* ជាបន្ទាន់ដោយមានហេតុផល។ *អត្តពលិក* ឬ*អង្គការជាតិប្រឆាំងដូប៉ា* ត្រូវមានរយៈពេលម្ភៃប្រាំមួយ (21) ថ្ងៃចាប់ពីការជូនដំណឹងនេះដើម្បីបញ្ជូនបញ្ហានេះទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដើម្បីពិនិត្យ។ ប្រសិនបើបញ្ហានេះត្រូវបានបញ្ជូនទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដើម្បីពិនិត្យឡើងវិញ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*ដែលផ្តល់ដោយ*អង្គការជាតិប្រឆាំងដូប៉ា* នៅតែមានសុពលភាពសម្រាប់ជាតិ *ការប្រកួត* កម្រិតជាតិ និង*ការធ្វើតេស្តក្រៅការប្រកួត* (ប៉ុន្តែមិនមានសុពលភាពសម្រាប់អន្តរជាតិទេ *ការប្រកួត*កម្រិតអន្តរជាតិ) រង់ចាំសេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក្នុងករណីបញ្ហាមិនត្រូវបានបញ្ជូនទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ដើម្បីពិនិត្យឡើងវិញក្នុងរយៈពេលកំណត់ 21 (ម្ភៃមួយ)ថ្ងៃទេនោះ *អង្គការជាតិប្រឆាំងដូប៉ា*របស់*អត្តពលិក*ត្រូវកំណត់ថា *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*ដើម ដែលខ្លួនបានផ្តល់គួរបន្តមានសុពលភាពសម្រាប់*ការប្រកួត*កម្រិតជាតិ និងកា*រធ្វើតេស្តក្រៅការប្រកួត* (ក្នុងលក្ខខណ្ឌដែលថា *អត្តពលិក*ទាំងនោះលែងជាអ*ត្តពលិកកម្រិតអន្តរជាតិ* និងមិនចូលរួមក្នុង*ការប្រកួត*កម្រិតអន្តរជាតិទេ)។ ដោយរង់ចាំសេចក្តីសម្រេចរបស់*អង្គការជាតិប្រឆាំងដូប៉ា* *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*នោះត្រូវបន្តសុពលភាព សម្រាប់*ការប្រកួត*កម្រិតជាតិ និង*ការធ្វើតេស្តក្រៅការប្រកួត* (ប៉ុន្តែមិនមានសុពលភាពសម្រាប់*ការប្រកួតកម្រិតអន្តរជាតិ*ទេ)។

4.4.3.2 ប្រសិនបើ *អត្តពលិក* មិនមាន *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែល* បានផ្តល់ដោយ*អង្គការជាតិប្រឆាំងដូប៉ា*របស់ពួកគេចំពោះសារធាតុ ឬវិធីសាស្ត្រនោះទេ *អត្តពលិក*ត្រូវដាក់ពាក្យដោយផ្ទាល់ទៅ សហព័ន្ធអន្តរជាតិ*របស់អត្តពលិក* ដើម្បីទទួលបាន *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* នៅពេលដែលមានតម្រូវការ។ ប្រសិនបើសហព័ន្ធអន្តរជាតិ (ឬ*អង្គការជាតិប្រឆាំងដូប៉ា*) ដែលខ្លួនបានយល់ព្រមពិចារណាលើពាក្យសុំក្នុងនាមសហព័ន្ធអន្តរជាតិ) បដិសេធ ពាក្យសុំរបស់*អត្តពលិក* វាត្រូវជូនដំណឹងដល់ *អត្តពលិក*ភ្លាមៗ ដោយមានហេតុផល។ ប្រសិនបើសហព័ន្ធអន្តរជាតិផ្តល់ការស្នើសុំរបស់*អត្តពលិក* វាត្រូវតែជូនដំណឹងមិនត្រឹមតែ *អត្តពលិក* ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់ *អង្គការជាតិប្រឆាំងដូប៉ារបស់*អត្តពលិកផងដែរ ហើយប្រសិនបើ*អង្គការជាតិប្រឆាំងដូប៉ា* ចាត់ទុកថា *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* មិនបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុង *ស្តង់ដារអន្តរជាតិស្តីពីការលើកលែងឲ្យប្រើប្រាស់ថ្នាំព្យាបាល* វាមានរយៈពេលម្ភៃមួយ (21) ថ្ងៃពីការជូនដំណឹងបែបនេះដើម្បីបញ្ជូនបញ្ហានេះទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដើម្បីពិនិត្យ។ ប្រសិនបើ*អង្គការជាតិប្រឆាំងដូប៉ា*បញ្ជូនបញ្ហានេះទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ឱ្យពិនិត្យឡើងវិញ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ដែលផ្តល់ដោយសហព័ន្ធកីឡាអន្តរជាតិនៅតែមានសុពលភាពសម្រាប់ការធ្វើតេស្ត*ការប្រកួត* កម្រិតអន្តរជាតិ និង*ការធ្វើតេស្តក្រៅការប្រកួត* (ប៉ុន្តែមិនមានសុពលភាពសម្រាប់*ការប្រកួត*

ថ្នាក់ជាតិទេ ) ដោយរង់ចាំសេចក្ដីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ ប្រសិនបើ *អង្គការជាតិប្រឆាំងដូប៉ា*មិនបញ្ជូនបញ្ហានេះទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឱ្យពិនិត្យឡើងវិញទេនោះ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ដែលផ្តល់ដោយសហព័ន្ធកីឡាអន្តរជាតិនោះ ក៏នៅមានសុពលភាពសម្រាប់ *ការប្រកួត*ថ្នាក់ជាតិដែរ នៅពេលការពិនិត្យឡើងវិញរយៈពេល 21 ( ម្ភៃមួយ ) ថ្ងៃ ត្រូវបានផុតកំណត់។

4.4.4 *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* អាចតម្រូវឱ្យអ្នកកីឡាអនុវត្តទៅសុំ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ប្រសិនបើពួកគេមានបំណងចង់ប្រើ *សារធាតុហាមឃាត់* ឬ*វិធីហាមឃាត់ដែល*ទាក់ទងនឹង *ព្រឹត្តិការណ៍* ក្នុងករណីនោះ៖

4.4.4.1 *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ត្រូវតែធានាថា ដំណើរការសុំ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* របស់ *អត្តពលិក* ប្រសិនបើគាត់មិនមាននោះទេ។ ប្រសិនបើទទួលបាន *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* គឺជាមានប្រសិទ្ធភាពសម្រាប់ *ព្រឹត្តិការណ៍*របស់ខ្លួនតែប៉ុណ្ណោះ។

4.4.4.2 ក្នុងករណីដែល *អត្តពលិក* ទទួលបាន *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* រួចទៅហើយពី *អង្គការជាតិប្រឆាំងដូប៉ា* ឬសហព័ន្ធអន្តរជាតិ*របស់អត្តពលិក* ប្រសិនបើ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* បំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុង *ស្តង់ដាអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ការព្យាបាល* *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ត្រូវតែទទួលស្គាល់។ ប្រសិនបើ *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* សម្រេចថា *ការលើកលែងឱ្យប្រើប្រាស់ជាថ្នាំព្យាបាល* មិនបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនោះទេ ហើយបដិសេធមិនទទួលស្គាល់វាទេនោះ ស្ថាប័ននោះត្រូវជូនដំណឹងដល់ *អត្តពលិក* ឱ្យបានពន្យល់ហេតុផលរបស់ខ្លួន។

4.4.4.3 សេចក្តីសម្រេចដោយ *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* មួយដែលមិនទទួលស្គាល់ ឬមិនផ្តល់ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* អាចត្រូវបានប្តឹងជំទាស់ដោយ *អត្តពលិក* ចំពោះស្ថាប័នឯករាជ្យដែលបង្កើតឡើង ឬតែងតាំងដោយ *ស្ថាប័នព្រឹត្តិការណ៍ធំ* ក្នុងគោលបំណងនោះ។ ប្រសិនបើ *អត្តពលិក* មិនប្តឹងជំទាស់ (ឬបណ្តឹងជំទាស់មិនទទួលបានជោគជ័យ) *អត្តពលិក* អាចនឹងមិន *ប្រើប្រាស់* សារធាតុ ឬវិធីសាស្ត្រដែលទាក់ទងនឹង *ព្រឹត្តិការណ៍* នោះទេ ប៉ុន្តែ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*ណាមួយដែលផ្តល់ដោយ *អង្គការជាតិប្រឆាំងដូប៉ា* និងសហព័ន្ធអន្តរជាតិរបស់ *អត្តពលិក*ចំពោះសារធាតុនោះ ឬវិធីសាស្ត្រនៅតែមានសុពលភាពនៅខាងក្រៅ *ព្រឹត្តិការណ៍* នោះ។[30]

4.4.5 ប្រសិនបើមាន *អង្គភាពប្រឆាំងដូប៉ា* បានជ្រើសរើសដើម្បីប្រមូល *សំណាក*មួយពី *អត្តពលិក*ដែលមិនមែនជា *អត្តពលិកកម្រិតអន្តរជាតិ* ឬ*អត្តពលិក*កម្រិតជាតិ និងថា *អត្តពលិក*ដែលត្រូវបានប្រើប្រាស់ *សារធាតុហាម*

30 *[សេចក្តីអធិប្បាយចំពោះប្រការ 4.4.4.3៖ ឧទាហរណ៍៖ នាយកដ្ឋានចំពោះកិច្ចរបស់មជ្ឈតកម្មកីឡា ឬស្ថាប័នស្រដៀងគ្នាអាចដើរតួជាស្ថាប័នបណ្តឹងឧទ្ធរណ៍ឯករាជ្យសម្រាប់ព្រឹត្តិការណ៍ជាក់លាក់ណាមួយ ឬបើមិនដូច្នោះទេទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចទទួលអនុវត្តមុខងារនោះ។ ប្រសិនបើទាំងមជ្ឈតកម្មកីឡា និងទាំងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកមិនអនុវត្តមុខងារនេះទេ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោករក្សាសិទ្ធិ (ប៉ុន្តែមិនមែនជាកាតព្វកិច្ច) ក្នុងការពិនិត្យឡើងវិញនូវសេចក្តីសម្រេចស្តីពីការលើកលែងឱ្យប្រើជាថ្នាំព្យាបាល ដែលត្រូវបានធ្វើឡើងទាក់ទងនឹងព្រឹត្តិការណ៍ នៅពេលណាមួយ ស្របតាមប្រការ 4.4.6 ]*

*ឃាត់* ឬវិធីសាស្ត្រហាមឃាត់សម្រាប់ហេតុផលព្យាបាល *អង្គការប្រឆាំងដូប៉ា* ត្រូវអនុញ្ញាតឱ្យ*អត្តពលិក* ដើម្បីអនុវត្តសម្រាប់អប្រតិសកម្ម។

4.4.6 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវតែពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់សហព័ន្ធអន្តរជាតិដែលមិនទទួលស្គាល់ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ដែលផ្តល់ដោយ*អង្គការជាតិប្រឆាំងដូប៉ា* ដែលត្រូវបានបញ្ជូនដោយ *អត្តពលិក* ឬ*អង្គការជាតិប្រឆាំងដូប៉ា*របស់*អត្តពលិក*។ *លើសពីនេះទៀត* *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវពិនិត្យឡើងវិញលើសេចក្តីសម្រេចផ្តល់*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* របស់សហព័ន្ធអន្តរជាតិដែលបានបញ្ជូនទៅ*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដោយរបស់*អង្គការជាតិប្រឆាំងដូប៉ា*។ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចផ្តល់*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ណាមួយផ្សេងទៀត គ្រប់ពេលវេលា ទោះជាតាមការស្នើសុំដោយអ្នក/ស្ថាប័នដែលរងផលប៉ះពាល់ ឬតាមការផ្តួចផ្តើមដោយខ្លួនឯង។ ប្រសិនបើសេចក្តីសម្រេច*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*ដែលកំពុងត្រូវបានពិនិត្យឡើងវិញនោះ បំពេញតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុង*ស្តង់ដាអន្តរជាតិស្តីពីការលើកលែងឲ្យប្រើប្រាស់ជាថ្នាំព្យាបាល* ហើយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងមិនជ្រៀតជ្រែកសេចក្តីសម្រេចនោះទេ។ ប្រសិនបើសេចក្តីសម្រេច*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*ដែលកំពុងត្រូវបានពិនិត្យឡើងវិញនោះ មិនបំពេញតាមលក្ខខណ្ឌតម្រូវទេ ទី*ភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*នឹងបដិសេធសេចក្តីសម្រេចនោះ។ [31]

4.4.7 រាល់សេចក្តីសម្រេចផ្តល់*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ដែលចេញដោយសហព័ន្ធកីឡាអន្តរជាតិ (ឬដោយ*អង្គការជាតិប្រឆាំងដូប៉ា* ប្រសិនបើយល់ព្រមទទួលយកពាក្យស្នើសុំ ក្នុងនាមជាសហព័ន្ធកីឡាអន្តរជាតិ) ដែលមិនត្រូវបានត្រួតពិនិត្យឡើងវិញដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬដែលត្រូវបានពិនិត្យឡើងវិញដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*តែមិនត្រូវបានបដិសេធក្រោយការពិនិត្យឡើងវិញនោះ អាចត្រូវបានជំទាស់ដោយ អត្តពលិក និង/ ឬ*អង្គការជាតិប្រឆាំងដូប៉ា* ទៅ*មជ្ឈត្តកម្មកីឡា*។[32]

4.4.8 សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក្នុងការបដិសេធសេចក្តីសម្រេច*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*អាចត្រូវបានប្តឹងជំទាស់ទៅ*មជ្ឈត្តកម្មកីឡា* ដោយ*អត្តពលិក* *អង្គការជាតិប្រឆាំងដូប៉ា* និង/ ឬសហព័ន្ធកីឡាអន្តរជាតិ។

4.4.9 ការខកខានក្នុងការអនុវត្តសេចក្តីសម្រេចតាមកាលកំណត់សមស្របទៅលើពាក្យសុំដែលបានបញ្ជូនត្រឹមត្រូវ ដើម្បីស្នើសុំការផ្តល់/ការទទួលស្គាល់ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ឬដើម្បីពិនិត្យឡើងវិញនូវសេចក្តីសម្រេចលើកលែងឱ្យប្រើជាថ្នាំព្យាបាល នឹងត្រូវបានចាត់ទុកថាជាការបដិសេធលើការស្នើសុំនោះ

---

31 *[សេចក្តីអធិប្បាយចំពោះប្រការ 4.4.6៖ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកមានសិទ្ធិគិតថ្លៃដើម្បីទូទាត់លើការចំណាយ៖ (ក) ការពិនិត្យឡើងវិញណាមួយដែតម្រូវឱ្យស្ថាប័ននេះអនុវត្តស្របតាមប្រការ 4.4.6 និង (ខ) ការពិនិត្យឡើងវិញណាមួយដែលស្ថាប័ននេះសម្រេចអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចដែលកំពុងត្រូវបានពិនិត្យត្រូវបានច្រានចោល។]*

32 *[សេចក្តីអធិប្បាយចំពោះ ប្រការ 4.4.7 ៖ ក្នុងករណីបែបនេះ សេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍គឺជាសេចក្តីសម្រេចលើការលើកលែងឱ្យប្រើជាថ្នាំព្យាបាលរបស់សហព័ន្ធអន្តរជាតិ មិនមែនជាសេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកក្នុងការមិនពិនិត្យ (ឬពិនិត្យ) ឡើងវិញនូវសេចក្តីសម្រេចលើការលើកលែងឱ្យប្រើជាថ្នាំព្យាបាល ដើម្បីមិនច្រានចោលសេក្តីសម្រេចលើការលើកលែងឱ្យប្រើជាថ្នាំព្យាបាលទេ។ ទោះយ៉ាងណាក៏ដោយ ពេលវេលាដើម្បីប្តឹងឧទ្ធរណ៍សេចក្តីសម្រេចលើការលើកលែងឱ្យប្រើជាថ្នាំព្យាបាលមិនចាប់ផ្តើមទេ រហូតដល់កាលបរិច្ឆេទដែលទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកផ្តល់ការជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួន។ ក្នុងករណីណាក៏ដោយ មិនថាការសម្រេចចិត្តត្រូវបានពិនិត្យដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬអត់នោះ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកត្រូវតែទទួលបានការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ដើម្បីឱ្យទីភ្នាក់ងារនេះអាចចូលរួម ប្រសិនបើវាសមស្រប។]*

ដែលនឹងនាំឱ្យមានការអនុវត្តសិទ្ធិពិនិត្យឡើងវិញ/ប្តឹងជំទាស់។

## 4.5 កម្មវិធីត្រួតពិនិត្យ

*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដោយមានការពិគ្រោះយោបល់ជាមួយ*ស្ថាប័នហត្ថលេខី* និងរដ្ឋាភិបាលនឹងបង្កើតកម្មវិធីត្រួតពិនិត្យមួយទាក់ទងនឹងសារធាតុដែលមិនមាននៅក្នុង*បញ្ជីហាមឃាត់* ប៉ុន្តែដែល*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ចង់ត្រួតពិនិត្យដើម្បីរកឱ្យឃើញពីទម្រង់នៃការប្រើប្រាស់ខុសក្នុងកីឡា។ លើសពីនេះ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចរួមបញ្ចូលនៅក្នុងកម្មវិធីត្រួតពិនិត្យសារធាតុដែលមាននៅក្នុង *បញ្ជីហាមឃាត់* ប៉ុន្តែដែលត្រូវត្រួតពិនិត្យក្រោមកាលៈទេសៈជាក់លាក់ឧទាហរណ៍ នៅ *ក្រៅការប្រកួត បានប្រើប្រាស់*សារធាតុមួយចំនួនដែលត្រូវបានហាមឃាត់ *ក្នុងការប្រកួត* តែប៉ុណ្ណោះ ឬការ*ប្រើប្រាស់* រួមបញ្ចូលគ្នា សារធាតុក្នុងកម្រិតទាប ("ការដាក់ជង់")-ក្នុងគោលបំណងបង្កើតគំរូនៃ*ការប្រើប្រាស់* ឬដើម្បីអាចអនុវត្តសេចក្តីសម្រេចឱ្យបានគ្រប់គ្រាន់ទាក់ទងនឹងការវិភាគរបស់ពួកគេដោយមន្ទីរពិសោធន៍ ឬស្ថានភាពរបស់ពួកគេនៅក្នុង *បញ្ជីហាមឃាត់*។

*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងបោះពុម្ពផ្សាយសារធាតុដែលនឹងត្រូវត្រួតពិនិត្យ។[33] មន្ទីរពិសោធន៍នឹងរាយការណ៍អំពីករណីដែលបានរាយការណ៍ពី *ការប្រើប្រាស់* ឬរកឃើញវត្តមាននៃសារធាតុទាំងនេះទៅ*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*  *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវផ្តល់ជូនដល់សហព័ន្ធអន្តរជាតិ និង*អង្គការជាតិប្រឆាំងដូប៉ា* យ៉ាងតិចជារៀងរាល់ឆ្នាំនូវព័ត៌មានសរុបតាមកីឡាទាក់ទងនឹងសារធាតុដែលបានត្រួតពិនិត្យ។ របាយការណ៍កម្មវិធីត្រួតពិនិត្យបែបនេះ មិនត្រូវមានព័ត៌មានលម្អិតបន្ថែមនោះទេអាចភ្ជាប់លទ្ធផលត្រួតពិនិត្យទៅនឹង*សំណាក* ជាក់លាក់។ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ត្រូវអនុវត្តវិធានការដើម្បីធានាថាភាពអនាមិកដ៏តឹងរ៉ឹងរបស់*អត្តពលិក*ម្នាក់ៗ ត្រូវបានរក្សាដោយគោរពតាមរបាយការណ៍ទាំងនោះ។ *ការប្រើប្រាស់* ឬការរកឃើញវត្តមាននៃសារធាតុដែលបានរាយការណ៍នឹងមិនបង្កើតជាការបំពានវិធានប្រឆាំងដូប៉ាឡើយ។

*33 [សេចក្តីអធិប្បាយចំពោះប្រការ 4.5៖ ដើម្បីបង្កើនប្រសិទ្ធភាពនៃកម្មវិធីត្រួតពិនិត្យ នៅពេលដែលសារធាតុថ្មីត្រូវបានបញ្ចូលទៅក្នុងកម្មវិធីត្រួតពិនិត្យ ដែលបានបោះផ្សាយនោះ មន្ទីរពិសោធន៍អាចដំណើរការទិន្នន័យឡើងវិញ និងធ្វើការវិភាគសំណាកដែលបានវិភាគពីមុនដើម្បីកំណត់អវត្តមាន ឬវត្តមានសារធាតុថ្មីណាមួយ។ ]*

## ប្រការ 5៖ ការ*ធ្វើតេស្ត* និងការស៊ើបអង្កេត

### 5.1 គោលបំណងនៃ*ការធ្វើតេស្ត* និងការស៊ើបអង្កេត

ការ*ធ្វើតេស្ត* និងការស៊ើបអង្កេតអាចត្រូវធ្វើឡើងក្នុងគោលបំណងប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា។[34]

5.1.1 ការ*ធ្វើតេស្ត*ត្រូវធ្វើឡើង ដើម្បីទទួលបានភស្តុតាងវិភាគ ដើម្បីកំណត់ថា តើ*អត្តពលិក*បានបំពានលើប្រការ 2.1 (វត្តមាននៃ*សារធាតុហាមឃាត់* ឬ*សារធាតុមេតាប៉ូលីស* ឬ*សារធាតុបិទបាំង*ក្នុង*សំណាក*របស់*អត្តពលិក*) ឬប្រការ 2.2 (*ការប្រើប្រាស់* ឬ*ការប៉ុនប៉ង ប្រើប្រាស់សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ដោយ*អត្តពលិក*) នៃក្រម ឬយ៉ាងណា។

### 5.2 អាជ្ញាធរធ្វើតេស្ត

*អត្តពលិក* ណាមួយអាចត្រូវបានតម្រូវឱ្យផ្តល់ *សំណាក* នៅពេលណាមួយ និងនៅកន្លែងណាមួយដោយ *អង្គការប្រឆាំងដូប៉ា* ដែល *មានអំណាចតេស្ត* លើគាត់។[35] ផ្អែកតាមដែនកំណត់នៃការធ្វើតេស្តសម្រាប់ព្រឹត្តិកាណ៍កីឡា ដូចដែលមានចែងក្នុងប្រការ5.3។

5.2.1 *អង្គការជាតិប្រឆាំងដូប៉ា* នីមួយៗ ត្រូវមានសិទ្ធិ *ក្នុងការប្រកួត* និង *ក្រៅការប្រកួត*លើ*អត្តពលិក*ទាំងអស់ដែលមានសញ្ជាតិ អ្នករស់នៅ អ្នកកាន់អាជ្ញាប័ណ្ណ ឬសមាជិកនៃអង្គការកីឡានៃប្រទេសនោះ ឬដែលមានវត្តមាននៅក្នុងប្រទេសរបស់*អង្គការជាតិប្រឆាំងដូប៉ា*។

5.2.2 សហព័ន្ធអន្តរជាតិនីមួយត្រូវមានសិទ្ធិធ្វើតេសត្ត *ក្នុងការប្រកួត* និង*ក្រៅការប្រកួត*លើគ្រប់*អត្តពលិក*ទាំងអស់ដែលស្ថិតនៅក្រោមច្បាប់របស់ខ្លួនរួមទាំងអ្នកដែលចូលរួមក្នុង*ព្រឹត្តិការណ៍អន្តរជាតិ* ឬអ្នកដែលចូលរួមក្នុង*ព្រឹត្តិការណ៍* ដែលគ្រប់គ្រងដោយច្បាប់របស់សហព័ន្ធអន្តរជាតិនោះ ឬអ្នកដែលជាសមាជិក ឬអាជ្ញាប័ណ្ណអ្នកកាន់សហព័ន្ធអន្តរជាតិនោះ ឬសមាជិកសហព័ន្ធជាតិរបស់ខ្លួន ឬសមាជិករបស់ខ្លួន។

5.2.3 *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* រួមទាំងគណៈកម្មាធិការអូឡាំពិកអន្តរជាតិ និងគណៈកម្មាធិប៉ារ៉ាឡាំពិអន្តរជាតិនឹងមានសិទ្ធិអំណាច*ការធ្វើតេស្តក្នុងការប្រកួត* សម្រាប់*ព្រឹត្តិការណ៍* និងសិទ្ធិអំណាច*ការធ្វើតេស្តក្រៅការប្រកួត*នៅលើ*អត្តពលិក*ទាំងអស់ដែលបានបញ្ចូលនៅក្នុងផ្នែកមួយនៃ*ព្រឹត្តិការណ៍*នាពេលអនាគតរបស់ខ្លួន ឬដែលខ្លួនបាន បើមិនដូច្នេះទេត្រូវបានបង្កើតឡើងជាកម្មវត្ថុនៃសិទ្ធិអំណាចការ*ធ្វើតេស្ត* របស់*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* សម្រាប់*ព្រឹត្តិការណ៍*នាពេលអនាគត។

---

34 *[សេចក្តីអធិប្បាយចំពោះប្រការ 5.1 ៖ ក្នុងករណីដែលតេស្តត្រូវបានធ្វើឡើងសម្រាប់គោលបំណងប្រឆាំងដូប៉ា លទ្ធផលវិភាគនិងទិន្នន័យអាចត្រូវបានប្រើសម្រាប់គោលបំណងត្រឹមត្រូវផ្សេងទៀត ក្រោមវិធានរបស់អង្គការប្រឆាំងដូប៉ា។ ឧទាហរណ៍៖ សូមមើលសេចក្តីអធិប្បាយចំពោះប្រការ 23.2.2 ។ ]*

35 *[សេចក្តីអធិប្បាយចំពោះប្រការ 5.2៖ សិទ្ធិបន្ថែមក្នុងការធ្វើតេស្តអាចត្រូវបានផ្តល់ឱ្យតាមរយៈមធ្យោបាយទ្វេភាគី ឬពហុភាគី ក្នុងចំណោមស្ថាប័នហត្ថលេខី។ លុះត្រាតែអត្តពលិកបានកំណត់ពេលវេលានៃការធ្វើតេស្តរយៈពេលហុកសិបនាទី ក្នុងកំឡុងពេលដែលបានពិពណ៌នាខាងក្រោម ឬបើមិនដូច្នេះទេ ត្រូវបានយល់ព្រម ក្នុងការធ្វើតេស្ត ក្នុងអំឡុងពេលនោះ មុនពេលធ្វើតេស្តអត្តពលិកនៅចន្លោះម៉ោង 11:00 យប់ដល់ 6:00 ព្រឹក អង្គការប្រឆាំងដូប៉ាគួរមានការសង្ស័យខ្លាំង និងជាក់លាក់ថា អត្តពលិកនោះអាចជាប់ពាក់ព័ន្ធនឹងសារធាតុដូប៉ា។ បញ្ហាប្រឈមមួយដែលថាតើអង្គការប្រឆាំងដូប៉ាមានការសង្ស័យគ្រប់គ្រាន់សម្រាប់ការធ្វើតេស្តក្នុងអំឡុងពេលនេះ ឬមិនមាន នឹងមិនត្រូវបានយកជាអំណះអំណាងការពារចំពោះការបំពានលើវិធានប្រឆាំងដូប៉ា ដោយផ្អែកលើការធ្វើតេស្ត ឬការប៉ុនប៉ងធ្វើតេស្តនោះទេ។ ]*

5.2.4 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*មានសិទ្ធិអំណាចការ*ធ្វើតេស្ត ក្រៅការប្រកួត* ដូចដែលបានចែងក្នុងប្រការ 20.7.10 នៃក្រម។

5.2.5 *អង្គការប្រឆាំងដូប៉ា* អាចធ្វើតេស្តលើ *អត្តពលិក* ណាម្នាក់ដែលពួកគេមាន សិទ្ធិអំណាចការ*ធ្វើតេស្ត* ដែលមិនបានចូលនិវត្ត រួមទាំង *អត្តពលិក*ដែលកំពុងអនុវត្តការ*ព្យួរសិទ្ធិ*។

5.2.6 ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិ ឬ*ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ*ណាមួយ ផ្តល់សិទ្ធិ ឬផ្តល់កិច្ចសន្យាផ្នែកណាមួយនៃការ*ធ្វើតេស្ត* ទៅឱ្យ*អង្គការជាតិប្រឆាំងដូប៉ា*ដោយផ្ទាល់ ឬតាមរយៈសហព័ន្ធកីឡាជាតិ *អង្គការជាតិប្រឆាំងដូប៉ា* អាចប្រមូល*សំណាក*បន្ថែម ឬឱ្យមន្ទីរពិសោធន៍ធ្វើការវិភាគប្រភេទផ្សេងទៀត ក្រោមការចំណាយរបស់*អង្គការជាតិប្រឆាំងដូប៉ា*។ ប្រសិនបើ*សំណាក* បន្ថែមត្រូវបានប្រមូលយក ឬប្រភេទនៃការវិភាគបន្ថែម ត្រូវបានអនុវត្ត សហព័ន្ធកីឡាអន្តរជាតិ ឬ*ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ*ត្រូវទទួលបានការជូនដំណឹងពីបញ្ហានោះ។

## *5.3 ការធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍កីឡា*

5.3.1 លើកលែងដូចដែលត្រូវបានកំណត់ខាងក្រោម មានតែស្ថាប័នមួយគត់ដែលមានសិទ្ធិការ*ធ្វើតេស្ត*នៅ*ទីលានព្រឹត្តការណ៍ការប្រកួត ក្នុងអំឡុងពេលព្រឹត្តការណ៍ការប្រកួតនោះ*។ នៅក្នុង*ព្រឹត្តិការណ៍កីឡាអន្តរជាតិ* អង្គការអន្តរជាតិដែលជាស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍* (ឧទាហរណ៍៖ គណៈកម្មាធិការអូឡាំពិកអន្តរជាតិសម្រាប់ការប្រកួតកីឡាអូឡាំពិក សហព័ន្ធអន្តរជាតិសម្រាប់ការប្រកួតជើងឯកពិភពលោក និងគណកម្មាធិការប៉ាណាម៉ាសម្រាប់កីឡាប៉ានអាមេរិក) មានសិទ្ធិ *ធ្វើតេស្ត*។ នៅក្នុង*ព្រឹត្តិការណ៍ជាតិ អង្គការជាតិប្រឆាំងដូប៉ា*របស់ប្រទេសនោះមានសិទ្ធិអំណាចក្នុងការ*ធ្វើតេស្ត*។ តាមការស្នើរបស់ស្ថាប័នមានសិទ្ធិសម្រាប់*ព្រឹត្តិការណ៍*កីឡាមួយរាល់ការ*ធ្វើតេស្តក្នុងអំឡុងពេលព្រឹត្តការណ៍ការប្រកួត* នៅខាងក្រៅ*ទីលានព្រឹត្តិការណ៍* ត្រូវសម្របស្រួលជាមួយស្ថាប័នមានសិទ្ធិសម្រាប់ព្រឹត្តិការណ៍នោះ។[36]

5.3.2 ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*ដែលមានសិទ្ធិក្នុង*ការធ្វើតេស្ត* តែពុំមានការទទួលខុសត្រូវក្នុងការផ្តួចផ្តើម និងគ្រប់គ្រង*ការធ្វើតេស្ត*នៅក្នុង*ព្រឹត្តិការណ៍* មានបំណងធ្វើតេស្តលើ*អត្តពលិក*នៅ*ទីលានព្រឹត្តិការណ៍ប្រកួត អង្គការប្រឆាំងដូប៉ា*នោះត្រូវពិភាក្សាជាមួយស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍*ដើម្បីទទួលបាននូវការអនុញ្ញាតឱ្យអនុវត្ត និងសម្របសម្រួលក្នុង*ការធ្វើតេស្ត*។ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*មិនពេញចិត្តនឹងការឆ្លើយតបរបស់ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍*ទេ *អង្គការប្រឆាំងដូប៉ា*នោះ អាចយោងតាមនីតិវិធីដែលបានពិពណ៌នាក្នុង*ស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត* និងការស៊ើបអង្កេត ស្នើទៅ*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដើម្បីសុំការអនុញ្ញាតការ*ធ្វើតេស្ត* និងដើម្បីកំណត់វិធីសម្របសម្រួលក្នុងការ*ធ្វើតេស្ត*នោះ។ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*មិនត្រូវផ្តល់ការអនុញ្ញាតឱ្យ*ការធ្វើតេស្ត* មុនពេលប្រឹក្សា និងជូនដំណឹងដល់ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍*ឡើយ។ សេចក្តីសម្រេចរបស់*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ជាសេចក្តីសម្រេចចុងក្រោយ និងមិនអាចត្រូវបានជំទាស់ទេ។ លើកលែងតែមានការបញ្ជាក់ក្នុងការផ្ទេរសិទ្ធិឱ្យ*ធ្វើតេស្ត* ការ*ធ្វើតេស្ត*នឹងត្រូវបានចាត់ទុកថាជា*ការធ្វើតេស្តក្រៅការប្រកួត*។ *ការដោះស្រាយវិវាទដូប៉ា*ចំពោះការ*ធ្វើតេស្ត*ណាមួយគឺ

36 *[សេចក្តីអធិប្បាយចំពោះប្រការ 5.3.1៖ ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍អន្តរជាតិមួយចំនួនអាចធ្វើតេស្តិ៍ផ្ទាល់ខ្លួនរបស់ពួកគេនៅខាងក្រៅទីកន្លែងប្រកួត ក្នុងកំឡុងពេលព្រឹត្តិការណ៍ ដូច្នេះគួរសម្របសម្រួលការធ្វើតេស្តនោះជាមួយការធ្វើតេស្តរបស់អង្គការប្រឆាំងដូប៉ា។]*

ជាទំនួលខុសត្រូវរបស់*អង្គការប្រឆាំងដូប៉ា* ដែលផ្តួចផ្តើមក្នុងការធ្វើតេស្តនេះ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះនៅក្នុងវិធានរបស់ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍*។[37]

## 5.4 លក្ខខណ្ឌតម្រូវនៃ*ការធ្វើតេស្ត*

5.4.1 *អង្គការប្រឆាំងដូប៉ា* ត្រូវរៀបចំផែនការបែងចែកការ *ធ្វើតេស្ត* និងអនុវត្តការ *ធ្វើតេស្ត*ឱ្យស្របតាម *ស្តង់ដារអន្តរជាតិស្តីពី ការធ្វើតេស្ត* និងការស៊ើបអង្កេត។

5.4.2 ប្រសិនបើអាចធ្វើបានការ *ធ្វើតេស្ត*ត្រូវសម្របសម្រួលតាមរយៈ *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់បំផុតនៃការខិតខំរួមគ្នានៃ *ការធ្វើតេស្ត* និងដើម្បីជៀសវាងការធ្វើតេស្តដដែលៗដែលមិនចាំបាច់។

## 5.5 ព័ត៌មានអំពីទីសំចតរបស់*អត្តពលិក*

*អត្តពលិក*ដែលត្រូវបានបញ្ចូលទៅក្នុង *បញ្ជីឈ្មោះធ្វើតេស្ត* ដោយសហព័ន្ធអន្តរជាតិរបស់ពួកគេ និង/ ឬ*អង្គការជាតិប្រឆាំងដូប៉ា* ត្រូវផ្តល់ព័ត៌មានអំពីទីសំចត តាមលក្ខណៈដែលបានបញ្ជាក់នៅក្នុង *ស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត* និងការស៊ើបអង្កេត ហើយត្រូវមាន *ផលវិបាក* ចំពោះបំពាន ប្រការ 2.4 នៅក្នុង ប្រការ 10.3.2 ។ សហព័ន្ធអន្តរជាតិ និង*អង្គការជាតិប្រឆាំងដូប៉ា*ត្រូវសម្របសម្រួលការកំណត់អត្តសញ្ញាណ *អត្តពលិក* ទាំងនោះ និងការប្រមូលព័ត៌មានអំពីទីសំចតរបស់ពួកគេ។ សហព័ន្ធអន្តរជាតិ និង*អង្គការជាតិប្រឆាំងដូប៉ា*នីមួយៗ តាមរយៈ*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ត្រូវផ្តល់បញ្ជីដែលកំណត់អត្តសញ្ញាណអត្តពលិកទាំងនោះ ដោយរួមបញ្ចូលទៅក្នុង*បញ្ជីឈ្មោះធ្វើតេស្ត* តាមឈ្មោះនីមួយៗ។ *អត្តពលិក*ត្រូវទទួលបានការជូនដំណឹងមុនពេលពួកគេត្រូវបានបញ្ចូល*ឈ្មោះទៅក្នុងបញ្ជី* និងនៅពេលពួកគេត្រូវបានដកចេញពីបញ្ជី។ *ព័ត៌មានអំពីទីសំចត*ក្នុងបញ្ជីឈ្មោះធ្វើតេស្ត ដែលអត្តពលិកផ្តល់ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និង*អង្គការប្រឆាំងដូប៉ា*ផ្សេងៗទៀត ដែលមានសិទ្ធិធ្វើតេស្តលើ*អត្តពលិក* ដូចដែលមានចែងក្នុងប្រការ 5.2 នឹងអាចរកបាននៅ*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា*។ *ព័ត៌មានអំពីទីសំចត*របស់*អត្តពលិក*នឹងត្រូវបានរក្សាជាសម្ងាត់គ្រប់ពេល ហើយព័ត៌មាននេះនឹងត្រូវបានប្រើប្រាស់សម្រាប់តែក្នុងគោលបំណងធ្វើផែនការ ការសម្របសម្រួល ឬដំណើរការគ្រប់គ្រងសារធាតុដូប៉ា ដោយផ្តល់ព័ត៌មានដែលទាក់ទងទៅនឹង*ប្រវត្តិជីវសាស្ត្រអត្តពលិក* ឬលទ្ធផលវិភាគផ្សេងទៀត ដើម្បីជាប្រយោជន៍ ដល់ការស៊ើបអង្កេតករណី បំពានវិធានប្រឆាំងដូប៉ាសក្តានុពល ឬដើម្បីគាំទ្រដល់នីតិវិធីចោទប្រកាន់ពីការបំពានវិធានប្រឆាំងដូប៉ា ហើយវានឹងត្រូវបានកម្ទេចចោលបន្ទាប់ពីវាលែងមានពាក់ព័ន្ធនឹងគោលបំណងទាំងនេះ ដោយយោងទៅ*តាមស្តង់ដារអន្តរជាតិស្តីពី*រក្សាការសម្ងាត់ និងព័ត៌មានបុគ្គល។

*អង្គការប្រឆាំងដូប៉ា* អាចអនុលោមតាម *ស្តង់ដារអន្តរជាតិ* ស្តីពី *ការធ្វើតេស្ត* និងការស៊ើបអង្កេត ប្រមូលព័ត៌មានអំពីទីសំចតរបស់ *អត្តពលិក* ដែលមិនត្រូវបានរាប់បញ្ចូលក្នុង *បញ្ជីឈ្មោះធ្វើតេស្ត* ហើយកំណត់ឱ្យបានត្រឹមត្រូវនូវសមា

37 *[សេចក្តីអធិប្បាយចំពោះប្រការ 5.3.2៖ មុននឹងផ្តល់ការយល់ព្រមដល់ស្ថាប័នជាតិប្រឆាំងដូប៉ាដើម្បីផ្តួចផ្តើម និងធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍អន្តរជាតិមួយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកត្រូវពិគ្រោះយោបល់ជាមួយអង្គការអន្តរជាតិដែលជាស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍នោះ។ មុននឹងផ្តល់ការយល់ព្រមដល់សហព័ន្ធអន្តរជាតិដើម្បីផ្តួចផ្តើម និងធ្វើតេស្តនៅព្រឹត្តិការណ៍ជាតិមួយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នជាតិប្រឆាំងដូប៉ានៃប្រទេសដែលរៀបចំព្រឹត្តិការណ៍នោះ។ អង្គការប្រឆាំងដូប៉ាដែល "ផ្តួចផ្តើម និងគ្រប់គ្រងការធ្វើតេស្ត" ក្រោមការសម្រេចរបស់ខ្លួន អាចចុះកិច្ចព្រមព្រៀងជាមួយភាគីទីបីដែលត្រូវបានចាត់តាំង ដែលខ្លួនប្រគល់ការទទួលខុសត្រូវឱ្យប្រមូលសំណាក ឬទិដ្ឋភាពផ្សេងទៀតនៃដំណើរការត្រួតពិនិត្យសារធាតុដូប៉ា។ ]*

មាត្រដែលមិនមាន*ក្រម* ប្រការ 2.4 ក្រោមច្បាប់របស់ខ្លួន។

## 5.6 អត្តពលិកចូលនិវត្តន៍ដែលត្រឡប់មកប្រកួតវិញ

5.6.1 ប្រសិនបើ*អត្តពលិកកម្រិតអន្តរជាតិ* និង*អត្តពលិកកម្រិតជាតិ* ដែលមានឈ្មោះក្នុង*បញ្ជីឈ្មោះធ្វើតេស្ត*របស់*អង្គការជាតិប្រឆាំងដូប៉ាំង*ដែលចូលនិវត្តន៍ ហើយមានបំណងចង់ចូលរួមប្រកួតកីឡាវិញ *អត្តពលិក*នោះមិនអាចចូលរួមព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតជាតិបានទេ លុះត្រាណាតែអត្តពលិករូបនោះអនុញ្ញាតឱ្យគេ*ធ្វើតេស្ត* ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនរយៈពេលពេល 6 (ប្រាំមួយ) ខែ ទៅសហព័ន្ធអន្តរជាតិ និង*អង្គការជាតិប្រឆាំងដូប៉ាំង*របស់ពួកគេ។ *ទីភ្នាក់ងារប្រឆាំងដូប៉ាំងពិភពលោក* ដោយពិគ្រោះយោបល់ជាមួយសហព័ន្ធអន្តរជាតិដែលពាក់ព័ន្ធ និង*អង្គការជាតិប្រឆាំងដូប៉ាំង* អាចផ្តល់ការលើកលែងចំពោះលក្ខខណ្ឌជូនដំណឹងជាលាយលក្ខណ៍អក្សររយៈពេល 6 (ប្រាំមួយ) ខែ ដែលការអនុវត្តលក្ខខណ្ឌនេះតឹងរ៉ឹងនឹងមិនយុត្តិធម៌ចំពោះ*អត្តពលិក*។ សេចក្តីសម្រេចនេះអាចត្រូវបានជំទាស់ដោយយោងតាមប្រការ13។[38]

5.6.1.1 លទ្ធផលទទួលបានដែលមានលក្ខខណៈប្រកួត ដែលបំពានប្រការ 5.6.1 នឹងត្រូវបាន "*ដកសិទ្ធិ*" លុះត្រាតែអត្តពលិកអាចបង្ហាញថា ខ្លួនមិនអាចដឹងតាមហេតុផលសមស្របថា វាជា*កព្រឹត្តិការណ៍កម្រិតអន្តរជាតិ* ឬ*ព្រឹត្តិការណ៍កម្រិតជាតិ*។

5.6.2 ប្រសិនបើ*អត្តពលិក*ណាម្នាក់ចូលនិវត្តន៍ក្នុងរយៈពេលនៃការ "*ព្យួរសិទ្ធិ*" អត្តពលិកនោះត្រូវជូនដំណឹងទៅ*អង្គការប្រឆាំងដូប៉ាំង*ដែលដាក់ពិន័យដោយការ*ព្យួរសិទ្ធិ*នោះ ជាលាយលក្ខណ៍អក្សរ អំពីការចូលនិវត្តន៍របស់ខ្លួន។ ប្រសិនបើ *អត្តពលិក*មានបំណងចង់ចូលរួមក្នុងការប្រកួតវិញ *អត្តពលិក*នោះមិនអាចចូលរួមក្នុង*ព្រឹត្តិការណ៍អន្តរជាតិ* ឬ*ព្រឹត្តិការណ៍កម្រិតជាតិ*ឡើយ លុះត្រាតែ*អត្តពលិក*នោះទទួលយកការ*ធ្វើតេស្ត*ក្នុងអំឡុងពេល 6 (ប្រាំមួយ) ខែ ចាប់ថ្ងៃទទួលដំណឹងជាលាយលក្ខណ៍អក្សរ (ឬការជូនដំណឹងត្រូវសមមូលស្មើនឹងរយៈពេលនៃការ "*ព្យួរសិទ្ធិ*" ដែលនៅសល់ គិតត្រឹមថ្ងៃដែលអត្តពលិកនោះចូលនិវត្តន៍ ប្រសិនបើអំឡុងនោះមិនយូរជាង 6 (ប្រាំមួយ) ខែ ទៅ*អង្គការជាតិប្រឆាំងដូប៉ាំង* និងសហព័ន្ធកីឡាអន្តរជាតិរបស់ពួកគេ។

38 *[សេចក្តីអធិប្បាយចំពោះប្រការ 5.6.1៖ ការណែនាំសម្រាប់កំណត់ថាតើការលើកលែងត្រូវបានផ្តល់ជូន ឬមិនផ្តល់ជូន នឹងត្រូវកំណត់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាំងពិភពលោក។ ]*

5.7 ការប្រមូលយកព័ត៌មានការស៊ើបអង្កេត និងការយកការណ៍

*អង្គការប្រឆាំងដូប៉ា* ត្រូវមានសមត្ថភាពដឹកនាំ និងធ្វើការស៊ើបអង្កេត និងប្រមូលព័ត៌មានស៊ើបការណ៍សម្ងាត់តាមតម្រូវការ *ស្តង់ដារអន្តរជាតិ* ស្តីពីការ *ធ្វើតេស្ត* និងការស៊ើបអង្កេត។

## ប្រការ 6៖ ការវិភាគ*សំណាក*

*សំណាក*នឹងត្រូវបានវិភាគដោយយោងទៅតាមគោលការណ៍ដូចខាងក្រោម៖

### 6.1 ការប្រើប្រាស់មន្ទីរពិសោធន៍ដែលត្រូវបានទទួលស្គាល់ និងទទួលសិទ្ធិ និងមន្ទីរពិសោធន៍ផ្សេងទៀត

ក្នុងគោលបំណងនៃការស្វែងរកដោយផ្ទាល់នូវ*លទ្ធផលវិភាគវិជ្ជមាន* ដូចមានចែងក្នុងប្រការ 2.1 *សំណាក*នឹងត្រូវបានវិភាគតែនៅក្នុងមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលត្រូវបានផ្តល់សិទ្ធិពី *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*តែប៉ុណ្ណោះ។ ការជ្រើសរើសមន្ទីរពិសោធន៍ដែលទទួលស្គាល់ ឬដែលផ្តល់សិទ្ធិដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ដើម្បីប្រើប្រាស់ក្នុងការធ្វើការវិភាគ*សំណាក*គឺជាសិទ្ធិសម្រេចផ្តាច់មុខរបស់*អង្គការប្រឆាំងដូប៉ា*ដែលទទួលខុសត្រូវសម្រាប់*ការដោះស្រាយវិវាទ*។[39]

6.1.1 ដូចដែលមានក្នុងប្រការ 3.2 អង្គហេតុទាក់ទងនឹងការបំពានវិធានប្រឆាំងជាតុដូប៉ា អាចត្រូវបានបង្ហាញតាមមធ្យោបាយដែលអាចជឿជាក់បាន។ ឧទាហរណ៍៖ វារួមបញ្ចូលទាំងមន្ទីរពិសោធន៍ដែលអាចជឿទុកចិត្តបាន ឬការធ្វើកោសល្យវិច្ច័យផ្សេងទៀតដែលធ្វើឡើងនៅខាងក្រៅមន្ទីរពិសោធន៍ដែលទទួលស្គាល់ ឬផ្តល់សិទ្ធិដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។

### 6.2 គោលបំណងនៃការវិភាគ*សំណាក* និងទិន្នន័យ

*សំណាក* និងទិន្នន័យវិភាគដែលពាក់ព័ន្ធ ឬ ព័ត៌មាននៃការ*ត្រួតពិនិត្យដូប៉ា* នឹងត្រូវបានវិភាគរក*សារធាតុហាមឃាត់* និង*វិធីសាស្ត្រហាមឃាត់* ដូចបានកំណត់នៅក្នុង *បញ្ជីហាមឃាត់* និងសារជាតុផ្សេងទៀត ដែលការងារនេះអាចត្រូវបានដឹកនាំដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយអនុលោមតាមកម្មវិធីត្រួតពិនិត្យ ដូចបានបញ្ជាក់ក្នុងប្រការ 4.5 នៃ*ក្រម* ឬដើម្បីជួយ*អង្គការប្រឆាំងដូប៉ា*ក្នុងការបញ្ជាក់ឱ្យបានច្បាស់នូវប៉ារ៉ាម៉ែត្រដែលពាក់ព័ន្ធនៅក្នុងទឹកនោម ឈាម ឬម៉ាទ្រីសផ្សេងទៀតរបស់អត្តពលិក រាប់បញ្ចូលទាំងឌីអិនអេ (DNA) ឬទម្រង់ពន្ធុវិទ្យា ឬសម្រាប់គោលបំណងស្របច្បាប់ប្រឆាំងដូប៉ាផ្សេងទៀត។[40]

---

39 *[សេចក្តីអធិប្បាយចំពោះប្រការ 6.1៖ សម្រាប់ហេតុផលនៃការចំណាយ និងការចូលទៅកាន់ទីតាំងភូមិសាស្ត្រ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចអនុម័តឱ្យមន្ទីរពិសោធន៍ដែលមិនត្រូវបានទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ធ្វើការវិភាគជាក់លាក់ ឧទាហរណ៍ការវិភាគឈាមដែលគួរត្រូវបានបញ្ជូនពីកន្លែងប្រមូលឈាមទៅមន្ទីរពិសោធន៍ក្នុងរយៈពេលកំណត់។ មុននឹងផ្តល់ការអនុម័តឱ្យមន្ទីរពិសោធន៍ណាមួយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកត្រូវធានាថាខ្លួនឆ្លើយតបទៅនឹងការវិភាគ និងការរក្សាទុកកម្រិតខ្ពស់ដែលតម្រូវដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។ ការបំពានប្រការ 2.1 អាចត្រូវបានបង្ហាញដោយការវិភាគសំណាកដែលអនុវត្តដោយមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលបានអនុម័តដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។ ការបំពានលើប្រការផ្សេងទៀតអាចត្រូវបានបង្ហាញដោយប្រើលទ្ធផលវិភាគពីមន្ទីរពិសោធន៍ផ្សេងទៀតដរាបណាលទ្ធផលនោះអាចជឿទុកចិត្តបាន។]*

40 *[សេចក្តីអធិប្បាយចំពោះប្រការ 6.2៖ ឧទាហរណ៍៖ ព័ត៌មានពាក់ព័ន្ធនឹងការត្រួតពិនិត្យសារជាតុដូប៉ាអាចត្រូវបានប្រើសម្រាប់គ្រប់គ្រងការធ្វើតេស្តគោលដៅ ឬដើម្បីគាំទ្រនីតិវិធីស្តីពីការ*

## 6.3 ការស្រាវជ្រាវលើ*សំណាក* និងទិន្នន័យ

សំណាក ទិន្នន័យវិភាគពាក់ព័ន្ធ និងព័ត៌មាន*ត្រួតពិនិត្យដូប៉ា* អាចត្រូវបានប្រើសម្រាប់គោលបំណងស្រាវជ្រាវប្រឆាំងដូប៉ា ទោះបីជាគ្មាន *សំណាក* ណាមួយអាចត្រូវបានប្រើសម្រាប់ការស្រាវជ្រាវ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អត្តពលិកក៏ដោយ។ *សំណាក* និងទិន្នន័យវិភាគដែលពាក់ព័ន្ធ ឬព័ត៌មាន*ត្រួតពិនិត្យសារដូប៉ា* ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងស្រាវជ្រាវ នឹងត្រូវបានដំណើរការជាមុន ក្នុងលក្ខណៈមួយដើម្បីបង្ការការប្រើប្រាស់*សំណាក* និងទិន្នន័យវិភាគដែលពាក់ព័ន្ធ ឬព័ត៌មាន*ត្រួតពិនិត្យដូប៉ា* ពីការស្វែងរក*អត្តពលិក*ជាក់លាក់ណាមួយបាន។[41] ការស្រាវជ្រាវណាមួយដែលពាក់ព័ន្ធនឹង*សំណាក* និងទិន្នន័យវិភាគពាក់ព័ន្ធ ឬព័ត៌មាន*ត្រួតពិនិត្យដូប៉ា* ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ ដូចដែលមានចែងក្នុងប្រការ 19 នៃ*ក្រម*។

## 6.4 ស្តង់ដារសម្រាប់ការវិភាគ*សំណាក* និងការរាយការណ៍[42]

មន្ទីរពិសោធន៍ត្រូវវិភាគ*សំណាក* និងរាយការណ៍លទ្ធផលដោយអនុលោមតាម *ស្តង់ដារអន្តរជាតិ* ស្តីពីមន្ទីរពិសោធន៍។

6.4.1 តាមគំនិតផ្តួចផ្តើម និងក្រោមការចំណាយរបស់ខ្លួន មន្ទីរពិសោធន៍អាចវិភាគ*សំណាក*រក*សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ដែល មិនមាននៅក្នុងបញ្ជី វិភាគ*សំណាក*ស្តង់ដារ ឬតាមការស្នើសុំពី*អង្គការប្រឆាំងដូប៉ា*។ ត្រូវរាយការណ៍លទ្ធផលដែលបានមកពីការវិភាគនេះទៅ *អង្គការប្រឆាំងដូប៉ា* ហើយវាមានសុពលភាព និង*ផលវិបាក*ដូចគ្នានឹងផលពីការវិភាគដទៃទៀតដែរ។

## 6.5 ការវិភាគបន្ថែមទៀតលើ*សំណាក* មុនពេល ឬក្នុងអំឡុងពេលនៃ*ដោះស្រាយវិវាទដូប៉ា* ឬដំណើការសវនាការ

មិនមានដែនកំណត់លើសិទ្ធិអំណាចរបស់មន្ទីរពិសោធន៍ក្នុងការធ្វើការវិភាគឡើងវិញ ឬការវិភាគបន្ថែមលើ*សំណាក* មុនពេលដែល*អង្គការប្រឆាំងដូប៉ា*ជូនដំណឹងដល់*អត្តពលិក*ថា *សំណាក*នោះគឺជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ពីការបំពានវិធានប្រឆាំងដូប៉ាប្រការ 2.1។ ប្រសិនបើបន្ទាប់ពីមានការជូនដំណឹងបែបនេះ *អង្គការប្រឆាំងដូប៉ា* ចង់ធ្វើការវិភាគបន្ថែមលើ*សំណាក*នោះ ទីភ្នាក់ងារនេះអាចធ្វើបានដោយមានការយល់ព្រមពី*អត្តពលិ ក* ឬការយល់ព្រមពីក្រុមប្រឹក្សាសវនាការ។

*បំពានវិធានប្រឆាំងដូប៉ា ក្រោមប្រការ 2.2 ឬទាំងពីរ។ សូមមើលផងដែរនូវសេចក្តីអធិប្បាយចំពោះប្រការ 5.1 និង 23.2.2 ។ ]*

41 *[សេចក្តីអធិប្បាយចំពោះប្រការ 6.3៖ ដូចករណីនៅក្នុងបរិបទវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រភាគច្រើន ការប្រើសំណាក និងព័ត៌មានពាក់ព័ន្ធសម្រាប់ការធានាគុណភាព ការកែលម្អគុណភាព ការកែលម្អវិធីសាស្ត្រ និងការអភិវឌ្ឍ ឬដើម្បីបង្កើតចំនួននៃក្រុមមនុស្ស មិនត្រូវបានចាត់ទុកថាជាការស្រាវជ្រាវទេ។ សំណាក និងព័ត៌មានពាក់ព័ន្ធដែលត្រូវបានប្រើសម្រាប់គោលបំណងមិនមែនស្រាវជ្រាវដែលត្រូវបានអនុញ្ញាតនោះ ដំបូងក៏ត្រូវដំណើរការក្នុងលក្ខណៈមួយដែលការពារកុំឱ្យគេតាមរកអត្តពលិកជាក់លាក់នោះបាន ដោយផ្អែកលើគោលការណ៍ដែលមានចែងក្នុងប្រការ 19 ក៏ដូចជាលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិសម្រាប់មន្ទីរពិសោធន៍ និងស្តង់ដារអន្តរជាតិសម្រាប់ការការពារឯកជនភាព និងព័ត៌មានផ្ទាល់ខ្លួន។ ]*

42 *[សេចក្តីអធិប្បាយចំពោះប្រការ 6.4៖ គោលបំណងនៃប្រការនេះគឺដើម្បីពង្រីកគោលការណ៍ "ធ្វើតេស្តវៃឆ្លាត" ធៀបនឹងមីនុយវិភាគសំណាក ដើម្បីរកសារធាតុដូប៉ាប្រកបដោយប្រសិទ្ធភាព និងមានប្រសិទ្ធផលបំផុត។ គេទទួលស្គាល់ថា ធនធានដើម្បីធប្រឆាំងនឹងដូប៉ាមានកំណត់ ហើយថាការបង្កើនបញ្ជីវិភាគសំណាកអាចកាត់បន្ថយ នៅក្នុងកីឡា និងប្រទេសខ្លះ ចំនួនសំណាកដែលអាចត្រូវបានវិភាគ។ ]*

## 6.6 ការវិភាគបន្ថែមលើ*សំណាក*ណាមួយ បន្ទាប់ពីវាត្រូវបានគេរាយការណ៍ថា វិជ្ជមាន ឬមិនមានលទ្ធផលក្នុងការចោទប្រកាន់ពីការបំពានវិធានប្រឆាំងដូប៉ា

បន្ទាប់ពីមន្ទីរពិសោធន៍បានរាយការណ៍ពីសំណាក នោះថាវិជ្ជមាន ឬ*សំណាក* នោះមិននាំឱ្យមានការចោទប្រកាន់ពីការបំពានវិធានប្រឆាំងដូប៉ាទេនោះ *សំណាក*នោះអាចត្រូវបានរក្សាទុក និងធ្វើការវិភាគបន្ថែម សម្រាប់គោលបំណងនៃប្រការ 6.2 នៅគ្រប់ពេលវេលា តាមការសម្រេចផ្តាច់មុខរបស់ *អង្គការប្រឆាំងដូប៉ា*ដែលផ្តួចផ្តើម និងដឹកនាំការប្រមូលសំណាក ឬ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ *អង្គការប្រឆាំងដូប៉ា*ណាមួយផ្សេងទៀតដែលមានសិទ្ធិ *ធ្វើតេស្ត អត្តពលិក* និងដែលមានបំណងធ្វើការវិភាគបន្ថែមលើ *សំណាក*ដែលត្រូវបានរក្សាទុក អាចធ្វើវាបាន ដោយមានការអនុញ្ញាតពី*អង្គការប្រឆាំងដូប៉ា*ដែលផ្តួចផ្តើម និងដឹកនាំការប្រមូល *សំណាក* ឬ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ហើយត្រូវទទួលខុសត្រូវចំពោះការតាមដាន *ការដោះស្រាយវិវាទដូប៉ា*នោះ។ ការរក្សាទុក*សំណាក*ណាមួយ ឬការវិភាគបន្ថែមដែលបានផ្តួចផ្តើមដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬ*អង្គការប្រឆាំងដូប៉ា*ផ្សេងទៀតត្រូវស្ថិតក្រោមការចំណាយរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬការចំណាយរបស់អង្គការនោះ។ ការវិភាគបន្ថែមទៀតលើសំណាក នឹងត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនៃ *ស្តង់ដារអន្តរជាតិ*ស្តីពីមន្ទីរពិសោធន៍។

## 6.7 ការបែងចែក*សំណាក* (ក) ឬ*សំណាក* (ខ)

ក្នុងករណីដែល *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* *អង្គការប្រឆាំងដូប៉ា*ដែលមានសិទ្ធិក្នុង *ការដោះស្រាយវិវាទដូប៉ា* និង/ឬមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* (ផ្តល់សិទ្ធិដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ឬ*អង្គការប្រឆាំងដូប៉ា*ជាមួយនឹង *ការដោះស្រាយវិវាទដូប៉ា*) មានបំណងញែកសំណាក(ក) ឬសំណាក (ខ) សម្រាប់គោលបំណងនៃការប្រើផ្នែកទីមួយសម្រាប់ការវិភាគសំណាក (ក) និងផ្នែកទីពីរនៃ *សំណាក*ដែលបានញែកសម្រាប់ការបញ្ជាក់នោះ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុង *ស្តង់ដារអន្តរជាតិ*ស្តីពីមន្ទីរពិសោធន៍។

## 6.8 សិទ្ធិរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ក្នុងការកាន់កាប់ *សំណាក* និងទិន្នន័យ

ក្រោមការសម្រេចផ្តាច់មុខរបស់ខ្លួន នៅពេលណាក៏បាន ដោយមាន ឬគ្មានការជូនដំណឹងជាមុន *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចទាមទាមជាកម្មសិទ្ធិនូវ*សំណាក* និងទិន្នន័យវិភាគ ឬព័ត៌មានដែលកាន់កាប់ដោយមន្ទីរពិសោធន៍ ឬ*អង្គការប្រឆាំងដូប៉ា*។ តាមការស្នើសុំដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* មន្ទីរពិសោធន៍ ឬ*អង្គការប្រឆាំងដូប៉ា*ដែលកាន់កាប់ *សំណាក* ឬទិន្នន័យ ត្រូវផ្តល់សិទ្ធិឱ្យចូលដំណើរការ និងអនុញ្ញាតឱ្យ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដែលកាប់កាប់ជាម្ចាស់កម្មសិទ្ធិនូវ*សំណាក* ឬទិន្នន័យនោះ។[43]ប្រសិនបើ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* មិនបានផ្តល់សេចក្តីជូនដំណឹងជាមុនដល់មន្ទីរពិសោធន៍ ឬ*អង្គការប្រឆាំងដូប៉ា* មុនពេលចូលកាន់កាប់ជាកម្មសិទ្ធិនូវ*សំណាក*ឬទិន្នន័យនោះទេ ទីភ្នាក់ងារនេះត្រូវជូនដំណឹងដល់មន្ទីរពិសោធន៍ និង*អង្គការប្រឆាំងដូប៉ា*នីមួយៗ ដែល*សំណាក* ឬទិន្នន័យរបស់ខ្លួនត្រូវបានទាញយកជាកម្មសិទ្ធិដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក្នុងរយៈពេលសមស្រប បន្ទាប់ពីការយកជាកម្មសិទ្ធិនោះ។ បន្ទាប់ពីការវិភាគ និងការស៊ើបអង្កេតណាមួយលើ*សំណាក* ឬ

*43 [សេចក្តីអធិប្បាយចំពោះប្រការ 6.8៖ ការប្រឆាំង ឬការបដិសេធមិនឱ្យទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកយកសំណាក ឬទិន្នន័យរាងកាយ អាចជាការធ្វើឱ្យខូចដំណើរការ ការសមគំនិត ឬសកម្មភាពនៃការមិនអនុលោមតាម ដូចដែលមានចែងក្នុងស្តង់ដារអន្តរជាតិសម្រាប់ការអនុលោមតាមក្រមដោយស្ថាប័នហត្ថលេខី ហើយក៏អាចជាការបំពានស្តង់ដារអន្តរជាតិសម្រាប់មន្ទីរពិសោធន៍ផងដែរ។ ក្នុងករណីចាំបាច់ មន្ទីរពិសោធន៍ និង/ឬអង្គការប្រឆាំងដូប៉ាត្រូវជួយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងការធានាថា សំណាក ឬទិន្នន័យដែលបានរឹបអូសមិនត្រូវបានពន្យារពេលដឹកចេញចេញពីប្រទេសជាធរមាននោះទេ។ ]*

ទិន្នន័យដែលរឹបអូស ហើយ *ទីភ្នាក់ងារប្រឆាំងដូប៉ាំងពិភពលោក* អាចចាត់តាំងឱ្យ*អង្គការប្រឆាំងដូប៉ា*មួយផ្សេងទៀត ដែលមានសិទ្ធិក្នុងការ*ធ្វើតេស្ត*លើ*អត្តពលិក* ដើម្បីទទួលខុសត្រូវលើ*ការដោះស្រាយវិវាទដូប៉ា* សម្រាប់*សំណាក* ឬ ទិន្នន័យនោះ ក្នុងករណីមានការបំពានវិធានប្រឆាំងដូប៉ា។[44]

## ប្រការ 7៖ *ការដោះស្រាយវិវាទដូប៉ា* ការទទួលខុសត្រូវ ការត្រួតពិនិត្យបឋម ការជូនដំណឹង និងការព្យួរសិទ្ធិបណ្ដោះអាសន្ន[45]

*ការដោះស្រាយវិវាទដូប៉ា* ក្រោម*ក្រម*នេះ (ដូចមានចែងក្នុងប្រការ 7, 8 និង13) បង្កើតជាដំណើរការមួយ ដែលត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាបំពានវិធានប្រឆាំងដូប៉ាប្រកបដោយភាពយុត្តិធម៌ រហ័ស និងមានប្រសិទ្ធភាព។ *ទីភ្នាក់ងារប្រឆាំងដូប៉ា*នីមួយៗ ដែលធ្វើ*ការដោះស្រាយវិវាទដូប៉ា* ត្រូវបង្កើតដំណើរការមួយសម្រាប់រដ្ឋបាលមុនសវនាការអំពីការបំពានវិធានប្រឆាំងដូប៉ាដែលអាចកើតមានដែលគោរពតាមគោលការណ៍ដែលមានចែងក្នុងប្រការនេះ។ ខណៈពេលដែល *ទីភ្នាក់ងារប្រឆាំងដូប៉ា*នីមួយៗត្រូវបានអនុញ្ញាតឱ្យអនុម័ត និងអនុវត្តដំណើរការ*ការដោះស្រាយវិវាទដូប៉ា*ផ្ទាល់ខ្លួន*ការដោះស្រាយវិវាទដូប៉ា* សម្រាប់រាល់*អង្គការប្រឆាំងដូប៉ា* ត្រូវបំពេញតាមតម្រូវការដែលមានចែងក្នុង *ស្តង់ដារអន្តរជាតិ* ស្តីពី*ការដោះស្រាយវិវាទដូប៉ា*។

### 7.1 ទំនួលខុសត្រូវក្នុងការអនុវត្ត*ការដោះស្រាយវិវាទដូប៉ា*

លើកលែងតែដូចអ្វីដែលមានចែងក្នុងប្រការ 6.6 ប្រការ 6.8 និងប្រការ 7.1.5 នៃក្រម *ការដោះស្រាយវិវាទដូប៉ា*នឹងត្រូវជាទំនួលខុសត្រូវ និងត្រូវបានគ្រប់គ្រងដោយវិធាននីតិវិធីរបស់អង្គការប្រឆាំងដូប៉ាដែលបានផ្តួចផ្តើម និងដឹកនាំការប្រមូល*សំណាក* (ឬបើមិនមានការប្រមូល*សំណាក*ទេ *អង្គការប្រឆាំងដូប៉ា* ដែលផ្តល់ការជូនដំណឹងបឋមដល់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតអំពីការបំពានវិធានប្រឆាំងដូប៉ា ហើយបន្ទាប់មកបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់បន្តថាការបំពានវិធានប្រឆាំងដូប៉ា)។ ស្ថាប័នណាក៏ដោយដែលធ្វើការ *ការដោះស្រាយវិវាទដូប៉ា* ត្រូវគោរពគោលការណ៍*ការដោះស្រាយវិវាទដូប៉ា* ដែលមានចែងក្នុង ប្រការ 8 ប្រការ 13 និង *ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា* ហើយវិធានរបស់*អង្គការប្រឆាំងដូប៉ា*នីមួយៗ ត្រូវបញ្ចូល និងអនុវត្តវិធានដែលមានចែងក្នុងប្រការ23.2.2 ដោយ

---

44 *[សេចក្តីអធិប្បាយចំពោះប្រការ 6.8៖ ជាការពិត ទីភ្នាក់ងារប្រឆាំងដូប៉ាំងពិភពលោកនឹងមិនកាន់កាប់ដោយឯកតោភាគីនូវសំណាក ឬទិន្នន័យវិភាគដោយគ្មានមូលហេតុទេ ទាក់ទងនឹងករណីសក្តានុពលនៃការបំពានវិធានប្រឆាំងការប្រើប្រាស់នឹងសារធាតុ ការមិនអនុលោមតាមដោយស្ថាប័នហត្ថលេខី ឬសកម្មភាពនៃដូប៉ារបស់បុគ្គលផ្សេងទៀត។ ទោះយ៉ាងណាការសម្រេចចិត្តថា តើមានហេតុផលសមស្រប ឬអត់ គឺជាឆន្ទានុសិទ្ធិរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ហើយមិនអាចត្រូវបានជំទាស់ឡើយ។ ជាពិសេស ថាតើមានហេតុផលសមស្រប ឬអត់ នឹងមិនអាចត្រូវបានយកជាអំណះអំណាងការពារប្រឆាំងនឹងការបំពានវិធានប្រឆាំងដូប៉ា ឬទណ្ឌកម្មណាមួយឡើយ។ ]*

45 *[សេចក្តីអធិប្បាយចំពោះប្រការ 7៖ ស្ថាប័នហត្ថលេខីផ្សេងៗបានបង្កើតវិធីសាស្ត្រផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ការដោះស្រាយវិវាទដូប៉ា។ ខណៈដែលវិធីសាស្ត្រផ្សេងៗមិនមានសង្គតិភាពទាំងស្រុង វិធីសាស្ត្រជាច្រើនត្រូវបានបង្ហាញថាជាប្រព័ន្ធយុត្តិធម៌ និងប្រសិទ្ធភាពសម្រាប់ការដោះស្រាយវិវាទដូប៉ា។ ក្រមនេះមិនជំនួសប្រព័ន្ធគ្រប់គ្រងលទ្ធផលតេស្តរបស់ស្ថាប័នហត្ថលេខីនីមួយៗទេ។ ទោះយ៉ាងណាក៏ដោយ ប្រការនេះ និងស្តង់ដារអន្តរជាតិសម្រាប់ការដោះស្រាយវិវាទដូប៉ាបានបញ្ជាក់អំពីគោលការណ៍ជាមូលដ្ឋាន ដើម្បីធានាបាននូវភាពយុត្តិធម៌ជាមូលដ្ឋាននៃដំណើរការដោះស្រាយវិវាទដូប៉ា ដែលត្រូវតែគោរពតាមដោយស្ថាប័នចុះហត្ថលេខីនីមួយៗ។ វិធានប្រឆាំងដូប៉ាជាក់លាក់របស់ស្ថាប័នហត្ថលេខីនីមួយៗត្រូវស្របជាមួយនឹងគោលការណ៍មូលដ្ឋានទាំងនេះ។ មិនមែនគ្រប់នីតិវិធីប្រឆាំងដូប៉ា ដែលផ្តួចផ្តើមឡើងដោយអង្គការប្រឆាំងដូប៉ា ត្រូវមានសវនាការទាំងអស់ទេ។ អាចមានករណីដែលអត្តពលិក ឬបុគ្គលផ្សេងទៀតយល់ស្របចំពោះការដាក់ទណ្ឌកម្ម ដែលកំណត់ដោយក្រមនេះ ឬដែលអង្គការប្រឆាំងដូប៉ាចាត់ទុកថាសមស្រប ក្នុងករណីដែលភាពបត់បែនក្នុងការដាក់ទណ្ឌកម្មត្រូវបានអនុញ្ញាត។ គ្រប់ករណីទាំងអស់ ការដាក់ទណ្ឌកម្មដែលផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងបែបនេះនឹងត្រូវរាយការណ៍ទៅភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមប្រការ 13.2.3 ដូចមានចែងក្នុងប្រការ 14 និងបោះផ្សាយដូចមាចែងក្នុងប្រការ 14.3 ។]*

គ្មានការផ្លាស់ប្តូរធំដុំឡើយ។

7.1.1 ប្រសិនបើមានជម្លោះកើតឡើងរវាង *អង្គការប្រឆាំងដូប៉ា* ថាតើអង្គការប្រឆាំងដូប៉ាណាដែលទទួលខុសត្រូវ *ការដោះស្រាយវិវាទដូប៉ា* *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវសម្រេចថាតើស្ថាប័នណាមានទំនួលខុសបែបនេះ។ សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចត្រូវបានប្តឹងជំទាស់ទៅ *មជ្ឈត្តកម្មកីឡា* ក្នុងរយៈពេលប្រាំពីរ (7) ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីសេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដោយអង្គការប្រឆាំងដូប៉ាដែលពាក់ព័ន្ធនឹងជម្លោះ។ បណ្តឹងជំទាស់នឹងត្រូវដោះស្រាយដោយ *មជ្ឈត្តកម្មកីឡា* ក្នុងលក្ខណៈឆាប់រហ័សហើយនឹងត្រូវបានស្តាប់នៅចំពោះមុខអាជ្ញាកណ្តាលតែមួយ។ *អង្គការប្រឆាំងដូប៉ា*ណា ដែលចង់ធ្វើ*ការដោះស្រាយវិវាទដូប៉ា* នៅក្រៅអាជ្ញាធរដែលមានចែងក្នុង ប្រការ 7.1 នេះ អាចស្វែងរកការយល់ព្រមដើម្បីធ្វើដូច្នេះពី *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។

7.1.2 ក្នុងការដែល*អង្គការជាតិប្រឆាំងដូប៉ា* ជ្រើសរើសយក *សំណាក* បន្ថែមយោងតាម ប្រការ 5.2.6 នោះអង្គការនេះនឹងត្រូវចាត់ទុកថាជា *អង្គការជាតិប្រឆាំងដូប៉ា* ដែលផ្តួចផ្តើម និងដឹកនាំការប្រមូល *សំណាក*។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីដែល*អង្គការជាតិប្រឆាំងដូប៉ា* គ្រាន់តែដឹកនាំមន្ទីរពិសោធន៍ ដើម្បីធ្វើការវិភាគប្រភេទបន្ថែមក្រោមការចំណាយរបស់*អង្គការជាតិប្រឆាំងដូប៉ា* នោះសហព័ន្ធអន្តរជាតិ ឬ*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ត្រូវបានចាត់ទុកថាជា *អង្គការប្រឆាំងដូប៉ា* ដែលផ្តួចផ្តើម និងដឹកនាំការប្រមូល *សំណាក*។

7.1.3 ក្នុងករណីដែលវិធានរបស់*អង្គការជាតិប្រឆាំងដូប៉ា* មិនផ្តល់ដល់*អង្គការជាតិប្រឆាំងដូប៉ា*នូវសិទ្ធិអំណាចលើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលមិនមែនមានសញ្ជាតិ ឬមិនមែនជានិវាសនជន អ្នកកាន់អាជ្ញាប័ណ្ណ ឬសមាជិកនៃអង្គការកីឡានៃប្រទេសនោះ ឬក្នុងករណីដែល*អង្គការជាតិប្រឆាំងដូប៉ា* បដិសេធមិនអនុវត្តអំណាចបែបនោះ *ការដោះស្រាយវិវាទដូប៉ា* ត្រូវអនុវត្តដោយសហព័ន្ធកីឡាអន្តរជាតិដែលមានសិទ្ធិ ឬដោយតតិយជនដែលមានសិទ្ធិអំណាចលើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ស្របតាមវិធានរបស់សហព័ន្ធកីឡាអន្តរជាតិដែលមានសិទ្ធិនោះ។ សម្រាប់គោលបំណង*ការដោះស្រាយវិវាទដូប៉ា* សម្រាប់ការធ្វើតេស្ត ឬការវិភាគបន្ថែមដែលធ្វើឡើងដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ឬការបំពានវិធានប្រឆាំងដូប៉ា ដែលរកឃើញដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*នឹងចាត់តាំង *អង្គការប្រឆាំងដូប៉ា*ដែលមានសិទ្ធិអំណាចលើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត។[46]

7.1.4 ចំពោះ*ការដោះស្រាយវិវាទដូប៉ា* ទាក់ទងនឹង*សំណាក*ដែលបានផ្តួចផ្តើម និងយកក្នុងកំឡុងពេល*ព្រឹត្តិការណ៍* ដែលធ្វើឡើងដោយ *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ឬការបំពានវិធានប្រឆាំងដូប៉ា ដែលកើតមានឡើងក្នុងកំឡុងពេល*ព្រឹត្តិការណ៍* នោះ *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* សម្រាប់ *ព្រឹត្តិការណ៍* នោះត្រូវទទួលខុសត្រូវចំពោះ *លទ្ធផលនៃការគ្រប់គ្រងយ៉ាងហោចណាស់* នៃការធ្វើសវនាការដើម្បីកំណត់ថា តើការបំពានលើវិធានប្រឆាំងដូប៉ាត្រូវបានប្រព្រឹត្ត ឬទេប្រសិនបើការ*ដកសិទ្ធិ*អនុវត្តតាមប្រការ 9 និង 10.1 ការរឹបអូសយកមេដាយ ពិន្ទុ ឬរង្វាន់ណាមួយពី *ព្រឹត្តិការណ៍* នោះ និងការស្តារឡើងវិញនូវថ្លៃដើមដែលអនុវត្តចំពោះការ

46 *[សេចក្តីអធិប្បាយចំពោះប្រការ 7.1.3៖ សហព័ន្ធអន្តរជាតិរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបានបង្កើតជាទីភ្នាក់ងារប្រឆាំងដូប៉ា ជាជម្រើសចុងក្រោយ សម្រាប់ការដោះស្រាយវិវាទដូប៉ា ដើម្បីចៀសវាងករណីដែលថា គ្មានអង្គការប្រឆាំងដូប៉ាណាមួយមានអំណាចលើការដោះស្រាយវិវាទដូប៉ា។ សហព័ន្ធអន្តរជាតិមានសិទ្ធិចែងក្នុងវិធានប្រឆាំងនឹងសារធាតុដូប៉ាផ្ទាល់របស់ខ្លួនថាស្ថាប័នជាតិប្រឆាំងដូប៉ារបស់អត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវអនុវត្តការដោះស្រាយវិវាទដូប៉ា។]*

បំពានលើវិធានប្រឆាំងដូប៉ា។ នៅក្នុង*ព្រឹត្តិការណ៍*ដែល *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* សន្មតថា មានការទទួលខុសត្រូវលើ*ការដោះស្រាយវិវាទដូប៉ា* មានកំណត់ករណីនេះត្រូវបញ្ជូនដោយ *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ទៅសហព័ន្ធអន្តរជាតិដែលពាក់ព័ន្ធដើម្បីបញ្ចប់*ការដោះស្រាយវិវាទដូប៉ា*។

7.1.5 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*អាចចាត់តាំងឱ្យ*អង្គការប្រឆាំងដូប៉ា*ដែលមានសិទ្ធិគ្រប់គ្រងធ្វើ*ការដោះស្រាយវិវាទដូប៉ា* ក្នុងករណីជាក់លាក់ណាមួយ។ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*បដិសេធមិនអនុវត្តការ*ការដោះស្រាយវិវាទដូប៉ា*តេស្តក្នុងរយៈពេលសមហេតុផលតាមកាលកំណត់របស់*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ទ ការបដិសេធបែបនេះនឹងត្រូវបានចាត់ទុកថាជាការមិនគោរពតាមច្បាប់ ហើយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*អាចចាត់តាំងឱ្យ*អង្គការជាតិប្រឆាំងដូប៉ា* មួយផ្សេងទៀតដែលមានអំណាចលើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលមានឆន្ទៈក្នុងការធ្វើដូច្នេះ ដើម្បីទទួលអនុវត្តការងារ*ការដោះស្រាយវិវាទដូប៉ា* ជំនួសឱ្យ*អង្គការជាតិប្រឆាំងដូប៉ា* ឬក្នុងករណីដែលមិនមាន*អង្គការជាតិប្រឆាំងដូប៉ា* បែបនោះទេ *អង្គការជាតិប្រឆាំងដូប៉ា*ណាមួយផ្សេងទៀត ដែលមានបំណងទទួលយកការងារនេះ។ ក្នុងករណីបែបនេះ *អង្គការជាតិប្រឆាំងដូប៉ា*ត្រូវសងថ្លៃចំណាយ និងថ្លៃសេវាមេធាវី ក្នុងការអនុវត្ត*ការដោះស្រាយវិវាទដូប៉ា* ទៅឱ្យ*អង្គការជាតិប្រឆាំងដូប៉ា* ផ្សេងទៀត ដែលកំណត់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ហើយការខកខានក្នុងការទូទាត់សំណង និងថ្លៃសេវាមេធាវី នឹងត្រូវចាត់ទុកថាជាការមិនគោរពច្បាប់។[47]

7.1.6 *ការដោះស្រាយវិវាទដូប៉ា* ទាក់ទងទៅនឹងការខកខានផ្តល់ព័ត៌មានអំពីទីសំចតសក្តានុពល (ការខកខានក្នុងការដាក់ឯកសារ ឬមិនបានធ្វើតេស្ត) នឹងត្រូវគ្រប់គ្រងដោយសហព័ន្ធកីឡាអន្តរជាតិ ឬ*អង្គការជាតិប្រឆាំងដូប៉ា* ដែល អត្តពលិកនោះ ត្រូវដាក់ឯកសារជូន ដូចមានចែងក្នុង*ស្តង់ដារអន្តរជាតិស្តីពី**ការដោះស្រាយវិវាទដូប៉ា*។ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*កំណត់ថា ជាការខកខានមិនបានបំពេញឯកសារ ឬការខកខានក្នុងការ*ធ្វើតេស្ត* ខ្លួននឹងបញ្ជូនព័ត៌មាននោះទៅ*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*តាមរយៈ*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ដែលជាកន្លែងដែលព័ត៌មាននេះ នឹងត្រូវបានផ្តល់ជូនទៅដល់*អង្គការប្រឆាំងដូប៉ា*ដែលពាក់ព័ន្ធផ្សេងៗទៀត ។

## 7.2 ការពិនិត្យឡើងវិញ និងការជូនដំណឹងទាក់ទងនឹងការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាសក្តានុពល

ការត្រួតពិនិត្យ និងការជូនដំណឹងទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ាណាមួយដែលមានសក្តានុពល ស្របតាម *ស្តង់ដារអន្តរជាតិស្តីពី**ការដោះស្រាយវិវាទដូប៉ា* ។

## 7.3 ការកំណត់អត្តសញ្ញាណនៃការបំពានវិធានប្រឆាំងដូប៉ា

មុនពេលផ្តល់ការជូនដំណឹងដល់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត អំពីការបំពានវិធានប្រឆាំងដូប៉ា ដូចមានចែងខាងលើ*អង្គការប្រឆាំងដូប៉ា* ត្រូវយោងលើ*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* និងទាក់ទង *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*និង*អង្គការប្រឆាំងដូប៉ា*ដទៃទៀត ដើម្បីកំណត់ថា តើមានការបំពានវិធានប្រឆាំងដូប៉ាណាមួយ ឬអត់ពីមុនមក។

---

*47 [សេចក្តីអធិប្បាយចំពោះប្រការ 7.1.5៖ ក្នុងករណីដែលទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកណែនាំអង្គការប្រឆាំងដូប៉ាផ្សេងទៀតឱ្យអនុវត្តការដោះស្រាយវិវាទដូប៉ា ឬសកម្មភាពត្រួតពិនិត្យសារជាតុហាមឃាត់ផ្សេងទៀត វាមិនត្រូវបានចាត់ទុកថាជា "ប្រតិភូកម្ម" នៃសកម្មភាពបែបនេះដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកឡើយ។ ]*

## 7.4 គោលការណ៍ដែលអនុវត្តចំពោះការព្យួរសិទ្ធិបណ្ដោះអាសន្ន[48]

7.4.1 ការព្យួរសិទ្ធិបណ្ដោះអាសន្នដែលចាំបាច់ បន្ទាប់ពីការរកឃើញ*លទ្ធផលវិភាគវិជ្ជមាន* ឬ*លទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ*

*ស្ថាប័នហត្ថលេខី*ដែលបានពិពណ៌នាខាងក្រោមនៅក្នុងកថាខណ្ឌនេះត្រូវប្រកាន់យកនូវវិធានដែលផ្ដល់ឱ្យនៅពេលដែល*លទ្ធផលវិភាគវិជ្ជមាន* ឬ*លទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ* (នៅពេលបញ្ចប់*លទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ*)ដំណើរការពិនិត្យឡើងវិញ) ត្រូវបានទទួលសម្រាប់ *សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់* ក្រៅពី *សារធាតុជាក់លាក់* ឬ*វិធីសាស្ត្រជាក់លាក់* *ការព្យួរសិទ្ធិបណ្ដោះអាសន្ន* ត្រូវដាក់ឱ្យអនុវត្តភ្លាមៗ ឬបន្ទាប់ពីការត្រួតពិនិត្យ និងការជូនដំណឹងដែលតម្រូវដោយ ប្រការ 7.2 ៖ ដែល*ស្ថាប័នហត្ថលេខី*គឺជាស្ថាប័នគ្រប់គ្រងនៃ*ព្រឹត្តិការណ៍*មួយ (សម្រាប់ការដាក់ពាក្យទៅ *ព្រឹត្តិការណ៍*នោះ) ក្នុងករណីដែល ស្ថាប័នហត្ថលេខីទទួលខុសត្រូវចំពោះការជ្រើសរើសក្រុម (សម្រាប់ការស្នើសុំជ្រើសរើសក្រុមនោះ) ។ ក្នុងករណីដែល *ស្ថាប័នហត្ថលេខី*គឺជាសហព័ន្ធអន្តរជាតិដែលអាចអនុវត្តបាន។ ឬក្នុងករណីដែល*ស្ថាប័នហត្ថលេខី* គឺជា*អង្គការប្រឆាំងដូប៉ា*ផ្សេងទៀត ដែលមានអំណាច*ការដោះស្រាយវិវាទដូប៉ា*លើការប្រឆាំងដែលបានចោទប្រកាន់ ការបំពានវិធានប្រឆាំងដូប៉ា ។ *ការព្យួរសិទ្ធិបណ្ដោះអាសន្ន*ចាំបាច់ អាចត្រូវបានលុបចោល ប្រសិនបើ៖

(i) អត្តពលិកបង្ហាញដល់ក្រុមប្រឹក្សាជំនុំជម្រះនៃ*អង្គការប្រឆាំងដូប៉ា*ថា ការបំពាននោះទំនងជាពាក់ព័ន្ធនឹង*ផលិតផលមិនស្មោះត្រង់* ឬ

(ii) ការបំពាននោះពាក់ព័ន្ធនឹង*សារធាតុបំពាន* ហើយ*អត្តពលិក*អាចបង្ហាញពីសិទ្ធិប្រើប្រាស់សម្រាប់រយៈពេលខ្លីនៃការ*ព្យួរសិទ្ធិ* តាមប្រការ 10.2.4.1។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះក្នុងការមិនលុបការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*ចាំបាច់ តាមការអះអាងរបស់*អត្តពលិក*ទាក់ទងនឹងផលិតផលដែលមានផ្ទុកសារធាតុដូប៉ាមិនអាចត្រូវបានប្ដឹងជំទាស់ទេ។

7.4.2 *ការព្យួរសិទ្ធិបណ្ដោះអាសន្ន*ជាជម្រើសផ្អែកលើ*លទ្ធផលវិភាគវិជ្ជមាន* សម្រាប់*សារធាតុជាក់លាក់* *វិធីសាស្ត្រជាក់លាក់* *ផលិតផលមិនស្មោះត្រង់* ឬការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាផ្សេងទៀត។

*ស្ថាប័នហត្ថលេខី* អាចអនុម័តច្បាប់ដែលអាចអនុវត្តចំពោះ *ព្រឹត្តិការណ៍* ណាមួយដែល *ស្ថាប័នហត្ថលេខី* ជាស្ថាប័នគ្រប់គ្រង ឬចំពោះដំណើរការជ្រើសរើសក្រុមណាមួយដែល *ស្ថាប័នហត្ថលេខី* ទទួលខុសត្រូវ ឬក្នុងករណីដែល *ស្ថាប័នហត្ថលេខី* ជាសហព័ន្ធអន្តរជាតិដែលអាចអនុវត្តបាន ឬមាន*សិទ្ធិអំណាចគ្រប់គ្រង*

---

48 [សេចក្ដីអធិប្បាយចំពោះប្រការ 7.4៖ មុនពេលការព្យួរសិទ្ធិបណ្ដោះអាចត្រូវបានដាក់ ដោយឯកតោភាគី ដោយ*អង្គការប្រឆាំងដូប៉ា* ត្រូវបំពេញការពិនិត្យផ្ទៃក្នុង ដូចដែលមានចែងនៅក្នុងក្រមនេះ ជាមុនសិន។ លើសពីនេះទៀត ស្ថាប័នហត្ថលេខីដែលកំណត់ការព្យួរសិទ្ធិបណ្ដោះអាសន្នត្រូវធានាថា អត្តពលិកត្រូវបានផ្ដល់ឱកាសឱ្យមានសវនាការបណ្ដោះអាសន្ន ទាំងមុន ឬភ្លាមៗបន្ទាប់ពីការកំណត់ការព្យួរសិទ្ធិបណ្ដោះអាសន្ននោះ ឬសវនាការចុងក្រោយដែលបានពន្លឿន តាមប្រការ 8 ភ្លាមៗបន្ទាប់ពីការកំណត់ការព្យួរសិទ្ធិបណ្ដោះអាសន្ននោះ។ អត្តពលិកមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមប្រការ 13.2.3។ ក្នុងកាលៈទេសៈដ៏កម្រដែលការវិភាគសំណាក ខ មិនបញ្ជាក់លទ្ធផលសំណាក ក អត្តពលិកដែលត្រូវបានព្យួរសិទ្ធិបណ្ដោះអាសន្ននឹងត្រូវបានអនុញ្ញាតតាមកាលៈទេសៈជាក់ស្ដែង ឱ្យចូលរួមការប្រកួតជាបន្តបន្ទាប់ ក្នុងព្រឹត្តិការណ៍នោះ។ ដូចគ្នានេះដែរ អាស្រ័យលើច្បាប់ពាក់ព័ន្ធរបស់សហព័ន្ធអន្តរជាតិក្នុងកីឡាជាក្រុម ប្រសិនបើក្រុមកីឡាកំពុងស្ថិតក្នុងការប្រកួត នោះអត្តពលិកអាចចូលរួមប្រកួតនាពេលអនាគត។ អត្តពលិក និងបុគ្គលផ្សេងទៀតនឹងទទួលបាន*កាត់បន្ថយ*សម្រាប់ការព្យួរសិទ្ធិបណ្ដោះអាសន្នទល់នឹងរយៈពេលណាមួយនៃការព្យួរសិទ្ធិ ដែលចុងក្រោយត្រូវបានកំណត់ ឬទទួលយក ដូចមានចែងក្នុងប្រការ 10.13.2 ]

លើការចោទប្រកាន់ប្រឆាំងដូប៉ា ការបំពានច្បាប់អនុញ្ញាតឱ្យមាន*ការព្យួរសិទ្ធិបណ្ដោះអាសន្ន* ចំពោះការបំពានវិធានប្រឆាំងដូប៉ាដែលមិនគ្របដណ្ដប់ដោយប្រការ 7.4.1 មុនពេលធ្វើការវិភាគលើ*សំណាករបស់អត្តពលិក* ឬសវនាការចុងក្រោយដូចដែលបានពិពណ៌នា នៅក្នុង ប្រការ ៨ ។

7.4.3 ឱកាសទទួលបានសវនាការ ឬបណ្ដឹងជំទាស់

ទោះមានចែងក្នុងប្រការ 7.4.1 និងប្រការ 7.4.2 ក៏ដោយ *ការព្យួរសិទ្ធិបណ្ដោះអាសន្ន*មិនអាចត្រូវបានអនុវត្តទេ លុះត្រាតែវិធានរបស់អង្គការប្រឆាំងសារធាតុដូប៉ាផ្តល់ឱ្យ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះបានទទួល៖

(ក) ឱកាសសម្រាប់*សវនាការ*បណ្ដោះអាសន្ន ទោះមុនពេល ឬនៅពេលសមស្រប បន្ទាប់ពីការដាក់ពិន័យ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*នោះ ឬ

(ខ) ឱកាសសម្រាប់សវនាការបន្ទាន់មួយ ស្របតាមប្រការ ៨ ដោយឈរលើមូលដ្ឋានពេលវេលាសមស្រប បន្ទាប់ពីការដាក់ពិន័យ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*នោះ។ វិធានរបស់*អង្គការប្រឆាំងដូប៉ា* ក៏នឹងផ្តល់ឱកាសសម្រាប់ការប្តឹងជំទាស់ឆាប់រហ័សប្រឆាំងនឹងការ*ព្យួរបណ្ដោះអាសន្ន* ឬសេចក្តីសម្រេចមិនដាក់ការ *ព្យួរសិទ្ធិបណ្ដោះអាសន្ន* ស្របតាម ប្រការ 13 ។

7.4.4 ការទទួលយកដោយស្ម័គ្រចិត្តនៃការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*

តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន អត្តពលិកអាចទទួលយកការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* ដោយស្ម័គ្រចិត្ត ប្រសិនបើពួកគេធ្វើដូច្នេះ មុនរយៈពេលចុងក្រោយនេះ

(i) ការផុតកំណត់រយៈពេលដប់ (10) ថ្ងៃបន្ទាប់ពីរបាយការណ៍ សំណាក (ខ) (ឬ ការបោះបង់សិទ្ធិលើ *សំណាក* (ខ) ឬដប់ (10) ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត ឬ

(ii) កាលបរិច្ឆេទដែលអត្តពលិកចូលរួមប្រកួតដំបូង បន្ទាប់ពីមានរបាយការណ៍ ឬ ការជូនដំណឹងបែបនេះ។ ក្រោមគំនិតផ្តួចផ្តើមដោយខ្លួនឯង បុគ្គលផ្សេងទៀតអាចទទួលយកការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* ដោយស្ម័គ្រចិត្ត ប្រសិនបើធ្វើដូច្នេះក្នុងរយៈពេលដប់ (10) ថ្ងៃចាប់ពីការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាទៅ។ ក្រោយការទទួលយកដោយស្ម័គ្រចិត្តបែបនេះ ការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*នឹងមានប្រសិទ្ធភាពពេញលេញ និងត្រូវបានអនុវត្តដូចគ្នានឹងការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* ដូចដែលត្រូវបានកំណត់ក្នុងប្រការ 7.4.1 ឬ ប្រការ 7.4.2 ក្នុងលក្ខខណ្ឌដែលថានៅពេលណាមួយបន្ទាប់ពីទទួលយកការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*ដោយស្ម័គ្រចិត្តនេះ *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀតអាចដកការទទួលយកការព្យួរសិទ្ធិនេះវិញបាន ដែលក្នុងករណីនេះ *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀតនឹងមិនទទួលបានការលើកលែងណាមួយចំពោះការអនុវត្តពីមុនក្នុងកំឡុងពេលនៃការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*នោះទេ។

7.4.5 ប្រសិនបើការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*នោះផ្អែកលើ*លទ្ធផលវិភាគវិជ្ជមាន* នៃសំណាក (ក) ហើយបន្ទប់

មក ការវិភាគ*សំណាក* (ខ) (ប្រសិនបើស្នើសុំដោយ *អត្តពលិក* ឬ*អង្គការប្រឆាំងដូប៉ា*) មិនបានបញ្ជាក់សុពលភាពនៃការវិភាគ*សំណាក* (ក) ទេនោះ *អត្តពលិក* នឹងមិនត្រូវទទួលរងការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* បន្ថែម លើការបំពានប្រការ 2.1។ ក្នុងកាលៈទេសៈដែល *អត្តពលិក* (ឬក្រុមរបស់ អត្តពលិកដូចដែលមានចែងនៅក្នុងវិធានរបស់*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ឬសហព័ន្ធអន្តរជាតិ) ត្រូវបានដកចេញពីព្រឹត្តិការណ៍កីឡាណាមួយ ដោយផ្អែកលើការបំពានប្រការ 2.1 ហើយបន្ទាប់មក ការវិភាគសំណាក (ខ) មិនបញ្ជាក់សុពលភាពលទ្ធផល សំណាក (ក) នោះ ប្រសិនបើវានៅតែអាចឱ្យ*អត្តពលិក* ឬក្រុមរបស់*អត្តពលិក*ចូលរួម*ព្រឹត្តិការណ៍*នោះឡើងវិញ ដោយមិនមានការប៉ះពាល់ដល់*ព្រឹត្តិការណ៍* *អត្តពលិក* ឬក្រុមនោះ អាចបន្តចូលរួមក្នុង*ព្រឹត្តិការណ៍*នោះបាន ។

## 7.5 សេចក្ដីសម្រេចស្ដីពី*ការដោះស្រាយវិវាទដូប៉ា*

7.5.1 សេចក្ដីសម្រេចលើ*ការដោះស្រាយវិវាទដូប៉ា* ឬសេចក្ដីសម្រេចរបស់*អង្គការប្រឆាំងដូប៉ា*មិនត្រូវបង្ហាញថាកំណត់ត្រឹមតែចំពោះតំបន់ភូមិសាស្ត្រ ឬកីឡាជាក់លាក់ណាមួយឡើយ ហើយដោយគ្មានដែនកំណត់ ត្រូវដោះស្រាយ និងកំណត់បញ្ហាដូចខាងក្រោម៖

(i) កំណត់ថា តើមានការបំពានវិធានប្រឆាំងដូប៉ា ឬទេ ឬថាតើគួរធ្វើការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* ឬទេ កំណត់មូលដ្ឋានសម្រាប់ធ្វើសេចក្ដីសម្រេច និងកំណត់ប្រការជាក់លាក់ដែលត្រូវបានបំពាន និង

(ii) រាល់ទណ្ឌកម្មទាំងអស់ដែលកើតចេញពីការបំពានវិធានប្រឆាំងដូប៉ា រួមទាំង ការ*ដកសិទ្ធិ* តាមប្រការ 9 និង 10.10 ការដកមេដាយ ឬរង្វាន់មកវិញរយៈពេល*ព្យួរសិទ្ធិ* (និងកាលបរិច្ឆេទចាប់ផ្ដើមដំណើរការ) និងទណ្ឌកម្មហិរញ្ញវត្ថុណាមួយ លើកលែងតែ*ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ* ដែលមិនត្រូវបានទាមទារឱ្យកំណត់ពីភាពការ*ព្យួរសិទ្ធិ* ឬទណ្ឌកម្មហិរញ្ញវត្ថុហួសពីវិសាលភាពនៃ*ព្រឹត្តិការណ៍*របស់ពួកគេឡើយ។[49]

7.5.2 សេចក្ដីសម្រេចស្ដីពី*ការដោះស្រាយវិវាទដូប៉ា* ឬការជំនុំជម្រះដោយ*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* ទាក់ទងនឹង *ព្រឹត្តិការណ៍*ណាមួយ របស់វាអាចត្រូវបានកំណត់នៅក្នុងវិសាលភាពរបស់វាប៉ុន្តែត្រូវដោះស្រាយបញ្ហា និងកំណត់យ៉ាងតិចនូវបញ្ហាដូចខាងក្រោម៖

(i) ថាតើការបំពានលើវិធានប្រឆាំងដូប៉ាត្រូវបានប្រព្រឹត្តជាមូលដ្ឋានសម្រាប់ការប្តេជ្ញាចិត្តបែបនេះអង្គហេតុ និងក្រមជាក់លាក់ប្រការបំពាន និង

(ii) ការ*ដកសិទ្ធិ*អនុវត្តតាមប្រការ 9 និង 10.1 ជាមួយនឹងការលះបង់លទ្ធផលនៃមេដាយ ពិន្ទុ និងរង្វាន់។ នៅក្នុងព្រឹត្តិការណ៍ដែល *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* មួយទទួលយកការទទួលខុសត្រូវមានកំណត់ចំពោះ សេចក្ដីសម្រេចស្ដីពី*ការដោះស្រាយវិវាទដូប៉ា* វាត្រូវតែអនុវត្តតាមប្រការ 7.1.4 ។[50]

---

49 [សេចក្ដីអធិប្បាយចំពោះ ប្រការ 7.5.1 ៖ សេចក្ដីសម្រេចលើ*ការដោះស្រាយវិវាទដូប៉ា*រួមមានការព្យួរសិទ្ធិបណ្ដោះអាសន្ន។ ]

50 [សេចក្ដីអធិប្បាយចំពោះប្រការ 7.5.2៖ លើកលែងតែមានសេចក្ដីសម្រេចស្ដីពី*ការដោះស្រាយវិវាទដូប៉ា*ដោយ*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ*។ សេចក្ដីសម្រេចនីមួយៗរបស់ស្ថាប័នប្រឆាំង*ដូប៉ា*គួរកំណត់ថា តើមានការ*បំពាន*វិធានប្រឆាំង*ដូប៉ា*ត្រូវបានប្រព្រឹត្ត ឬទេ និងរាល់ទណ្ឌកម្មដែលកើតចេញពីការ*បំពាន*នោះ រួមទាំងការដកសិទ្ធិណាមួយ ឬការដកសិទ្ធិផ្សេងទៀតតាមប្រការ

## 7.6 ការជូនដំណឹងអំពីសេចក្តីសម្រេចលើ *ការដោះស្រាយវិវាទដូប៉ា*

*អត្តពលិក បុគ្គល*ផ្សេងទៀត *ស្ថាប័នហត្ថលេខី* និង *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចលើការ*ដោះស្រាយវិវាទដូប៉ា* ដូចមានចែងក្នុងប្រការ 14 និងក្នុង*ស្តង់ដាអន្តរជាតិ* ស្តីពី *ការដោះស្រាយវិវាទដូប៉ា*។

## 7.7 ការចូលនិវត្តន៍ពីកីឡា[51]

ប្រសិនបើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតចូលនិវត្តន៍នៅពេលដែលកំពុង*ដោះស្រាយវិវាទដូប៉ា* អង្គការប្រឆាំងដូប៉ារក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការ *ការដោះស្រាយវិវាទដូប៉ា*របស់ខ្លួន។ ប្រសិនបើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតចូលនិវត្តន៍មុនពេលនៃការចាប់ផ្តើម ដំណើរ*ការដោះស្រាយវិវាទដូប៉ា* ហើយប្រសិនបើ*អង្គការប្រឆាំងដូប៉ា*អាចមានសិទ្ធិលើការ គ្រប់គ្រង លើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ នៅពេលដែល *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ បានបំពានវិធានប្រឆាំងដូប៉ា អង្គការប្រឆាំងដូប៉ាមានសិទ្ធិក្នុងការអនុវត្ត*ការដោះស្រាយវិវាទដូប៉ា* ។

# ប្រការ ៨៖ *ការដោះស្រាយវិវាទដូប៉ា*៖ សិទ្ធិទទួលបានសវនាការយុត្តិធម៌ និងការជូនដំណឹងអំពីសេចក្តីសម្រេចរបស់សវនាការ

## 8.1 សវនាការយុត្តិធម៌

ចំពោះ*បុគ្គល*ណាដែលត្រូវបានអះអាងថា បានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ា *អង្គការប្រឆាំងដូប៉ា*ជាមួយនឹងការទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ាត្រូវផ្តល់សវនាការដោយយុត្តិធម៌ក្នុងរយៈពេលសមហេតុផល តាមរយៈក្រុមប្រឹក្សាជំនុំជម្រះដែលយុត្តិធម៌ មិនលម្អៀង និងឯករាជ្យក្នុងប្រតិបត្តិការ ដោយអនុលោមតាមក្រម និង*ស្តង់ដាអន្តរជាតិ*ស្តីពី*ការដោះស្រាយវិវាទដូប៉ា*។ សេចក្តីសម្រេចដែលមានហេតុផល និងទាន់ពេលវេលាមួយ ដែលរួមទាំងការពន្យល់ហេតុផលសម្រាប់រយៈពេលនៃការ*ព្យួរសិទ្ធិ* ការ*ដកសិទ្ធិ*ក្រោម ប្រការ10.10 ដែលត្រូវផ្សព្វផ្សាយជាសាធារណៈដូចមានចែងក្នុងប្រការ 14.3។[52]

---

10.1 (ដែលស្ថិតក្រោមការសម្រេចរបស់ស្ថាប័នគ្រប់គ្រងការព្រឹត្តិការណ៍កីឡា) ។ អនុលោមតាមប្រការ 15 ការសម្រេចចិត្តបែបនេះ និងការកំណត់ទណ្ឌកម្មនឹងមានឥទ្ធិពលដោយស្វ័យប្រវត្តិនៅក្នុងគ្រប់កីឡានៅគ្រប់ប្រទេស។ ឧទាហរណ៍៖ ដើម្បីកំណត់ថាអត្តពលិកម្នាក់បានបំពានវិធានប្រឆាំង*ដូប៉ា* ឬមិនបាន ដោយផ្អែកលើលទ្ធផលវិភាគ*វិជ្ជមាន*សម្រាប់សំណាកដែលបានយកក្នុងការប្រកួត លទ្ធផលរបស់អត្តពលិកដែលទទួលបានក្នុងការប្រកួតនឹងត្រូវបានមោឃភាពតាមប្រការ 9 ហើយលទ្ធផលដែលមានលក្ខខណៈប្រកួតប្រជែងផ្សេងទៀតទាំងអស់របស់អត្តពលិកនោះ ចាប់ពីថ្ងៃដែលសំណាកត្រូវបានប្រមូលក្នុងរយៈពេលនៃការព្យួរសិទ្ធិ ក៏ត្រូវបានមោឃភាពផងដែរតាមប្រការ 10.10។ ប្រសិនបើមានលទ្ធផលវិភាគ*វិជ្ជមាន*កើតចេញពីការធ្វើតេស្តនៅក្នុងព្រឹត្តិការណ៍កីឡាណាមួយនោះ វានឹងជាការទទួលខុសត្រូវរបស់ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំ ក្នុងការសម្រេចថាតើលទ្ធផលជាលក្ខខណៈបុគ្គលផ្សេងទៀតរបស់អត្តពលិកនោះនៅក្នុងព្រឹត្តិការណ៍មុនពេលប្រមូលសំណាក ត្រូវបានមោឃភាពតាម ប្រការ 10.1 ដែរឬទេ។ ]

51 [សេចក្តីអធិប្បាយចំពោះប្រការ 7.7៖ ការប្រព្រឹត្តរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត មុនពេលអត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបានដាក់ក្រោមអំណាចរបស់*អង្គការប្រឆាំង*ការប្រើប្រាស់សារធាតុដូប៉ាណាមួយ នឹងមិនបង្កើតជាការ*បំពាន*វិធានប្រឆាំង*ដូប៉ា*ទេ ប៉ុន្តែអាចជាមូលដ្ឋានសមស្របក្នុងការបដិសេធអត្តពលិក ឬសមាជិកភាពបុគ្គលផ្សេងទៀតនៅក្នុងអង្គការកីឡា។ ]

52 [សេចក្តីតីអធិប្បាយចំពោះប្រការ 8.1៖ ប្រការនេះតម្រូវថា នៅពេលណាមួយនៅក្នុងដំណើរ*ការដោះស្រាយវិវាទដូប៉ា* អត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបានផ្តល់ឱកាសឱ្យមានសវនាការទាន់ពេលវេលាដោយយុត្តិធម៌ និងមិនលំអៀង។ គោលការណ៍ទាំងនេះក៏មានចែងនៅក្នុងមាត្រា 6.1 នៃអនុសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហើយជាគោលការណ៍ដែលត្រូវបានទទួលយកជាទូទៅនៅក្នុងច្បាប់អន្តរជាតិ។ ប្រការនេះមិនមានបំណងជំនួសវិធានផ្ទាល់ខ្លួនរបស់*អង្គការប្រឆាំងដូប៉ា* សម្រាប់សវនាការនោះទេ ប៉ុន្តែជាការធានាថា *អង្គការប្រឆាំងដូប៉ា*នីមួយៗផ្តល់នូវដំណើរការសវនាការស្របតាមគោលការណ៍ទាំងនេះ។ ]

## 8.2 សវនាការ*ព្រឹត្តិការណ៍*

សវនាការដែលទាក់ទងនឹង *ព្រឹត្តិការណ៍* អាចត្រូវបានធ្វើឡើងដោយដំណើរការលឿនតាមការអនុញ្ញាតដោយវិធានរបស់*អង្គការប្រឆាំងដូប៉ា* ដែលពាក់ព័ន្ធ និងក្រុមប្រឹក្សាជំនុំជម្រះ។[53]

## 8.3 ការបោះបង់សិទ្ធិទទួលបានសវនាការ

សិទ្ធិទទួលបានសវនាការអាចត្រូវបានបោះបង់ដោយផ្ទាល់ ឬដោយការខកខាន*របស់អត្តពលិក*ឬ *បុគ្គល*ផ្សេងទៀត ដើម្បីប្រឆាំងនឹងការអះអាងរបស់*អង្គការប្រឆាំងដូប៉ា* ថាការបំពានវិធានប្រឆាំងដូប៉ាបានកើតឡើងក្នុងរយៈពេលជាក់លាក់ដែលមានចែងក្នុងវិធានរបស់*អង្គការប្រឆាំងដូប៉ា* ។

## 8.4 ការជូនដំណឹងស្តីពីការសេចក្តីសម្រេច

សេចក្តីសម្រេចលើសវនាការដោយមានហេតុផល ឬក្នុងករណីដែលសវនាការត្រូវបានលើកលែង សេចក្តីសម្រេចដោយហេតុផលដែលពន្យល់ពីសកម្មភាពដែលបានអនុវត្តត្រូវផ្តល់ដោយ*អង្គការប្រឆាំងដូប៉ា* ដោយមានការទទួលខុសត្រូវ*ការដោះស្រាយវិវាទដូប៉ា* ចំពោះ*អត្តពលិក* និង*អង្គការប្រឆាំងដូប៉ា* ដទៃទៀតដែលមានសិទ្ធិ បណ្តឹងជំទាស់ក្រោម ប្រការ 13.2.3 ដូចមានចែងក្នុង ប្រការ 14 និងបានបោះពុម្ពផ្សាយស្របតាម ប្រការ 14.3 ។

## 8.5 សវនាការតែមួយលើកនៅចំពោះមុខមជ្ឈត្តកម្មកីឡា

ការបំពានវិធានប្រឆាំងដូប៉ាដែលត្រូវបានចោទប្រឆាំងនឹង*អត្តពលិកកម្រិតអន្តរជាតិ អត្តពលិកកម្រិតជាតិ* ឬ *បុគ្គល*ដទៃទៀត ដោយមានការយល់ព្រមពី*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត *អង្គការប្រឆាំងដូប៉ា*ក្នុងករណីទទួលខុសត្រូវក្នុង*ការដោះស្រាយវិវាទដូប៉ា* និង *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចត្រូវបានធ្វើសវនាការតែមួយលើកដោយផ្ទាល់នៅ*មជ្ឈត្តកម្មកីឡា*។[54]

# ប្រការ 9 ៖ ការ*ដកសិទ្ធិ*ដោយស្វ័យប្រវត្តិនៃលទ្ធផលឯកត្តជន

ការបំពានវិធានប្រឆាំងដូប៉ានៅក្នុងកីឡាឯកត្តជន ពាក់ព័ន្ធនឹងការធ្វើតេស្តសម្រាប់*ក្នុងការប្រកួត* នាំឱ្យមានការបដិសេធលទ្ធផលប្រកួតដោយស្វ័យប្រវត្តិ ព្រមទាំងទណ្ឌកម្មទាំងអស់ រួមទាំងការដកមេដាយ ពិន្ទុ និងរង្វាន់មក វិញ។[55]

---

53 [សេចក្តីអធិប្បាយចំពោះប្រការ 8.2៖ ឧទាហរណ៍៖ សវនាការអាចត្រូវបានពន្លឿននៅមុនថ្ងៃព្រឹត្តិការណ៍សំខាន់មួយ ក្នុងករណីដែលសេចក្តីសម្រេចស្តីពីការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ាមានភាពចាំបាច់ ដើម្បីកំណត់សិទ្ធិរបស់អត្តពលិកក្នុងការចូលរួមព្រឹត្តិការណ៍ ឬអំឡុងព្រឹត្តិការណ៍នោះ ដែលសេចក្តីសម្រេចនៃសំណុំរឿងនឹងប៉ះពាល់ដល់សុពលភាពនៃលទ្ធផល ឬការបន្តចូលរួមក្នុងព្រឹត្តិការណ៍នេះរបស់អត្តពលិក។ ]

54 [សេចក្តីអធិប្បាយចំពោះប្រការ 8.5 ៖ ក្នុងករណីខ្លះ ការចំណាយរួមសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង នៅកម្រិតអន្តរជាតិ ឬថ្នាក់ជាតិ បន្ទាប់មកជំនុំជម្រះឡើងវិញនូវករណីដោយចាប់ផ្តើមឡើងវិញនៅចំពោះមុខមជ្ឈត្តកម្មកីឡាអាចមានសារៈសំខាន់ខ្លាំងណាស់។ ក្នុងករណីដែលភាគីទាំងអស់ដែលបានកំណត់នៅក្នុងប្រការនេះពេញចិត្តថា ផលប្រយោជន៍របស់ពួកគេនឹងត្រូវបានការពារគ្រប់គ្រាន់នៅក្នុងសវនាការតែមួយនោះ មិនចាំបាច់ឱ្យអត្តពលិក ឬ*អង្គការប្រឆាំងដូប៉ា*ចំណាយបន្ថែមលើសវនាការជាលើកទីពីរនោះទេ។ *អង្គការប្រឆាំងដូប៉ា*អាចចូលរួមក្នុងសវនាការមជ្ឈត្តកម្មកីឡា ក្នុងនាមជាអ្នកសង្កេតការណ៍។ ]

## ប្រការ 10៖ ការដាក់ទណ្ឌកម្មលើឯកត្តជន [56]

### 10.1 *ដកសិទ្ធិ*នៃលទ្ធផលនៅក្នុង*ព្រឹត្តិការណ៍* ដែលមានការបំពានវិធានប្រឆាំងដូប៉ា

ការបំពានវិធានប្រឆាំងដូប៉ាដែលកើតឡើងក្នុងអំឡុងពេល ឬពាក់ព័ន្ធនឹង*ព្រឹត្តិការណ៍*មួយ តាមសេចក្តីសម្រេចរបស់ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍*នោះ អាចនាំឱ្យមានការដកសិទ្ធិទាំងអស់របស់អត្តពលិកដែលទទួលបានក្នុង*ព្រឹត្តិការណ៍*នោះ ជាមួយទណ្ឌកម្មទាំងអស់ ដែលរួមទាំងការដកមេដាយ ពិន្ទុ និងរង្វាន់ទាំងអស់មកវិញ លើកលែងតែករណីដូចមានចែងក្នុងប្រការ 10.1.1 ។ [57]

តួអង្គដែលត្រូវបានរាប់បញ្ចូលក្នុងការពិចារណាថា តើត្រូវដកសិទ្ធិផ្សេងទៀតនៅក្នុង*ព្រឹត្តិការណ៍*មួយ អាចរួមបញ្ចូលឧទាហរណ៍ ភាពធ្ងន់ធ្ងរនៃការបំពានវិធានប្រឆាំងដូប៉ារបស់*អត្តពលិក* និងថាតើ*អត្តពលិក*មាន*លទ្ធផលតេស្តវិជ្ជមាន*នៅ*ការប្រកួត*ផ្សេងទៀត ឬទេ។

10.1.1 ប្រសិនបើ*អត្តពលិក*អាចបញ្ជាក់ថាខ្លួន*គ្មានកំហុស* ឬ*ការធ្វេសប្រហែស*ចំពោះការបំពាន របស់*អត្តពលិក*ឯកត្តកជន នៅ*ការប្រកួត*ផ្សេងទៀតនឹងមិនត្រូវ*ដកសិទ្ធិ*ឡើយ លើកលែងតែលទ្ធផលរបស់*អត្តពលិក*នៅ*ការប្រកួត* ដែលកើតមានការបំពានវិធានប្រឆាំងដូប៉ានោះផ្ទាល់ ហើយវាទំនងជាប៉ះពាល់ដល់វិធានប្រឆាំងដូប៉ារបស់*អត្តពលិក*។

### 10.2 ការ*ព្យួរសិទ្ធិ* ចំពោះវត្តមាន *ការប្រើប្រាស់ ឬប៉ុនប៉ងប្រើប្រាស់ ឬការកាន់កាប់ សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់*

រយៈពេលនៃការ*ព្យួរសិទ្ធិ* ចំពោះការបំពានលើប្រការ 2.1 ប្រការ 2.2 ឬប្រការ 2.6 នឹងមានដូចខាងក្រោម អាស្រ័យតាមការបន្ធូរបន្ថយ ឬការព្យួរសក្តានុពលស្របតាមប្រការ 10.5 ប្រការ 10.6 ឬប្រការ 10.7៖

10.2.1 រយៈពេលនៃការ*ព្យួរសិទ្ធិ* អាស្រ័យតាមប្រការ 10.2.4 នឹងមានរយៈពេលបួន (4) ឆ្នាំ ក្នុងករណីដែល៖

---

55 [សេចក្តីអធិប្បាយចំពោះប្រការ 9៖ សម្រាប់កីឡាជាក្រុម ពានរង្វាន់ណាមួយដែលទទួលបានដោយកីឡាករម្នាក់ៗនឹងត្រូវដកហូត។ ទោះយ៉ាងណាក៏ដោយ ការដកសិទ្ធិក្រុមនឹងមានដូចក្នុងប្រការ 11 ។ នៅក្នុងកីឡាដែលមិនមែនជាកីឡាជាក្រុម ប៉ុន្តែរង្វាន់ត្រូវបានផ្តល់ដល់ក្រុម ការដកសិទ្ធិ ឬសកម្មភាពវិន័យផ្សេងទៀតប្រឆាំងនឹងក្រុម នៅពេលសមាជិកក្រុមម្នាក់ ឬច្រើននាក់បានប្រព្រឹត្តល្មើសនឹងវិធានប្រឆាំងសារធាតុដូប៉ា ត្រូវអនុវត្ត ដូចមានចែងក្នុងវិធានជាធរមាននៃសហព័ន្ធអន្តរជាតិ។ ]

56 [សេចក្តីអធិប្បាយចំពោះប្រការ 10៖ សុខដុមនីយកម្មនៃទណ្ឌកម្មគឺជាផ្នែកមួយដែលត្រូវបានពិភាក្សា និងជជែកវែកញែកច្រើនបំផុត អំពីការប្រឆាំង*ដូប៉ា*។ មានន័យថាវិធាន និងលក្ខណៈវិនិច្ឆ័យដូចគ្នាត្រូវបានអនុវត្ត ដើម្បីវាយតម្លៃការពិតជាក់លាក់នៃករណីនីមួយៗ។ អំណះអំណាងប្រឆាំងនឹងការតម្រូវឱ្យមានសង្គតិភាពនៃការដាក់ទណ្ឌកម្មគឺផ្អែកលើភាពខុសគ្នារវាងកីឡារួមទាំងភាពខុសគ្នាដូចខាងក្រោម៖ នៅក្នុងកីឡាខ្លះ អត្តពលិកគឺជាអ្នកជំនាញដែលរកប្រាក់ចំណូលបានច្រើនពីកីឡានោះ ហើយនៅក្នុងកីឡាផ្សេងទៀត អត្តពលិកគឺជាអ្នកដែលមិនយកកីឡាជាអាជីពទេ។ នៅក្នុងកីឡាដែលអាជីពរបស់អត្តពលិកមានរយៈពេលខ្លី រយៈពេលស្តង់ដារនៃការព្យួរសិទ្ធិមានឥទ្ធិពលខ្លាំងទៅលើអត្តពលិក ជាងកីឡាដែលជាអាជីពយូរអង្វែង។ អំណះអំណាងចម្បងក្នុងការធ្វើឱ្យមានសង្គតិភាពគឺថា វាមិនត្រឹមត្រូវទេដែលថាអត្តពលិកពីរនាក់មកពីប្រទេសតែមួយ ដែលធ្វើតេស្តវិជ្ជមានចំពោះសារធាតុហាមឃាត់ដូចគ្នា ក្នុងកាលៈទេសៈស្រដៀងគ្នា ទទួលទណ្ឌកម្មផ្សេងគ្នា ដោយសារតែពួកគេចូលរួមក្នុងកីឡាផ្សេងៗគ្នានោះ។ លើសពីនេះ ភាពបត់បែនច្រើនពេកក្នុងការដាក់ទណ្ឌកម្ម ជារឿយៗត្រូវបានគេមើលឃើញថា ផ្តល់ឱកាសច្រើនពេកដល់ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាមួយចំនួនក្នុងការសម្រាលទណ្ឌកម្មដល់អ្នកប្រើសារធាតុដូប៉ា។ ការខ្វះសង្គតិភាពនៃទណ្ឌកម្មក៏តែងតែជាប្រភពនៃជម្លោះរវាងសហព័ន្ធអន្តរជាតិ និងស្ថាប័នជាតិប្រឆាំង*ដូប៉ា*ដែរ។ ]

57 [សេចក្តីតីអធិប្បាយចំពោះប្រការ 10.1៖ ទោះបីប្រការ 9 ធ្វើមោឃភាពលទ្ធផលក្នុងការប្រកួតតែមួយដែលអត្តពលិកបានធ្វើតេស្តវិជ្ជមាន (ឧទាហរណ៍៖ កីឡាហែលទឹកផ្ងារក្រោយចម្ងាយ 100 ម៉ែត្រ) ប្រការនេះអាចនាំឱ្យមោឃភាពលទ្ធផលនៃការប្រកួតទាំងអស់ក្នុងព្រឹត្តិការណ៍ (ឧទាហរណ៍៖ ការប្រកួតជើងឯកហែលទឹកពិភពលោក។ ]

10.2.1.1 ការបំពានវិធានប្រឆាំងដូប៉ាមិនពាក់ព័ន្ធនឹង*សារធាតុជាក់លាក់* ឬ*វិធីសាស្ត្រជាក់លាក់* លើកលែងតែ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតអាចបញ្ជាក់ថា ការបំពានវិធានប្រឆាំងដូប៉ាកើតឡើងដោយមិនមានចេតនា។[58]

10.2.1.2 ការបំពានវិធាននៃដូប៉ាពាក់ព័ន្ធនឹង*សារធាតុជាក់លាក់* ឬ*វិធីសាស្ត្រជាក់លាក់* ហើយ*អង្គការប្រឆាំងដូប៉ា* អាចបញ្ជាក់ថាការបំពានវិធានប្រឆាំងដូប៉ាកើតឡើងដោយមានចេតនា។

10.2.2 ប្រសិនបើប្រការ 10.2.1 មិនត្រូវបានអនុវត្តទេ អាស្រ័យតាមប្រការ 10.2.4.1 រយៈពេលនៃការ*ព្យួរសិទ្ធិ* គឺពីរ (2) ឆ្នាំ។

10.2.3 ដូចដែលបានប្រើក្នុងប្រការ 10.2 ពាក្យ "មានចេតនា" ត្រូវបានប្រើដើម្បីកំណត់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តិ ដែលពួកគេបានដឹងថាជាការបំពានវិធានប្រឆាំងដូប៉ា ឬដឹងថាមានហានិភ័យធ្ងន់ធ្ងរ ដែលការប្រព្រឹត្តិនោះ អាចជា ឬបណ្ដាលឱ្យមានការបំពានវិធានប្រឆាំងដូប៉ា និងការមិនអើពើចំពោះហានិភ័យនោះ។[59] ការបំពានវិធានប្រឆាំងដូប៉ាដែលកើតចេញពី*លទ្ធផលវិភាគវិជ្ជមាន* រកសារធាតុដែលត្រូវបានហាមឃាត់តែនៅ*ក្នុងការប្រកួត* នឹងត្រូវបានសន្មតថា "មិនមានចេតនា" ប្រសិនបើសារធាតុនោះជា*សារធាតុជាក់លាក់* ហើយ*អត្តពលិក*អាចបង្ហាញថា សារធាតុហាមឃាត់នោះត្រូវបានគេប្រើប្រាស់នៅ*ក្រៅការប្រកួត*។ ការបំពានវិធានប្រឆាំងដូប៉ាដែលបណ្ដាលមកពី*លទ្ធផលវិភាគវិជ្ជមាន* សម្រាប់ការស្វែងរកសារធាតុហាមឃាត់*ក្នុងការប្រកួត* នឹងមិនត្រូវបានចាត់ទុកថា "មានចេតនា" ទេ ប្រសិនបើសារធាតុនោះមិនមែនជា*សារធាតុជាក់លាក់* ហើយ*អត្តពលិក*អាចបញ្ជាក់ថា *សារធាតុហាមឃាត់*នោះ ត្រូវបានគេ*ប្រើប្រាស់*នៅ*ក្រៅការប្រកួត* នៅក្នុងបរិបទដែលមិនទាក់ទងទៅនឹងការប្រកួតកីឡា។

10.2.4 មិនមានបទប្បញ្ញត្តិផ្សេងទៀតនៅក្នុងប្រការ 10.2 ដែលការបំពានលើវិធានប្រឆាំងដូប៉ាទាក់ទងនឹង*សារធាតុបំពាន*៖

10.2.4.1 ប្រសិនបើ*អត្តពលិក*អាចបង្ហាញថា ការលេបចូល ឬ*ប្រើប្រាស់*បានកើតឡើងនៅ*ក្រៅការប្រកួត* និងមិនទាក់ទងនឹងការប្រកួតកីឡា នោះរយៈពេលនៃការ*ព្យួរសិទ្ធិ*គឺបី (3) ខែ។

លើសពីនេះទៀត រយៈពេលនៃការ*ព្យួរសិទ្ធិ* ដែលកំណត់ក្រោមប្រការ 10.2.4.1 អាចនឹងត្រូវបន្ថយមកនៅត្រឹមមួយ (1) ខែ ប្រសិនបើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតបានអនុវត្តជាទីពេញចិត្តនូវកម្មវិធីព្យាបាល*សារធាតុបំពាន* ដែលអនុម័តដោយ*អង្គការប្រឆាំងដូប៉ា*ដែលមានទំនួលខុសត្រូវក្នុង*ការដោះស្រាយវិវាទដូប៉ា*។[60] រយៈពេលនៃការ*ព្យួរសិទ្ធិ*ដូចដែលបានកំណត់ក្នុងប្រការ

---

58 [សេចក្តីអធិប្បាយចំពោះប្រការ 10.2.1.1៖ ទោះបីជាទ្រឹស្តី អត្តពលិក ឬបុគ្គលផ្សេងទៀតអាចបង្ហាញថា ការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ាមិនមែនជាចេតនា ដោយមិនបង្ហាញពីរបៀបដែលសារធាតុហាមឃាត់ចូលក្នុងប្រព័ន្ធរាងកាយរបស់គេក៏ដោយ វាពិតជាមិនទំនងទេ ក្នុងករណីសារធាតុដូប៉ាក្រោមមាត្រា 2.1 ដែលថា អត្តពលិកម្នាក់នឹងទទួលជោគជ័យក្នុងការបង្ហាញថា អត្តពលិកនោះបានធ្វើសកម្មភាពដោយអចេតនា ដោយមិនបានបង្ហាញប្រភពនៃសារធាតុហាមឃាត់នោះ។ ]

59 [សេចក្ដីតីអធិប្បាយចំពោះប្រការ 10.2.3៖ ប្រការ 10.2.3 ផ្តល់និយមន័យពិសេសមួយនៃ "ចេតនា" ដែលត្រូវអនុវត្តសម្រាប់គោលបំណងតែមួយគត់នៃប្រការ 10.2 ។ ]

60 [សេចក្តីអធិប្បាយចំពោះប្រការ 10.2.4.1៖ ការកំណត់ថាតើកម្មវិធីព្យាបាលត្រូវបានអនុម័ត ហើយថាតើអត្តពលិក ឬបុគ្គលផ្សេងទៀតបានបញ្ចប់កម្មវិធីព្យាបាលដោយពេញចិត្តឬអត់នោះ គឺជាឆន្ទានុសិទ្ធិផ្តាច់មុខរបស់*អង្គការប្រឆាំងដូប៉ា*។ ប្រការនេះមានគោលបំណងផ្តល់ឱ្យ*អង្គការប្រឆាំងដូប៉ា*នូវវិធីអនុវត្តការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីកំណត់និងអនុម័តកម្មវិធីព្យាបាលដែលសមស្រប និងត្រូវបានទទួលស្គាល់ ជាជាងកម្មវិធីព្យាបាលបែប "ក្លែងបន្លំ" ។ ទោះយ៉ាងណាក៏ដោយ វាត្រូវបានគេរំពឹងទុ

10.2.4.1 នេះមិនត្រូវបានបន្ថយដោយផ្អែកលើបទប្បញ្ញត្តិណាមួយនៅក្នុងប្រការ 10.6 ទេ។

10.2.4.2 ប្រសិនបើការលេបចូល *ការប្រើប្រាស់* ឬ *ការកាន់កាប់* កើតឡើង នៅក្នុងអំឡុងពេលនៃ *ក្នុងការប្រកួត* ហើយ *អត្តពលិក* អាចបញ្ជាក់ថាបរិបទនៃការលេបចូលការ *ប្រើប្រាស់* ឬ ការ *កាន់កាប់* នោះ មិនទាក់ទងទៅនឹងសមត្ថភាពប្រកួតកីឡាទេនោះ ការលេបចូល ការ *ប្រើប្រាស់* ឬការ *កាន់កាប់* នោះ មិនត្រូវចាត់ទុកថាជាចេតនាឡើយ ដោយយោងតាមប្រការ 10.2.1 និងមិនត្រូវបានយកធ្វើជាមូលដ្ឋានសម្រាប់ការស្វែងរក *ស្ថានទម្ងន់ទោស* ក្រោមប្រការ10.4ឡើយ។

## 10.3 ការ *ព្យួរសិទ្ធិ* សម្រាប់ការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត

រយៈពេលនៃការ *ព្យួរសិទ្ធិ* សម្រាប់ការបំពានវិធានប្រឆាំងដូប៉ា ក្រៅពីអ្វីដែលមានចែងក្នុងប្រការ 10.2 នឹងមានដូចខាងក្រោម លើកលែងតែប្រការ 10.6 ឬប្រការ 10.7 ត្រូវបានអនុវត្ត៖

10.3.1 ចំពោះការបំពានប្រការ 2.3 ឬ ប្រការ 2.5 រយៈពេលនៃការ *ព្យួរសិទ្ធិ* គឺបួន (4) ឆ្នាំ លើកលែងតែ៖

(i) ក្នុងករណីខកខានមិនបានបញ្ជូនទៅការប្រមូល *សំណាក* ប្រសិនបើ *អត្តពលិក* អាចបង្ហាញថាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ានោះធ្វើឡើងដោយគ្មានចេតនា នោះរយៈពេលនៃការ *ព្យួរសិទ្ធិ* គឺពីរ (2) ឆ្នាំ។

(ii) ក្នុងករណីផ្សេងទៀតទាំងអស់ ប្រសិនបើ *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀតអាចបង្ហាញកាលៈទេសៈពិសេសដែលអាចផ្តល់ហេតុផលសម្រាប់ការបន្ធូរបន្ថយរយៈពេលនៃការ *ព្យួរសិទ្ធិ* នោះរយៈពេលនៃការ *ព្យួរសិទ្ធិ* គឺចន្លោះពីពីរ (2) ឆ្នាំទៅបួន (4) ឆ្នាំអាស្រ័យលើកម្រិតកំហុសរបស់ *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀតនោះ ឬ

(iii) ក្នុងករណីដែលពាក់ព័ន្ធនឹង *បុគ្គលដែលត្រូវបានការពារ* ឬ *អត្តពលិកកម្សាន្ត* រយៈពេលនៃការ *ព្យួរសិទ្ធិ* គឺចន្លោះពីអតិបរមាពីរ (2) ឆ្នាំ និងការស្តីបន្ទោសដោយគ្មានការព្យួរសិទ្ធិ អាស្រ័យលើកម្រិត *កំហុស* របស់ *បុគ្គលដែលត្រូវបានការពារ* ឬ *អត្តពលិកកម្សាន្ត* នោះ។

10.3.2 ចំពោះការបំពានប្រការ 2.4 រយៈពេលនៃការ *ព្យួរសិទ្ធិ* គឺពីរ (2) ឆ្នាំ និងអាចត្រូវបានបន្ធូរបន្ថយមកនៅត្រឹមកម្រិតអប្បបរមាមួយ (1) ឆ្នាំ អាស្រ័យលើកម្រិត *កំហុស* របស់ *អត្តពលិក*។ ភាពបត់បែនរវាងពីរ (2) ឆ្នាំ និងមួយ (1) ឆ្នាំ នៃការព្យួរសិទ្ធិនៅក្នុងប្រការនេះ មិនអាចយកទៅប្រើសម្រាប់ *អត្តពលិក* បានទេ ក្នុងករណីដែលទម្រង់នៃព័ត៌មានអំពីទីសំចតរបស់ *អត្តពលិក* ចុងក្រោយ ឬការប្រព្រឹត្តិផ្សេងទៀតបង្កឱ្យមានការសង្ស័យធ្ងន់ធ្ងរថា *អត្តពលិក* ព្យាយាមគេចវេះពីការធ្វើតេស្ត ។

10.3.3 ចំពោះការបំពានប្រការ 2.7 ឬ ប្រការ 2.8 រយៈពេលនៃការ *ព្យួរសិទ្ធិ* គឺអប្បបរមាបួន (4) ឆ្នាំ រហូតដល់ការ *ព្យួរសិទ្ធិ* មួយជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពាននោះ។ ការបំពានប្រការ 2.7 ឬប្រការ 2.8 ដែលពាក់ព័ន្ធនឹង *បុគ្គលដែលត្រូវបានការពារ* នឹងត្រូវចាត់ទុកជាការបំពានធ្ងន់ធ្ងរ ហើយប្រសិនបើប្រព្រឹត្តដោយ *អ្នក*

---

កថាលក្ខណៈនៃកម្មវិធីព្យាបាលសមស្របអាចប្រែប្រួលខ្លាំង និងផ្លាស់ប្តូរនៅពេលណាមួយ ដែលវានឹងលែងមានប្រសិទ្ធភាពសម្រាប់ទីភ្នាក់ងារប្រឆាំង *ដូប៉ា* ពិភពលោក ដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យចាំបាច់សម្រាប់កម្មវិធីព្យាបាលដែលអាចទទួលយកបាន។ ]

*គាំពារអត្តពលិក* ចំពោះការបំពានក្រៅពីសារធាតុដាក់លាក់នោះនឹងនាំឱ្យមានការ*ព្យួរសិទ្ធិ*មួយជីវិតចំពោះ*អ្នកគាំពារអត្តពលិក*។ លើសពីនេះទៀត ការបំពាន សំខាន់ៗលើប្រការ 2.7 ឬប្រការ 2.8 ដែលក៏អាចជាការរំលោភច្បាប់ និងបទប្បញ្ញត្តិមិនទាក់ទងនឹងកីឡា នឹងត្រូវបានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចរដ្ឋបាល វិជ្ជាជីវៈ ឬតុលាការ។[61]

10.3.4 ចំពោះការបំពានប្រការ 2.9 រយៈពេលនៃការ*ព្យួរសិទ្ធិ*គឺយ៉ាងតិចពីរ (2) ឆ្នាំ រហូតដល់ការ*ព្យួរសិទ្ធិ*ពេញមួយជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពាននោះ។

10.3.5 ចំពោះការបំពានប្រការ 2.10 រយៈពេលដែលការ*ព្យួរសិទ្ធិ*គឺពីរ (2) ឆ្នាំ និងអាចត្រូវបានបន្ធូរបន្ថយមកនៅត្រឹមកម្រិតអប្បបរមា (1) ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត និងលើកាលៈទេសៈផ្សេងទៀតនៃករណីនោះ។ [62]

10.3.6 ចំពោះការបំពានប្រការ 2.11 រយៈពេលនៃការ*ព្យួរសិទ្ធិ*ចូលគឺអប្បបរមាពីរ (2) ឆ្នាំ រហូតដល់ការ*ព្យួរសិទ្ធិ*ពេញមួយជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពានរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត។[63]

## 10.4 *ស្ថានទម្ងន់ទោស*ដែលអាចបង្កើនរយៈពេលនៃការ*ព្យួរសិទ្ធិ*

ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*អាចបង្ហាញ ក្នុងករណីដោយឡែក ដែលពាក់ព័ន្ធនឹងការបំពានវិធានប្រឆាំងដូប៉ាក្រោមប្រការ 2.7 (ការ*ជួញដូរ* ឬ*ការប៉ុនប៉ងជួញដូរ*) ប្រការ 2.8 (*ការផ្តល់* ឬ*ការប៉ុនប៉ងផ្តល់*) ប្រការ 2.9 (ការ*សមគំនិត*) ឬប្រការ 2.11 (ការប្រព្រឹត្តិរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដើម្បីរារាំង ឬសងសឹកប្រឆាំងនឹងការរាយការណ៍) ថាមាន*ស្ថានទម្ងន់ទោស* ដែលផ្តល់ហេតុផលអំពីការ*ព្យួរសិទ្ធិ*មិនត្រឹមត្រូវ លើសពីទណ្ឌកម្មស្តង់ដារ នោះរយៈពេលនៃការ*ព្យួរសិទ្ធិ*ត្រូវកើនឡើងបន្ថែមរហូតដល់ទៅពីរ (2) ឆ្នាំ អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពាន និងលក្ខណៈនៃ*ស្ថានទម្ងន់ទោស*នោះ លើកលែងតែ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតអាចបញ្ជាក់ថា ខ្លួនមិនបានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា។[64]

---

61 [សេចក្តីអធិប្បាយចំពោះប្រការ 10.3.3៖ អ្នកដែលជាប់ពាក់ព័ន្ធក្នុងការផ្តល់សារធាតុដូប៉ាដល់អត្តពលិក ឬលាក់បាំងសារធាតុដូប៉ាគួរត្រូវបានដាក់ទណ្ឌកម្មធ្ងន់ធ្ងរជាងអត្តពលិកដែលធ្វើតេស្តវិជ្ជមាន។ ជាទូទៅ ដោយសារសិទ្ធិអំណាចរបស់ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាត្រូវបានកំណត់ត្រឹមតែការព្យួរសិទ្ធិសម្រាប់ការទទួលស្គាល់ សមាជិកភាព និងអត្ថប្រយោជន៍កីឡាដទៃទៀត ការរាយការណ៍អំពីបុគ្គលិកគាំទ្រអត្តពលិកទៅអាជ្ញាធរមានសមត្ថកិច្ចគឺជាជំហានសំខាន់ក្នុងការទប់ស្កាត់ការប្រើសារធាតុដូប៉ា។ ]

62 [សេចក្តីតីអធិប្បាយចំពោះប្រការ 10.3.5៖ ក្នុងករណីដែល "បុគ្គលផ្សេងទៀត" យោងតាមប្រការ 2.10 (ទំនាក់ទំនងដែលត្រូវបានហាមឃាត់របស់អត្តពលិក ឬបុគ្គលផ្សេងទៀត) គឺជាអង្គភាព និងមិនមែនជាបុគ្គលទេ ហើយអង្គភាពនោះអាចត្រូវបានដាក់វិន័យ ដូចមានចែងក្នុងប្រការ 12]

63 [សេចក្តីអធិប្បាយចំពោះប្រការ 10.3.6៖ ការប្រព្រឹត្តដែលត្រូវបានរកឃើញថា*បំពាន*លើប្រការ 2.5 (ការធ្វើឱ្យខូចដំណើរការ) និងប្រការ 2.11 (សកម្មភាពរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ដើម្បីបង្អាក់ ឬសងសឹកចំពោះការរាយការណ៍ទៅអាជ្ញាធរ) នឹងត្រូវដាក់ទណ្ឌកម្ម ដោយផ្អែកលើការ*បំពាន*នោះ ដោយអនុវត្តការដាក់ទណ្ឌកម្មកាន់តែធ្ងន់ធ្ងរ។

64 [សេចក្តីអធិប្បាយចំពោះប្រការ 10.4៖ ការរំលោភក្រោមប្រការ 2.7 (ការជួញដូរ ឬការប៉ុនប៉ងជួញដូរ) ប្រការ 2.8 (ការចាក់ចូល ឬការប៉ុនប៉ងចាក់ចូល) 2.9 (ការសមគំនិត ឬការប៉ុនប៉ងសមគំនិត) និងប្រការ 2.11 (សកម្មភាពដោយអត្តពលិក ឬបុគ្គលផ្សេងទៀតដើម្បីបង្អាក់ ឬសងសឹកចំពោះការរាយការណ៍ទៅអាជ្ញាធរ) មិនត្រូវបានរាប់បញ្ចូលក្នុងការអនុវត្តប្រការ 10.4 ទេ ព្រោះទណ្ឌកម្មចំពោះការ*បំពាន*ទាំងនេះមានសុពលភាពគ្រប់គ្រាន់រហូតដល់ការហាមឃាត់ពេញមួយជីវិត ដើម្បីអនុញ្ញាតឱ្យមានការពិចារណាលើស្ថានទម្ងន់ទោសទាំងអស់។ ]

## 10.5 ការដកបរយៈពេលនៃការ*ព្យួរសិទ្ធិ*ក្នុងករណីដែលគ្មាន*កំហុស*ឬការ*ធ្វេសប្រហែស*

ប្រសិនបើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតបង្ហាញនៅក្នុងករណីដោយឡែកថា គាត់គ្មាន*កំហុស*ធ្ងន់ធ្ងរ ឬការ*ធ្វេសប្រហែស* នោះរយៈពេលនៃការ*ព្យួរសិទ្ធិ*នឹងត្រូវបានលុបចេញ។[65]

## 10.6 ការកាត់បន្ថយរយៈពេលនៃការ*ព្យួរសិទ្ធិ*ផ្អែកលើការគ្មាន*កំហុស* ឬការ*ធ្វេសប្រហែស*

10.6.1 ការកាត់បន្ថយទណ្ឌកម្មក្នុងកាលៈទេសៈពិសេសសម្រាប់ការបំពាន ប្រការ 2.1 ប្រការ 2.2 ឬប្រការ 2.6 ។

ការកាត់បន្ថយទាំងអស់ក្រោមប្រការ 10.6.1 គឺមិនអាចអនុវត្តទន្ទឹមគ្នា និងមិនបង្គរគ្នាទេ។

10.6.1.1 *សារធាតុជាក់លាក់* ឬ*វិធីសាស្ត្រជាក់លាក់*

ក្នុងករណីដែលការបំពានវិធានប្រឆាំងដូប៉ាពាក់ព័ន្ធនឹង*សារធាតុជាក់លាក់* (ក្រៅពី*សារធាតុបំពាន*) ឬ*វិធីសាស្ត្រជាក់លាក់* ហើយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត អាចបង្ហាញថាគ្មាន *កំហុស*ធ្ងន់ធ្ងរ ឬ*ការធ្វេសប្រហែស* នោះការដាក់ពិន័យ អប្បបរមាគឺការស្តីបន្ទោសដោយគ្មានការ*ព្យួរសិទ្ធិ* ហើយការដាក់ពិន័យអតិបរមាគឺការ*ព្យួរសិទ្ធិ*រយៈពេលពីរ (2) ឆ្នាំ ដោយផ្អែកលើកម្រិតកំហុសរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ ។

10.6.1.2 *ផលិតផលមិនស្មោះត្រង់*

10.6.1.3 ក្នុងករណីដែល *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតអាចបង្ហាញថា គ្មានទាំង *កំហុស*ធ្ងន់ធ្ងរ ឬការ*ធ្វេសប្រហែស* ហើយថា*សារធាតុហាមឃាត់*ដែលត្រូវបានរកឃើញ (ក្រៅពី*សារធាតុបំពាន*) បានមកពី*ផលិតផលមិនស្មោះត្រង់* នោះការពិន័យអប្បបរមាគឺការស្តីបន្ទោសដោយគ្មានការ*ព្យួរសិទ្ធិ* និងអតិបរមានគឺការ*ព្យួរសិទ្ធិ*រយៈពេលពីរ (2) ឆ្នាំ អាស្រ័យលើកម្រិត*កំហុស*របស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ។[66]

---

65 [សេចក្តីអធិប្បាយចំពោះប្រការ 10.5៖ ប្រការនេះ និង ប្រការ 10.6.2 អនុវត្តចំពោះតែការដាក់ទណ្ឌកម្មប៉ុណ្ណោះ។ វាមិនត្រូវបានអនុវត្តចំពោះការកំណត់ថា តើមានការ*បំពាន*វិធានប្រឆាំង*ដូប៉ា* ឬអត់នោះទេ។ ឧទាហរណ៍៖ វាត្រូវបានអនុវត្តតែនៅក្នុងកាលៈទេសៈពិសេស ដែលអត្តពលិកអាចបង្ហាញថា ទោះបីជាគាត់យកចិត្តទុកដាក់ហើយក៏ដោយ គាត់ត្រូវបានធ្វើឱ្យខូចដោយគូប្រជែង។ ផ្ទុយទៅវិញ ការគ្មានកំហុស ឬការធ្វេសប្រហែសនឹងមិនអនុវត្តចំពោះកាលៈទេសៈដូចខាងក្រោមទេ៖ (ក) ការធ្វើតេស្តវិជ្ជមានដែលបណ្តាលមកពីវីតាមីន ឬសារធាតុបំប៉នដែលដាក់ស្លាកមិនត្រឹមត្រូវ ឬប្រឡាក់សារធាតុ (អត្តពលិកទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានលេបចូល (ប្រការ 2.1) ហើយត្រូវបានប្រាប់ឱ្យប្រុងប្រយ័ត្នចំពោះលទ្ធភាពនៃការប៉ះពាល់សារធាតុបន្ថែម) (ខ) ការចាក់សារធាតុហាមឃាត់ចូលដោយគ្រូពេទ្យ ឬគ្រូបង្វឹកផ្ទាល់ខ្លួនរបស់អត្តពលិក ដោយគ្មានការបង្ហាញដល់អត្តពលិក (អត្តពលិកត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសបុគ្គលិកវេជ្ជសាស្ត្ររបស់ពួកគេ និងត្រូវប្រាប់បុគ្គលិកវេជ្ជសាស្ត្រថា ពួកគេមិនអាចផ្តល់សារធាតុហាមឃាត់ណាមួយឡើយ) និង (គ) ការធ្វើឱ្យខូចដល់អាហារ ឬភេសជ្ជៈរបស់អត្តពលិកដោយប្តី/ប្រពន្ធ គ្រូបង្វឹក ឬបុគ្គលផ្សេងទៀត ក្នុងរង្វង់ក្រុមការងាររបស់អត្តពលិក (អត្តពលិកទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានទទួល និងការប្រព្រឹត្តរបស់បុគ្គលទាំងនោះ ដែលពួកគេប្រគល់សិទ្ធិក្នុងការរៀបចំអាហារ និងភេសជ្ជៈរបស់ពួកគេ។ ) ។ ទោះយ៉ាងណាក៏ដោយ អាស្រ័យលើការពិតនៃករណីជាក់លាក់ ការបង្ហាញដែលត្រូវបានយោងអាចនាំឱ្យមានការកាត់បន្ថយទណ្ឌកម្មតាមប្រការ 10.6 ដោយផ្អែកលើកំហុសមិនសំខាន់ ឬការធ្វេសប្រហែស។ ]

66 [សេចក្តីអធិប្បាយចំពោះប្រការ 10.6.1.2៖ ដើម្បីទទួលបានអត្ថប្រយោជន៍នៃប្រការនេះ អត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបង្ហាញមិនត្រឹមតែថា សារធាតុហាមឃាត់ដែលបានរកឃើញមកពីផលិតផលដែលប្រឡាក់សារធាតុប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវតែបង្ហាញការគ្មានកំហុសសំខាន់ ឬការធ្វេសប្រហែស ដាច់ដោយឡែកផងដែរ។ គួរកត់សម្គាល់បន្ថែមទៀតថា អត្តពលិកត្រូវចងចាំថា ពួកគេទទួលទានអាហារបំប៉ន ក្រោមហានិភ័យផ្ទាល់ខ្លួន។ ការកាត់បន្ថយទណ្ឌកម្មដោយផ្អែកលើកំហុសមិនសំខាន់ ឬការធ្វេសប្រហែស កម្រត្រូវបានអនុវត្តនៅក្នុងករណីផលិតផលប្រឡាក់សារធាតុណាស់ លុះត្រាតែអត្តពលិកបានអនុវត្តការប្រុងប្រយ័ត្នខ្ពស់ មុននឹងទទួលផលិតផលប្រឡាក់នោះ។ នៅក្នុងការវាយតម្លៃថាតើអត្តពលិកអាចបង្ហាញប្រភពនៃសារធាតុហាមឃាត់បាន ឬអត់ ។

10.6.1.4 *បុគ្គលដែលត្រូវបានការពារ ឬ អត្តពលិកកម្សាន្ត*

ក្នុងករណីការបំពានវិធានប្រឆាំងដូប៉ា ដែលមិនពាក់ព័ន្ធនឹង*សារធាតុបំពាន*ត្រូវបានប្រព្រឹត្ត ដោយ*បុគ្គលដែលត្រូវបានការពារ* ឬ*អត្តពលិកកម្សាន្ត* និងក្នុងករណីដែល*បុគ្គលដែលត្រូវបានការពារ* ឬ*អត្តពលិកកម្សាន្ត*អាចបង្ហាញថា គ្មាន*កំហុស*ធ្ងន់ ឬជាការ*ធ្វេសប្រហែស* នោះរយៈពេលនៃការ*ព្យួរសិទ្ធិ*នឹងមានក្នុងកម្រិតអប្បបរមាត្រឹមការស្តីបន្ទោសដោយគ្មានការ*ព្យួរសិទ្ធិ* ហើយអតិបរមាគឺការ*ព្យួរសិទ្ធិ*រយៈពេលពីរ (2) ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់*បុគ្គលដែលត្រូវបានការពារ* ឬ*អត្តពលិកកម្សាន្ត*នោះ។

10.6.2 ការដាក់ពាក្យសុំ គ្មាន*កំហុស* ឬការ*ធ្វេសប្រហែស*លើសការអនុវត្តប្រការ 10.6.1[67]

ប្រសិនបើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ក្នុងករណីដោយឡែកដែលប្រការ 10.6.1 មិនត្រូវបានអនុវត្ត អាចបង្ហាញថាគាត់គ្មាន*កំហុស* ឬជាការ*ធ្វេសប្រហែស*នោះ អាស្រ័យលើការកាត់បន្ថយ ឬការដកចេញដូចមានចែងក្នុងប្រការ 10.7 រយៈពេលនៃការព្យួរសិទ្ធិដែលអាចអនុវត្តបានផ្សេងទៀតអាចត្រូវបានកាត់បន្ថយ ដោយផ្អែកលើកម្រិត*កំហុស*របស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ប៉ុន្តែការកាត់បន្ថយរយៈពេលនៃការ*ព្យួរសិទ្ធិ*នោះនឹងមិនអាចដល់កម្រិតតិចជាងពាក់កណ្តាល នៃរយៈពេលនៃការ*ព្យួរសិទ្ធិ*ដែលអាចអនុវត្តបាននោះទេ។ ប្រសិនបើរយៈពេលនៃការ*ព្យួរសិទ្ធិ*ដែលអាចអនុវត្តបានគឺជាការ*ព្យួរសិទ្ធិ*ពេញមួយជីវិត នោះរយៈពេលកាត់បន្ថយនៅក្រោមប្រការនេះមិនអាចតិចជាងប្រាំបីឆ្នាំ (8) ឆ្នាំទេ។

## 10.7 ការដក ការកាត់បន្ថយ ឬផ្អាករយៈពេលនៃការ*ព្យួរសិទ្ធិ* ឬ*ផលវិបាក*ផ្សេងសម្រាប់ហេតុផលក្រៅពីកំហុស

### 10.7.1 *ជំនួយសំខាន់*ក្នុងការស្វែងរក ឬការបង្ហាញការបំពាន*ក្រម*[68]

10.7.1.1 *អង្គការប្រឆាំងដូប៉ា*ដែលមានទំនួលខុសត្រូវលើ*ការដោះស្រាយវិវាទដូប៉ា* មុនការសម្រេចលើការប្តឹងជំទាស់តាមប្រការ 13 ឬមុនផុតកំណត់នៃរយៈពេលប្តឹងជំទាស់ អាចផ្អាកផ្នែកណាមួយនៃទណ្ឌកម្ម (ក្រៅពីការ*ដកសិទ្ធិ* និងកាតព្វកិច្ចផ្សព្វផ្សាយជា សាធារណៈ) ដែលបានកំណត់ក្នុងករណីដោយឡែកដែល*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតបាន ផ្តល់ជំនួយសំខាន់ៗ ដល់*អង្គការ*

ឧទាហរណ៍៖ វាមានសារៈសំខាន់សម្រាប់គោលបំណងកំណត់ថា តើអត្តពលិកបានប្រើផលិតផលប្រឡាក់ ឬអត់ ថាតើអត្តពលិកក្រោយមកបានរាយការណ៍ពីផលិតផលប្រឡាក់នោះដោយប្រើទម្រង់ត្រួតពិនិត្យសារធាតុដូប៉ា ឬអត់។

ប្រការនេះមិនគួរត្រូវបានពង្រីកហួសពីផលិតផលដែលបានឆ្លងកាត់ដំណើរការផលិតមួយចំនួនឡើយ។ ក្នុងករណីដែលលទ្ធផលវិភាគ*វិជ្ជមាន*ដែលកើតចេញពីបរិស្ថានដែលមានសារធាតុលាយឡំ/ប្រឡាក់ "សារធាតុមិនមែនផលិតផល" ដូចជាទឹករ៉ូប៊ីណេ ឬទឹកបឹង ដែលក្នុងកាលៈទេសៈធម្មតាមិនត្រូវបានរំពឹងថានឹងមានហានិភ័យនៃការ*បំពាន*លើវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា វានឹងត្រូវបានកំណត់ថាគ្មានកំហុស ឬមិនមែនជាការធ្វេសប្រហែសតាមប្រការ 10.5 ។ ]

67 [សេចក្តីអធិប្បាយចំពោះប្រការ 10.6.2៖ ប្រការ 10.6.2 អាចត្រូវបានអនុវត្តចំពោះការ*បំពាន*វិធានប្រឆាំងសារធាតុដូប៉ាណាមួយ លើកលែងតែប្រការ ដែលចេតនាគឺជាធាតុមួយនៃការ*បំពាន*វិធានប្រឆាំង*ដូប៉ា* ( ឧទាហរណ៍ ប្រការ 2.5, 2.7 , 28 , 2.9 ឬ 2.11 ) ឬធាតុនៃការដាក់ទណ្ឌកម្មជាក់លាក់មួយ ( ឧទាហរណ៍ ប្រការ 10.2.1 ) ឬការព្យួរសិទ្ធិនានា ត្រូវបានកំណត់រួចហើយ នៅក្នុងប្រការមួយ ដែលផ្អែកលើកម្រិតកំហុសអត្តពលិក ឬរបស់បុគ្គលផ្សេងទៀត។]

68 [សេចក្តីអធិប្បាយចំពោះប្រការ 10.7.1៖ កិច្ចសហការរបស់អត្តពលិក បុគ្គលិកគាំទ្រអត្តពលិក និងបុគ្គលដទៃទៀតដែលទទួលស្គាល់កំហុសរបស់ខ្លួន ហើយមានឆន្ទៈក្នុងការរាយការណ៍ពីការ*បំពាន*លើវិធានប្រឆាំងសារធាតុញៀនផ្សេងៗ មានសារៈសំខាន់ក្នុងការធ្វើឱ្យកីឡាមានភាពស្អាតស្អំ។

*ប្រឆាំងដូប៉ា* ស្ថាប័នព្រហ្មទណ្ឌ ឬស្ថាប័នវិន័យវិជ្ជាជីវៈ ដែលនាំឱ្យ៖

(i) *អង្គការប្រឆាំងដូប៉ា*ដែលរកឃើញ ឬដែលចោទថាមានការបំពានវិធានប្រឆាំងដូប៉ា ដោយបុគ្គលម្នាក់ផ្សេងទៀត ឬ

(ii) ដែលនាំឱ្យស្ថាប័នព្រហ្មទណ្ឌ ឬស្ថាប័នវិន័យវិជ្ជាជីវៈ ឬចោទថាមានបទល្មើសព្រហ្មទណ្ឌ ឬការបំពានវិធានវិជ្ជាជីវៈដែលបានប្រព្រឹត្តដោយ*បុគ្គល*ម្នាក់ទៀត និងព័ត៌មានដែលផ្ដល់ដោយ*បុគ្គល*ដែលផ្ដល់ *ជំនួយសំខាន់ៗ* ត្រូវបានផ្ដល់ជូន*អង្គការប្រឆាំងដូប៉ា* ឬស្ថាប័នដទៃទៀត ដែលទទួលខុសត្រូវក្នុង*ការដោះស្រាយវិវាទដូប៉ា* ឬ

(iii) ដែលនាំឱ្យ*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ចាប់ផ្ដើមនីតិវិធីប្រឆាំងនឹង*ស្ថាប័នហត្ថលេខី* មន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬស្ថាប័នគ្រប់គ្រងប្រវត្តជីវសាស្ត្រអត្តពលិក (ដូចបានកំណត់នៅក្នុង*ស្តង់ដារអន្តរជាតិស្ដីពីការធ្វើតេស្ត* និងការស៊ើបអង្កេត)សម្រាប់ការមិនអនុលោមតាម*ក្រម ស្តង់ដារអន្តរជាតិ* ឬ*ឯកសារបច្ចេកទេស* ឬ

(iv) ដោយការអនុម័តពី *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ដែលនាំឱ្យស្ថាប័នព្រហ្មទណ្ឌ ឬស្ថាប័នវិន័យវិជ្ជាជីវៈ ពាក្យបណ្ដឹងពីបទល្មើសព្រហ្មទណ្ឌ ឬការបំពានលើវិធានអាជីព ឬកីឡា ដែលកើតឡើងពីការបំពានលើសុចរិតភាពកីឡា ក្រៅពីដូប៉ា។ បន្ទាប់ពីចេញសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ក្រោមប្រការ 13 ឬការផុតកំណត់រយៈពេលសម្រាប់ប្ដឹងជំទាស់ហើយ *អង្គការប្រឆាំងដូប៉ា*អាចផ្អាកតែផ្នែកណាមួយនៃទណ្ឌកម្មដែលអាចអនុវត្តបាន ដោយមានការអនុម័តពី*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* និងសហព័ន្ធកីឡាអន្តរជាតិ។

រយៈពេលដែលការ*ព្យួរសិទ្ធិ*អាចនឹងត្រូវបានផ្អាកនោះ ត្រូវផ្អែកលើភាពធ្ងន់ធ្ងរនៃការបំពានវិធានប្រឆាំងដូប៉ាដោយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត និងសារៈសំខាន់នៃការផ្ដល់ជំនួយសក្ដានុពលដោយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់សារធាតុដូប៉ាក្នុងវិស័យកីឡា ការមិនអនុលោមតាម*ក្រម* ការបំពាន*ក្រម*និង/ ឬការបំពានលើភាពសុចរិតនៃកីឡា។ ការផ្អាករយៈពេល*ព្យួរសិទ្ធិ*មិនត្រូវលើសបីភាគបួននៃរយៈពេល*ព្យួរសិទ្ធិ*ដែលត្រូវអនុវត្តនោះទេ។ ប្រសិនបើរយៈពេល*ព្យួរសិទ្ធិ*ដែលត្រូវអនុវត្ត គឺជាការ*ព្យួរសិទ្ធិ* មួយជីវិត រយៈពេលបាន*ព្យួរសិទ្ធិ*ដែលមិនត្រូវបានផ្អាកក្រោមប្រការនេះមិនត្រូវតិចជាងប្រាំបី (៨) ឆ្នាំទេ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ រយៈពេលដែលអាចអនុវត្តបាននៃ*ការព្យួរសិទ្ធិ*មិនត្រូវរាប់បញ្ចូលរយៈពេលនៃ*ការព្យួរសិទ្ធិ* ណាមួយដែលអាចត្រូវបានបន្ថែម ក្រោមប្រការ 10.9.3.2 នៃវិធានប្រឆាំងដូប៉ាទាំងនេះឡើយ។

ប្រសិនបើមានការស្នើសុំពីសំណាក់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលព្យាយាមផ្ដល់*ជំនួយសំខាន់ អង្គការប្រឆាំងដូប៉ា* ជាមួយនឹងការដោះស្រាយវិវាទដូប៉ាដែលទទួលខុសត្រូវ នឹងអនុញ្ញាតឱ្យ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះផ្ដល់ព័ត៌មានទៅ*អង្គការប្រឆាំងដូប៉ា* បានដោយផ្អែកលើកិច្ចព្រម

ព្រៀងរក្សាសិទ្ធិភាគី ។

ប្រសិនបើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតខកខានក្នុងការបន្តសហការ និងផ្តល់*ជំនួយសំខាន់* ដែលពេញលេញ និងគួរឱ្យទុកចិត្តបាន ក្រោយពេលដែល*អង្គការប្រឆាំងដូប៉ា* ការផ្អាកនៃការអនុវត្តទណ្ឌកម្ម *អង្គការប្រឆាំងដូប៉ា* ត្រូវអនុវត្តទណ្ឌកម្មដើមឡើយវិញ។ ប្រសិនបើ*អង្គការប្រឆាំងកាដូប៉ា*សម្រេចអនុវត្តទណ្ឌកម្មដើមដែលត្រូវបានផ្អាកនោះឡើយវិញ ឬសម្រេចមិនអនុវត្តទណ្ឌកម្មដើមដែលត្រូវបានផ្អាកនោះទេ សេចក្តីសម្រេចនោះអាចត្រូវបានប្តឹងជំទាស់ដោយបុគ្គលណាមួយដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ 13។

10.7.1.2 ដើម្បីលើកទឹកចិត្ត*អត្តពលិក* និង*បុគ្គល*ដទៃទៀតឱ្យផ្តល់*ជំនួយសំខាន់*ដល់*អង្គការប្រឆាំងដូប៉ា* តាមរយៈសំណើរបស់*អង្គការប្រឆាំងដូប៉ា* ឬតាមសំណើរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលមាន ឬត្រូវបានអះអាងថា បានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ា ឬការបំពានផ្សេងទៀតលើ*ក្រម ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចយល់ព្រមនៅដំណាក់កាលណាមួយនៃដំណើរ*ការដោះស្រាយវិវាទដូប៉ា* រួមទាំងបន្ទាប់ពីសេចក្តីសម្រេចនៃបណ្តឹងជំទាស់ តាមប្រការ 13 ចំពោះអ្វីដែលខ្លួនចាត់ទុកថាជាការផ្អាកសមស្របនៃរយៈពេល*ព្យួរសិទ្ធិ* និងទណ្ឌកម្មផ្សេងទៀត ដែលអាចអនុវត្តបាន។ ក្នុងកាលៈទេសៈពិសេស *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចយល់ព្រមលើការផ្អាករយៈពេល*ព្យួរសិទ្ធិ* និងការពិន័យផ្សេងទៀតសម្រាប់ *ជំនួយសំខាន់* ដែលធំលើសពីអ្វីដែលបានចែងក្នុងប្រការនេះ ឬសូម្បីតែការមិន*ព្យួរសិទ្ធិ* ការមិនតម្រូវឱ្យបង្ហាញព័ត៌មានជាសាធារណៈ និង/ ឬការមិនដកមកវិញនូវប្រាក់រង្វាន់ ឬការបង់ប្រាក់ពិន័យ ឬការចំណាយផ្សេងៗ។ ការអនុម័តរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*អាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មឡើងវិញ បើមិនដូច្នេះទេ ត្រូវអនុវត្តដូចដែលមានចែងក្នុងប្រការនេះ។ ទោះដូចមានចែងក្នុងប្រការ 13 ក៏ដោយ សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*នៅក្នុងបរិបទនៃប្រការ 10.7.1.2 នេះមិនអាចត្រូវបានប្តឹងជំទាស់ទេ។

10.7.1.3 ប្រសិនបើ*អង្គការប្រឆាំងដូប៉ា* សម្រេចព្យួរផ្នែកណាមួយនៃការដាក់ទណ្ឌ កម្មដែលអាចអនុវត្តបាន ដោយសារតែមានការផ្តល់*ជំនួយសំខាន់* ស្ថាប័ននេះត្រូវជូនដំណឹងអំពីការផ្តល់យុត្តិកម្មចំពោះការសម្រេចនោះដល់*អង្គការប្រឆាំងដូប៉ា*ផ្សេងទៀត ដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ 13.2.3 ដូចមានចែងក្នុងប្រការ 14។

ក្នុងកាលៈទេសៈជាក់លាក់ដែលទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកកំណត់ថា វាជាផលប្រយោជន៍ល្អបំផុតក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងដូប៉ា ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចផ្តល់សិទ្ធិដល់អង្គការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាឱ្យចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់សមស្រប ដោយកំណត់ ឬពន្យារពេលការបង្ហាញពីកិច្ចព្រមព្រៀងផ្តល់ជំនួយសំខាន់ ឬលក្ខណៈនៃការផ្តល់ជំនួយសំខាន់ ដែលកំពុងត្រូវបានផ្តល់ជូន។

10.7.2 ការទទួលយកថាបានបំពានវិធានប្រឆាំងដូប៉ាដោយអវត្តមាននៃភស្តុតាងផ្សេងទៀត

នៅពេលដែល*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ពេញចិត្តក្នុងការទទួលស្គាល់ថាបានបំពានវិធានប្រឆាំង

ដូប៉ាមុនពេលទទួលបានការជូនដំណឹងអំពីការប្រមូល*សំណាក* ដែលអាចបង្កើតជាការបំពានវិធានប្រឆាំងដូប៉ា (ឬក្នុងករណីដែលវិធានប្រឆាំងដូប៉ា ក្រៅពីប្រការ 2.1 មុនពេលទទួលបានសេចក្តីជូនដំណឹងដំបូងអំពីការបំពានដែលខ្លួនទទួលយក ដោយអនុលោមតាមប្រការ 7) ហើយដែលថា ការទទួលយកនោះគឺជាភស្តុតាងដែលអាចទុកចិត្តបានតែមួយគត់នៃការរំលោភ នោះរយៈពេលនៃការព្យួរសិទ្ធិ អាចត្រូវបានកាត់បន្ថយ ប៉ុន្តែមិនត្រូវទាបជាងពាក់កណ្តាលនៃរយៈពេលនៃការ*ព្យួរសិទ្ធិ* ប្រសិនបើរកឃើញថា មាន*កំហុស*នោះទេ។[69]

### 10.7.3 ការប្រើប្រាស់ហេតុផលច្រើនសម្រាប់ន្ធូបន្ថយទណ្ឌកម្ម

នៅពេលដែលអត្តពលិក ឬបុគ្គលដទៃទៀតបង្ហាញថាខ្លួនមានសិទ្ធិទទួលបានការបន្ធូរបន្ថយទណ្ឌកម្មក្រោមបទប្បញ្ញត្តិលើសពីមួយនៃប្រការ 10.5 ប្រការ 10.6 ឬប្រការ 10.7 មុនពេលអនុវត្តការបន្ធូរបន្ថយ ឬការព្យួរការអនុវត្តទណ្ឌកម្ម ក្រោមប្រការ 10.7នោះ រយៈពេលនៃការព្យួរសិទ្ធិ ត្រូវកំណត់ស្របតាមប្រការ 10.2 ប្រការ 10.3 ប្រការ 10.5 និងប្រការ 10.6 ។ ប្រសិនបើមានអត្តពលិក ឬបុគ្គលផ្សេងទៀតអាចបង្ហាញសិទ្ធិទទួលបានការបន្ធូរបន្ថយ ឬការផ្អាកនៃរយៈពេលនៃការព្យួរសិទ្ធិ ក្រោមប្រការ 10.7 នោះ រយៈពេលនៃការព្យួរសិទ្ធិអាចត្រូវបានកាត់បន្ថយ ឬផ្អាក ប៉ុន្តែមិនត្រូវតិចជាងមួយភាគបួននៃរយៈពេលព្យួរសិទ្ធិដែលត្រូវអនុវត្តនោះទេ។

## 10.8 កិច្ចព្រមព្រៀង*ការដោះស្រាយវិវាទដូប៉ា*

### 10.8.1 ការបន្ធូរបន្ថយទណ្ឌកម្មមួយ (1)ឆ្នាំ ចំពោះការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាដោយផ្អែកលើការសារភាព និងការទទួលយកទណ្ឌកម្មជាមុន

ក្នុងករណីដែល*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត បន្ទាប់ពីត្រូវបានជូនដំណឹងដោយ*អង្គការប្រឆាំងដូប៉ា* អំពីការបំពានវិធានប្រឆាំងដូប៉ាសំខាន់ណាមួយ ដែលត្រូវទទួលពិន័យនៃការ*ព្យួរសិទ្ធិ*រយៈពេលបួន (4) ឆ្នាំ ឬច្រើនជាងនេះ (រាប់បញ្ចូលទាំងរយៈពេលនៃការ*ព្យួរសិទ្ធិ* តាមប្រការ 10.4) ទទួលស្គាល់ថាបានបំពាន និងទទួលយករយៈពេលនៃ*ការព្យួរសិទ្ធិ*ក្នុងរយៈពេលមិនលើសពីម្ភៃ (20) ថ្ងៃបន្ទាប់ពីទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ថាបានបំពានវិធានប្រឆាំងដូប៉ានោះ *អត្តពលិក*ឬ*បុគ្គល*ផ្សេងទៀត អាចទទួលបានការបន្ធូរបន្ថយរយៈពេលមួយ (1) ឆ្នាំ ក្នុងរយៈពេលនៃកា*រព្យួរសិទ្ធិ* ដែលកំណត់ដោយ*អង្គការប្រឆាំងដូប៉ា*។ នៅពេលដែល*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ទទួលបានការបន្ធូរបន្ថយទណ្ឌកម្មរយៈពេលមួយ (1) ឆ្នាំ ក្នុងរយៈពេលអនុវត្តការ*ព្យួរសិទ្ធិ* ក្រោមប្រការ 10.8.1 នេះ គ្មានការបន្ធូរបន្ថយរយៈពេល *ព្យួរសិទ្ធិ*បន្ថែមទៀតត្រូវបានអនុញ្ញាតក្រោមប្រការណាមួយឡើយ។[70]

---

69 [សេចក្តីអធិប្បាយចំពោះប្រការ 10.7.2៖ ប្រការនេះមានបំណងអនុវត្ត នៅពេលដែលអត្តពលិក ឬបុគ្គលផ្សេងទៀតចេញមុខ ហើយសារភាពថាបាន*បំពាន*វិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា នៅក្នុងកាលៈទេសៈដែលគ្មាន*អង្គការប្រឆាំងដូប៉ា*ណាមួយដឹងថាមានការ*បំពាន*លើវិធានប្រឆាំង*ដូប៉ា*។ វាមិនមានបំណងអនុវត្តចំពោះកាលៈទេសៈដែលការសារភាពកើតឡើងបន្ទាប់ពីអត្តពលិក ឬមនុស្សផ្សេងទៀតជឿជាក់ថា គាត់នឹងត្រូវគេចាប់បាននោះទេ។ រយៈពេលនៃការព្យួរសិទ្ធិដែលត្រូវបានកាត់បន្ថយគួរផ្អែកលើលទ្ធភាពដែលអត្តពលិក ឬបុគ្គលផ្សេងទៀតអាចត្រូវបានចាប់ ប្រសិនបើគាត់មិនសារភាពដោយស្ម័គ្រចិត្ត។ ]

70 [សេចក្តីអធិប្បាយចំពោះប្រការ 10.8.1៖ ឧទាហរណ៍ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*ចោទប្រកាន់ថា អត្តពលិកម្នាក់បាន*បំពាន*លើប្រការ 2.1 ទាក់ទងនឹងការប្រើប្រាស់*ថសាពវ*ធាតុ*អាវ* ណាបូលីកស្តេរ៉ូយ ហើយកំណត់រយៈពេលព្យួរសិទ្ធិ 4 (បួន) ឆ្នាំ អត្តពលិកនោះអាចកាត់បន្ថយរយៈពេលនៃការព្យួរសិទ្ធិដោយខ្លួនឯងមកត្រឹម 3 (បី) ឆ្នាំ ដោយសារភាពថាមានការ*បំពាន*

### 10.8.2 កិច្ចព្រមព្រៀងដំណោះស្រាយករណី

នៅពេលដែល *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតទទួលសារភាពថាបានបំពានវិធានប្រឆាំងដូប៉ា បន្ទាប់ពីត្រូវបានចោទប្រកាន់ថាបានបំពានវិធានប្រឆាំងដូប៉ាដោយ*អង្គការប្រឆាំងដូប៉ា* ហើយយល់ព្រមនឹងទណ្ឌកម្មដែលបានទទួលយកដោយ*ទីភ្នាក់ងារប្រឆាំងដូប៉ា* និង*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* តាមសេចក្ដីសម្រេចរបស់ស្ថាប័នទាំងនេះមក នោះ៖

(ក) *អត្តពលិក* ឬ*បុគ្គលផ្សេង*ទៀតអាចទទួលបានការបន្ធូរបន្ថយរយៈពេលនៃការ*ព្យួរសិទ្ធិ* ផ្អែកលើការវាយតម្លៃដោយ*អង្គការប្រឆាំងដូប៉ា* និង*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* លើពាក្យស្នើសុំក្រោមប្រការ 10.1 ដល់ប្រការ 10.7 ចំពោះការបំពានវិធានប្រឆាំងដូប៉ា កម្រិត*កំហុស* របស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត និងថាតើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ទទួលស្គាល់ថា បានបំពានឆាប់ហើយប៉ុណ្ណា និង

(ខ) រយៈពេលនៃការ*ព្យួរសិទ្ធិ* អាចចាប់ផ្តើមនៅដើមកាលបរិច្ឆេទនៃការ*ប្រមូលសំណាក* ឬកាលបរិច្ឆេទដែលការបំពានវិធានប្រឆាំងដូប៉ាមួយផ្សេងទៀត កើតឡើងចុងក្រោយបំផុត។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីនីមួយៗ ដែលប្រការនេះត្រូវបានអនុវត្ត *អត្តពលិក* ឬ*បុគ្គល*ដទៃទៀតត្រូវអនុវត្តយ៉ាងតិចមួយពាក់កណ្ដាលនៃរយៈពេល*ព្យួរសិទ្ធិ* ដែលបានព្រមព្រៀងគ្នា រាប់ចាប់ពីមុនកាលបរិច្ឆេទដែល *អត្តពលិក*ឬ*បុគ្គល*ផ្សេងទៀត ទទួលយកការដាក់ការដាក់ទណ្ឌកម្ម ឬការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* ដែលត្រូវបានអនុវត្តតាមលំដាប់លំដោយ ដោយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត។ សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* និង*អង្គការប្រឆាំងដូប៉ា*ក្នុងការចូលរួម ឬមិនចូលរួមក្នុងកិច្ចព្រមព្រៀងផ្តល់ដំណោះស្រាយ និងរយៈពេលនៃការបន្ធូរបន្ថយ និងកាលបរិច្ឆេទចាប់ផ្តើមនៃរយៈពេលព្យួរសិទ្ធិនោះ មិនមែនជាបញ្ហាសម្រាប់សេចក្តីសម្រេច ឬការពិនិត្យឡើងវិញដោយអង្គសវនាការទេ ហើយមិនអាចត្រូវបានប្ដឹងជំទាស់តាមប្រការ 13 ឡើយ។

ប្រសិនបើមានការស្នើសុំពី*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដែលព្យាយាមចូលរួមក្នុងកិច្ចព្រមព្រៀងផ្តល់ដំណោះស្រាយក្រោមប្រការនេះ *អង្គការប្រឆាំងដូប៉ា*ដែលទទួលខុសត្រូវក្នុង*ការដោះស្រាយវិវាទដូប៉ា* ត្រូវអនុញ្ញាតឱ្យ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ពិភាក្សាអំពីការទទួលយកការបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើកិច្ចព្រមព្រៀងរក្សាសិទ្ធិភាគី ។[71]

---

និងទទួលយករយៈពេលបីឆ្នាំនៃការព្យួរសិទ្ធិ ក្នុងរយៈពេលដែលត្រូវបានបញ្ជាក់នៅក្នុងប្រការនេះ ដោយគ្មានការបន្ធូរបន្ថយបន្ថែមណាមួយទៀតត្រូវបានអនុញ្ញាតឡើយ។ ចំណុចនេះកំណត់ការដោះស្រាយករណីដោយមិនចាំបាច់មានសវនាការ។ ]

71 [សេចក្តីអធិប្បាយចំពោះប្រការ 10.8.2៖ រាល់កត្តាបន្ធូរបន្ថយ ឬបង្កើនស្ថានទម្ងន់ទោសដែលមានចែងក្នុងប្រការ 10 នេះ នឹងត្រូវបានពិចារណាក្នុងការកំណត់ទណ្ឌកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងដំណោះស្រាយករណី ហើយមិនត្រូវអនុវត្តលើសពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះទេ។
នៅប្រទេសខ្លះ ការកំណត់រយៈពេលនៃការព្យួរសិទ្ធិត្រូវបានផ្តល់សិទ្ធិទាំងស្រុងទៅឱ្យស្ថាប័នជំនុំជម្រះ។ នៅក្នុងប្រទេសទាំងនោះ *អង្គការប្រឆាំងដូប៉ា*មិនអាចកំណត់រយៈពេលជាក់លាក់ណាមួយនៃការព្យួរសិទ្ធិ សម្រាប់គោលបំណងនៃប្រការ 10.8.1 និងមិនមានអំណាចយល់ព្រមលើរយៈពេលជាក់លាក់ណាមួយនៃការព្យួរសិទ្ធិ ស្របតាមប្រការ 10.8.2 ឡើយ។ នៅក្នុងកាលៈទេសៈទាំងនេះ ប្រការ 10.8.1 និងប្រការ 10.8.2 នឹងមិនត្រូវបានអនុវត្តទេ ប៉ុន្តែអាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះ។ ]

## 10.9 ការបំពានជាច្រើនដង

### 10.9.1 ការបំពានវិធានប្រឆាំងដូប៉ាលើកទី 2 ឬទី 3

10.9.1.1 សម្រាប់ការបំពានវិធានប្រឆាំងដូប៉ារបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ជាលើកទី 2 ការបំពាន រយៈពេលនៃការ*ព្យួរសិទ្ធិ* ត្រូវមានកម្រិតធំជាង៖

(ក) រយៈពេល*ព្យួរសិទ្ធិ*ប្រាំមួយ (6) ខែ ឬ

(ខ) រយៈពេលនៃ*ការព្យួរសិទ្ធិ* នៅក្នុងចន្លោះពី៖

(i) រយៈពេលសរុបនៃការ*ព្យួរសិទ្ធិ*សម្រាប់ការបំពានវិធានប្រឆាំងដូប៉ាលើកទីមួយ បូក នឹងរយៈពេលនៃការ*ព្យួរសិទ្ធិ* ដែលត្រូវអនុវត្ត ប្រសិនបើមានការបំពានប្រឆាំងដូប៉ាជា លើកទី 2 ដែលត្រូវបានចាត់ទុកថាដូចជាការបំពានលើកទីមួយដែរ ហើយ

(ii) ពីរដងនៃរយៈពេលនៃការព្យួរសិទ្ធិ ដែលត្រូវអនុវត្តប្រសិនបើការបំពានវិធានប្រឆាំងដូ ប៉ាលើកទីពីរត្រូវបានចាត់ទុកដូចការបំពានជាលើកទីមួយ។

រយៈពេលនៃការព្យួរសិទ្ធិនៅក្នុងរយៈពេលនេះត្រូវបានកំណត់ដោយផ្អែកលើស្ថានភាពទាំងមូល និងកម្រិតកំហុសរបស់ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ទាក់ទងនឹងការបំពានលើកទីពីរ។

10.9.1.2 ការបំពានវិធានប្រឆាំងដូប៉ាលើកទី 3 នឹងបណ្តាលឱ្យមានការ*ព្យួរសិទ្ធិ*មួយជីវិត លើកលែងតែ ការបំពានលើកទី 3 នោះ បំពេញលក្ខខណ្ឌសម្រាប់ការលុបចោល ឬការបន្ធូរបន្ថយរយៈពេលនៃ ការ*ព្យួរសិទ្ធិ* តាមប្រការ 10.5 ឬប្រការ 10.6 ឬពាក់ព័ន្ធនឹងការបំពានប្រការ 2.4 ។ ក្នុងករណី ពិសេសទាំងនេះ រយៈពេលនៃការ*ព្យួរសិទ្ធិ* គឺពីប្រាំបី (8) ឆ្នាំដល់ការព្យួរសិទ្ធិពេញមួយជីវិត។

10.9.1.3 រយៈពេលនៃការ*ព្យួរសិទ្ធិ* ដូចត្រូវបានកំណត់ក្នុងប្រការ 10.9.1.1 និង 10.9.1.2 អាចត្រូវបាន បន្ធូរបន្ថយបន្ថែមទៀតដោយការអនុវត្តប្រការ 10.7 ។

10.9.2 ករណីបំពានវិធានប្រឆាំងដូប៉ាដែល *អត្តពលិក* ឬ*បុគ្គល*ដទៃទៀត អាចបង្ហាញថាខ្លួន គ្មាន*កំហុស* ឬការ*ធ្វេសប្រហែស* នឹងមិនត្រូវបានចាត់ទុកថាជាការបំពាន សម្រាប់គោលបំណងនៃប្រការ 10.9 នេះទេ។ លើសពីនេះទៀត ការបំពានវិធានប្រឆាំងដូប៉ាដែលត្រូវបានដាក់ទណ្ឌកម្មក្រោមប្រការ 10.2.4.1 នឹងមិន ត្រូវចាត់ទុកជាការបំពានសម្រាប់គោលបំណងនៃប្រការ 10.9 ទេ។

### 10.9.3 វិធានបន្ថែមចំពោះការបំពាន់ធ្ងន់ធ្ងរដាក់លាក់ច្រើនដង

10.9.3.1 សម្រាប់គោលបំណងដាក់ទណ្ឌកម្មក្រោមប្រការ 10.9 លើកលែងដូចមានចែងក្នុងប្រការ 10.9.3.2 និងប្រការ 10.9.3.3 ការបំពានវិធានប្រឆាំងដូប៉ានឹងត្រូវបានចាត់ទុកថាជាការបំពានជាលើកទី 2 លុះត្រាតែ*អង្គការប្រឆាំងដូប៉ា*អាចបង្ហាញថា *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត បានប្រព្រឹត្តការបំពាន វិធានប្រឆាំងដូប៉ាបន្ថែម បន្ទាប់ពី*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត បានទទួលសេចក្តីជូនដំណឹង

ដោយអនុលោមតាមប្រការ 7 ឬបន្ទាប់ពី*អង្គការប្រឆាំងដូប៉ា* បានខិតខំប្រឹងប្រែងសមហេតុផល ដើម្បីផ្តល់សេចក្តីជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាលើកទីមួយ ហើយ។ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*មិនអាចបង្ហាញករណីនោះបានទេ ការបំពានត្រូវបានចាត់ទុកជាការបំពានតែម្តងលើកទី1 ហើយការដាក់ទណ្ឌកម្មត្រូវផ្អែកលើការបំពាន ដែលត្រូវអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ រួមទាំងការអនុវត្តស្ថានទម្ងន់ទោស។ លទ្ធផល*ការប្រកួត*ទាំងអស់រាប់ចាប់តាំងកាលបរិច្ឆេទដំបូងនៃការបំពានវិធានប្រឆាំងដូប៉ានឹងត្រូវ*ដកសិទ្ធិ* ដូចមានចែងក្នុងប្រការ 10.10 ។[72]

10.9.3.2 ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*បានកំណត់ថា *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត បានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាមុនការជូនដំណឹង ហើយថាការបំពានបន្ថែមបានកើតឡើងក្នុងរយៈពេលដប់ពីរ(12)ខែ ឬច្រើនជាងនេះ មុន ឬក្រោយការបំពានលើកទី1 ដែលត្រូវបានជូនដំណឹងនោះ រយៈពេលនៃការ*ព្យួរសិទ្ធិ* ចំពោះការបំពានបន្ថែមនឹងត្រូវបានគណនា ដូចការបំពានបន្ថែមលើកទី1 ផ្សេងទៀត ហើយរយៈពេលនៃការ*ព្យួរសិទ្ធិ*ត្រូវអនុវត្តបន្តគ្នា ជាជាងទន្ទឹមគ្នា ជាមួយនឹងរយៈពេលនៃការ*ព្យួរសិទ្ធិ* សម្រាប់ការបំពានដែលបានជូនដំណឹងពីមុនៗ។ ក្នុងករណីដែលប្រការ 10.9.3.2 នេះត្រូវបានអនុវត្ត ការបំពានដែលបានកើតឡើងរួមគ្នាត្រូវបានចាត់ទុកថាជាការបំពានតែមួយ សម្រាប់គោលបំណងនៃប្រការ 10.9.1 ។

10.9.3.3 ប្រសិនបើ*អង្គការប្រឆាំងដូប៉ា* អាចបង្ហាញថា *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត បានប្រព្រឹត្តបំពានប្រការ 2.5 ទាក់ទងនឹងដំណើរគ្រប់គ្រងសារធាតុដូប៉ា សម្រាប់ការបំពានវិធានប្រឆាំងដូប៉ាដែលត្រូវបានចោទ ការបំពានប្រការ 2.5 នឹងត្រូវបានចាត់ទុកថា ជាការបំពានលើកទីមួយដោយឡែក ហើយរយៈពេលនៃការព្យួរសិទ្ធិចំពោះការបំពានបែបនេះនឹងត្រូវបានអនុវត្តបន្តគ្នា ជាជាងទន្ទឹមគ្នាជាមួយនឹងរយៈពេលនៃការ*ព្យួរសិទ្ធិ* បើមានកំណត់សម្រាប់ការបំពានវិធានប្រឆាំងដូប៉ានោះ។ ក្នុងករណីដែលប្រការ 10.9.3.3 ត្រូវបានអនុវត្ត ការបំពានដែលបានកើតឡើងរួមគ្នាត្រូវបានចាត់ទុកថាជាការបំពានតែមួយសម្រាប់គោលបំណងនៃប្រការ 10.9.1 ។

10.9.3.4 ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*អាចបង្ហាញថា*បុគ្គល*ម្នាក់ បានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ាជាលើកទី២ ឬទី៣ ក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ នោះរយៈពេលនៃការព្យួរសិទ្ធិសម្រាប់ការបំពានច្រើនដងនឹងត្រូវអនុវត្តជាបន្តបន្ទាប់គ្នា ជាជាងដំណាលគ្នា។

10.9.4 ការបំពានវិធានប្រឆាំងដូប៉ាច្រើនដងក្នុងអំឡុងពេលដប់ (10) ឆ្នាំ

សម្រាប់គោលបំណងនៃប្រការ 10.9 រាល់ការបំពានវិធានប្រឆាំងដូប៉ាត្រូវកើតឡើងក្នុងរយៈពេលដប់ (10) ឆ្នាំដូចគ្នា ដើម្បីចាត់ទុកជាការបំពានច្រើនដង។

72 [សេចក្តីអធិប្បាយចំពោះប្រការ 10.9.3.1៖ វិធានដូចគ្នាត្រូវបានអនុវត្ត បន្ទាប់ពីការដាក់ទណ្ឌកម្ម ក្នុងករណីដែល*អង្គការប្រឆាំងដូប៉ា*បានរកឃើញការពិតដែលទាក់ទងនឹងការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ា ដែលបានកើតឡើងមុនពេលជូនដំណឹងអំពីការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ាជាលើកដំបូង ឧទាហរណ៍៖ *អង្គការប្រឆាំងដូប៉ា*ត្រូវកំណត់ទណ្ឌកម្មដោយផ្អែកលើការដាក់ទណ្ឌកម្មដែលអាចត្រូវបានកំណត់ ប្រសិនបើការ*បំពាន*ទាំងពីរនេះត្រូវបានជំនុំជម្រះក្នុងពេលតែមួយ រួមទាំងការអនុវត្តស្ថានទម្ងន់ទោស]

## 10.10 ការ*ដកសិទ្ធិ*នៃលទ្ធផលនៅការប្រកួត បន្ទាប់ពីការប្រមូល*សំណាក* ឬការប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា

បន្ថែមលើការ*ដកសិទ្ធិ*លទ្ធផលប្រកួតដោយស្វ័យប្រវត្តិ ដែលបណ្តាលពី*សំណាក*វិជ្ជមានក្រោមប្រការ ៩ រាល់លទ្ធផលដែលមានលក្ខណៈ*ប្រកួត*ដទៃទៀតទាំងអស់របស់*អត្តពលិក* ដែលទទួលបានចាប់ពីកាលបរិច្ឆេទដែល*សំណាក*វិជ្ជមានត្រូវបានប្រមូល (មិនថា*ក្នុងការប្រកួត* ឬ*ក្រៅការប្រកួត*ទេ) ឬការបំពានវិធានដូប៉ាផ្សេងទៀត បានកើតឡើងតាមរយៈការចាប់ផ្តើមអនុវត្តការ*ព្យួរសិទ្ធិបណ្តោះអាសន្ន*ណាមួយ ឬអំឡុងពេល*ព្យួរសិទ្ធិ* លុះត្រាតែភាពយុត្តិធម៌តម្រូវឱ្យអនុវត្តផ្សេងពីនោះ នឹងត្រូវបាន*ដកសិទ្ធិ* ដោយមានទណ្ឌកម្មពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងការដកមេដាយ ពិន្ទុ និងរង្វាន់មកវិញ។[73]

## 10.11 ប្រាក់រង្វាន់ដែលត្រូវបានដកយកវិញ

ប្រសិនបើ*អង្គការប្រឆាំងដូប៉ា* ឬ*ស្ថាប័នហត្ថលេខី*ដទៃទៀតស្តារមកវិញនូវប្រាក់រង្វាន់ដែលត្រូវដកយកវិញដោយសារការបំពានវិធានប្រឆាំងដូប៉ានោះ ខ្លួននឹងចាត់វិធានការសមហេតុផលក្នុងការវិភាជ និងបែងចែកប្រាក់រង្វាន់នោះដល់អត្តពលិក ដែលមានសិទ្ធិទទួលបាន ប្រសិនបើ*អត្តពលិក* ដែលត្រូវបានដកសិទ្ធិនោះមិនជំទាស់។ សហព័ន្ធអន្តរជាតិអាចផ្តល់នូវវិធានរបស់ខ្លួនថា តើប្រាក់រង្វាន់ដែលបានចែកចាយឡើងវិញនឹងត្រូវយកមកពិចារណាក្នុងគោលបំណងធ្វើចំណាត់ថ្នាក់*អត្តពលិក* ឬអត់។[74]

## 10.12 *ផលវិបាក*ហិរញ្ញវត្ថុ

តាមវិធានរបស់ខ្លួន *អង្គការប្រឆាំងដូប៉ា* អាចនឹងផ្តល់នូវការស្តារឡើងវិញនូវការចំណាយ ឬទណ្ឌកម្មហិរញ្ញវត្ថុដោយសារការបំពានលើវិធានប្រឆាំងដូប៉ា។ ទោះយ៉ាងណាក៏ដោយ *អង្គការប្រឆាំងដូប៉ា* អាចដាក់ទណ្ឌកម្មហិរញ្ញវត្ថុតែក្នុងករណីដែលរយៈពេលអតិបរមានៃការ*ព្យួរសិទ្ធិ* ដែលអនុវត្តបានត្រូវបានកំណត់រួចហើយ។ ទណ្ឌកម្មហិរញ្ញវត្ថុអាចត្រូវបានកំណត់តែនៅពេលដែលគោលការណ៍នៃសមាមាត្រពេញចិត្ត។ គ្មានការស្តារចំណាយ ឬការដាក់ទណ្ឌកម្មហិរញ្ញវត្ថុណាមួយអាចត្រូវបានចាត់ទុកថា ជាមូលដ្ឋានសម្រាប់កាត់បន្ថយការ*ព្យួរសិទ្ធិ*ទទួល ឬទណ្ឌកម្មផ្សេងទៀតដែលអាចត្រូវអនុវត្តតាម *ក្រមនេះ* ទេ។

## 10.13 ការចាប់ផ្តើមនៃរយៈពេល*ព្យួរសិទ្ធិ*

ក្នុងករណីដែល*អត្តពលិក* កំពុងអនុវត្តរយៈពេល*ព្យួរសិទ្ធិ* ចំពោះការបំពានវិធានប្រឆាំងដូប៉ារយៈពេល*ព្យួរសិទ្ធិ*ថ្មីណាមួយនឹងចាប់ផ្តើមនៅថ្ងៃដំបូងបន្ទាប់ពីរយៈពេល*ព្យួរសិទ្ធិ* បច្ចុប្បន្នត្រូវបានអនុវត្តចប់សព្វគ្រប់ហើយ។ បើមិនដូច្នោះទេ លើកលែងដូចអ្វីដែលបានចែងនៅខាងក្រោម រយៈពេលនៃការ*ព្យួរសិទ្ធិ* នឹងចាប់ផ្តើមនៅកាលបរិច្ឆេទនៃសេចក្តីសម្រេចសវនាការចុងក្រោយ ដែលកំណត់ការ*ព្យួរសិទ្ធិ*នោះ ឬប្រសិនបើសវនាការត្រូវបានលើកលែង ឬមិន

---

73 [សេចក្តីអធិប្បាយចំពោះប្រការ 10.10៖ គ្មានអ្វីនៅក្នុងក្រមនេះហាមប្រាមអត្តពលិក ឬបុគ្គលផ្សេងទៀតដែលស្អាតស្អំ ដែលបានរងគ្រោះដោយសកម្មភាពរបស់បុគ្គលម្នាក់ផ្សេងទៀតដែលបានប្រព្រឹត្តល្មើសនឹងវិធានប្រឆាំងសារធាតុដូប៉ា ពីការស្វែងរកសិទ្ធិណាមួយឡើយ បើមិនដូច្នេះទេ ពួកគេនឹងត្រូវស្វែងរកការទាមទារសំណងខូចខាតពីបុគ្គលនោះ។ ]

74 [សេចក្តីអធិប្បាយចំពោះប្រការ 10.11៖ ប្រការនេះមិនមានបំណងកំណត់កាតព្វកិច្ចផ្លូវច្បាប់ដើម្បីឱ្យ*អង្គការប្រឆាំងដូប៉ា* ឬស្ថាប័នហត្ថលេខីផ្សេងទៀត ធ្វើសកម្មភាពណាមួយដើម្បីប្រមូលប្រាក់រង្វាន់ដែលត្រូវបានរឹបអូសនោះទេ។ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*សម្រេចថាមិនចាត់វិធានការណាមួយដើម្បីប្រមូលប្រាក់រង្វាន់ដែលត្រូវបានរឹបអូសនោះ ស្ថាប័ននេះអាចផ្តល់សិទ្ធិក្នុងការស្តារប្រាក់ទាំងនោះមកវិញ ទៅឱ្យអត្តពលិកដែលគួរទទួលបានប្រាក់នោះ។ "វិធានការណ៍សមហេតុផលដើម្បីបែងចែក និងចែកចាយប្រាក់រង្វាន់នេះ" អាចរួមបញ្ចូលទាំងការប្រើប្រាស់ប្រាក់រង្វាន់រឹបអូសដែលប្រមូលបាន តាមការយល់ព្រមរបស់សហព័ន្ធអន្តរជាតិ និងអត្តពលិករបស់ស្ថាប័ននេះ។ ]

មានសវនាការ វាត្រូវចាប់ផ្តើមនៅកាលបរិច្ឆេទដែល ការ*ព្យួរសិទ្ធិ* ត្រូវបានទទួលយក ឬត្រូវបានដាក់ចេញ។

10.13.1 ការពន្យារពេលមិនពាក់ព័ន្ធនឹង*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត

ក្នុងករណីដែលមានការពន្យារពេលសំខាន់ៗ ក្នុងដំណើរការសវនាការ ឬទិដ្ឋភាពផ្សេងទៀតនៃការត្រួតពិនិត្យសារធាតុដូប៉ា ហើយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតអាចបញ្ជាក់ថាការពន្យារពេលបែបនោះមិនមែនបង្កដោយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតទេនោះ ស្ថាប័នដែលកំណត់ទណ្ឌកម្មនោះអាចចាប់ផ្តើមរយៈពេលនៃការ*ព្យួរសិទ្ធិ* នៅកាលបរិច្ឆេទប្រតិសកម្ម រហូតដល់កាលបរិច្ឆេទចាប់ផ្តើមនៃការប្រមូល*សំណាក* ឬកាលបរិច្ឆេទដែលការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀតបានកើតឡើង។ រាល់លទ្ធផលប្រកួតដែលទទួលបានក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ រាប់បញ្ចូលទាំងកាលបរិច្ឆេទប្រតិសកម្មនៃការ*ព្យួរសិទ្ធិ* នឹងត្រូវ*ដកសិទ្ធិ*។[75]

10.13.2 ផលប្រយោជន៍ចំពោះការអនុវត្តការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ឬការអនុវត្តរយៈពេល*ព្យួរសិទ្ធិ*

10.13.2.1 ប្រសិនបើការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ត្រូវបានគោរពដោយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត នោះ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត នឹងទទួលបានប្រយោជន៍សម្រាប់ការអនុវត្តរយៈពេល*ព្យួរបណ្តោះអាសន្ន* ដែលនឹងត្រូវបានកាត់ចេញពីរយៈពេលនៃការ*ព្យួរសិទ្ធិ* ដែលត្រូវបានដាក់ចេញចុងក្រោយ។ ប្រសិនបើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត មិនគោរពការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* នោះ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនឹងមិនទទួលបានផលប្រយោជន៍ពីការអនុវត្តរយៈពេលនៃការ*ព្យួរសិទ្ធិបណ្តោះអាសន្ន*នោះឡើយ។ ប្រសិនបើរយៈពេលនៃការ*ព្យួរសិទ្ធិ* ត្រូវបានអនុវត្តតាមការសម្រេចដែលក្រោយមកត្រូវបានប្តឹងជំទាស់ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនឹងទទួលបានផលប្រយោជន៍ចំពោះរយៈពេលនោះ ដែលនឹងត្រូវបានដកចេញពីរយៈពេល*ព្យួរសិទ្ធិ* ដែលនឹងត្រូវបានដាក់ចេញចុងក្រោយចំពោះបណ្តឹងជំទាស់នោះ។

10.13.2.2 ប្រសិនបើ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតយល់ព្រមទទួលការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ដោយស្ម័គ្រចិត្ត ជាលាយលក្ខណ៍អក្សរពី*អង្គការប្រឆាំងដូប៉ា* ហើយបន្ទាប់មក គោរពការ*ព្យួរសិទ្ធិបណ្តោះអាសន្ន*នោះ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនឹងទទួលបានផលប្រយោជន៍សម្រាប់រយៈពេលនៃការ*ព្យួរសិទ្ធិបណ្តោះអាសន្ន*ដោយស្ម័គ្រចិត្តនោះ ដែលនឹងត្រូវបានដកចេញពីរយៈពេល*ព្យួរសិទ្ធិ* នឹងត្រូវដាក់ចេញចុងក្រោយ។ ឯកសារមួយច្បាប់នៃការទទួលយកដោយស្ម័គ្រចិត្តរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតចំពោះការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* នឹងត្រូវផ្តល់ឱ្យភ្លាមៗដល់ភាគីនីមួយៗដែលមានសិទ្ធិទទួលបានការជូនដំណឹង អំពីការបំពានវិធានប្រឆាំងប៉ាក្រោមប្រការ 14.1 ។[76]

75 [សេចក្តីអធិប្បាយចំពោះប្រការ 10.13.1៖ ក្នុងករណីមានការ*បំពាន*លើវិធានប្រឆាំង*ដូប៉ា* ក្រៅពីប្រការ 2.1 រយៈពេលដែលត្រូវការសម្រាប់ស្ថាប័នប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាស្វែងយល់ និងបង្កើតអង្គហេតុគ្រប់គ្រាន់ ដើម្បីបង្ហាញការ*បំពាន*វិធានប្រឆាំង*ដូប៉ា* អាចមានរយៈពេលវែង ជាពិសេសនៅករណីដែលអត្តពលិក ឬបុគ្គលផ្សេងទៀតបានចាត់វិធានការដើម្បីចៀសវាងការរកឃើញនោះ។ ក្នុងកាលៈទេសៈទាំងនេះ ភាពបត់បែនដែលមានចែងនៅក្នុងប្រការនេះ ដើម្បីចាប់ផ្តើមដាក់ទណ្ឌកម្មកាលពីមុនមិនគួរត្រូវបានប្រើទេ។ ]

76 [សេចក្តីអធិប្បាយចំពោះប្រការ 10.13.2.2៖ ការយល់ព្រមដោយស្ម័គ្រចិត្តរបស់អត្តពលិកចំពោះការព្យួរសិទ្ធិបណ្តោះអាសន្នមិនមែនជាការសារភាពដោយអត្តពលិកទេ ហើយនឹងមិនត្រូវបានប្រើក្នុងវិធីណាមួយ ដើម្បីទាញការសន្និដ្ឋាន*វិជ្ជមាន*ចំពោះអត្តពលិកឡើយ។ ]

10.13.2.3 គ្មានផលប្រយោជន៍ណាមួយដែលនឹងត្រូវផ្តល់ឱ្យដោយដកចេញពីរយៈពេល*ព្យួរសិទ្ធិ*ទ មុនកាលបរិច្ឆេទ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ឬការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ដោយស្ម័គ្រចិត្តចូលជាធរមាន ដោយមិនគិតថាតើ*អត្តពលិក*ត្រូវបានជ្រើសរើសឱ្យចូលប្រកួត ឬត្រូវបាន*ព្យួរសិទ្ធិ* ដោយក្រុមមួយនោះទេ។

10.13.2.4 នៅក្នុងកីឡាជាក្រុម ប្រសិនបើរយៈពេលនៃការ*ព្យួរសិទ្ធិ* ត្រូវបានដាក់លើក្រុម លើកលែងតែការធ្វើដូច្នោះបង្កឱ្យមានភាពអយុត្តិធម៌ បើមិនដូច្នេះទេ រយៈពេលនៃការ*ព្យួរសិទ្ធិ*នោះ នឹងចាប់ផ្តើមនៅកាលបរិច្ឆេទនៃសេចក្តីសម្រេចសវនាការចុងក្រោយ ដែលកំណត់ការ*ព្យួរសិទ្ធិ*នោះ ឬប្រសិន បើសវនាការត្រូវបានលើកលែង ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទ*ព្យួរសិទ្ធិ* ដែលត្រូវបានទទួលយក ឬត្រូវបានដាក់។ រយៈពេលនៃការ*ព្យួរសិទ្ធិបណ្តោះអាសន្ន*របស់ក្រុម (ទោះជាត្រូវបានដាក់ ឬទទួលយកដោយស្ម័គ្រចិត្តក៏ដោយ) នឹងត្រូវផ្តល់ជាប្រយោជន៍ដោយដកចេញពីរយៈពេលនៃការព្យួរសិទ្ធិ ដែលត្រូវអនុវត្តនោះ។

## 10.14 ស្ថានភាពក្នុងកំឡុងពេលនៃការ*ព្យួរសិទ្ធិ* ឬការ*ព្យួរសិទ្ធិបណ្តោះអាសន្ន*

### 10.14.1 ការហាមឃាត់មិនឱ្យចូលរួមក្នុងកំឡុងពេលនៃ*ការព្យួរសិទ្ធិ ឬការព្យួរសិទ្ធិបណ្តោះអាសន្ន*

គ្មាន*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតណាមួយ ដែលត្រូវបានប្រកាសថា ស្ថិតក្រោមការ*ព្យួរសិទ្ធិ* ឬដែលជាកម្មវត្ថុនៃការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ក្នុងអំឡុងពេលនៃការ*ព្យួរសិទ្ធិ* ឬការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* អាចចូលរួមនៅក្នុងសមត្ថភាពណាមួយនៅ*ការប្រកួត* ឬសកម្មភាព (ផ្សេងទៀតក្រៅពីកម្មវិធី*អប់រំ* ឬកែប្រែប្រឆាំងដូប៉ាដែលត្រូវបានអនុញ្ញាត) ដែលត្រូវបានអនុញ្ញាត ឬរៀបចំដោយ*ស្ថាប័នហត្ថលេខី* អង្គការដែលជាសមាជិក*ស្ថាប័នហត្ថលេខី* ឬក្លឹប ឬសមាជិកដទៃទៀតនៃអង្គការដែលជាសមាជិករបស់*ស្ថាប័នហត្ថលេខី*នោះ ឬក្នុងការប្រកួតដែលត្រូវបានអនុញ្ញាត ឬរៀបចំដោយលីកអាជីព ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាថ្នាក់ជាតិ ឬអន្តរជាតិ ឬក្នុងសកម្មភាពកីឡាថ្នាក់ជាតិ ដែលផ្តល់មូលនិធិដោយទីភ្នាក់ងាររដ្ឋាភិបាលទេ។ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលស្ថិតក្នុងរយៈពេលនៃការ*ព្យួរសិទ្ធិ* លើសពីបួន (4) ឆ្នាំ បន្ទាប់ពីបញ្ចប់រយៈពេលបួន (4) ឆ្នាំនៃការ*ព្យួរសិទ្ធិ*នោះ អាចចូលរួមក្នុងនាមជា*អត្តពលិក* ក្នុង*ព្រឹត្តិការណ៍*ក្នុងស្រុក ដែលមិនស្ថិតក្រោមទណ្ឌកម្ម ឬបើមិនដូច្នេះទេស្ថិតក្រោមសិទ្ធិអំណាចរបស់*ស្ថាប័នហត្ថលេខី*នៃ*ក្រុម*នេះ ឬសមាជិកនៃ*ស្ថាប័នហត្ថលេខី* នៃ*ក្រុម*នេះ ប៉ុន្តែមិនអាចចូលរួមក្នុង*ព្រឹត្តិការណ៍*ក្នុងស្រុកណា ដែលអាចផ្តល់សិទ្ធិដល់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ ក្នុងការចូលរួមដោយផ្ទាល់ ឬដោយប្រយោល (ឬប្រមូលពិន្ទុឆ្ពោះទៅចូលរួម) ក្នុងការប្រកួតជើងឯកថ្នាក់ជាតិ ឬ*ព្រឹត្តិការណ៍*អន្តរជាតិបានទេ ហើយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ មិនអាចពាក់ព័ន្ធក្នុងសមត្ថភាពណាមួយជាមួយ*បុគ្គលដែលត្រូវបានការពារ*ឡើយ។[77]

77 [សេចក្តីអធិប្បាយចំពោះប្រការ 10.14.៖ ឧទាហរណ៍ យោងតាមប្រការ 10.14.2 ខាងក្រោម អត្តពលិកដែលគ្មានសិទ្ធិមិនអាចចូលរួមក្នុងជំរុំហ្វឹកហាត់ ការតាំងពិពណ៌ ឬការអនុវត្តដែលរៀបចំដោយសហព័ន្ធ ឬក្លឹបជាតិរបស់ពួកគេ ដែលជាសមាជិកនៃសហព័ន្ធជាតិ ឬដែលត្រូវបានឧបត្ថម្ភថវិកាដោយស្ថាប័នរដ្ឋាភិបាលនោះទេ។ លើសពីនេះ អត្តពលិកដែលគ្មានសិទ្ធិមិនអាចចូលរួមប្រកួតនៅក្នុងលីកកីឡាអាជីពរបស់ស្ថាប័នមិនមែនហត្ថលេខីទេ (ឧទាហរណ៍៖ សម្ព័ន្ធកីឡាហុកគីជាតិ សមាគមបាល់បោះជាតិ ។ ល។) ព្រឹត្តិការណ៍ដែលរៀបចំឡើងដោយស្ថាប័នរៀបចំព្រឹត្តិការណ៍អន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កម្រិតជាតិដែលមិនមែនជាស្ថាប័នហត្ថលេខី ដោយមិនបង្កឱ្យមានការដាក់ទណ្ឌកម្ម ដូចដែលបានចែងក្នុងមាត្រា 10.14.3។ ពាក្យថា "សកម្មភាព" ក៏រួមបញ្ចូលផងដែរ ឧទាហរណ៍ នូវសកម្មភាពរដ្ឋបាល ដូចជាការបំពេញការងារជាមន្ត្រី នាយក បុគ្គលិក ឬអ្នកស្ម័គ្រចិត្តរបស់ស្ថាប័នដែលបានពិពណ៌នានៅក្នុងប្រការនេះ។ ការព្យួរសិទ្ធិនៅក្នុងកីឡាមួយក៏ត្រូវតែមានការទទួលស្គាល់ដោយកីឡាផ្សេងទៀតផងដែរ (សូមមើលប្រការ 15.1 ប្រសិទ្ធភាពនៃការភ្ជាប់ដោយស្វ័យប្រវត្តិនៃការសម្រេច

*អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀត ដែលស្ថិតក្នុងរយៈពេលនៃការ*ព្យួរសិទ្ធិ*នឹងនៅតែជាកម្មវត្ថុនៃការ*ធ្វើតេស្ត*និងគ្រប់លក្ខខណ្ឌតម្រូវរបស់*អង្គការប្រឆាំងដូប៉ា* ដើម្បីផ្ដល់ព័ត៌មានអំពីទីសំចត។

10.14.2 ការត្រឡប់ទៅការហ្វឹកហាត់

ជាករណីលើកលែងចំពោះប្រការ 10.14.1 *អត្តពលិក*អាចវិលត្រឡប់មកធ្វើការហ្វឹកហាត់ជាមួយនឹងក្រុមវិញ ឬប្រើបរិក្ខារក្លឹប ឬស្ថាប័នសមាជិកផ្សេងទៀតរបស់*អង្គការប្រឆាំងដូប៉ា* ឬសមាជិករបស់*ស្ថាប័នហត្ថលេខី*ផ្សេងទៀតក្នុងកំឡុងពេល៖ (1) ពីរខែចុងក្រោយនៃរយៈពេលព្យួរសិទ្ធិរបស់*អត្តពលិក* ឬ (2) មួយភាគបួនចុងក្រោយនៃរយៈពេល*ព្យួរសិទ្ធិ*។[78]

10.14.3 ការបំពានលើការហាមឃាត់មិនឱ្យចូលរួមក្នុងកំឡុងពេលនៃការ*ព្យួរសិទ្ធិ* ឬការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*

ក្នុងករណីដែល *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលត្រូវបានប្រកាសថាស្ថិតក្រោមការ*ព្យួរសិទ្ធិ*បានបំពានលើការហាមឃាត់មិនឱ្យចូលរួម ក្នុងកំឡុងពេលនៃការ*ព្យួរសិទ្ធិ* ដូចដែលបាន ពិពណ៌នានៅក្នុងប្រការ 10.14.1 លទ្ធផលនៅក្នុងការចូលរួមប្រកួតទាំងនោះនឹងត្រូវបាន*ដកសិទ្ធិ* ហើយរយៈពេល*ព្យួរសិទ្ធិ*ថ្មី ស្មើនឹងរយៈពេល*ព្យួរសិទ្ធិ*ដើម នឹងត្រូវបានបន្ថែម នៅចុងបញ្ចប់នៃរយៈពេល*ព្យួរសិទ្ធិ*ដើម។ រយៈពេលនៃការ*ព្យួរសិទ្ធិ*ថ្មី រាប់បញ្ចូលទាំងការស្ដីបន្ទោសដោយគ្មានការ*ព្យួរសិទ្ធិ* អាចត្រូវបានកែប្រែ ដោយផ្អែកលើកម្រិត*កំហុស*របស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតនោះ និងកាលៈទេសៈផ្សេងៗនៃករណីនោះ។ ការកំណត់ថាតើ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតបានបំពានលើការហាមឃាត់ប្រឆាំងនឹងការចូលរួម និងថាតើការកែតម្រូវមានភាពសមស្រប ស្ថិតក្រោមសិទ្ធិសម្រេចរបស់*អង្គការប្រឆាំងដូប៉ា* ដែល*ការដោះស្រាយវិវាទដូប៉ា* នាំឱ្យមានការ*ព្យួរសិទ្ធិ*ក្នុងរយៈពេលដំបូង។ សេចក្ដីសម្រេចនេះ អាចត្រូវបានជំទាស់ដោយយោងតាមប្រការ 13។

*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលបំពានលើការហាមឃាត់មិនឱ្យចូលរួមក្នុងអំឡុងពេលនៃការព្យួរសិទ្ធិបណ្ដោះអាសន្ន ដូចដែលមានចែងក្នុងប្រការ 10.14.1 នឹងមិនទទួលបានផលប្រយោជន៍ចំពោះរយៈពេលនៃការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន*ណាមួយឡើយ ហើយលទ្ធផលនៃការចូលរួមប្រកួតទាំងនោះនឹងត្រូវដកសិទ្ធិ។

ក្នុងករណីដែល*អ្នកគាំពារអត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ជួយបុគ្គលណាមួយក្នុងការបំពានលើការហាមឃាត់មិនឱ្យចូលរួមក្នុងអំឡុងពេលនៃការ*ព្យួរសិទ្ធិ* ឬការ*ព្យួរសិទ្ធិបណ្ដោះអាសន្ន* *អង្គការប្រឆាំងដូប៉ា*មានសិទ្ធិលើ*អ្នកគាំពារអត្តពលិក* ឬបុគ្គលផ្សេងទៀត ត្រូវដាក់ទណ្ឌកម្មចំពោះការបំពានប្រការ 2.9 សម្រាប់ការជួយបែបនេះ។

10.14.4 ការដកការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងកំឡុងពេលនៃ*ការព្យួរសិទ្ធិ*

ចិត្ត)។ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលកំពុងអនុវត្តការព្យួរសិទ្ធិ ត្រូវបានហាមឃាត់មិនឱ្យធ្វើជាគ្រូបង្វឹក ឬបម្រើការជាជំនួយការអត្តពលិកក្នុងសមត្ថភាពផ្សេងទៀត នៅពេលណាមួយក្នុងកំឡុងពេលនៃការព្យួរសិទ្ធិឡើយ ហើយការធ្វើដូច្នេះអាចបណ្ដាលឱ្យមានការ*បំពាន*លើ 2.10 ដោយអត្តពលិកម្នាក់ទៀត។ ស្តង់ដារលទ្ធផលណាមួយដែលសម្រេចបានក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ នឹងមិនត្រូវបានទទួលស្គាល់ដោយស្ថាប័នហត្ថលេខី ឬសហព័ន្ធជាតិរបស់ខ្លួនក្នុងគោលបំណងណាមួយឡើយ។

78 [សេចក្ដីអធិប្បាយចំពោះប្រការ 10.14.2៖ នៅក្នុងកីឡាជាក្រុម និងកីឡាបុគ្គលមួយចំនួន (ឧទាហរណ៍៖ ការលោតស្គី និងកាយសម្ព័ន្ធ) អត្តពលិកមិនអាចហ្វឹកហាត់ដោយខ្លួនឯងប្រកបដោយប្រសិទ្ធភាព ដើម្បីត្រៀមប្រកួតនៅចុងរយៈពេលនៃការព្យួរសិទ្ធិរបស់អត្តពលិកនោះទេ។ ក្នុងកំឡុងពេលហ្វឹកហាត់ ដូចដែលបានពិពណ៌នានៅក្នុងប្រការនេះ អត្តពលិកដែលគ្មានសិទ្ធិមិនអាចចូលរួមប្រកួត ឬចូលរួមក្នុងសកម្មភាពណាមួយដែលបានពិពណ៌នានៅក្នុងប្រការ 10.14.1 ក្រៅពីការបណ្ដុះបណ្ដាលឡើយ។]

លើសពីនេះទៀត ចំពោះការបំពានវិធានប្រឆាំងដូប៉ាណាមួយ ដែលមិនពាក់ព័ន្ធនឹងការបន្ធូរបន្ថយទណ្ឌកម្ម ដូចមានចែងក្នុងប្រការ 10.5 ឬប្រការ 10.6 ការគាំទ្រផ្នែកហិរញ្ញវត្ថុ អត្ថប្រយោជន៍ទាក់ទងនឹងកីឡាដទៃទៀតមួយចំនួន ឬទាំងអស់ដែលទទួលបានដោយ*បុគ្គល*នោះ នឹងត្រូវដកហូតដោយ*ស្ថាប័នហត្ថលេខី* អង្គការ និងរដ្ឋាភិបាលដែលជាសមាជិក*ស្ថាប័នហត្ថលេខី*។

### 10.15 ការផ្សព្វផ្សាយទណ្ឌកម្មដោយស្វ័យប្រវត្តិ

ផ្នែកដែលចាំបាច់នៃទណ្ឌកម្មនីមួយៗ រួមមានការបោះផ្សាយដោយស្វ័យប្រវត្តិ ដូចមានចែងក្នុងប្រការ 14.3 ។

## ប្រការ11៖ *ផលវិបាក*សម្រាប់ក្រុម

### 11.1 ការ*ធ្វើតេស្ត*សម្រាប់*កីឡាជាក្រុម*

ក្នុងករណីដែលមានសមាជិកច្រើនជាងមួយ (1) នាក់នៃក្រុមក្នុង*កីឡាជាក្រុម* ត្រូវបានជូនដំណឹងអំពីការបំពានវិធានប្រឆាំងនឹងប្រការ 7 ទាក់ទងនឹង*ព្រឹត្តិការណ៍*មួយ ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍នោះ ត្រូវធ្វើតេស្តគោលដៅលើ*ក្រុមកីឡា*នោះ ក្នុងកំឡុងពេលនៃ*ព្រឹត្តិការណ៍* ។

### 11.2 *ផលវិបាក*សម្រាប់កីឡាជាក្រុម

ប្រសិនបើមានសមាជិកច្រើនជាងពីរនាក់នៃក្រុមមួយនៅក្នុង *កីឡាជាក្រុម*ត្រូវបានគេរកឃើញថាបានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាក្នុងអំឡុងពេលនៃ*ព្រឹត្តិការណ៍* នោះស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍* នឹងដាក់ទណ្ឌកម្មសមស្របលើក្រុម (ឧទាហរណ៍៖ ការដកពិន្ទុ *ដកសិទ្ធិ*ពីការប្រកួត ឬពី*ព្រឹត្តិការណ៍* ឬការដាក់ទណ្ឌកម្មផ្សេងទៀត) បន្ថែមលើទ*ផលវិបាក*ដែលបានដាក់ទៅលើ*អត្តពលិក*ជាឯកត្តជន ដែលប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ា។

### 11.3 ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍* ឬសហព័ន្ធអន្តរជាតិអាចបន្ថែម*ផលវិបាក*តឹងរ៉ឹងសម្រាប់កីឡាជាក្រុម

ស្ថាប័នគ្រប់គ្រង*ព្រឹត្តិការណ៍*ប្រកួតកីឡាអាចសម្រេចបង្កើតវិធានសម្រាប់គ្រប់គ្រង*ព្រឹត្តិការណ៍*ដែលកំណត់*ផលវិបាក*ចំពោះ*កីឡាជាក្រុម*ធ្ងន់ធ្ងរជាងទណ្ឌកម្មដែលមានចែងក្នុងប្រការ 11.2 សម្រាប់គោលបំណងនៃ*ព្រឹត្តិការណ៍*នោះ។[79] ដូចគ្នានេះដែរ ក្រោមសិទ្ធិសម្រេចរបស់ខ្លួន សហព័ន្ធកីឡាអន្តរជាតិអាចបង្កើតវិធានដែលដាក់ទណ្ឌកម្មធ្ងន់ធ្ងរសម្រាប់កីឡាជាក្រុមជាងទណ្ឌកម្មក្នុងប្រការ 11.2 ។

---

79 [សេចក្តីអធិប្បាយចំពោះប្រការ 11.3៖ ឧទាហរណ៍ គណៈកម្មាធិការអូឡាំពិកអន្តរជាតិអាចបង្កើតវិធានដែលនឹងតម្រូវឱ្យមានការដកសិទ្ធិក្រុមចេញពីការប្រកួតកីឡាអូឡាំពិក ដោយផ្អែកលើចំនួននៃការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ាក្នុងកំឡុងពេលប្រកួត។ ]

## ប្រការ12៖ ការដាក់ទណ្ឌកម្មដោយ*ស្ថាប័នហត្ថលេខី*លើស្ថាប័នកីឡាផ្សេងទៀត

*ស្ថាប័នហត្ថលេខី*នីមួយៗ ត្រូវប្រកាន់យកនូវវិធានដែលមានកាតព្វកិច្ចចំពោះអង្គភាពនីមួយៗរបស់ខ្លួន និងស្ថាប័នកីឡាដទៃទៀត ដែលខ្លួនមានសិទ្ធិអនុវត្តគាំទ្រ និងពង្រឹង*ក្រម*នេះ នៅក្នុងតំបន់ដែលមានសមត្ថភាពរបស់អង្គភាព ឬស្ថា ប័ននោះ។[80] នៅពេលដែល *ស្ថាប័នហត្ថលេខី* ដឹងថា អង្គការណាមួយរបស់ខ្លួន ឬស្ថាប័នកីឡាផ្សេងទៀត ដែលខ្លួនមានសិទ្ធិអំណាចមិនបានបំពេញកាតព្វកិច្ចនោះ *ស្ថាប័នហត្ថលេខី* ត្រូវចាត់វិធានការសមស្របចំពោះស្ថាប័ន ឬស្ថាប័ននោះ។ ជាពិសេស *សកម្មភាព និង ច្បាប់របស់ស្ថាប័នហត្ថលេខី* ត្រូវរួមបញ្ចូលលទ្ធភាពនៃការមិនរាប់បញ្ចូលសមាជិកក្រុម ឬស្ថាប័នណាមួយពី *ព្រឹត្តិការណ៍* នាពេលអនាគត ឬ *ព្រឹត្តិការណ៍* ទាំងអស់ដែលបានធ្វើឡើងក្នុងរយៈពេលដាក់លាក់ណាមួយ។[81]

## ប្រការ 13៖ *ការដោះស្រាយវិវាទដូប៉ា*៖ បណ្តឹងជំទាស់[82]

### 13.1 *ការដោះស្រាយវិវាទដូប៉ា* ៖ ប្តឹងជំទាស់

សេចក្តីសម្រេចដែលធ្វើឡើងក្រោម*ក្រម* ឬវិធានប្រឆាំងដូប៉ាអាចត្រូវបានប្តឹងជំទាស់ ដូចមានចែងក្នុងប្រការ 13.2 ដល់ប្រការ 13.4 ឬត្រូវបានកំណត់ក្នុងវិធានប្រឆាំងដូប៉ា ក្នុង*ក្រម* ឬក្នុង*ស្តង់ដារអន្តរជាតិ*។ សេចក្តីសម្រេចបែបនេះនឹងនៅតែមានសុពលភាព ទោះបីក្នុងអំឡុងពេលនៃបណ្តឹងជំទាស់ក៏ដោយ លើកលែងតែស្ថាប័នបណ្តឹងជំទាស់សម្រេចផ្សេងពីនេះ។

#### 13.1.1 វិសាលភាពនៃការពិនិត្យឡើងវិញមិនមានដែនកំណត់

វិសាលភាពនៃការពិនិត្យលើបណ្តឹងជំទាស់ រួមបញ្ចូលបញ្ហាទាំងអស់ដែលទាក់ទងនឹងករណីនោះ ហើយត្រូវបានបង្ហាញយ៉ាងច្បាប់ថា មិនកំណត់ចំពោះតែបញ្ហា ឬវិសាលភាពនៃការពិនិត្យឡើងវិញមុនការផ្តល់សេចក្តីសម្រេចដំបូងឡើយ។ ភាគីណាមួយនៅក្នុងបណ្តឹងជំទាស់អាចដាក់ភស្តុតាងអំណះអំណាងច្បាប់ និងបណ្តឹងទាមទារសំណង ដែលមិនមាននៅក្នុងសវនាការបឋមបាន ដរាបណាវាកើតចេញពីមូលហេតុដូចគ្នានៃសកម្មភាព ឬអង្គហេតុ ឬកាលៈទេសៈទូទៅដូចគ្នា ដែលត្រូវបានលើកឡើង ឬដោះស្រាយនៅ

---

80 [សេចក្តីអធិប្បាយចំពោះប្រការ 12៖ ប្រការនេះមិនមានបំណងកំណត់កាតព្វកិច្ចផ្លូវច្បាប់ឱ្យស្ថាប័នហត្ថលេខីត្រួតពិនិត្យដោយសកម្មលើស្ថាប័នសមាជិកនីមួយៗរបស់ខ្លួន ចំពោះទង្វើមិនអនុលោមតាមក្រមនោះទេ ប៉ុន្តែគ្រាន់តែទាមទារឱ្យស្ថាប័នហត្ថលេខីធ្វើសកម្មភាពនៅពេលដែលខ្លួនដឹងថាមានទង្វើបែបនោះ។ ]

81 [សេចក្តីអធិប្បាយចំពោះប្រការ 12៖ ប្រការនេះបញ្ជាក់យ៉ាងច្បាស់ថា ក្រមនេះមិនដាក់កំហិតលើសិទ្ធិដាក់វិន័យណាមួយរវាងស្ថាបន័ និងស្ថាប័នឡើយ។ ចំពោះការដាក់ទណ្ឌកម្មលើស្ថាប័នហត្ថលេខី ចំពោះការមិនអនុលោមតាមក្រម សូមមើលប្រការ 24.1 ]

82 [សេចក្តីអធិប្បាយចំពោះប្រការ 13៖ គោលបំណងនៃក្រមនេះគឺដើម្បីដោះស្រាយបញ្ហាវំលោភវិធានប្រឆាំង*ដូប៉ា* តាមរយៈដំណើរការផ្ទៃក្នុងប្រកបដោយយុត្តិធម៌ និងតម្លាភាព ដោយប្រើបណ្តឹងឧទ្ធរណ៍ចុងក្រោយ។ សេចក្តីសម្រេចករណីប្រើប្រាស់សារធាតុដូប៉ាដោយ*អង្គការប្រឆាំងដូប៉ា*ត្រូវបានធ្វើឱ្យមានតម្លាភាពនៅក្នុងប្រការ 14 ។ បុគ្គល និងស្ថាប័នដែលត្រូវបានបញ្ជាក់ រួមទាំងទីភ្នាក់ងារប្រឆាំង*ដូប៉ា*ពិភពលោកត្រូវបានផ្តល់ឱកាសដើម្បីប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចទាំងនោះ។ សូមកត់សម្គាល់ថា និយមន័យនៃបុគ្គល និងស្ថាប័នដែលមានអត្ថប្រយោជន៍ ដែលមានសិទ្ធិប្តឹងឧទ្ធរណ៍តាមប្រការ 13 មិនរាប់បញ្ចូលអត្តពលិក ឬសហព័ន្ធជាតិរបស់ពួកគេ ដែលអាចទទួលបានអត្ថប្រយោជន៍ពីការការដកសិទ្ធិអត្តពលិកផ្សេងទៀតពីការប្រកួតនោះទេ។ ]

ក្នុងសវនាការបឋម។[83]

13.1.2 *មជ្ឈត្តកម្មកីឡា* មិនត្រូវរង់ចាំលទ្ធផលបណ្តឹងជំទាស់ដែលកំពុងដំណើរការឡើយ

ក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន *មជ្ឈត្តកម្មកីឡា* មិនត្រូវរង់ចាំសេចក្តីសម្រេច ដែលនឹងអនុវត្តដោយស្ថាប័នដែលសេចក្តីសម្រេចរបស់ខ្លួនកំពុងត្រូវបានប្តឹងជំទាស់ឡើយ។[84]

13.1.3 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*មិនចាំបាច់ខិតខំស្វែងរកគ្រប់ដំណោះស្រាយផ្ទៃក្នុងរបស់ខ្លួនទេ[85]

ក្នុងករណីដែល *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*មានសិទ្ធិប្តឹងជំទាស់តាមប្រការ 13 ហើយគ្មានភាគីណាមួយបានប្តឹងជំទាស់នឹងសេចក្តីសម្រេចចុងក្រោយនៅក្នុងដំណើរការរបស់*អង្គការប្រឆាំងដូប៉ា*ទេនោះ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចប្តឹងជំទាស់ចំពោះសេចក្តីសម្រេចបែបនេះដោយផ្ទាល់ទៅ*មជ្ឈតកម្មកីឡា* ដោយមិនចាំបាច់ប្រើគ្រប់លទ្ធភាពនៃដំណោះស្រាយផ្សេងទៀតនៅក្នុងដំណើរការរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាទេ។

83 [សេចក្តីអធិប្បាយចំពោះប្រការ 13.1.1 ៖ ខ្លឹមសារដែលត្រូវបានកែសម្រួលនេះមិនមានបំណងធ្វើឱ្យមានការផ្លាស់ប្តូរធំដុំចំពោះក្រម ឆ្នាំ 2015 ទេ ប៉ុន្តែវាជាការបញ្ជាក់ឱ្យច្បាស់។ ឧទាហរណ៍៖ ក្នុងករណីដែលអត្តពលិកម្នាក់ត្រូវបានចោទប្រកាន់ក្នុងសវនាការលើកដំបូង តែពីបទធ្វើឱ្យខូចដំណើរការប៉ុណ្ណោះ ប៉ុន្តែការប្រព្រឹត្តដូចគ្នានោះអាចបង្កើតបានជាបទសមគំនិត ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍អាចប្តឹងទាំងពីបទធ្វើឱ្យខូចដំណើរការ និងបទសមគំនិតប្រឆាំងអត្តពលិកនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ]

84 [សេចក្តីអធិប្បាយចំពោះប្រការ 13.1.2៖ ដំណើរការរបស់មជ្ឈតកម្មកីឡាគឺត្រូវចាប់ផ្តើមឡើងវិញ។ ដំណើរការនីតិវិធីមុនៗមិនកំហិតស្គុតាង ឬមានទម្ងន់នៅក្នុងសវនាការនៅចំពោះមុខមជ្ឈតកម្មកីឡាឡើយ។ ]

85 [សេចក្តីអធិប្បាយចំពោះប្រការ 13.1.3៖ ក្នុងករណីដែលសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងមុនដំណាក់កាលចុងក្រោយនៃដំណើរការរបស់*អង្គការប្រឆាំង*ការប្រើប្រាស់សារធាតុដូប៉ា (ឧទាហរណ៍៖ សវនាការលើកដំបូង) ហើយគ្មានភាគីណាមួយជ្រើសរើសប្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចនោះទៅកម្រិតបន្ទាប់នៃដំណើរការរបស់ស្ថាប័នប្រឆាំងការប្រើប្រាស់ សារធាតុដូប៉ា (ឧទាហរណ៍៖ គណកម្មាការគ្រប់គ្រង) នោះទីភ្នាក់ងារប្រឆាំង*ដូប៉ា*ពិភពលោកអាចរំលងជំហានដែលនៅសល់នៅក្នុងដំណើរការផ្ទៃក្នុងរបស់ស្ថាប័នប្រឆាំង*ដូប៉ា* ហើយប្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅមជ្ឈតកម្មកីឡា ។ ]

## 13.2 ការប្តឹងជំទាស់សេចក្តីសម្រេចទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា *ផលវិបាក ការព្យួរសិទ្ធិបណ្តោះអាសន្ន* ការអនុវត្តសេចក្តីសម្រេច និងសិទ្ធិអំណាច

សេចក្តីសម្រេចថា តើមានការបំពានវិធានប្រឆាំងដូប៉ា សេចក្តីសម្រេចក្នុងការដាក់*ផលវិបាក* ឬការមិនដាក់*ផលវិបាក* សម្រាប់ការបំពានវិធានប្រឆាំងដូប៉ា ឬសេចក្តីសម្រេចថាមិនមានការវិធានប្រឆាំងដូប៉ា សេចក្តីសម្រេចថានីតិវិធីស្តីពីការបំពានវិធានប្រឆាំងដូប៉ាមិនអាចបន្តទៅមុខបានតាមហេតុផលនីតិវិធី (រួមទាំង ឧទាហរណ៍ ដោយសារវេជ្ជបញ្ជា) សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* មិនឱ្យលើកលែងលក្ខខណ្ឌតម្រូវក្នុងការជូនដំណឹងរយៈពេល 6(ប្រាំមួយ)ខែ សម្រាប់ឱ្យ*អត្តពលិក*ចូលនិវត្តន៍ត្រឡប់ទៅចូលរួមការប្រកួតវិញ ដូចមានចែងក្នុងប្រការ 5.6.1 សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដែលចាត់តាំងលើ*ការដោះស្រាយវិវាទដូប៉ា* តាមប្រការ 7.1 នៃក្រម សេចក្តីសម្រេចដោយ*អង្គការប្រឆាំងដូប៉ា*ក្នុងការមិនលើកយក*លទ្ធផលវិភាគវិជ្ជមាន* ឬ*លទ្ធផលមិនធម្មតា*ថាជាមូលដ្ឋាននៃការបំពានវិធានប្រឆាំងដូប៉ា ឬសេចក្តីសម្រេចមិនបន្តនីតិវិធីស្តីពីការបំពានវិធានប្រឆាំងដូប៉ា បន្ទាប់ពីការស៊ើបអង្កេតស្របតាម*ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា* សេចក្តីសម្រេចក្នុងការដាក់ ឬដក*ការព្យួរសិទ្ធិបណ្តោះអាសន្ន* ដែលជាលទ្ធផលនៃ*សវនាការបណ្តោះអាសន្ន* ការខកខានរបស់ស្ថាប័នប្រឆាំងដូប៉ា ក្នុងការអនុលោមតាម ប្រការ 7.4 សេចក្តីសម្រេចដែលថា*អង្គការប្រឆាំងដូប៉ា* មិនមានសិទ្ធិអំណាចក្នុងការសម្រេចថាតើមាន ឬមិនមានការបំពានវិធានប្រឆាំងដូប៉ា ឬទណ្ឌកម្មនៃការបំពាននោះ សេចក្តីសម្រេចព្យួរ ឬមិនព្យួរសិទ្ធិ ផលវិបាក ឬសេចក្តីសម្រេចផ្តល់សិទ្ធិ មិនផ្តល់សិទ្ធិឡើងវិញ ផលវិបាកដែលមានចែងក្នុងប្រការ 10.7.1 ការមិនអនុលោមតាមប្រការ 7.1.4 និង ប្រការ 7.1.5 នៃ*ក្រម* ការមិនអនុលោមតាម ប្រការ 10.8.1 សេចក្តីសម្រេចក្រោមប្រការ 10.14.3 សេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាមិនឱ្យអនុវត្តសេចក្តីសម្រេច របស់*អង្គការប្រឆាំងដូប៉ា*ផ្សេងទៀត ក្រោមប្រការ 15 និងសេចក្តីសម្រេចក្រោមប្រការ 27.3 នៃ*ក្រម*នេះអាចត្រូវបានប្តឹងជំទាស់ទាំងស្រុង ដូចមានចែងក្នុងប្រការ 13.2 នេះ។

### 13.2.1 ការប្តឹងជំទាស់ដែលពាក់ព័ន្ធនឹង*អត្តពលិកកម្រិតអន្តរជាតិ* ឬ*ព្រឹត្តិការណ៍កីឡាអន្តរជាតិ*

ក្នុងករណីដែលកើតឡើងពីការចូលរួមក្នុង*ព្រឹត្តិការណ៍កីឡាអន្តរជាតិ* ឬក្នុងករណីពាក់ព័ន្ធនឹង*អត្តពលិកកម្រិតអន្តរជាតិ* សេចក្តីសម្រេចអាចត្រូវបានប្តឹងជំទាស់ទាំងស្រុងទៅ*មជ្ឈត្តកម្មកីឡា*។[86]

### 13.2.2 ការប្តឹងជំទាស់ដែលពាក់ព័ន្ធនឹង*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត

ក្នុងករណីដែលប្រការ 13.2.1 មិនអាចអនុវត្តបាន សេចក្តីសម្រេចអាចត្រូវបានប្តឹងជំទាស់ទៅក្រុមប្រឹក្សាបណ្តឹងជំទាស់អនុលោមតាមវិធានដែលបង្កើតឡើងដោយ*អង្គការប្រឆាំងដូប៉ា*។ ដំណើរការបណ្តឹងជំទាស់ទាក់ទងនឹងគោលការណ៍ណែនាំដូចខាងក្រោម៖

- សវនាការទាន់ពេលវេលា
- ដែលត្រឹមត្រូវ មិនលម្អៀង និងការប្រតិបត្តិការឯករាជ្យ និងក្រុមប្រឹក្សាជំនុំជម្រះឯករាជ្យ

86 [សេចក្តីអធិប្បាយចំពោះប្រការ 13.2.1៖ សេចក្តីសម្រេចរបស់មជ្ឈត្តកម្មកីឡាគឺជាសេចក្តីសម្រេចចុងក្រោយ និងចងកាតព្វកិច្ច លើកលែងតែការពិនិត្យឡើងវិញដែលច្បាប់តម្រូវឱ្យអនុវត្តចំពោះការលុបចោល ឬការអនុវត្តន៍ដីការអាជ្ញាកណ្តាល។ ]

- សិទ្ធិត្រូវបានតំណាងដោយការប្រឹក្សាដោយចំណាយផ្ទាល់ខ្លួនរបស់*បុគ្គល* និង
- សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងមានហេតុផលទាន់ពេលវេលា

ប្រសិនបើគ្មានស្ថាប័នដូចបានរៀបរាប់ខាងលើនៅនឹងកន្លែងទេ ហើយអាចរកបាននៅពេលប្តឹងជំទាស់ *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀត មានសិទ្ធិប្តឹងជំទាស់ទៅ*មជ្ឈត្តកម្មកីឡា*។

13.2.3 *បុគ្គល*ដែលមានសិទ្ធិប្តឹងជំទាស់

13.2.3.1 ការប្តឹងជំទាស់ដែលពាក់ព័ន្ធនឹង *អត្តពលិកកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍កីឡាអន្តរជាតិ*

ក្នុងករណីដូចមានចែងក្នុងប្រការ 13.2.1 ភាគីដូចខាងក្រោមមានសិទ្ធិប្តឹងជំទាស់ទៅ*មជ្ឈត្តកម្មកីឡា*៖

(ក) *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចដែលកំពុងត្រូវបានប្តឹងជំទាស់។

(ខ) ភាគីផ្សេងទៀតក្នុងរឿងក្តី ដែលត្រូវអនុវត្តសេចក្តីសម្រេចនោះ។

(គ) សហព័ន្ធកីឡាអន្តរជាតិពាក់ព័ន្ធ។

(ឃ) *អង្គការជាតិប្រឆាំងដូប៉ា* និង (បើផ្សេងពី) អង្គការប្រឆាំងដូប៉ាជាតិនៃប្រទេស បុគ្គលនោះរស់នៅ ឬប្រទេសដែលផ្តល់សញ្ជាតិ ឬអាជ្ញាប័ណ្ណកីឡាដល់បុគ្គលនោះ។

(ង) គណៈកម្មាធិការអូឡាំពិកអន្តរជាតិ ឬគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ តាមករណីដែលអាចអនុវត្តបាន ដែលសេចក្តីសម្រេចអាចមានឥទ្ធិពលទាក់ទងនឹងកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក ដែលរួមបញ្ចូលទាំងសេចក្តីសម្រេចដែលមានឥទ្ធិពលលើសិទ្ធិចូលរួមកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក។

(ច) *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។

13.2.3.2 ការប្តឹងជំទាស់ដែលពាក់ព័ន្ធនឹង*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត

ក្នុងករណី ដូចមានចែងក្នុងប្រការ 13.2.2 ភាគីដែលមានសិទ្ធិប្តឹងជំទាស់ទៅស្ថាប័នជំទាន់ដូចដែលមានចែងក្នុងវិធានរបស់*អង្គការជាតិប្រឆាំងកដូប៉ា* ប៉ុន្តែយ៉ាងហោចណាស់ត្រូវរួមបញ្ចូលភាគីដូចខាងក្រោម៖

(ក) *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចដែលកំពុងត្រូវបានប្តឹងជំទាស់។

(ខ) ភាគីផ្សេងទៀតក្នុងរឿងក្តី ដែលត្រូវអនុវត្តសេចក្តីសម្រេចនោះ។

(គ) សហព័ន្ធកីឡាអន្តរជាតិពាក់ព័ន្ធ

(ឃ) *អង្គការជាតិប្រឆាំងដូប៉ា* និង (បើផ្សេងពី) អង្គការជាតិប្រឆាំងដូប៉ានៃប្រទេសដែល *បុគ្គល*នោះរស់នៅ ឬប្រទេសដែលផ្តល់សញ្ញាតិ ឬអាជ្ញាប័ណ្ណកីឡាដល់បុគ្គលនោះ។

(ង) គណៈកម្មាធិការអូឡាំពិកអន្តរជាតិ ឬគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ តាមករណីដែលអាចអនុវត្តបាន ដែលសេចក្តីសម្រេចអាចមានឥទ្ធិពលទាក់ទងនឹងកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក ដែលរួមបញ្ចូលទាំងសេចក្តីសម្រេចដែលមានឥទ្ធិពលលើសិទ្ធិចូលរួមកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក និង

(ច) *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ ចំពោះករណីដែលមានចែងក្នុងប្រការ 13.2.2 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* គណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកអន្តរជាតិ និងសហព័ន្ធកីឡាអន្តរជាតិដែលពាក់ព័ន្ធក៏មានសិទ្ធិប្តឹងជំទាស់ទៅ*មជ្ឈតកម្មកីឡា* ដោយគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងជំទាស់។ ភាគីដែលដាក់ពាក្យបណ្តឹងជំទាស់នឹងមានសិទ្ធិទទួលបានជំនួយពី *មជ្ឈតកម្មកីឡា* ដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធទាំងអស់ពី *អង្គការប្រឆាំងដូប៉ា* ដែលសេចក្តីសម្រេចរបស់ខ្លួនកំពុងត្រូវបានប្តឹងជំទាស់ ហើយព័ត៌មាននឹងត្រូវផ្តល់ជូនប្រសិនបើ*មជ្ឈត្តកម្មកីឡា*កំណត់ដូច្នោះ។

13.2.3.3 ភាកិច្ចក្នុងការជូនដំណឹង

គ្រប់ភាគីនៃបណ្តឹងជំទាស់របស់*មជ្ឈតកម្មកីឡា*ត្រូវធានាថា *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* និងភាគីដទៃទៀតដែលមានសិទ្ធិប្តឹងជំទាស់ ត្រូវបានផ្តល់សេចក្តីជូនដំណឹងអំពីបណ្តឹងជំទាស់ឱ្យបានទាន់ពេលវេលា។

13.2.3.4 ថ្ងៃផុតកំណត់សម្រាប់ភាគីផ្សេងទៀតបណ្តឹងក្រៅពី*ភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*

ថ្ងៃផុតកំណត់ប្តឹងជំទាស់សម្រាប់ភាគីផ្សេងទៀត ក្រៅពី *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* បានផ្តល់នៅក្នុងវិធាននៃ*អង្គការប្រឆាំងដូប៉ា*ធ្វើ*ការដោះស្រាយវិវាទដូប៉ា*។

13.2.3.5 បណ្តឹងជំទាស់សម្រាប់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*

ទោះយ៉ាងណាក៏ដោយ ថ្ងៃផុតកំណត់នៃការដាក់បណ្តឹងជំទាស់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងត្រូវធ្វើឡើងនៅកាលបរិច្ឆេទ៖

(ក) ម្ភៃមួយ (21) ថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលភាគីផ្សេងទៀតដែលមានសិទ្ធិប្តឹងជំទាស់អាចប្តឹងជំទាស់ ឬ

(ខ) ម្ភៃមួយ (21) ថ្ងៃបន្ទាប់ពីទទួលបានឯកសារពេញលេញដែលទាក់ទងនឹងសេចក្តី

សម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ។[87]

13.2.3.6 ការប្តឹងជំទាស់ពីការអនុវត្ត*ការល្បួសិទ្ធិបណ្តោះអាសន្ន*

ទោះបីជាមានបទប្បញ្ញត្តិផ្សេងៗនៅក្នុងវិធាននេះក៏ដោយ បុគ្គលតែម្នាក់គត់ដែលអាចប្តឹងជំទាស់នឹងការដាក់ទណ្ឌកម្មដោយ*ការព្យួរសិទ្ធិបណ្តោះអាសន្ន* គឺ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលត្រូវអនុវត្ត*ការព្យួរបណ្តោះអាសន្ន*នោះ។

13.2.4 ការប្តឹងជំទាស់ទៅវិញទៅមក និងការប្តឹងជំទាស់ជាបន្តបន្ទាប់ផ្សេងទៀតត្រូវបានអនុញ្ញាត[88]

ការប្តឹងជំទាស់ទៅវិញទៅមក និងប្តឹងជំទាស់បន្តបន្ទាប់ផ្សេងទៀតដោយចុងចម្លើយណាម្នាក់ ដែលមានឈ្មោះនៅក្នុងរឿងក្តីដែលត្រូវបានបញ្ជូនទៅ មជ្ឈតកម្មកីឡា ក្រោមក្រមនេះ ត្រូវបានអនុញ្ញាតជាពិសេស។ ភាគីណាមួយដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ 13 នេះ ត្រូវដាក់ពាក្យប្តឹងជំទាស់ទៅវិញទៅមក ឬបណ្តឹងជំទាស់ជាបន្តបន្ទាប់ យ៉ាងយូរបំផុតជាមួយចម្លើយរបស់ភាគី។

## 13.3. ការខកខានក្នុងការផ្តល់សេចក្តីសម្រេចឱ្យបានទាន់ពេលវេលាដោយ*អង្គការប្រឆាំងដូប៉ា*[89]

ក្នុងករណីជាក់លាក់ ប្រសិនបើ*អង្គការប្រឆាំងដូប៉ា*ខកខានមិនបានធ្វើសេចក្តីសម្រេចទាក់ ទងនឹងថាតើមាន ឬមិនមានការបំពានវិធានប្រឆាំងដូប៉ា ក្នុងពេលវេលាកំណត់សមរម្យដែលកំណត់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*នោះ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចសម្រេចប្តឹងជំទាស់ដោយផ្ទាល់ទៅ *មជ្ឈត្តកម្មកីឡា* ដូចជាក្នុងករណីដែល*អង្គការប្រឆាំងដូប៉ា*ធ្វើសេចក្តីសម្រេចដោយរកថាមិនមានការបំពានវិធានប្រឆាំងដូប៉ានោះ។ ប្រសិនបើ ក្រុមប្រឹក្សាជំនុំជម្រះរបស់*មជ្ឈតកម្មកីឡា* កំណត់ថាមានការបំពានវិធានប្រឆាំងដូប៉ា ហើយកំណត់ថា *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* បានអនុវត្តសមហេតុផលក្នុងការសម្រេចប្តឹងជំទាស់ដោយផ្ទាល់ទៅ *មជ្ឈតកម្មកីឡា* នោះការចំណាយ និងថ្លៃមេធាវីរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក្នុងការប្តឹងជំទាស់នោះ នឹងត្រូវទូទាត់សងទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*វិញដោយអង្គការប្រឆាំងដូប៉ា។

## 13.4. ការប្តឹងជំទាស់ទាក់ទងនឹង*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល*

សេក្តីសម្រេចលើ*ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* អាចត្រូវបានប្តឹងជំទាស់តែក្នុងករណី ដូចមានចែងក្នុង

---

87 [សេចក្តីអធិប្បាយចំពោះប្រការ 13.2.3: ទោះបីត្រូវគ្រប់គ្រងដោយវិធានមជ្ឈតកម្មកីឡា ឬប្រការ 13.2.3 ក៏ដោយ កាលបរិច្ឆេទផុតកំណត់របស់ភាគីមួយក្នុងការប្តឹងឧទ្ធរណ៍ មិនត្រូវបានចាប់ផ្តើមទេ រហូតទាល់តែទទួលបានសេចក្តីសម្រេចនោះ។ ដោយហេតុផលនោះ មិនអាចការផុតកំណត់នៃសិទ្ធិប្តឹងឧទ្ធរណ៍របស់ភាគីទេ ប្រសិនបើភាគីនោះមិនទាន់បានទទួលសេចក្តីសម្រេច។ ]

88 [សេចក្តីអធិប្បាយចំពោះប្រការ 13.2.4៖ បទប្បញ្ញត្តិនេះគឺចាំបាច់ ព្រោះចាប់តាំងពីឆ្នាំ 2011 វិធានមជ្ឈតកម្មកីឡាលែងអនុញ្ញាតឱ្យអត្តពលិកមានសិទ្ធិប្តឹងឧទ្ធរណ៍ទាស់ ក្នុងករណី*អង្គការប្រឆាំងដូប៉ា*ប្តឹងឧទ្ធរណ៍សេចក្តីសម្រេចមួយ បន្ទាប់ពីរយៈពេលសម្រាប់អត្តពលិកប្តឹងឧទ្ធរណ៍បានផុតកំណត់។ បទប្បញ្ញត្តិនេះអនុញ្ញាតឱ្យមានសវនាការពេញលេញសម្រាប់គ្រប់ភាគី។ ]

89 [សេចក្តីអធិប្បាយចំពោះប្រការ 13.3 ៖ ដោយសារកាលៈទេសៈខុសៗគ្នានៃការស៊ើបអង្កេតលើករណី*បំពាន*លើវិធានប្រឆាំង*ដូប៉ា* និងដំណើរការគ្រប់គ្រងលទ្ធផលតេស្តនីមួយៗ វាមិនអាចធ្វើទៅបានទេក្នុងការកំណត់រយៈពេលច្បាស់លាស់មួយ សម្រាប់ឱ្យ*អង្គការប្រឆាំងដូប៉ា*ផ្តល់សម្រេចមួយ មុនពេលទីភ្នាក់ងារប្រឆាំង*ដូប៉ា*ពិភពលោកអាចធ្វើអន្តរាគមន៍ដោយប្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅមជ្ឈតកម្មកីឡា។ ទោះយ៉ាងណា មុនចាត់វិធានការបែបនោះ ទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោកនឹងពិគ្រោះយោបល់ជាមួយ*អង្គការប្រឆាំងដូប៉ា* ហើយផ្តល់ឱកាសឱ្យ*អង្គការប្រឆាំងដូប៉ា*ពន្យល់ពីមូលហេតុដែលខ្លួនមិនទាន់ផ្តល់សេចក្តីសម្រេចនោះ។ គ្មានអ្វីនៅក្នុងប្រការនេះហាមឃាត់សហព័ន្ធអន្តរជាតិមិនឱ្យមានច្បាប់ដែលអនុញ្ញាតឱ្យខ្លួនទទួលសិទ្ធិអំណាចចំពោះបញ្ហា ដែលការគ្រប់គ្រងលទ្ធផលតេស្តដែលអនុវត្តដោយសហព័ន្ធជាតិមួយរបស់ខ្លួន ត្រូវបានពន្យារពេលដោយមិនសមស្របនោះទេ។ ]

ប្រការ 4.4 ប៉ុណ្ណោះ។

### 13.5. ការជូនដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងជំទាស់

អង្គការប្រឆាំងដូប៉ាត្រូវផ្តល់សេចក្តីសម្រេចលើបណ្តឹងជំទាស់ភ្លាមៗទៅ *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀត និង*អង្គការប្រឆាំងដូប៉ា*ផ្សេងទៀត ដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ 13.2.3 ដូចមានចែងក្នុងប្រការ 14 ។

### 13.6. ការប្តឹងជំទាស់សេចក្តីសម្រេចតាមប្រការ 24.1

សេចក្តីជូនដំណឹងដែលមិនមានជម្លោះហើយដូច្នេះក្លាយជាការសម្រេចចុងក្រោយនៅក្រោម ប្រការ 24.1 ដោយចំពោះការមិនអនុវត្តតាម*ក្រម*ក៏ដូចជាលក្ខខណ្ឌសម្រាប់ការ ចូលជាធរមាន នៃ*ស្ថាប័នហត្ថលេខី* អាចត្រូវបានប្តឹងជំទាស់ទៅ*មជ្ឈត្តកម្មកីឡា* ដែលមានចែងនៅក្នុង *ស្តង់ដាអន្តរជាតិ* សម្រាប់ការអនុលោមតាម *ក្រម* ដោយ*ស្ថាប័នហត្ថលេខី*។

### 13.7. បណ្តឹងជំទាស់ពីសេចក្តីសម្រេចផ្អាក ឬដកហូតការទទួលស្គាល់គុណភាពពិសោធន៍

សេចក្តីសម្រេចរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក្នុងការព្យួរ ឬដកហូតការ ទទួលស្គាល់គុណភាព *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* របស់មន្ទីរពិសោធន៍អាចត្រូវបានប្តឹងជំទាស់តែដោយមន្ទីរពិសោធន៍នោះប៉ុណ្ណោះជាមួយនឹងការប្តឹងជំទាស់ចំពោះ *មជ្ឈត្តកម្មកីឡា*។

## ប្រការ 14៖ ការរក្សាការសម្ងាត់ និងការរាយការណ៍

គោលការណ៍នៃការសម្របសម្រួលលទ្ធផលប្រឆាំងដូប៉ាតម្លាភាពសាធារណៈ និងគណនេយ្យភាព និងការគោរពឯកជនភាពរបស់ *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀតមានដូចខាងក្រោម៖

### 14.1 ព័ត៌មានទាក់ទងនឹងលទ្ធផលវិភាគវិជ្ជមាន លទ្ធផលមិនធម្មតា និងការបំពានវិធានប្រឆាំងការប្រើសារធាតុដូប៉ាដែលបានបញ្ជាក់ផ្សេងទៀត

14.1.1 ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាដល់*អត្តពលិក* និង *បុគ្គល*ដទៃទៀត

ទម្រង់បែបបទ និងលក្ខណៈនៃការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ដែលមានចែងនៅក្នុងវិធានរបស់*អង្គការប្រឆាំងដូប៉ា*ដែល មានការទទួលខុសត្រូវ*ការដោះស្រាយវិវាទដូប៉ា*។

14.1.2 ការជូនដំណឹងពីការបំពានវិធានប្រឆាំងដូប៉ាទៅ*អង្គការជាតិប្រឆាំងដូប៉ា* សហព័ន្ធកីឡាអន្តរជាតិ និង *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*

*អង្គការប្រឆាំងដូប៉ា*ដែលមានការទទួលខុសត្រូវ*ការដោះស្រាយវិវាទដូប៉ា* ការជូនដំណឹងក៏ត្រូវជូនដំណឹងដល់*អង្គការជាតិប្រឆាំងដូប៉ា* សហព័ន្ធកីឡាអន្តរជាតិ និងអង្គការ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អំពីការអះអាងអំពីការបំពានវិធានប្រឆាំងដូប៉ា ក្នុងពេលដំណាលគ្នាជាមួយនឹងការជូនដំណឹងដល់*អត្តពលិក*

ឬ*បុគ្គល*ផ្សេងទៀត។

14.1.3 ខ្លឹមសារនៃការជូនដំណឹងស្តីពីការបំពានវិធានប្រឆាំងដូប៉ា

ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ារួមមាន៖ ឈ្មោះ*អត្តពលិក* ឬឈ្មោះបុគ្គលផ្សេងទៀត ប្រភេទកីឡា និងវិញ្ញាសានៅក្នុងកីឡា កម្រិតនៃភាពប្រកួតរបស់*អត្តពលិក* មិនថាជាការធ្វើតេស្ត*ក្នុងការប្រកួត* ឬ*ក្រៅការប្រកួត*ទ កាលបរិច្ឆេទនៃការប្រមូល*សំណាក* លទ្ធផលវិភាគដែលរាយការណ៍ដោយមន្ទីរពិសោធន៍ និងព័ត៌មានផ្សេងទៀតតាមតម្រូវការរបស់*ស្តង់ដារអន្តរជាតិ*ស្តីពីការ*ធ្វើតេស្ត* និងការស៊ើបអង្កេត ឬវិធានប្រឆាំងដូប៉ា ក្រៅពីប្រការ 2.1 ក៏ត្រូវរាប់បញ្ចូលទាំងវិធានដែលបានបំពាន និងមូលដ្ឋាននៃការបំពានដែលត្រូវបានចោទនោះផងដែរ។

14.1.4 របាយការណ៍ស្ថានភាព

លើកលែងតែទាក់ទងនឹងការស៊ើបអង្កេតដែលមិនបានបណ្តាលឱ្យមានការជូនដំណឹង អំពីការបំពានវិធានប្រឆាំងដូប៉ា តាមប្រការ 14.1.1 *អង្គការប្រឆាំងដូប៉ាពិភពលោក*យោងទៅលើប្រការ14.1.2 ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំលើស្ថានភាព និងលទ្ធផលការត្រួតពិនិត្យ ឬដំណើរការណាមួយដែលធ្វើឡើងស្របតាមប្រការ 7.8 ឬប្រការ 13 ហើយត្រូវផ្តល់ការព្យល់ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ហេតុផល និងធ្វើឡើងភ្លាមៗ ឬផ្តល់សេចក្តីសម្រេចដែលពន្យល់អំពីការដោះស្រាយចំពោះបញ្ហានោះ។

14.1.5 ការរក្សាការសម្ងាត់

ស្ថាប័នទទួលនឹងមិនត្រូវបង្ហាញព័ត៌មាននេះទៅបុគ្គលណាក្រៅតែពី បុគ្គលដែលត្រូវដឹង (ដែលរួមបញ្ចូលទាំងបុគ្គលិកសមស្របនៃគណៈកម្មាធិការជាតិអូឡាំពិក សហព័ន្ធកីឡាជាតិ និងក្រុមក្នុងកីឡាជាក្រុម) រហូតដល់*អង្គការប្រឆាំងដូប៉ា*បាន*ផ្សព្វផ្សាយជាសាធារណៈ* ដូចមានចែងក្នុងប្រការ 14.3 ។[90]

## 14.2 ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ឬការបំពានលើសេចក្តីសម្រេច*ព្យួរសិទ្ធិ* ឬសេចក្តីសម្រេច*ព្យួរសិទ្ធិបណ្តោះអាសន្ន* និងការស្នើសុំឯកសារ

14.2.1 សេចក្តីសម្រេចស្តីពីការបំពានវិធានប្រឆាំងដូប៉ា ដែលពាក់ព័ន្ធនឹងការបំពានការ*ព្យួរសិទ្ធិ* ឬ*ការព្យួរសិទ្ធិបណ្តោះអាសន្ន* ត្រូវបានអនុវត្តស្របតាមប្រការ 7.6 ប្រការ 8.4 ប្រការ 10.5 ប្រការ 10.6 ប្រការ 10.6 ប្រការ 10.7 ប្រការ 10.14.3 ឬប្រការ 13.5 ដោយរួមបញ្ចូល បើអាចអនុវត្តបាន នូវយុត្តិកម្មថាហេតុអ្វីមិនដាក់ទណ្ឌកម្មសក្តានុពលអតិបរមា។ ក្នុងករណីដែលសេចក្តីសម្រេចនោះមិនមែនជាភាសាអង់គ្លេស ឬបារាំង អង្គការប្រឆាំងដូប៉ាត្រូវផ្តល់សេចក្តីសង្ខេបជាភាសាអង់គ្លេស ឬបារាំងអំពីសេចក្តីសម្រេច និងហេតុផលគាំទ្រ។

14.2.2 *អង្គការប្រឆាំងដូប៉ា* មានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចដែលបានទទួល ដោយអនុលោមតាមប្រការ

---

90 [សេចក្តីអធិប្បាយចំពោះប្រការ 14.1.5៖ ក្រោមវិធានប្រឆាំង*ដូប៉ា*ផ្ទាល់របស់ខ្លួន *អង្គការប្រឆាំងដូប៉ា*នីមួយៗត្រូវផ្តល់នីតិវិធីសម្រាប់ការរក្សាព័ត៌មានសម្ងាត់ និងសម្រាប់ការស៊ើបអង្កេត និងការដាក់វិន័យលើការបង្ហាញព័ត៌មានសម្ងាត់មិនត្រឹមត្រូវដោយបុគ្គលិក ឬ*អង្គការប្រឆាំងដូប៉ា*។ ]

14.2.1 ក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃបន្ទាប់ពីបានទទួលសំណើសុំសំណុំឯកសារទាំងមូលដែលទាក់ទងនឹងសេចក្តីសម្រេចនោះ។

## 14.3 ការ*ផ្សព្វផ្សាយជាសាធារណៈ*

14.3.1 បន្ទាប់ពីផ្តល់ការជូនដំណឹងដល់ *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀតស្របតាម *ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា* និងទៅឱ្យ*អង្គការប្រឆាំងដូប៉ា* ដោយអនុលោមតាមប្រការ 14.1.2 ហើយអត្តសញ្ញាណរបស់*អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀត ដែលជាត្រូវបានជូនដំណឹងអំពីការបំពានលើវិធានប្រឆាំងដូប៉ា សារជាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ និងលក្ខណៈនៃការបំពានដែលពាក់ព័ន្ធ និងថាតើ *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀតនោះ ត្រូវទទួលរងការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ឬយ៉ាងណា អាចត្រូវបាន *ផ្សព្វផ្សាយជាសាធារណៈ* ដោយអង្គការប្រឆាំងដូប៉ាដែលមានតួនាទីទទួលខុសត្រូវក្នុងការ*ដោះស្រាយវិវាទដូប៉ា*។

14.3.2 មិនលើសពីម្ភៃ (20) ថ្ងៃ បន្ទាប់ពីត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់តាមប្រការ 13.2.1 ឬប្រការ 13.2.2 ឬប្រសិនបើបណ្តឹងជំទាស់នោះត្រូវបានលើកលែង ឬសវនាការ ដែលអនុលោមតាមប្រការ 8 ត្រូវបានលើកលែង ឬការចោទប្រកាន់អំពីការបំពានវិធានប្រឆាំងដូប៉ាមិនត្រូវបានគេជំទាស់ទេ ឬបញ្ហានេះត្រូវបានដោះស្រាយតាមប្រការ 10.8 ឬរយៈពេលថ្មីនៃការ*ព្យួរសិទ្ធិ* ឬការស្តីបន្ទោសត្រូវបានកំណត់ក្នុងប្រការ 10.14.3 *អង្គការប្រឆាំងដូប៉ា*ត្រូវ*ផ្សព្វផ្សាយជាសាធារណៈ*នូវការសម្រេចស្តីពីបញ្ហានៃការប្រើប្រាស់សារជាតុដូប៉ា រួមទាំងកីឡា វិធានប្រឆាំងដូប៉ាដែលត្រូវបានបំពាន ឈ្មោះ*អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀត ដែលបាន ប្រព្រឹត្តការបំពាន *សារជាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់*ដែលពាក់ព័ន្ធ (ប្រសិនបើមាន) និងទណ្ឌកម្មដែលត្រូវបានដាក់។ *អង្គការប្រឆាំងដូប៉ា*ដដែលនេះត្រូវ*ផ្សព្វផ្សាយជាសាធារណៈ* ក្នុងរយៈពេលម្ភៃ (20) ថ្ងៃក្រោយលទ្ធផលនៃសេចក្តីសម្រេច ដែលទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា រួមទាំងព័ត៌មានដែលបានពិពណ៌នាខាងលើ។[91]

14.3.3 ក្រោយការបំពានវិធានប្រឆាំងដូប៉ា ត្រូវបានកំណត់ថាបានប្រព្រឹត្តនៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់តាមប្រការ 13.2.1 ឬប្រការ 13.2.2 ឬបណ្តឹងជំទាស់ត្រូវបានលើកលែង ឬនៅក្នុងសវនាការ ស្របតាមប្រការ 8 ឬក្នុងករណីដែលសវនាការបែបនេះត្រូវបានលើកលែង ឬការអះអាងអំពីការបំពានលើវិធានប្រឆាំងដូប៉ាមិនត្រូវបានជំទាស់ទាន់ពេលវេលា ឬបញ្ហាត្រូវបានដោះស្រាយតាមប្រការ 10.8 *អង្គការប្រឆាំងដូប៉ា*ដែលទទួលខុសត្រូវក្នុង*ការដោះស្រាយវិវាទដូប៉ា* អាចធ្វើការកំណត់ ឬសម្រេចប្រកាសជាសាធារណៈ ហើយអាចធ្វើអត្ថាធិប្បាយលើបញ្ហានេះជាសាធារណៈបាន។

14.3.4 ក្នុងករណីណាក៏ដោយ ប្រសិនបើត្រូវបានកំណត់ បន្ទាប់ពីសវនាការ ឬបណ្តឹងជំទាស់ថា *អត្តពលិក* ឬ *បុគ្គល*ផ្សេងទៀត មិនបានប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាទេនោះ លទ្ធផលនៃបណ្តឹងជំទាស់ដែលបដិសេធសេចក្តីសម្រេចដំបូងនោះអាចត្រូវបាន*ផ្សព្វផ្សាយសាធារណៈ*។ ទោះយ៉ាងណាក៏ដោយ សេចក្តីសម្រេច និងអង្គហេតុសំខាន់ៗរបស់វានឹងមិនអាចត្រូវបាន*ផ្សព្វផ្សាយសាធារណៈ*ទេ លើកលែងតែមាន

91 [សេចក្តីអធិប្បាយចំពោះប្រការ 14.3.2៖ ក្នុងករណីដែលការបង្ហាញព័ត៌មានជាសាធារណៈ តាមលក្ខខណ្ឌតម្រូវដោយប្រការ 14.3.2 នឹងបណ្តាលឱ្យមានការរំលោភច្បាប់ជាធរមានផ្សេងទៀត ការខកខានរបស់*អង្គការប្រឆាំងដូប៉ា*ក្នុងការបង្ហាញព័ត៌មានជាសាធារណៈនោះ នឹងមិននាំឱ្យមានការកំណត់ថាជាការមិនអនុលោមតាមក្រមទេ ដូចមានចែងក្នុងប្រការ 4.2 នៃស្តង់ដារអន្តរជាតិសម្រាប់ការការពារឯកជនភាព និងព័ត៌មានផ្ទាល់ខ្លួន។ ]

ការយល់ព្រមពី*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចនោះ។ *អង្គការប្រឆាំងដូប៉ា* ត្រូវប្រើកិច្ចខិតខំប្រឹងប្រែងសមហេតុផលដើម្បីទទួលបានការព្រមព្រៀងបែបនេះ ហើយប្រសិនបើទទួល បានការព្រមព្រៀងហើយ ត្រូវ*ផ្សព្វផ្សាយជាសាធារណៈ* នូវសេចក្តីសម្រេចនេះទាំងស្រុង ឬក្នុងទម្រង់ ដែលត្រូវលុបផ្នែកខ្លះ តាមការយល់ព្រមរបស់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត។

14.3.5 ការបោះផ្សាយត្រូវធ្វើឡើងយ៉ាងតិចបំផុតដោយដាក់ព័ត៌មានចាំបាច់នៅលើគេហទំព័រ របស់*អង្គការប្រឆាំងដូប៉ា* ហើយត្រូវរក្សាទុកព័ត៌មាននេះឱ្យបានយ៉ាងតិចមួយ (01) ខែ ឬស្មើរយៈពេលនៃការ*ព្យួរសិទ្ធិ*។

14.3.6 លើកលែងដូចអ្វីដែលបានចែងក្នុងប្រការ 14.3.1 និង ប្រការ 14.3.3 អង្គការប្រឆាំងដូប៉ា សហព័ន្ធកីឡាជាតិ ឬមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ត្រីនៃស្ថាប័នបែបនោះ មិនត្រូវធ្វើអត្ថាធិប្បាយជាសាធារណៈលើអង្គហេតុជាក់លាក់នៃករណីដែលកំពុងដំណើរការ (ក្រៅពីការពិពណ៌នាទូទៅនៃដំណើរការ និងវិទ្យាសាស្ត្រ) លើកលែងតែការឆ្លើយតបទៅនឹងមតិសាធារណៈ ដែលត្រូវបានសន្មត ឬផ្អែកលើព័ត៌មានដែលផ្តល់ដោយ *អត្តពលិក* *បុគ្គល*ផ្សេងទៀត ឬអ្នកអមរបស់ពួកគេ ឬតំណាងផ្សេងទៀតតែប៉ុណ្ណោះ។

14.3.7 ការផ្សព្វផ្សាយជាសាធារណៈដូចដែលមានចែងក្នុងប្រការ 14.3.2 និងមិនចាំបាច់អនុវត្តទេ ក្នុងករណីដែល អត្តពលិក ឬ បុគ្គលផ្សេងទៀតដែលត្រូវបានគេរកឃើញថាបានបំពានវិធានប្រឆាំងដូប៉ា គឺជាអនីតិជន *បុគ្គលដែលត្រូវបានការពារ* ឬ*អត្តពលិកកម្សាន្ត* ។ រាល់ការ*ផ្សព្វផ្សាយជាសាធារណៈ*ដែលមិនមែនជាលក្ខខណ្ឌតម្រូវ ក្នុងករណីដែលពាក់ព័ន្ធនឹង អនីតិជន *បុគ្គលដែលត្រូវបានការពារ* ឬ*អត្តពលិកកម្សាន្ត* ត្រូវមានសមាមាត្រទៅនឹងអង្គហេតុ និងកាលៈទេសៈនៃករណីនោះ។

## 14.4 របាយការណ៍ស្ថិតិ

*អង្គការប្រឆាំងដូប៉ា* យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ ផ្សព្វផ្សាយរបាយការណ៍ស្ថិតិទូទៅអំពីសកម្មភាព*ត្រួតពិនិត្យដូប៉ា*របស់ខ្លួន ដោយមានផ្តល់ឯកសារនោះមួយច្បាប់ដល់*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ *អង្គការប្រឆាំងដូប៉ា* ក៏អាចផ្សព្វផ្សាយរបាយការណ៍ដែលបង្ហាញពីឈ្មោះ *អត្តពលិក*នីមួយៗដែលត្រូវបាន*ធ្វើតេស្ត* និងកាលបរិច្ឆេទនៃការ*ធ្វើតេស្ត*នីមួយៗផងដែរ។ យ៉ាងហោចណាស់រៀងរាល់ឆ្នាំ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវបោះពុម្ពផ្សាយរបាយការណ៍ស្ថិតិដែលសង្ខេបព័ត៌មានដែលខ្លួនទទួលបានពីអង្គការប្រឆាំងដូប៉ា និងមន្ទីរពិសោធន៍។

## 14.5 មូលដ្ឋានទិន្នន័យនៃការ*ត្រួតពិនិត្យដូប៉ា* និងការត្រួតពិនិត្យអនុលោមភាព

ដើម្បីឱ្យ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អនុវត្តតួនាទីត្រួតពិនិត្យអនុលោមភាពរបស់ខ្លួន និងដើម្បីធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃធនធាន និងការចែករំលែកព័ត៌មាននៃការ*ត្រួតពិនិត្យដូប៉ា*ក្នុងចំណោម *អង្គការប្រឆាំងដូប៉ា* *ទីភ្នាក់ងារប្រឆាំងដូប៉ា*ត្រូវរាយការណ៍ទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* តាមរយៈព័ត៌មានទាក់ទងនឹងការត្រួត*ពិនិត្យសារធាតុដូប៉ា*នៃ *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ជាពិសេស រួមទាំង៖

(ក) ទិន្នន័យ*ប្រវត្តិជីវសាស្ត្ររបស់អត្តពលិក*សម្រាប់*អត្តពលិកកម្រិតអន្តរជាតិ* និង *អត្តពលិក*កម្រិតជាតិ

(ខ) ព័ត៌មានអំពីទីសំចតរបស់អត្តពលិក រួមទាំងអ្នកដែលមានឈ្មោះនៅក្នុងបញ្ជី *ឈ្មោះធ្វើតេស្ត*

(គ) សេចក្តីសម្រេច *លើការលើកលែងឱ្យប្រើជាថ្នាំព្យាបាល* និង

(ឃ) សេចក្តីសម្រេចស្តីពី *ការការដោះស្រាយវិវាទដូប៉ា*

តេស្តតាមលក្ខខណ្ឌតម្រូវនៃ *ស្តង់ដារអន្តរជាតិ* ជាធរមាន។

14.5.1 ដើម្បីសហការរៀបចំផែនការបែងចែកការធ្វើតេស្តដែលមានការសម្របសម្រួល ជៀសវាងការធ្វើតេស្តស្ទួនមិនចាំបាច់ ដោយ *អង្គការប្រឆាំងដូប៉ា* នានា និងដើម្បីធានាថា *ប្រវត្តិជីវសាស្ត្រអត្តពលិក* ត្រូវបានធ្វើបច្ចុប្បន្នភាព *អង្គការប្រឆាំងដូប៉ា* ត្រូវរាយការណ៍រាល់ការធ្វើតេស្ត *ក្នុងការប្រកួត* និង *ក្រៅការប្រកួត* ទាំងអស់ទៅ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដោយបញ្ចូលទំរង់ *ត្រួតពិនិត្យដូប៉ា* ទៅក្នុង *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ដោយអនុលោមទៅតាមលក្ខខណ្ឌតម្រូវ និងពេលវេលា ដូចបានកំណត់នៅក្នុង *ស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត* និងការស៊ើបអង្កេត។

14.5.2 ដើម្បីសម្របសម្រួលការត្រួតពិនិត្យ និងសិទ្ធិបណ្តឹងជំទាស់របស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* សម្រាប់ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* *អង្គការប្រឆាំងដូប៉ា* នីមួយៗត្រូវរាយការណ៍អំពីពាក្យស្នើសុំសេចក្តីសម្រេច និងឯកសារគាំទ្រ *ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល* ទាំងអស់ ដោយប្រើប្រាស់ *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ដោយអនុលោមតាមលក្ខខណ្ឌតម្រូវ និងពេលវេលាដែលមានចែងនៅក្នុង *ស្តង់ដារអន្តរជាតិស្តីពី ការលើកលែងឱ្យការប្រើប្រាស់ថ្នាំព្យាបាល* ។

14.5.3 ដើម្បីសម្របសម្រួលការត្រួតពិនិត្យ និងសិទ្ធិប្តឹងជំទាស់របស់ *ទីភ្នាក់ងារដូប៉ាពិភពលោក* ស្តីពីការ *ដោះស្រាយវិវាទដូប៉ា* *អង្គការប្រឆាំងដូប៉ា* ត្រូវរាយការណ៍ព័ត៌មានដូចខាងក្រោមនៅក្នុង *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ស្របតាមលក្ខខណ្ឌតម្រូវ និងការកំណត់ពេលវេលា ដូចមានចែងក្នុង *ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា*៖

(ក) ការជូនដំណឹងស្តីពីការបំពានវិធានប្រឆាំងដូប៉ា និងសេចក្តីសម្រេចពាក់ព័ន្ធសម្រាប់ *លទ្ធផលវិភាគវិជ្ជមាន*

(ខ) ការជូនដំណឹង និងសេចក្តីសម្រេចពាក់ព័ន្ធចំពោះការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត ដែលមិនមែនជាលទ្ធផលវិភាគអវិជ្ជ មាន

(គ) ការខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចត

(ឃ) សេចក្តីសម្រេចណាមួយដែលដាក់ទណ្ឌកម្ម ឬផ្តល់សិទ្ធិឡើងវិញចំពោះការ *ព្យួរសិទ្ធិបណ្តោះអាសន្ន*។

14.5.4 ព័ត៌មានដូចមានចែងក្នុងប្រការនេះនឹងត្រូវបានផ្តល់ជូន នៅពេលដែលសមស្រប និងស្របតាមវិធានជាធរមានដល់ *អត្តពលិក* *អង្គការជាតិប្រឆាំងដូប៉ា* របស់ *អត្តពលិក* និង *សហព័ន្ធកីឡាអន្តរជាតិ* និង *អង្គការ*

*ប្រឆាំងដូប៉ា*ណាមួយផ្សេងទៀត ដែលមានសិទ្ធិ *ធ្វើតេស្តលើអត្តពលិក*។[92]

### 14.6 ភាពឯកជននៃទិន្នន័យ[93]

*អង្គការប្រឆាំងដូប៉ា*អាចប្រមូល រក្សាទុក ដំណើរការ ឬផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនទាក់ទងនឹង *អត្តពលិក* និង *បុគ្គល* ដទៃទៀត ក្នុងករណីចាំបាច់ និងសមស្រប ដើម្បីធ្វើសកម្មភាពប្រឆាំងដូប៉ារបស់ខ្លួនតាម*ក្រមស្តង់ដារអន្តរជាតិ* (រួមបញ្ចូលជាពិសេស *ស្តង់ដារអន្តរជាតិ*ស្តីពីការការពារភាពឯកជន និងព័ត៌មានផ្ទាល់ខ្លួន) វិធានប្រឆាំងដូប៉ា និងដោយអនុលោមតាមច្បាប់ជាធរមាន។

## ប្រការ 15៖ ការអនុវត្តសេចក្តីសម្រេច

### 15.1. ផលប៉ះពាល់នៃសេចក្តីសម្រេចដែលភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិរបស់*អង្គការប្រឆាំងដូប៉ា* ដែលជា*ស្ថាប័នហត្ថលេខី*

15.1.1 សេចក្តីសម្រេចស្តីពីការបំពានវិធានប្រឆាំងដូប៉ា ដែលធ្វើឡើងដោយ*ស្ថាប័នហត្ថលេខីប្រឆាំងដូប៉ា* ស្ថាប័នបណ្តឹងជំទាស់ (ប្រការ 13.2.2 នៃ*ក្រម*) ឬ*មជ្ឈត្តកម្មកីឡា* នឹងបន្ទាប់ពីភាគីនៃនីតិវិធីត្រូវបានជូនដំណឹង ត្រូវភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិ លើភាគីក្នុងដំណើរការនីតិវិធី ចំពោះរាល់*ស្ថាប័នហត្ថលេខី* នៃកីឡាទាំងអស់ ដោយមានផលដូចបានរៀបរាប់ខាងក្រោម៖

15.1.1.1 សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើ ដែលដាក់ទណ្ឌកម្ម*ព្យួរសិទ្ធិ*បណ្តោះអាសន្ន (បន្ទាប់ពី*សវនាការបណ្តោះអាសន្ន*ត្រូវបានធ្វើឡើង ឬ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតបានទទួលយកការ*ព្យួរសិទ្ធិបណ្តោះអាសន្ន* ឬបានលះបង់សិទ្ធិទទួលបាន*សវនាការបណ្តោះអាសន្ន* សវនាការបន្ទាន់ ឬការប្តឹងជំទាស់បន្ទាន់ ដូចមានចែងក្នុងប្រការ 7.4.3) ហាមឃាត់ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត ពីការចូលរួមដោយស្វ័យប្រវត្តិ (ដូចដែលមានចែងក្នុងប្រការ 10.14.1) នៅក្នុងកីឡាទាំងអស់ ក្រោមសិទ្ធិអំណាចរបស់ស្ថាប័នហត្ថលេខីណាមួយ ក្នុងអំឡុងពេលនៃការព្យួរសិទ្ធិបណ្តោះអាសន្ននោះ។

15.1.1.2 សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើ ដែលដាក់ទណ្ឌកម្ម*ព្យួរសិទ្ធិ* (បន្ទាប់ពីសវនាការត្រូវបានធ្វើឡើង ឬត្រូវបានលើកលែង) ហាមឃាត់ដោយស្វ័យប្រវត្តិចំពោះ *អត្តពលិក* ឬ*បុគ្គល*ដទៃទៀតពីការចូលរួមប្រកួត (ដូចដែលមានចែងក្នុងប្រការ 10.14.1) នៅ

92 [សេចក្តីអធិប្បាយចំពោះប្រការ 14.5 ៖ ប្រព័ន្ធគ្រប់គ្រង និងរដ្ឋបាលប្រឆាំង*ដូប៉ា*ត្រូវបានដំណើរការ ចាត់ចែង និងគ្រប់គ្រងដោយទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោក និងត្រូវបានបង្កើតឡើង ដើម្បីឱ្យស្របតាមវិធាន និងច្បាប់ស្តីពីឯកជនភាពទិន្នន័យ ដែលអនុវត្តចំពោះទីភ្នាក់ងារប្រឆាំង*ដូប៉ា*ពិភពលោក និងស្ថាប័នដទៃទៀតដែលប្រើប្រព័ន្ធនេះ។ ព័ត៌មានផ្ទាល់ខ្លួនទាក់ទងនឹងអត្តពលិក ឬបុគ្គលផ្សេងទៀតដែលត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រង និងរដ្ឋបាលប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា នឹងត្រូវបានគ្រប់គ្រងដោយភាពសម្ងាត់បំផុត និងស្របតាមស្តង់ដារអន្តរជាតិសម្រាប់ការការពារឯកជនភាព និងព័ត៌មានផ្ទាល់ខ្លួន។ ]

93 [សេចក្តីអធិប្បាយចំពោះប្រការ 14.6៖ រដ្ឋាភិបាលនីមួយៗគួរដាក់ចេញនូវច្បាប់ បទបញ្ញា គោលនយោបាយ ឬការអនុវត្តរដ្ឋបាលសម្រាប់៖ កិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មានជាមួយ*អង្គការប្រឆាំងដូប៉ា*នានា, ការចែករំលែកទិន្នន័យក្នុងចំណោម*អង្គការប្រឆាំងដូប៉ា* ដូចមានចែងក្នុងក្រម (...)]

ក្នុងកីឡាទាំងអស់ក្រោមសិទ្ធិអំណាចរបស់*ស្ថាប័នហត្ថលេខី*ណាមួយ សម្រាប់រយៈពេលនៃការ*ព្យួរសិទ្ធិ*នោះ។

15.1.1.3 សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើ ដែលទទួលយកការបំពានវិធានប្រឆាំងដូប៉ា នឹងភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិលើ*ស្ថាប័នហត្ថលេខី*ទាំងអស់។

15.1.1.4 សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើក្នុងការដកសិទ្ធិលទ្ធផលប្រកួតតាមប្រការ 10.10 សម្រាប់រយៈពេលជាក់លាក់ណាមួយ នឹងជាការបដិសេធដោយស្វ័យប្រវត្តិចំពោះ*ដកសិទ្ធិលទ្ធផលប្រកួត*ទាំងអស់ ដែលទទួលបានក្នុងសិទ្ធិអំណាចនៃ*ស្ថាប័នហត្ថលេខី*ណាមួយក្នុងអំឡុងពេលដែលបានកំណត់។ [94]

15.1.2 *ស្ថាប័នហត្ថលេខី*នីមួយៗស្ថិតនៅក្រោមកាតព្វកិច្ចនេះត្រូវទទួលស្គាល់ និងអនុវត្តសេចក្តីសម្រេច និងផលប៉ះពាល់របស់វា ដូចដែលបានចែងក្នុងប្រការ 15.1.1 ដោយមិនចាំបាច់មានសកម្មភាពអ្វីបន្ថែមទៀតទេ នៅមុនកាលបរិច្ឆេទដែល *អង្គការប្រឆាំងដូប៉ា*ទទួលបានការជូនដំណឹងជាក់ស្តែង អំពីសេចក្តីសម្រេច ឬកាលបរិច្ឆេទដែលសេចក្តីសម្រេចនោះត្រូវបានដាក់ដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នៅក្នុង*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា*។

15.1.3 សេចក្តីសម្រេចដោយ*អង្គការប្រឆាំងដូប៉ា* ដោយស្ថាប័នជំទាស់ ឬ ដោយ*មជ្ឈត្តកម្មកីឡា* ក្នុងការផ្អាក ឬការលើកលែង *ផលវិបាក* នឹងត្រូវមានសុពលភាពចំពោះ*ស្ថាប័នហត្ថលេខី* ដោយមិនចាំបាច់មានសកម្មភាពបន្ថែមទៀតនៅមុនកាលបរិច្ឆេទដែល *ទីភ្នាក់ងារប្រឆាំងដូប៉ា*ទទួលបានការជូនដំណឹងជាក់ស្តែងអំពីសេចក្តីសម្រេច ឬកាលបរិច្ឆេទដែលសេចក្តីសម្រេចនោះត្រូវបានដាក់នៅក្នុង*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា*។

15.1.4 ទោះបីជាមានបទប្បញ្ញត្តិនៅក្នុងប្រការ 15.1.1 យ៉ាងណាក៏ដោយ សេចក្តីសម្រេចស្តីពីការបំពានវិធានប្រឆាំងដូប៉ាដោយ *ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ* ណាមួយ ដែលបានធ្វើឡើងក្នុងដំណើរការបន្ទាន់ក្នុងអំឡុងពេល *ព្រឹត្តិការណ៍* នឹងមិនត្រូវមានសុពលភាពលើ*ស្ថាប័នហត្ថលេខី*ផ្សេងទៀតទេ ប្រសិនបើវិធានរបស់*ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ* នោះមិនផ្តល់ឱកាសដល់*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដើម្បីប្តឹងជំទាស់ក្រោមនីតិវិធីដែលមិនបន្ទាន់នោះ។

## 15.2 ការអនុវត្តសេចក្តីសម្រេចផ្សេងទៀតដោយ*អង្គការប្រឆាំងដូប៉ា*

*ស្ថាប័នហត្ថលេខី*អាចសម្រេចអនុវត្តសេចក្តីសម្រេចប្រឆាំងដូប៉ាផ្សេងទៀតដែលត្រូវបានផ្តល់ដោយ *អង្គការប្រឆាំងដូប៉ា* ដែលមិនមានចែងក្នុងប្រការ 15.1.1 ខាងលើដូចជា*ការព្យួរសិទ្ធិបណ្តោះអាសន្ន* មុនពេល*សវនាការបណ្តោះ*

94 [សេចក្តីអធិប្បាយចំពោះប្រការ 15.1.4៖ ឧទាហរណ៍ ក្នុងករណីដែលវិធាននៃស្ថាប័នការរៀបចំព្រឹត្តិការណ៍ធំៗ ផ្តល់ជម្រើសឱ្យអត្តពលិក ឬបុគ្គលផ្សេងទៀតជ្រើសរើសដាក់បណ្តឹងឧទ្ធរណ៍រហ័សទៅមជ្ឈត្តកម្មកីឡា ឬបណ្តឹងឧទ្ធរណ៍ទៅមជ្ឈត្តកម្មកីឡា តាមនីតិវិធីមជ្ឈត្តកម្មកីឡា ធម្មតា សេចក្តីសម្រេច ឬការជំនុំជម្រះចុងក្រោយដោយ*ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ*ក៏មានសុពលភាពចំពោះស្ថាប័នហត្ថលេខីផ្សេងទៀតដែរ ដោយមិនគិតអំពីថា តើអត្តពលិក ឬបុគ្គលផ្សេងទៀតជ្រើសរើសជម្រើសបណ្តឹងឧទ្ធរណ៍រហ័ស ឬអត់នោះទេ។ ]

*អាសន្ន* ឬការទទួលយកដោយ*អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត។[95]

### 15.3 ការអនុវត្តសេចក្ដីសម្រេចដោយស្ថាប័នដែលមិនមែន*ស្ថាប័នហត្ថលេខី*

សេចក្ដីសម្រេចប្រឆាំងដូប៉ាដោយស្ថាប័នមិនមែនជា*ស្ថាប័នហត្ថលេខី*នៃ*ក្រម*នេះ នឹងត្រូវអនុវត្តដោយ*ស្ថាប័នហត្ថលេខី*នីមួយៗ ប្រសិនបើ*ស្ថាប័នហត្ថលេខី*នោះយល់ឃើញថាសេចក្ដីសម្រេចនោះ ស្ថិតក្នុងសិទ្ធិអំណាចស្ថាប័ននោះ និងវិធានប្រឆាំងដូប៉ារបស់ស្ថាប័ននោះស្របតាម*ក្រម*។[96]

## ប្រការ 16 ការ*ត្រួតពិនិត្យដូប៉ា* សម្រាប់ការប្រកួតកីឡាសត្វ

16.1. នៅក្នុងកីឡាណាមួយដែលរួមបញ្ចូលសត្វនៅ*ក្នុងការប្រកួត* សហព័ន្ធអន្តរជាតិសម្រាប់កីឡានោះត្រូវ បង្កើត និងអនុវត្តវិធានប្រឆាំងដូប៉ាចំពោះសត្វដែលមាននៅក្នុងកីឡានោះ។ វិធានប្រឆាំងដូប៉ាត្រូវរួមបញ្ចូល*បញ្ជីសារធាតុហាមឃាត់* នីតិវិធី*ធ្វើតេស្ត* សមស្រប និងបញ្ជីឈ្មោះមន្ទីរពិសោធន៍ដែលបានអនុម័តសម្រាប់ការវិភាគ*សំណាក*។

16.2. ទាក់ទងទៅនឹងការកំណត់ការបំពានលើវិធានប្រឆាំងដូប៉ា*ការដោះស្រាយវិវាទដូប៉ា* សវនាការដោយយុត្តិធម៌ *ផលវិបាក* និងការប្ដឹងជំទាស់ចំពោះសត្វដែលពាក់ព័ន្ធនឹងកីឡាសហព័ន្ធអន្តរជាតិសម្រាប់កីឡានោះត្រូវបង្កើត និងអនុវត្តវិធានដែលជាទូទៅស្របនឹង ប្រការ 1 , 2 , 3 , 9 , 10 , 11 , 13 និង 17 នៃ*ក្រម*នេះ។

95 [សេចក្ដីអធិប្បាយចំពោះប្រការ 15.1 និង 15.2៖ សេចក្ដីសម្រេចរបស់*អង្គការប្រឆាំងដូប៉ា*ក្រោមប្រការ 15.1 ត្រូវបានអនុវត្តដោយស្ថាប័នហត្ថលេខីផ្សេងទៀត ដោយស្វ័យប្រវត្តិ ដោយមិនតម្រូវឱ្យមានការសម្រេចចិត្ត ឬសកម្មភាពបន្ថែមដោយស្ថាប័នហត្ថលេខីឡើយ។ ឧទាហរណ៍៖ នៅពេលដែល*អង្គការប្រឆាំង*ការប្រើប្រាស់សារធាតុដូប៉ាជាតិសម្រេចព្យួរសិទ្ធិអត្តពលិកម្នាក់ជាបណ្ដោះអាសន្ន សេចក្ដីសម្រេចនោះត្រូវផ្ដល់សុពលភាពជាស្វ័យប្រវត្តិនៅកម្រិតសហព័ន្ធអន្តរជាតិ។ ដើម្បីឱ្យកាន់តែច្បាស់ "សេចក្ដីសម្រេច" គឺជាការសម្រេចចិត្តរបស់ស្ថាប័នជាតិប្រឆាំងដូប៉ា មិនមានការសម្រេចដាច់ដោយឡែកពីគ្នា ដែលត្រូវធ្វើឡើងដោយសហព័ន្ធអន្តរជាតិឡើយ។ ដូច្នេះ រាល់ការអះអាងរបស់អត្តពលិកដែលថា ការព្យួរសិទ្ធិបណ្ដោះអាសន្នត្រូវបានកំណត់ដោយមិនត្រឹមត្រូវអាចត្រូវបានអះអាងសម្រាប់តែប្រឆាំងនឹងស្ថាប័នជាតិប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាតែប៉ុណ្ណោះ។ ការអនុវត្តការសម្រេចចិត្តរបស់*អង្គការប្រឆាំងដូប៉ា*ក្រោមប្រការ 15.2 គឺជាឆន្ទានុសិទ្ធិរបស់ស្ថាប័នហត្ថលេខីនីមួយៗ។ ការអនុវត្តសេចក្ដីសម្រេចរបស់ស្ថាប័នហត្ថលេខីក្រោមប្រការ 15.1 ឬ ប្រការ 15.2 គឺមិនអាចប្ដឹងឧទ្ធរណ៍ដាច់ដោយឡែកពីបណ្ដឹងឧទ្ធរណ៍ណាមួយនៃសេចក្ដីសម្រេចនេះឡើយ។ វិសាលភាពនៃការទទួលស្គាល់សេចក្ដីសម្រេចលើការលើកលែងឱ្យប្រើជាថ្នាំព្យាបាលរបស់*អង្គការប្រឆាំងដូប៉ា*ដទៃទៀត ត្រូវកំណត់ដោយប្រការ 4.4 និងស្តង់ដារអន្តរជាតិសម្រាប់ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល។ ]

96 [សេចក្ដីអធិប្បាយចំពោះប្រការ 15.3៖ ក្នុងករណីដែលសេចក្ដីសម្រេចរបស់ស្ថាប័នដែលមិនទទួលយកក្រមនេះ ទោះទាក់ទងនឹងការអនុលោម ឬមិនអនុលោមតាមក្រមនេះក៏ដោយ ស្ថាប័នហត្ថលេខីគួរព្យាយាមអនុវត្តសេចក្ដីសម្រេចនេះ ឱ្យស្របតាមគោលការណ៍នៃក្រម។ ឧទាហរណ៍៖ ប្រសិនបើនៅក្នុងដំណើរការមានសង្គតិភាពតាមក្រម ស្ថាប័នមិនមែនចុះហត្ថលេខីបានរកឃើញថាអត្តពលិកម្នាក់បានប្រព្រឹត្តការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ា ដោយសារវត្តមាននៃសារធាតុដូប៉ានៅក្នុងខ្លួនរបស់អត្តពលិក ប៉ុន្តែរយៈពេលនៃការព្យួរសិទ្ធិគឺខ្លីជាងរយៈពេលដែលមានចែងក្នុងក្រម ដូច្នេះស្ថាប័នហត្ថលេខីទាំងអស់គួរទទួលស្គាល់ការរកឃើញនូវការ*បំពាន*លើវិធានប្រឆាំងសារធាតុដូប៉ា ហើយស្ថាប័នប្រឆាំដូប៉ារបស់អត្តពលិកគួរធ្វើសវនាការ ស្របតាមប្រការ 8 ដើម្បីកំណត់ថាតើរយៈពេលនៃការព្យួរសិទ្ធិដែលមានចែងក្នុងក្រមនេះ គួរតែត្រូវបានកំណត់ ឬទេ។ អនុវត្តសេចក្ដីសម្រេចឱ្យ (ឬមិនឱ្យ) អនុវត្តសេចក្ដីសម្រេចរបស់ស្ថាប័នហត្ថលេខីក្រោមប្រការ 15.3 អាចត្រូវបានប្ដឹងឧទ្ធរណ៍នៅក្រោមប្រការ 13 ។ ]

## ប្រការ 17៖ ច្បាប់អាជ្ញាយុកាល

មិនមាននីតិវិធីប្រឆាំងដូប៉ាណាមួយអាចត្រូវបានចាប់ផ្តើមឡើងប្រឆាំងនឹង *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀតបានទេលើកលែងតែ *អត្តពលិក* ឬ *បុគ្គល* ផ្សេងទៀតនោះត្រូវបានជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ដូចមានចែងក្នុងប្រការ 7 ឬការជូនដំណឹងត្រូវបានប៉ុនប៉ងផ្តល់ជូនដោយសមហេតុផលក្នុងរយៈពេលដប់ (10) ឆ្នាំ ចាប់ពីកាលបរិច្ឆេទចោទនៃការប្រកាន់ថាបានបំពាន។



# ផ្នែកទីពីរ

# ការសិក្សា និងស្រាវជ្រាវ

## ប្រការ 18៖ ការអប់រំ

### 18.1. គោលការណ៍

កម្មវិធី*អប់រំ*គឺសំខាន់ណាស់ដើម្បីធានាឱ្យបាននូវកម្មវិធីប្រឆាំងដូប៉ាដែលមានភាពសុខដុមនីយកម្មសម្របសម្រួល និងប្រសិទ្ធភាពនៅកម្រិតអន្តរជាតិ និងកម្រិតជាតិ។ ពួកគេមានបំណងអភិរក្សស្មារតីកីឡា និងការការពារសុខភាពរបស់*អត្តពលិក* និងសិទ្ធិប្រកួតលើទីលានប្រកួតគ្មានសារធាតុដូប៉ាដូចដែលបានពិពណ៌នានៅក្នុងសេចក្តីផ្តើម*ក្រម*នេះ។

កម្មវិធី*អប់រំ*នឹងលើកកម្ពស់ការយល់ដឹងផ្តល់ព័ត៌មានត្រឹមត្រូវ និងអភិវឌ្ឍសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចដើម្បីការពារប្រឆាំងនឹងការបំពានវិធានប្រឆាំងដូប៉ាដោយចេតនា និងអចេតនា និងការបំពានផ្សេងទៀតនៃ*ក្រម*។ កម្មវិធី*អប់រំ* និងការអនុវត្តរបស់ពួកគេត្រូវបង្កើតគុណតម្លៃ និងគោលការណ៍ផ្ទាល់ខ្លួនដែលការពារស្មារតីកីឡា។

*ស្ថាប័នហត្ថលេខី*ទាំងអស់ត្រូវស្ថិតនៅក្នុងវិសាលភាពនៃការទទួលខុសត្រូវរបស់ខ្លួន និងសហការគ្នារៀបចំផែនការ អនុវត្ត តាមដាន វាយតម្លៃ និងលើកកម្ពស់កម្មវិធី*អប់រំ* ស្របតាមតម្រូវការដែលមានចែងក្នុង *ស្តង់ដារអន្តរជាតិ* ស្តីពីការ*អប់រំ*។

### 18.2. កម្មវិធី និងផែនការអប់រំដោយស្ថាប័នហត្ថលេខី

កម្មវិធី*អប់រំ* ដែលមានចែងក្នុង*ស្តង់ដារអន្តរជាតិ*ស្តីពីការអប់រំត្រូវលើកកម្ពស់ស្មារតីកីឡា និងមានឥទ្ធិពលវិជ្ជមាន និងយូរអង្វែងទៅលើការជ្រើសរើសរបស់ *អត្តពលិក* និង*បុគ្គល*ផ្សេងទៀត។

*ស្ថាប័នហត្ថលេខី*ត្រូវបង្កើតផែនកា*អប់រំ* តាមតម្រូវការក្នុង*ស្តង់ដារអន្តរជាតិ*ស្តីពីការអប់រំ។ ការផ្តល់អាទិភាពដល់ក្រុមគោលដៅ ឬសកម្មភាពត្រូវមានភាពត្រឹមត្រូវដោយផ្អែកលើហេតុផលច្បាស់លាស់នៃផែនការ*អប់រំ*។[97]

*ស្ថាប័នហត្ថលេខី*ត្រូវរៀបចំផែនការអប់រំរបស់ខ្លួនដល់*ស្ថាប័នហត្ថលេខី*ផ្សេងទៀត តាមការស្នើសុំដើម្បីចៀសវាងកិច្ចខិតខំប្រឹងប្រែងដែលអាចធ្វើទៅបាន និងដើម្បីគាំទ្រដល់ដំណើរការទទួលស្គាល់ដែលមានចែងក្នុង*ស្តង់ដារអន្តរជាតិ*ស្តីពីការ*អប់រំ*។

កម្មវិធីអប់រំរបស់*អង្គការប្រឆាំងដូប៉ា* ត្រូវរួមបញ្ចូលការយល់ដឹងព័ត៌មានគុណតម្លៃ និងសមាសធាតុ*អប់រំ* ដូចតទៅដែលអាចមាននៅលើគេហទំព័រ។[98]

---

97 [សេចក្តីអធិប្បាយចំពោះប្រការ 18.2៖ ការវាយតម្លៃហានិភ័យដែល*អង្គការប្រឆាំងដូប៉ា*ត្រូវបានតម្រូវឱ្យអនុវត្ត ក្រោមស្តង់ដារអន្តរជាតិសម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត ផ្តល់នូវក្របខ័ណ្ឌទាក់ទងនឹងហានិភ័យនៃ*ដូប៉ា*ក្នុងវិស័យកីឡា។ ការវាយតម្លៃបែបនេះអាចត្រូវបានប្រើ ដើម្បីកំណត់ក្រុមគោលដៅ អាទិភាពសម្រាប់កម្មវិធីអប់រំ។ ទីភ្នាក់ងារប្រឆាំង*ដូប៉ា*ពិភពលោកក៏ផ្តល់នូវធនធានអប់រំសម្រាប់ឱ្យស្ថាប័នហត្ថលេខីប្រើប្រាស់ ដើម្បីគាំទ្រដល់ការផ្តល់កម្មវិធីរបស់ពួកគេផងដែរ។ ]

98 [សេចក្តីអធិប្បាយចំពោះប្រការ 18.2៖ ឧទាហរណ៍ *អង្គការប្រឆាំងដូប៉ា*ជាក់លាក់ណាមួយ ដែលមិនមានគេហទំព័រផ្ទាល់ខ្លួន ព័ត៌មានដែលត្រូវការចាំបាច់អាចត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់គណៈកម្មាធិការជាតិអូឡាំពិករបស់ប្រទេស ឬស្ថាប័នផ្សេងទៀតដែលទទួលខុសត្រូវលើកីឡានៅក្នុងប្រទេស ។ ]

- គោលការណ៍ និងគុណតម្លៃទាក់ទងនឹងកីឡាស្អាតស្អំ
- *អត្តពលិក អត្តពលិកគាំពារបុគ្គលិក* និងសិទ្ធិ និងការទទួលខុសត្រូវរបស់ក្រុមផ្សេងទៀតក្រោម*ក្រមនេះ*
- គោលការណ៍នៃ*ការទទួលខុសត្រូវតឹងរ៉ឹង*
- *ផលវិបាក*នៃការប្រើសារធាតុហាមឃាត់ឧទាហរណ៍សុខភាពរាងកាយ និងផ្លូវចិត្តផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច និងការដាក់ទណ្ឌកម្ម
- ការបំពានលើវិធានប្រឆាំងដូប៉ា
- សារធាតុ និងវិធីសាស្ត្រក្នុង*បញ្ជីហាមឃាត់*
- ហានិភ័យនៃការប្រើប្រាស់បន្ថែម
- *ការប្រើប្រាស់ថ្នាំ* និង *ការព្យាបាលការលើកលែង*
- នីតិវិធី*ធ្វើតេស្ត*រួមមានតេស្តទឹកនោម ឈាម និង *ប្រវត្តិជីវសាស្ត្រអត្តពលិក*
- លក្ខខណ្ឌតម្រូវនៃ *បញ្ជីឈ្មោះធ្វើតេស្ត*រួមទាំងព័ត៌មានអំពីទីសំចត និងការប្រើប្រាស់ *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ។
- និយាយឡើងដើម្បីចែករំលែកកង្វល់អំពីដូប៉ា

18.2.1 ក្រុម*អប់រំ*និងក្រុមគោលដៅបង្កើតឡើងដោយ*ស្ថាប័នហត្ថលេខី*

*ស្ថាប័នហត្ថលេខី* ត្រូវកំណត់ក្រុមគោលដៅរបស់ពួកគេហើយបង្កើតជាបញ្ជី*អប់រំ* ស្របតាមតម្រូវការអប្បបរមាដែលមានចែងក្នុង *ស្តង់ដារអន្តរជាតិស្តីពី**ការអប់រំ*[99]

18.2.2 ការអនុវត្តកម្មវិធី*អប់រំ*ដោយ*ស្ថាប័នហត្ថលេខី*

រាល់ការសកម្មភាពអប់រំដឹកនាំនៅបញ្ជី*អប់រំ*នឹងត្រូវគេបញ្ជូនដោយណ្តុះបណ្តាល និងបានអនុញ្ញាតបុគ្គលយោងទៅតាមតម្រូវការកំណត់នៅក្នុង*ស្តង់ដារអន្តរជាតិស្តី*ពីការ*អប់រំ*។[100]

---

99 [សេចក្តីអធិប្បាយចំពោះប្រការ 18.2.1៖ បញ្ជីអត្តពលិកសម្រាប់ការអប់រំមិនគួរត្រូវបានកំហិតត្រឹមតែចំពោះអត្តពលិកកម្រិតជាតិ ឬអន្តរជាតិទេ ហើយគួររួមបញ្ចូលបុគ្គលទាំងអស់ រួមទាំងយុវជនដែលចូលរួមក្នុងកីឡា ក្រោមអាណាព្យាបាលរបស់ស្ថាប័នហត្ថលេខី រដ្ឋាភិបាល ឬអង្គការកីឡាដទៃទៀត ដែលទទួលអនុវត្តក្រមនេះ។

100 [សេចក្តីអធិប្បាយចំពោះប្រការ 18.2.2៖ គោលបំណងនៃបទប្បញ្ញត្តិនេះគឺដើម្បីណែនាំពីទស្សនៈរបស់អ្នកអប់រំ។ ការអប់រំនឹងត្រូវផ្តល់ជូនដោយបុគ្គលដែលបានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាព ស្រដៀងនឹងការធ្វើតេស្ត ដែលមានតែមន្ត្រីគ្រប់គ្រង*ដូប៉ា*ដែលទទួលបានការបណ្តុះបណ្តាល និងតែងតាំងប៉ុណ្ណោះដែលអាចធ្វើតេស្តបាន។ ក្នុងករណីទាំងពីរនេះ លក្ខខណ្ឌតម្រូវសម្រាប់បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលគឺដើម្បីការពារអត្តពលិក និងរក្សានូវស្តង់ដារនៃការអនុវត្ត។ ព័ត៌មានលម្អិតបន្ថែមស្តីពីការបង្កើតកម្មវិធីទទួលស្គាល់គុណភាពអប់រំសាមញ្ញសម្រាប់អ្នកអប់រំ ត្រូវបានគូសបញ្ជាក់នៅក្នុងគោលការណ៍ណែនាំគំរូរបស់ទីភ្នាក់ងារប្រឆាំង*ដូប៉ា*ពិភពលោក សម្រាប់ការអប់រំ រួមទាំងឧទាហរណ៍ការអនុវត្តល្អបំផុតនៃអន្តរាគមន៍ដែលអាចអនុវត្តបាន។ ]

### 18.2.3 ការចូលរួម និងសហប្រតិបត្តិការ

*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីគាំទ្រដល់ការអនុវត្ត*ស្តង់ដាអន្តរជាតិ*ស្តីពីការ*អប់រំ* និងធ្វើជាឃ្លាំងកណ្តាលសម្រាប់ផ្តល់ព័ត៌មាន និងការអប់រំធនធានមនុស្ស និង/ឬបង្កើតកម្មវិធីអប់រំដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬ*ស្ថាប័នហត្ថលេខី*។ *ស្ថាប័នហត្ថលេខី* ត្រូវសហការគ្នា និងរដ្ឋាភិបាលដើម្បីសម្របសម្រួលកិច្ចប្រឹងប្រែងរបស់ពួកគេ។

នៅថ្នាក់ជាតិ កម្មវិធី*អប់រំ* ត្រូវសម្របសម្រួលដោយ*អង្គការជាតិប្រឆាំងដូប៉ា*ដោយ ធ្វើការសហការជាមួយសហព័ន្ធកីឡាជាតិរៀងៗខ្លួន គណៈកម្មាធិការជាតិអូឡាំពិកគណៈកម្មាធិការ ជាតិប៉ារ៉ាឡាំពិកជាតិ រដ្ឋាភិបាល និងស្ថាប័ន*អប់រំ*។ ការសម្របសម្រួលនេះនឹងពង្រីកលទ្ធភាពឈានដល់អតិបរមានៃ កម្មវិធី*អប់រំ* នៅទូទាំងកីឡា *អត្តពលិក* និង*អ្នកគាំពារអត្តពលិក* និងកាត់បន្ថយការខិតខំប្រឹងប្រែងទ្វេដង។

កម្មវិធី*អប់រំ* សំដៅលើ*អត្តពលិកកម្រិតអន្តរជាតិ* គឺជាអាទិភាពរបស់*សហព័ន្ធអន្តរជាតិ*។ ការ*អប់រំ* ផ្អែកលើ*ព្រឹត្តិការណ៍* នឹងជាធាតុចាំបាច់នៃកម្មវិធីប្រឆាំងដូប៉ាដែលពាក់ព័ន្ធនឹង *ព្រឹត្តិការណ៍អន្តរជាតិ*។

24.1.10 ប្រសិនបើមាន*ស្ថាប័នហត្ថលេខី*មួយ ដែលមានបំណងដើម្បីបដិសេធការចោទប្រកាន់របស់*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*ដែល*ស្ថាប័នហត្ថលេខី*នេះមិនបានជួបប្រជុំគ្នានៅឡើយទេទាំងអស់នៃលក្ខខណ្ឌទារឱ្យដាក់នៅលើវាហើយដូច្នេះមិនមានសិទ្ធិទទួលនៅឡើយទេដើម្បីជាការធ្វើឱ្យដូចដើមទៅក្នុងបញ្ជីនៃ*ក្រម* *ស្ថាប័នហត្ថលេខី*ដែលជា*ស្ថាប័នហត្ថលេខី* ត្រូវតែណែនាំរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ក្នុងការសរសេរនៅក្នុងម្ភៃ មួយ (21) ថ្ងៃបន្ទាប់ពីខ្លួនបានទទួលការចោទប្រកាន់ពី *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នៅក្នុង*ព្រឹត្តិការណ៍*នោះ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងត្រូវជូនដំណឹងជាផ្លូវការអំពីជំលោះជាមួយ*មជ្ឈតកម្មកីឡា* ហើយវិវាទនឹងត្រូវបានដោះស្រាយដោយនាយកដ្ឋានអាជ្ញាកណ្តាល*មជ្ឈត្តកម្មកីឡា* តាមប្រការ 24.1.6 ដល់ 24.1.8 ។ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងមានបន្ទុកដើម្បីបង្ហាញដល់ក្រុមប្រឹក្សា*មជ្ឈតកម្មកីឡា* ផ្អែកលើតុល្យភាពតក្កិកម្មដែល*ស្ថាប័នហត្ថលេខី* មិនទាន់បំពេញបានគ្រប់ ល័ក្ខខ័ណ្ឌនៃការស្តារឡើងវិញ ដែលបានដាក់លើវាហើយដូច្នេះមិនទាន់មានសិទ្ធិត្រូវបាន*ស្តារឡើងវិញ*ទេ។ យោងតាមសិទ្ធិនៅក្រោមច្បាប់ស្វីសដើម្បីជំទាស់នឹងសេចក្តីសម្រេចរបស់*មជ្ឈតកម្មកីឡា* នៅចំពោះមុខសាលាក្តីសហព័ន្ធស្វីស សេចក្តីសម្រេចរបស់*មជ្ឈតកម្មកីឡា* នឹងត្រូវបញ្ចប់ និងអាចអនុវត្តបានដោយមានប្រសិទ្ធភាពភ្លាមៗ យោងតាម ប្រការ 24.1.9 ។

24.1.11 តម្រូវការផ្សេងៗដែលដាក់លើ*ស្ថាប័នហត្ថលេខី* ដោយ *ក្រម* និង *ស្តង់ដារអន្តរជាតិ* ត្រូវចាត់ថ្នាក់ថា *សំខាន់* ឬជាអាទិភាពខ្ពស់ ឬ*ជាទូទៅ* ស្របតាម*ស្តង់ដារអន្តរជាតិ* សម្រាប់ការអនុលោមតាម *ក្រម* ដោយ*ស្ថាប័នហត្ថលេខី* អាស្រ័យលើសារៈសំខាន់ទាក់ទងរបស់ពួកគេចំពោះការប្រយុទ្ធប្រឆាំងដូប៉ានៅក្នុងកីឡា។ ការចាត់ថ្នាក់នោះនឹងក្លាយជាកត្តាសំខាន់ក្នុងការកំណត់ថាតើផលវិបាកអ្វីខ្លះដែលត្រូវដាក់ក្នុងករណីមានការមិនអនុលោមតាមតម្រូវការទាំងនេះស្របតាមប្រការ 10 នៃ*ស្តង់ដារអន្តរជាតិ* សម្រាប់ការអនុលោមតាម*ក្រម* ដោយ*ស្ថាប័នហត្ថលេខី* ។ *ស្ថាប័នហត្ថលេខី* មានសិទ្ធិជំទាស់នឹងការចាត់ថ្នាក់នៃតំរូវការក្នុងករណីនេះ *មជ្ឈតកម្មកីឡា* នឹងសម្រេចលើការចាត់ថ្នាក់សមស្រប។

24.1.12 *ផលវិបាក*ដូចខាងក្រោមអាចត្រូវបានដាក់ជាលក្ខណៈ*បុគ្គល* ឬសរុបនៅលើ *ស្ថាប័នហត្ថលេខី* ដែលមិនបានគោរពតាម*ក្រម* និង/ឬ*ស្តង់ដារអន្តរជាតិ*ដោយ ផ្អែកលើអង្គហេតុ និងកាលៈទេសៈដាក់លាក់នៃសំណុំរឿង និងបទប្បញ្ញត្តិនៃ ប្រការ 10 នៃ *ស្តង់ដារអន្តរជាតិ* សម្រាប់ការអនុលោមតាម *ក្រម* ដោយ*ស្ថាប័នហត្ថលេខី* ៖

24.1.12.1 ការ*ព្យួរសិទ្ធិ* ឬការដកសិទ្ធិរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*៖

(ក) អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃលក្ខន្តិកៈរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* *អ្នកតំណាងនៃស្ថាប័នហត្ថលេខីដែល* ត្រូវបានគ្រប់គ្រងមិនមានសិទ្ធិក្នុងកំឡុងពេលដាក់លាក់ណាមួយដើម្បីកាន់កាប់ការិយាល័យ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬមុខតំណែងណាមួយជាសមាជិក *ក្រុមប្រឹក្សាភិបាល* ឬ*គណៈកម្មាធិការ*របស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬស្ថាប័នផ្សេងទៀត (រួមទាំងប៉ុន្តែមិនកំណត់ជូនចំពោះ *ក្រុមប្រឹក្សាមូលនិធិ*របស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* គណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការអចិន្ត្រៃយ៍ណាមួយ) (ទោះបីជា *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* អាចអនុញ្ញាតឱ្យ *អ្នកតំណាង* នៃ *ស្ថាប័នហត្ថលេខី* បន្តធ្វើជាសមាជិក ក្រុមអ្នកជំនាញរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ដែលគ្មានប្រសិទ្ធភាពជំនួសក៏ដោយ)។

(ខ) *ស្ថាប័នហត្ថលេខី* ដែលត្រូវបានគ្រប់គ្រងមិនមានសិទ្ធិធ្វើជាម្ចាស់ផ្ទះ*ព្រឹត្តិការណ៍*ណាមួយដែលបានរៀបចំ ឬការសហការរៀបចំ ឬការសហការរៀបចំដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។

(គ) *អ្នកតំណាង*នៃ *ស្ថាប័នហត្ថលេខី*ដែលត្រូវបានគ្រប់គ្រងមិនមានសិទ្ធិចូលរួមក្នុង *កម្មវិធីអង្កេតការណ៍ឯករាជ្យ*របស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬកម្មវិធីផ្សព្វផ្សាយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឬសកម្មភាពផ្សេងទៀតរបស់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ឡើយ។

(ឃ) ការដកមូលនិធិ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ទៅឱ្យ *ស្ថាប័នស្ថាប័នហត្ថលេខី* (ដោយផ្ទាល់ ឬដោយប្រយោល) ទាក់ទងនឹងការអភិវឌ្ឍសកម្មភាព

ជាក់លាក់ ឬការចូលរួមក្នុងកម្មវិធីជាក់លាក់។ និង

(ង) *អ្នកតំណាងនៃស្ថាប័នហត្ថលេខី* ត្រូវបានគ្រប់គ្រងមិនមានសិទ្ធិក្នុងរយៈពេលជាក់លាក់ណាមួយដើម្បីកាន់តំណែង ឬមុខតំណែងជាសមាជិកក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការ ឬស្ថាប័នផ្សេងទៀតនៃ *ស្ថាប័នហត្ថលេខី* ផ្សេងទៀត (ឬសមាជិករបស់ខ្លួន) ឬសមាគម *ស្ថាប័នហត្ថលេខី*។

24.1.12.2 ពិសេសត្រួតពិនិត្យមួយចំនួន ឬទាំងអស់នៃការប្រឆាំងដូប៉ាសកម្មភាពនេះ *ស្ថាប័នហត្ថលេខី* ហួតដល់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ចាត់ទុកថា *ស្ថាប័នហត្ថលេខី* ស្ថិតនៅក្នុងជំហរដើម្បីអនុវត្ត *សកម្មភាពប្រឆាំងដូប៉ា* ក្នុងលក្ខណៈបែបនេះដោយគ្មានការត្រួតពិនិត្យដូចមួយ។

24.1.12.3 ការ *ត្រួតពិនិត្យ* និង/ឬការដណ្ដើមយក *សកម្មភាពប្រឆាំងដូប៉ា* មួយចំនួនរបស់ភ្នាក់ងារស្ថាប័នហត្ថលេខីដោយ *ភាគីទីបីដែលបានយល់ព្រម* ហួតដល់ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ពិចារណាថា *ស្ថាប័នហត្ថលេខី* ស្ថិតនៅក្នុងតួនាទីអនុវត្ត *សកម្មភាពប្រឆាំងដូប៉ា* តាមលក្ខណៈដែលត្រូវអនុវត្តដោយគ្មានវិធានការបែបនេះ៖

(ក) ប្រសិនបើការ មិនអនុលោមតាមច្បាប់ មិនអនុលោមតាមបទបញ្ញា និង/ ឬច្បាប់ទេនោះ *សកម្មភាពប្រឆាំងដូប៉ា* ដែលមានបញ្ហានឹងត្រូវអនុវត្តតាមវិធានដែលអាចអនុវត្តបានផ្សេងទៀត (នៃ *អង្គការប្រឆាំងដូប៉ា* មួយ ឬច្រើនផ្សេងទៀតឧទាហរណ៍សហព័ន្ធអន្តរជាតិ ឬ *អង្គការប្រឆាំងដូប៉ា* ឬ *អង្គការក្នុងតំបន់*) ដែលមានគ្រាប់តាមដូចបានដឹកនាំដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ។ ក្នុងករណីនោះខណៈពេលដែល *សកម្មភាពប្រឆាំងដូប៉ា* (រួមទាំងការ *ធ្វើតេស្ត* និង *ការដោះស្រាយវិវាទដូប៉ា*) នឹងត្រូវបានគ្រប់គ្រងដោយ *ភាគីទីបី* ដែលបានអនុម័តក្រោម និងអនុលោមតាមវិធានដែលអាចអនុវត្តបានផ្សេងទៀតនៅក្នុងការចំណាយរបស់អ្នកមិន *ចុះហត្ថលេខា* លើការចំណាយណាមួយដែលកើតឡើងដោយ *អង្គការប្រឆាំងដូប៉ា* ដែលជាលទ្ធផលនៃការប្រើប្រាស់ច្បាប់របស់ពួកគេក្នុងលក្ខណៈនេះនឹងត្រូវសងដោយ *ស្ថាប័នហត្ថលេខីដែល* មិនគោរពតាម។

(ខ) ប្រសិនបើមិនអាចបំពេញចន្លោះនៅក្នុង *សកម្មភាពប្រឆាំងដូប៉ា* របស់ *ស្ថាប័នហត្ថលេខី* តាមវិធីនេះទេ (ឧទាហរណ៍ដោយសារតែច្បាប់ជាតិហាមឃាត់វា ហើយ *អង្គការ ជាតិប្រឆាំងដូប៉ា* មិនបានធានាការធ្វើវិសោធនកម្មច្បាប់ ឬដំណោះស្រាយផ្សេងទៀតទេ) វាអាចជាវិធានការជំនួសដើម្បីមិនរាប់បញ្ចូល *អត្តពលិក* ដែលនឹងត្រូវបានគ្របដណ្ដប់ដោយ *សកម្មភាពប្រឆាំងដូប៉ា* របស់ *ស្ថាប័នហត្ថលេខី* ពីការចូលរួមក្នុងការប្រកួតកីឡាអូឡាំពិក/ប៉ារ៉ាឡាំពិក/*ព្រឹត្តិការណ៍* ផ្សេងទៀត ដើម្បីការពារសិទ្ធិរបស់ *អត្តពលិក* ស្អាតស្អំ និងរក្សាទំនុកចិត្តពីសាធារណៈ នៅក្នុងភាពសុចរិតនៃការប្រកួតនៅក្នុង *ព្រឹត្តិការណ៍*

ទាំងនោះ។

24.1.12.4 *ការផាកពិន័យ*

24.1.12.5 ការព្យួរ ឬការបាត់បង់សិទ្ធិទទួលបានមូលនិធិខ្លះ ឬទាំងអស់ និង/ឬអត្ថប្រយោជន៍ផ្សេងទៀតពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ ឬគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ ឬ*ស្ថាប័នហត្ថលេខី*ផ្សេងទៀតក្នុងរយៈពេលជាក់លាក់ណាមួយ (ដោយមាន ឬគ្មានសិទ្ធិទទួលបានមូលនិធិ និង/ឬ អត្ថប្រយោជន៍ផ្សេងទៀតសម្រាប់រយៈពេលនោះបន្ទាប់ពីការស្តារឡើងវិញ) ។

24.1.12.6 ការផ្តល់អនុសាសន៍ទៅអាជ្ញាធរសាធារណៈដែលពាក់ព័ន្ធទៅនឹងដកហូតការផ្តល់មូលនិធិ និង/ ឬប្រយោជន៍ផ្សេងទៀតមួយចំនួនផ្សេងទៀត ឬទាំងអស់សាធារណៈ និង/ឬពី*ស្ថាប័នហត្ថលេខី*សម្រាប់រយៈពេលដែលបានបញ្ជាក់មួយ (ដោយមាន ឬគ្មាននៅខាងស្តាំនេះដើម្បីទទួលបានថវិកាបែបនេះ និង/ឬប្រយោជន៍ផ្សេងទៀតសម្រាប់រយៈពេលតាមការ*ស្តារឡើងវិញ*) ។

24.1.12.7 ក្នុងករណីដែល *ស្ថាប័នហត្ថលេខី*ជា*អង្គការជាតិប្រឆាំងដូប៉ា* ឬ*គណៈកម្មាធិការជាតិអូឡាំពិក*ដែលដើរតួជា*អង្គការជាតិប្រឆាំងដូប៉ា* *ប្រទេសរបស់ស្ថាប័នហត្ថលេខី*ដែលត្រូវបានកំណត់ថាគ្មានសិទ្ធិធ្វើជាម្ចាស់ផ្ទះ ឬធ្វើជាសហម្ចាស់ផ្ទះ និង/ឬដើម្បីទទួលបានសិទ្ធិធ្វើជាម្ចាស់ផ្ទះ ឬសហម្ចាស់ផ្ទះ *ព្រឹត្តិការណ៍អន្តរជាតិ* (ឧទាហរណ៍ អូឡាំពិករដូវក្តៅ ប៉ារ៉ាឡាំពិក *ព្រឹត្តិការណ៍របស់ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗផ្សេងទៀត* ការប្រកួតជើងឯកពិភពលោក ការប្រកួតជើងឯកថ្នាក់តំបន់ ឬទ្វីប និង/ឬ*ព្រឹត្តិការណ៍កីឡាអន្តរជាតិ*ផ្សេងទៀត)៖

(ក) ប្រសិនបើសិទ្ធិធ្វើជាម្ចាស់ផ្ទះ ឬធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតជើងឯកពិភពលោក និង/ឬព្រឹត្តិការណ៍អន្តរជាតិ ផ្សេងទៀតត្រូវបានផ្តល់ជូនរួចហើយ ប្រទេសដែលមាន សញ្ជាតិ ជាហត្ថលេខីដែលផ្តល់សិទ្ធិនោះត្រូវតែវាយតម្លៃថាតើវាមានភាពស្របច្បាប់ និងអាចអនុវត្តបានទេក្នុងការដកសិទ្ធិនោះហើយប្រគល់*ព្រឹត្តិការណ៍*នេះ ទៅប្រទេសផ្សេងវិញ។ ប្រសិនបើអាចធ្វើទៅបានតាមច្បាប់ និងអាចអនុវត្តបាននោះ*ស្ថាប័នហត្ថលេខី*នឹងធ្វើដូច្នេះ។

(ខ) *ស្ថាប័នហត្ថលេខី* ត្រូវធានាថាពួកគេមានសិទ្ធិអំណាចស្របតាមលក្ខន្តិកៈ វិធាន និងបទបញ្ញា និង/ ឬកិច្ចព្រមព្រៀងធ្វើជាម្ចាស់ផ្ទះដើម្បីអនុលោមតាមតម្រូវការនេះ (រួមទាំងសិទ្ធិក្នុងកិច្ចព្រមព្រៀងធ្វើជាម្ចាស់ផ្ទះណាមួយ ដើម្បីលុបចោលកិច្ចព្រមព្រៀងដោយគ្មានការពិន័យដែលប្រទេសពាក់ព័ន្ធត្រូវបានគ្រប់គ្រងមិនមានសិទ្ធិធ្វើជាម្ចាស់ផ្ទះ*ព្រឹត្តិការណ៍*) ។

24.1.12.8 ក្នុងករណីដែល ស្ថាប័នហត្ថលេខី គឺជាអង្គការ ជាតិប្រឆាំងដូប៉ា ឬគណៈកម្មាធិការជាតិអូឡាំពិក ឬគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកការមិនអនុញ្ញាតឱ្យ *បុគ្គល* ដូចខាងក្រោមចូលរួម ឬចូលរួមក្នុងព្រឹត្តិការណ៍អូឡាំពិក និងកីឡាប៉ារ៉ាឡាំពិក និង/ឬ *ព្រឹត្តិការណ៍* ជាក់លាក់ផ្សេងទៀតការប្រកួតជើងឯកពិភពលោកតំបន់ ឬការប្រកួតជើងឯកទ្វីប និង/ ឬព្រឹត្តិការណ៍អន្តរជាតិផ្សេងទៀតសម្រាប់រយៈពេលជាក់លាក់ណាមួយ៖

(ក) *គណៈកម្មាធិការជាតិអូឡាំពិក* និង/ឬគណៈកម្មាធិការប៉ារ៉ាឡាំពិកជាតិនៃ *ស្ថាប័នហត្ថលេខី*

(ខ) *អ្នកតំណាង* នៃប្រទេសនោះ និង/ឬ *គណៈកម្មាធិការជាតិអូឡាំពិក* និង/ឬគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកនៃប្រទេសនោះ និង/ ឬ

(គ) *អត្តពលិក* និង *អ្នកគាំពារអត្តពលិកដែល* មានទំនាក់ទំនងជាមួយប្រទេសនោះ និង/ឬជាមួយ *គណៈកម្មាធិការជាតិអូឡាំពិក* និង/ឬជាមួយគណៈកម្មាធិការប៉ារ៉ាឡាំពិកជាតិ គណៈកម្មាធិការ និង/ឬសហព័ន្ធសហព័ន្ធនៃប្រទេសនោះ។

24.1.12.9 ក្នុងករណីដែល *ហត្ថលេខី* គឺជា *សហព័ន្ធអន្តរជាតិ* ការដកជនដូចខាងក្រោមពីការចូលរួមនៅក្នុង ឬចូលរួមក្នុង *ព្រឹត្តិការណ៍កីឡាអូឡាំពិក* និង *ប៉ារ៉ាឡាំពិក* និង/ឬ *ព្រឹត្តិការណ៍* ផ្សេងទៀតសម្រាប់រយៈពេលដែលបានបញ្ជាក់មួយ៖ *តំណាងនៃសហព័ន្ធអន្តរជាតិ* និង/ឬ *អត្តពលិក* និង *អ្នកគាំពារអត្តពលិក* ដែលចូលរួមក្នុងកីឡារបស់សហព័ន្ធអន្តរជាតិ (ឬនៅក្នុងវិញ្ញាសាមួយ ឬច្រើននៃកីឡានោះ)។

24.1.12.10 ក្នុងករណីដែល *ស្ថាប័នចុះហត្ថលេខា* គឺជា *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ*៖

(ក) ការពិនិត្យតាមដានពិសេស ឬការ *ត្រួតពិនិត្យ* ឬសកម្មភាពប្រឆាំងដូប៉ារបស់ *ស្ថាប័នរៀបចំព្រឹត្តិការណ៍ធំៗ* មកអនុវត្តនៅក្នុងព្រឹត្តិការណ៍លើកក្រោយរបស់ខ្លួន និង/ ឬ

(ខ) ការព្យួរ ឬការបាត់បង់សិទ្ធិទទួលបានមូលនិធិ និងអត្ថប្រយោជន៍ផ្សេងទៀតពី និង/ឬការទទួលស្គាល់/សមាជិកភាព/ការឧបត្ថម្ភ (តាមលទ្ធភាព) របស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិសមាគម *គណៈកម្មាធិការជាតិអូឡាំពិក* ឬស្ថាប័នឧបត្ថម្ភផ្សេងទៀត និង/ ឬ

(គ) ការបាត់បង់ការទទួលស្គាល់ *ព្រឹត្តិការណ៍* របស់ខ្លួនថាជាព្រឹត្តិការណ៍ជម្រុះសម្រាប់អូឡាំពិក ឬប៉ារ៉ាឡាំពិក។

24.1.12.11 ការផ្អាកការទទួលស្គាល់ដោយចលនាអូឡាំពិក និង/ឬសមាជិកភាពនៃចលនាប៉ារ៉ាឡាំពិក។

24.1.3 *ផលវិបាក*ផ្សេងទៀត

រដ្ឋាភិបាល និង*ស្ថាប័នហត្ថលេខី* និងសមាគម ហត្ថលេខី អាចដាក់ចេញនូវ*ផលវិបាក*បន្ថែមទៀតក្នុងវង្វង់សិទ្ធិអំណាចរៀងៗខ្លួន ចំពោះការមិនអនុលោមតាម ហត្ថលេខីដែល បានផ្តល់ឱ្យថានេះមិនធ្វើឱ្យខូច ឬដាក់កម្រិតតាមមធ្យោបាយណាដែលមានសមត្ថភាពអនុវត្ត*ផលវិបាក*តាមប្រការ 24.1 នេះឡើយ។

### 24.1 ការត្រួតពិនិត្យការអនុលោមតាមអនុសញ្ញាអន្តរជាតិរបស់អង្គការ*យូណេស្កូ*

ការអនុលោមតាមការប្តេជ្ញាចិត្តដែលបានឆ្លុះបញ្ចាំងនៅក្នុងអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ*នឹងត្រូវបានត្រួតពិនិត្យតាមការកំណត់របស់សន្និសីទភាគីនៃអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ* បន្ទាប់ពីការពិគ្រោះយោបល់ជាមួយរដ្ឋភាគី និង*ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវផ្តល់យោបល់ដល់រដ្ឋាភិបាលស្តីពីការអនុវត្ត *ក្រម*នេះ ដោយ*ស្ថាប័នហត្ថលេខី*ហើយត្រូវផ្តល់យោបល់ដល់*ស្ថាប័នហត្ថលេខី*អំពីការផ្តល់សច្ចាប័នការទទួលយកការយល់ព្រម ឬការចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិរបស់*អង្គការយូណេស្កូ*ដោយរដ្ឋាភិបាល។

## ប្រការ 25 ការកែប្រែ និងការដកចេញ

### 25.1. ការកែប្រែ

25.1.1 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យការវិវត្ត និងការធ្វើឱ្យប្រសើរឡើងនៃ*ក្រម*នេះ។ *អត្តពលិក* និងអ្នកពាក់ព័ន្ធដទៃទៀត និងរដ្ឋាភិបាលនឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងដំណើរការនេះ។

25.1.2 *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ត្រូវផ្តួចផ្តើមការធ្វើវិសោធនកម្ម *ក្រម*នេះ និងត្រូវធានាដំណើរការពិគ្រោះយោបល់ដើម្បីទទួល និងឆ្លើយតបទៅនឹងអនុសាសន៍ និងដើម្បីជួយសម្រួលដល់ការពិនិត្យឡើងវិញ និងការផ្តល់យោបល់ពី *អត្តពលិក* និងអ្នកពាក់ព័ន្ធដទៃទៀត និងរដ្ឋាភិបាលលើការធ្វើវិសោធនកម្មដែលបានណែនាំ។

25.1.3 វិសោធនកម្ម*ក្រម*នឹងបន្ទាប់ពីបានពិគ្រោះយោបល់សមស្របត្រូវបានអនុម័ត ដោយសំឡេងភាគច្រើនពីភាគបីនៃក្រុមប្រឹក្សាភិបាលមូលនិធិរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក រួមទាំងភាគច្រើននៃការទាំងវិស័យសាធារណៈ និងសមាជិកចលនាអូឡាំពិកការបោះឆ្នោតមួយ។ ការធ្វើវិសោធនកម្មត្រូវមានសុពលភាពរយៈពេលបី (បី) ខែបន្ទាប់ពីការយល់ព្រមនេះ។

25.1.4 *ស្ថាប័នហត្ថលេខី*ត្រូវកែប្រែច្បាប់របស់ខ្លួនដើម្បីបញ្ចូល*ក្រម* 2021 នៅ ឬមុនថ្ងៃទី 1 ខែមករាឆ្នាំ 2021 ដែលនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមករាឆ្នាំ 2021 ។ *ស្ថាប័នហត្ថលេខី*ត្រូវអនុវត្តការធ្វើវិសោធនកម្មណាមួយជាបន្តបន្ទាប់ក្នុងការអនុវត្តក្រមក្នុងរយៈពេលមួយ (1) ឆ្នាំនៃការអនុម័តដោយក្រុមប្រឹក្សាភិបាលមូលនិធិ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក*។

25.2 ការដកការទទួលយកក្រម

*ស្ថាប័នហត្ថលេខី* អាចដកការទទួលយក*ក្រម*នេះ បន្ទាប់ពីផ្ដល់ជូន *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* នូវសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សររយៈពេលប្រាំមួយខែអំពីបំណងរបស់ពួកគេក្នុងការដកប្រាក់។*ស្ថាប័នហត្ថលេខី* នឹងមិនត្រូវបានចាត់ទុកថាជាអនុលោមភាពទៀតទេនៅពេលដែលការយល់ព្រមត្រូវបានដក។

## ប្រការ 26៖ ការបកស្រាយក្រម

26.1. អត្ថបទផ្លូវការនៃក្រមនេះនឹងត្រូវបានរក្សាទុកដោយ *ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក* ហើយនឹងត្រូវបោះពុម្ពផ្សាយជាភាសាអង់គ្លេស និងបារាំង។ ក្នុងករណីមានភាពខុសគ្នាណាមួយរវាងអត្ថបទជាភាសាអង់គ្លេស និងភាសាបារាំង ត្រូវយកភាសាអង់គ្លេសជាគោល។

26.2. មតិយោបល់ដែលផ្ដល់សេចក្ដីអធិប្បាយលើបទប្បញ្ញត្តិផ្សេងៗនៃក្រមនេះ ត្រូវយកមកប្រើដើម្បីបកស្រាយ*ក្រម*នេះ។

26.3. *ក្រម*នេះត្រូវបានបកស្រាយជាអត្ថបទឯករាជ្យ និងស្វយ័ត ហើយមិនយោងទៅលើច្បាប់ ឬលក្ខន្តិកៈដែលមានស្រាប់របស់ស្ថាប័នហត្ថលេខី ឬរដ្ឋាភិបាលនោះទេ។

26.4. ចំណងជើងដែលប្រើសម្រាប់ផ្នែក និងប្រការផ្សេងៗនៃក្រមនេះ គឺសម្រាប់តែភាពងាយស្រួលយល់ប៉ុណ្ណោះ ហើយមិនត្រូវចាត់ទុកថាជាផ្នែកនៃខ្លឹមសាររបស់*ក្រម*នេះ ឬប៉ះពាល់ដល់ភាសា តាមរបៀបណាមួយ នៃបទប្បញ្ញត្តិដែលចំណងជើងសំដៅលើនោះទេ។

22.1 នៅពេលដែលពាក្យ "ថ្ងៃ" ត្រូវបានប្រើប្រាស់ក្នុង*ក្រម*ឬ*ស្តង់ដារអន្តរជាតិ*វាមានន័យថាជាថ្ងៃប្រតិទិន លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

22.1 *ក្រម*នេះ នឹងមិនត្រូវអនុវត្តចំពោះបញ្ហាដែលមិនទាន់សម្រេចក្នុងលក្ខណៈប្រតិសកម្មមុនកាលបរិច្ឆេទដែលក្រមនេះត្រូវបានទទួលយកដោយស្ថាប័នស្ថាប័នហត្ថលេខី និងអនុវត្តក្នុងវិធានរបស់ខ្លួនឡើយ។ ទោះយ៉ាងណាក៏ដោយ ការបំពានវិធានប្រឆាំងដូប៉ាមុនការទទួលយកក្រម នឹងបន្តរាប់ជា "ការបំពានលើកទីមួយ" ឬ "ការបំពានលើកទីពីរ" ក្នុងគោលបំណងកំណត់ការដាក់ទណ្ឌកម្មតាមប្រការ 10 ចំពោះការបំពាន ក្រោយការទទួលយកក្រមនេះ។

22.1 គោលបំណង វិសាលភាព និងការរៀបចំកម្មវិធីប្រឆាំងដូប៉ាពិភពលោក និង ក្រម និងឧបសម្ព័ន្ធទី 1 និយមន័យ និងឧបសម្ព័ន្ធទី 2 ឧទាហរណ៍នៃការអនុវត្តប្រការ 10 ត្រូវចាត់ទុកជាផ្នែកសំខាន់នៃក្រមនេះ ។

## ប្រការ 27៖ អន្តរប្បញ្ញត្តិ

27.1 ការអនុវត្តទូទៅនៃក្រម 2021

ក្រម2021នឹងត្រូវអនុវត្តពេញលេញចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2021 ("កាលបរិច្ឆេទមានប្រសិទ្ធភាព") ។

**27.2 មិនមានលក្ខខណៈប្រតិសកម្មទេ លើកលែងតែ ប្រការ 10.9.4 និងប្រការ 17 ឬលុះត្រាតែគោលការណ៍ "Lex Miltor " ត្រូវបានអនុវត្ត**

រាល់ករណីបំពានវិធានប្រឆាំងដូប៉ាំដែលនៅបន្តដំណើរការនៅកាលបរិច្ឆេទចូលជាធរមាន និងករណីបំពានវិធានប្រឆាំងដូប៉ាំណាមួយដែលត្រូវបានចោទក្រោយ កាលបរិច្ឆេទចូលជាធរមាន ដោយផ្អែកលើការបំពានវិធានប្រឆាំងដូប៉ាំ ដែលបានកើតឡើងមុនកាលបរិច្ឆេទចូលជាធរមានត្រូវបានគ្រប់គ្រងដោយវិធានប្រឆាំងដូប៉ាំឯករាជ្យ ដែលចូលជាធរមាននៅពេលមានការចោទប្រកាន់ថាមានការបំពានលើវិធានប្រឆាំងដូប៉ាំ ហើយមិនមែនគ្រប់តាមវិធានប្រឆាំងដូប៉ាំដែលមានចែងនៅក្នុងវិធានប្រឆាំងដូប៉ាំនេះឡើយ លើកលែងតែក្រុមប្រឹក្សាជំនុំជម្រះករណីនេះកំណត់គោលការណ៍ "អនុគ្រោះ" ដែលត្រូវអនុវត្តក្រោមកាលៈទេសៈនៃករណីនេះ។ សម្រាប់គោលបំណងទាំងនេះ រយៈពេលប្រតិសកម្មនៃការបំពានពីអតីតកាលអាចត្រូវបានពិចារណា សម្រាប់គោលបំណងនៃការបំពានច្រើនដងក្រោមប្រការ 10.9.4 និងច្បាប់អាជ្ញាយុកាល ដូចដែលមានចែងក្នុងប្រការ 17 គឺជាវិធាននីតិវិធី មិនមែនជាវិធានឯករាជ្យទេ ហើយគួរត្រូវបានអនុវត្តលក្ខណៈប្រតិសកម្ម រួមជាមួយវិធាននីតិវិធីផ្សេងទៀតទាំងអស់នៅក្នុងវិធានប្រឆាំងដូប៉ាំនេះ (ប៉ុន្តែ ក្នុងលក្ខខណ្ឌដែលថាប្រការ 17 ត្រូវបានអនុវត្តលក្ខណៈប្រតិសកម្ម ប្រសិនបើច្បាប់អាជ្ញាយុកាលមិនទាន់ផុតកំណត់តាមកាលបរិច្ឆេទចូលជាធរមានទេនោះ) ។

**27.3 ការដាក់ពាក្យសុំសេចក្តីសម្រេចដែលបានផ្តល់ឱ្យមុនក្រម 2021**

ទាក់ទងទៅនឹងករណីដែលសេចក្តីសម្រេចចុងក្រោយ រកឃើញថាមានការបំពានវិធានប្រឆាំងដូប៉ាំមុនកាលបរិច្ឆេទចូលជាធរមាន ប៉ុន្តែ *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតកំពុងអនុវត្តរយៈពេលនៃការ*ព្យួរសិទ្ធិ*ត្រឹមកាលបរិច្ឆេទចូលជាធរមាន *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀត អាចស្នើសុំទៅ*អង្គការប្រឆាំងដូប៉ាំ*ផ្សេងទៀត ដែលមានទំនួលខុសត្រូវក្នុង*ការដោះស្រាយវិវាទដូប៉ាំ*ចំពោះការបំពានវិធានប្រឆាំងដូប៉ាំ ដើម្បីឱ្យពិចារណាបន្ធូរបន្ថយរយៈពេលនៃការ*ព្យួរសិទ្ធិ* ក្រោមវិធានប្រឆាំងដូប៉ាំទាំងនេះ។ ពាក្យសុំបែបនេះត្រូវធ្វើមុនពេលផុតកំណត់រយៈពេលនៃការ*ព្យួរសិទ្ធិ*។ សេចក្តីសម្រេចដែលផ្តល់ដោយ*អង្គការប្រឆាំងដូប៉ាំ* អាចត្រូវបានប្តឹងជំទាស់ដោយអនុលោមតាម ប្រការ 13.2 ។ ក្រមឆ្នាំ 2021 នេះមិនត្រូវអនុវត្តចំពោះករណីណាដែលសេចក្តីសម្រេចចុងក្រោយរកឃើញថាមានការបំពានវិធានប្រឆាំងដូប៉ាំ ហើយរយៈពេលនៃការ*ព្យួរសិទ្ធិ* បានផុតកំណត់នោះទេ។

**27.4 ការបំពានជាច្រើនដែលការបំពានដំបូងកើតឡើងមុនថ្ងៃទី 1 ខែមករាឆ្នាំ 2021**

ដើម្បីវាយតម្លៃរយៈពេលនៃការ*ព្យួរសិទ្ធិ*ចំពោះការបំពានជាលើកទី 2 តាមប្រការ 10.9.1 ក្នុងករណីដែលទណ្ឌកម្មចំពោះការបំពានលើកទី 1 ត្រូវបានកំណត់ដោយផ្អែកលើវិធានជាធរមាន មុនកាលបរិច្ឆេទចូលជាធរមាន ត្រូវបានអនុវត្តរយៈពេលនៃការព្យួរសិទ្ធិដែលត្រូវបានវាយតម្លៃចំពោះការបំពានលើកទី 1 ក្នុងករណីដែល*ក្រម*ឆ្នាំ 2021 នេះត្រូវបានអនុវត្ត។

**27.5 ការកែប្រែក្រមបន្ថែម**

ការធ្វើវិសោធនកម្ម*ក្រម* បន្ថែមណាមួយនឹងចូលជាធរមានដូចមានចែងក្នុង ប្រការ 27.1 ។

## 27.6 ការផ្លាស់ប្តូរ*បញ្ជីហាមឃាត់*

ការផ្លាស់ប្តូរ *បញ្ជីហាមឃាត់* និង *ឯកសារបច្ចេកទេស* ទាក់ទងទៅនឹងសារធាតុ ដែលមាននៅក្នុង *បញ្ជីហាមឃាត់* មិនត្រូវ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ អនុវត្តតាមលក្ខណៈប្រតិសកម្មទេ។ ទោះយ៉ាងណាក៏ដោយ ករណីលើកលែងនៅពេលដែល *សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់* ត្រូវបានដកចេញពី *បញ្ជីហាមឃាត់* *អត្តពលិក* ឬ*បុគ្គល*ផ្សេងទៀតដែលកំពុងអនុវត្តរយៈពេល*ព្យួរសិទ្ធិ* ក្នុងករណី*សារធាតុហាមឃាត់* ឬ*វិធីសាស្ត្រហាមឃាត់* ពីមុន អាចអនុវត្តចំពោះ*អង្គការប្រឆាំងដូប៉ា*ផ្សេងទៀតដែលមាន ការទទួលខុសត្រូវលើ*ការដោះស្រាយវិវាទដូប៉ា* ចំពោះការបំពានវិធានប្រឆាំងដូប៉ា ដើម្បីពិចារណាពីកាត់បន្ថយរយៈពេល នៃការ*ព្យួរសិទ្ធិ* សម្រាប់ការដកសារធាតុនោះចេញពី*បញ្ជីហាមឃាត់*។



## ឧបសម្ព័ន្ធ 1

# និយមន័យ

## និយមន័យ

*ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា* ៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ាគឺជាឧបករណ៍គ្រប់គ្រងទិន្នន័យលើអ៊ីនធឺណិត សម្រាប់ការបញ្ចូល ការរក្សា ការចែករំលែក និងការរាយការណ៍ទិន្នន័យ ដែលត្រូវបានបង្កើតឡើងដើម្បីជួយភាគីពាក់ព័ន្ធ និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងប្រតិបត្តិការប្រឆាំងដូប៉ាដោយអនុលោមតាមច្បាប់ការពារទិន្នន័យ។

*ការផ្តល់សារធាតុដូប៉ា៖* ការផ្តល់ ការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការសម្របសម្រួល ឬការចូលរួមក្នុងការប្រើប្រាស់ ឬ ការប៉ុនប៉ងប្រើប្រាស់ ដោយ បុគ្គល ម្នាក់ទៀតនៃសារធាតុ ហាមឃាត់ ឬ វិធីសាស្ត្រហាមឃាត់ ។ ទោះយ៉ាងណាក៏ដោយ និយមន័យនេះនឹងមិនរាប់បញ្ចូលសកម្មភាពពិតប្រាកដរបស់បុគ្គលិកវេជ្ជសាស្ត្រលើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ដែល ត្រូវបានប្រើសម្រាប់គោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬយុត្តិកម្មដែលអាចទទួលយកបានផ្សេងទៀត និងមិនរាប់បញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹង សារធាតុហាមឃាត់ ដែលមិនត្រូវបានហាមឃាត់នៅក្នុង ការធ្វើតេស្តក្រៅការប្រកួតឡើយ លុះត្រាតែកាលៈទេសៈទាំងមូលបង្ហាញថា សារធាតុហាមឃាត់ បែបនេះមិនមែនត្រូវបានប្រើក្នុងគោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬមានគោលបំណងដើម្បីបង្កើនសមត្ថភាពកីឡា។

*លទ្ធផលវិភាគវិជ្ជមាន៖* របាយការណ៍ពីមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ ទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ដែលត្រូវបានអនុម័តដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកផ្សេងទៀត ដែលស្របនឹងស្តង់ដារអន្តរជាតិសម្រាប់មន្ទីរពិសោធន៍ បង្ហាញថានៅក្នុងសំណាកមានវត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាប៉ូលីស ឬសារធាតុបិទបាំង ឬភស្តុតាងនៃការប្រើប្រាស់វិធីសាស្ត្រហាមឃាត់ណាមួយ ។

*លទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ៖* របាយការណ៍ដែលកំណត់ថាជាលទ្ធផលប្រវត្តិជីវសាស្ត្រវិជ្ជមាន ដូចដែលបានពិពណ៌នានៅក្នុងស្តង់ដារអន្តរជាតិជាធរមាន ។

*ស្ថានទម្ងន់ទោស៖* ស្ថានភាពដែលពាក់ព័ន្ធនឹង ឬសកម្មភាពរបស់ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលអាចបង្ហាញហេតុផលអំពីការព្យួរសិទ្ធិមិនត្រឹមត្រូវដែលមានទម្ងន់ធ្ងន់ជាង ការដាក់ទណ្ឌកម្មស្តង់ដារ។ កាលៈទេសៈ និងសកម្មភាពបែបនេះរួមបញ្ចូលទាំង៖ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលបានប្រើ ឬកាន់កាប់សារធាតុហាមឃាត់ច្រើនមុខ ឬវិធីសាស្ត្រហាមឃាត់ផ្សេងៗគ្នា ប្រើ ឬកាន់កាប់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ច្រើនដង ឬបានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាច្រើនដង ឬបុគ្គលធម្មតាទំនងជាទទួលបានផលពីការបង្កើនសមត្ថភាពកីឡាដោយបំពានវិធានប្រឆាំងដូប៉ាលើសពីរយៈពេលនៃការអនុវត្តការព្យួរសិទ្ធិ ឬអត្តពលិក ឬបុគ្គលដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបែបបោកបញ្ឆោត ឬរារាំងដើម្បីជៀសវាងការរកឃើញ ឬការវិនិច្ឆ័យចំពោះការបំពានវិធានប្រឆាំងដូប៉ា ឬ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹង ការធ្វើឱ្យខូចដំណើរការ ក្នុងអំឡុងពេលនៃការដោះស្រាយវិវាទដូប៉ា។ ដើម្បីចៀសវាងការសង្ស័យ ឧទាហរណ៍នៃកាលៈទេសៈ និងការប្រព្រឹត្តដែលបានពិពណ៌នានៅក្នុងឯកសារនេះមិនរួមបញ្ចូលកាលៈទេសៈទាំងអស់ទេ ហើយកាលៈទេសៈ ឬការប្រព្រឹត្តស្រដៀងគ្នាផ្សេងទៀតក៏អាចជាហេតុផលនៃការដាក់ទណ្ឌកម្មដោយព្យួរសិទ្ធិរយៈពេលវែងផងដែរ។

*សកម្មភាពប្រឆាំងដូប៉ា៖* ការអប់រំ និងព័ត៌មានស្តីពីការប្រឆាំងដូប៉ា ផែនការបែងចែកការធ្វើតេស្ត ការថែទាំបញ្ជីឈ្មោះធ្វើតេស្ត ការគ្រប់គ្រងប្រវត្តិជីវសាស្ត្រអត្តពលិក ការធ្វើតេស្ត ការរៀបចំការវិភាគសំណាក ការប្រមូលព័ត៌មានស៊ើបការណ៍ និងការអនុវត្តការស៊ើបអង្កេត ដំណើរការនៃការអនុវត្តការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ការដោះស្រាយវិវាទដូប៉ា ការពិនិត្យតាមដាន និងការពង្រឹងអនុលោមភាពនៃការអនុវត្ត ទណ្ឌកម្ម ដែលបានកំណត់ និងសកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងការប្រឆាំងដូប៉ា ដែលអនុវត្តដោយ ឬក្នុងនាមអង្គការប្រឆាំងដូប៉ា ដូចមានចែងក្នុង ក្រម និង/ ឬ ស្តង់ដារអន្តរជាតិ ។

***អង្គការប្រឆាំងដូប៉ា៖*** ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬស្ថាប័នហត្ថលេខីដែលទទួលខុសត្រូវចំពោះការទទួលយកវិធាន ដើម្បីផ្តួចផ្តើម អនុវត្ត ឬពង្រឹងការអនុវត្តផ្នែកមួយនៃដំណើរការត្រួតពិនិត្យសារធាតុដូប៉ា។ នេះរួមបញ្ចូលទាំងគណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗផ្សេងទៀតដែលធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍កីឡា សហព័ន្ធកីឡាអន្តរជាតិ និងអង្គការប្រឆាំងដូប៉ាជាតិ។

***អត្តពលិក៖*** បុគ្គលណាម្នាក់ដែលចូលរួមប្រកួតកីឡានៅកម្រិតអន្តរជាតិ (ដូចដែលបានកំណត់ដោយសហព័ន្ធកីឡាអន្តរជាតិនីមួយៗ) ឬកម្រិតជាតិ (ដូចដែលបានកំណត់ដោយ អង្គការប្រឆាំងដូប៉ាជាតិនីមួយៗ)។ អង្គការប្រឆាំងដូប៉ា មានធន្ទានុសិទ្ធិក្នុងការអនុវត្តវិធានប្រឆាំងដូប៉ា លើអត្តពលិក ដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ហើយក៏មិនមែនជាអត្តពលិកកម្រិតជាតិ ដើម្បីឱ្យត្រូវតាមនិយមន័យ "អត្តពលិក" ។ ទាក់ទងនឹងអត្តពលិកដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ឬអត្តពលិកកម្រិតជាតិ អង្គការប្រឆាំងដូប៉ាអាចជ្រើសរើស៖ ធ្វើតេស្តមានកំណត់ ឬមិនធ្វើតេស្តទាល់តែសោះ វិភាគសំណាកក្នុងកម្រិតតិចជាងបញ្ជីពេញលេញនៃសារធាតុហាមឃាត់ ទាមទារព័ត៌មានអំពីទីសំចតតិចតួច ឬមិនទាមទារ ឬមិនទាមទារការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលជាមុន។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើមានការបំពានវិធានប្រឆាំងដូប៉ាតាមប្រការ 2.1 ប្រការ 2-3 ឬ 2.5 ការប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាអន្តរជាតិត្រូវបានធ្វើដោយអត្តពលិកណាម្នាក់ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អង្គការប្រឆាំងដូប៉ា អាចសម្រេចប្រើសិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើតេស្តលើអត្តពលិកនោះដែលចូលរួមប្រកួតនៅកម្រិតក្រោមកម្រិតអន្តរជាតិ ឬកម្រិតជាតិនោះ ទណ្ឌកម្មដែលមានចែងនៅក្នុងក្រមនេះ ត្រូវបានអនុវត្ត។ សម្រាប់គោលបំណងនៃប្រការ 2.8 និងប្រការ 2.9 និងសម្រាប់គោលបំណងប្រឆាំងដូប៉ា និងការអប់រំបុគ្គលណាម្នាក់ដែលចូលរួមប្រកួតក្រោមស្ថាប័នហត្ថលេខី រដ្ឋាភិបាល ឬអង្គការកីឡាដទៃទៀតដែលទទួលយក ក្រម នេះ គឺជាអត្តពលិក ។

***ប្រវត្តិជីវសាស្ត្រអត្តពលិក៖*** កម្មវិធី និងវិធីសាស្ត្រនៃការប្រមូល និងបញ្ចូលទិន្នន័យ ដូចដែលបានពិពណ៌នានៅក្នុង ស្តង់ដាអន្តរជាតិសម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត និងស្តង់ដារអន្តរជាតិ សម្រាប់មន្ទីរពិសោធន៍។

***អ្នកគាំពារអត្តពលិក៖*** គ្រូបង្វឹក គ្រូបណ្តុះបណ្តាល អ្នកគ្រប់គ្រងភ្នាក់ងារ បុគ្គលិករបស់ក្រុម មន្ត្រី បុគ្គលិកពេទ្យ បុគ្គលិកជំនួយវេជ្ជសាស្ត្រ ឪពុក ឬម្តាយ ឬបុគ្គលណាមួយផ្សេងទៀត ដែលធ្វើការជាមួយ ព្យាបាល ឬជួយដល់អត្តពលិក ដែលចូលរួមនៅក្នុងការប្រកួត ឬដែលត្រៀមរៀបចំសម្រាប់ការប្រកួត។

***ការប៉ុនប៉ង៖*** ការចូលរួមដោយចេតនាក្នុងការប្រព្រឹត្តដែលបង្កើតបានជាជំហានសំខាន់មួយ ក្នុងការប្រព្រឹត្តដែលបានគ្រោងទុក ដើម្បីឈានដល់ការបំពានវិធានប្រឆាំងដូប៉ា។ ប៉ុន្តែ ក្នុងលក្ខខណ្ឌដែលថា គ្មានការបំពានវិធានប្រឆាំងដូប៉ាណាមួយដែលផ្អែកទាំងស្រុងលើការប៉ុនប៉ងប្រព្រឹត្តការបំពានបំពាននោះទេ ប្រសិនបើបុគ្គលនោះលះបង់ចោលការប៉ុនប៉ង មុនពេលវាត្រូវបានរកឃើញដោយភាគីទីបី ដែលមិនពាក់ព័ន្ធនៅក្នុងការប៉ុនប៉ងនោះ។

***លទ្ធផលមិនធម្មតា៖*** របាយការណ៍ពីមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ដែលអនុម័តដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដែលទាមទារឱ្យមានការស៊ើបអង្កេតបន្ថែម ដូចដែលចែងក្នុងស្តង់ដារអន្តរជាតិសម្រាប់មន្ទីរពិសោធន៍ ឬឯកសារបច្ចេកទេសដែលពាក់ព័ន្ធ មុនពេលនៃការសម្រេចលើលទ្ធផលវិភាគវិជ្ជមាន ។

***ការរកឃើញប្រវត្តិជីវសាស្ត្រមិនល្អ៖*** របាយការណ៍ដែលកំណត់ថាជាការរកឃើញប្រវត្តិជីវសាស្ត្រមិនប្រក្រតី ដូចដែលបានពិពណ៌នានៅក្នុងស្តង់ដារអន្តរជាតិជាធរមាន ។

***មជ្ឈត្តកម្មកីឡា៖*** តុលាការអាជ្ញាកណ្តាលផ្នែកកីឡា។

*ក្រុម៖* ក្រុមប្រឆាំងដូប៉ាពិភពលោក។

*ការប្រកួត៖* ការប្រណាំងប្រជែង ការប្រកួត កីឡាតែមួយ ឬការប្រឡងប្រជែងកីឡាតែមួយ។ ឧទាហរណ៍៖ កីឡាបាល់បោះ ឬការប្រកួតផ្តាច់ព្រ័ត្រនៃការរត់ប្រណាំងកីឡាអូឡាំពិកចម្ងាយ 100 ម៉ែត្រក្នុងវិញ្ញាសាអត្តពលិក។ សម្រាប់ការកួតកីឡាតាមវគ្គ និងការប្រកួតកីឡាដទៃទៀត ដែលរង្វាន់ត្រូវបានផ្តល់ជូនជារៀងរាល់ថ្ងៃ ឬផ្អែកលើមូលដ្ឋានបណ្តោះអាសន្ន ភាពខុសគ្នារវាង ការប្រកួត និង ព្រឹត្តិការណ៍កីឡា នឹងត្រូវបានចែងក្នុងវិធានជាធរមានរបស់សហព័ន្ធកីឡាអន្តរជាតិនោះ។

*ផលវិបាក ("ទណ្ឌកម្ម ")៖* ការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ារបស់អត្តពលិក ឬ បុគ្គលផ្សេងទៀត អាចបណ្តាលឱ្យមានលទ្ធផលមួយ ឬច្រើនដូចខាងក្រោម៖ (ក) ការដកសិទ្ធិ មានន័យថា លទ្ធផលរបស់អត្តពលិក ក្នុងការប្រកួត ឬ ព្រឹត្តិការណ៍កីឡា ជាក់លាក់ណាមួយត្រូវអសុពលភាព និងត្រូវទទួលទណ្ឌកម្មនានា រួមទាំងការដកមេដាយ ពិន្ទុ និងរង្វាន់មកវិញ (ខ) ការព្យួរសិទ្ធិ មានន័យថា អត្តពលិក ឬ បុគ្គលផ្សេងទៀតត្រូវបានហាមឃាត់ដោយសារការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា ក្នុង រយៈពេលជាក់លាក់មួយ ពីការចូលរួមក្នុង ការប្រកួត ណាមួយ ឬសកម្មភាពណាមួយ ឬមូលនិធិ ដូចដែលមានចែងក្នុងប្រការ 10.14 (គ) ការព្យួរសិទ្ធិបណ្តោះអាសន្ន មានន័យថា អត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបានហាមឃាត់ជាបណ្តោះអាសន្នពីការចូលរួមក្នុងការប្រកួតណាមួយ ឬសកម្មភាពណាមួយ មុនពេលមានសេចក្តីសម្រេចចុងក្រោយនៅក្នុងសវនាការ ដែលត្រូវប្រព្រឹត្តទៅតាមប្រការ 8 (ឃ) ទណ្ឌកម្មហិរញ្ញវត្ថុ មានន័យថាការដាក់ទណ្ឌកម្មហិរញ្ញវត្ថុដែលបានកំណត់សម្រាប់ការបំពានវិធានប្រឆាំងដូប៉ា ឬដើម្បីស្តារការចំណាយដែលពាក់ព័ន្ធនឹងការបំពានវិធានប្រឆាំងដូប៉ា និង (ង) ការផ្សព្វផ្សាយជាសាធារណៈមានន័យថាការផ្សព្វផ្សាយ ឬចែកចាយព័ត៌មានដល់សាធារណជនទូទៅ ឬជនដែលក្រៅពីបុគ្គលទាំងឡាយដែលមានសិទ្ធិទទួលបានការជូនដំណឹងជាមុន ស្របតាមប្រការ 14 ។ ក្រុមក្នុងកីឡាជាក្រុមក៏អាចជាកម្មវត្ថុនៃទណ្ឌកម្មផងដែ ឬ ដូចមានចែងក្នុងប្រការ 11 ។

*ផលិតផលមិនស្មោះត្រង់៖* ជាផលិតផលដែលមានសារធាតុហាមឃាត់ ដែលមិនត្រូវបានបង្ហាញនៅលើស្លាកផលិតផល ឬនៅក្នុងព័ត៌មានដែលអាចរកបានតាមការខិតខំសមស្របក្នុងការស្វែងរកលើអ៊ីធឺណែត។

*កម្រិតនៃសេចក្តីសម្រេច៖* តម្លៃនៃលទ្ធផលសម្រាប់កម្រិតកំណត់នៃសារធាតុនៅក្នុងសំណាកមួយដែលលើសកម្រិតលទ្ធផលវិភាគវិជ្ជមាន ដូចដែលបានកំណត់នៅក្នុងស្តង់ដារអន្តរជាតិសម្រាប់មន្ទីរពិសោធន៍។

*ប្រតិភូកម្មភាគីទីបី ៖* បុគ្គលណាម្នាក់ដែលអង្គការប្រឆាំងដូប៉ាផ្ទេរសិទ្ធិលើទិដ្ឋភាពណាមួយនៃកម្មវិធីត្រួតពិនិត្យដូប៉ា ឬកម្មវិធីអប់រំប្រឆាំងដូប៉ា ទាំងភាគីទីបី ឬអង្គការប្រឆាំងដូប៉ា ផ្សេងទៀតដែលធ្វើការប្រមូល សំណាក ឬផ្តល់សេវាកម្ម ត្រួតពិនិត្យសារធាតុដូប៉ាផ្សេងទៀត ឬផ្តល់កម្មវិធីអប់រំប្រឆាំងដូប៉ា សម្រាប់ទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា ឬបុគ្គលដែលបម្រើការជាអ្នកម៉ៅការឯករាជ្យ ដែលផ្តល់សេវាគ្រប់គ្រងសារធាតុដូប៉ាសម្រាប់អង្គការប្រឆាំងដូប៉ា (ឧទាហរណ៍៖ មន្ត្រីត្រួតពិនិត្យសារធាតុដូប៉ាដែលមិនមែនជាបុគ្គលិក ឬអ្នកមើលថែ)។ និយមន័យនេះមិនរាប់បញ្ចូល មជ្ឈតកម្មកីឡាទេ។

*ដកសិទ្ធិ ៖* សូមមើល ទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ា ខាងលើ។

*ត្រួតពិនិត្យដូប៉ា៖* រាល់ជំហាន និងដំណើរការនៃផែនការបែងចែកការធ្វើតេស្តរហូតដល់ការសម្រេចចុងក្រោយលើបណ្តឹងជំទាស់ណាមួយ និងការពង្រឹងការអនុវត្តទណ្ឌកម្ម រួមទាំងជំហាន និងដំណើរការទាំងអស់ដែលស្ថិតក្នុងចន្លោះពេលនោះ រាប់បញ្ចូលទាំងការធ្វើតេស្ត ការស៊ើបអង្កេត ព័ត៌មានអំពីទីសំចត ការលើកលែងឱ្យប្រើជាថ្នាំព្យាបាល ការប្រមូលសំណាក និងការគ្រប់គ្រងការវិភាគរបស់មន្ទីរពិសោធន៍ *ការដោះស្រាយវិវាទដូប៉ា* និងការស៊ើបអង្កេត ឬកិច្ចដំណើរការទាក់ទងទៅនឹងការបំពានប្រការ 10.14 (ស្ថានភាពក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ ឬ ការព្យួរបណ្តោះអាសន្ន)។

***ការអប់រំ៖*** ដំណើរការនៃការរៀនសូត្រដើម្បីពង្រឹងគុណតម្លៃ និងអភិវឌ្ឍឥរិយាបថដែលជំរុញ និងការពារស្មារតីកីឡា និងទប់ស្កាត់ដូប៉ាដោយចេតនា និងដោយអចេតនា។

***ព្រឹត្តិការណ៍៖*** ការប្រកួតកីឡាណាមួយដែលធ្វើឡើងរួមគ្នាក្រោមស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡាតែមួយ( ឧទាហរណ៍៖ ការប្រកួតកីឡាអូឡាំពិក ការប្រកួតជើងឯកពិភពលោកនៃសហព័ន្ធកីឡាអន្តរជាតិ ឬព្រឹត្តិការកីឡា Pan American Games ) ។

***កំឡុងពេលព្រឹត្តិការណ៍៖*** ពេលដែលនៅចន្លោះរវាងការចាប់ផ្ដើម និងចុងបញ្ចប់នៃព្រឹត្តិការណ៍កីឡា ដូចដែលត្រូវបានកំណត់ដោយស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍កីឡា ។

***ទីលានព្រឹត្តិការណ៍៖*** ទីកន្លែងទាំងឡាយណាដែលត្រូវបានកំណត់ដោយស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡា។

***កំហុស៖*** កំហុសគឺបំពានណាមួយលើកាតព្វកិច្ច ឬការខ្វះការយកចិត្តទុកដាក់សមរម្យទៅនឹងស្ថានភាពជាក់លាក់មួយ។ កត្តាដែលត្រូវយកមកពិចារណាក្នុងការវាយតម្លៃកម្រិតកំហុសរបស់អត្តពលិករបស់ ឬបុគ្គលផ្សេងទៀត រួមមានដូចជា បទពិសោធផ្ទាល់ខ្លួនរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ថាតើអត្តពលិក ឬបុគ្គលផ្សេងទៀតគឺបុគ្គលដែលត្រូវបានការពារ ឬទេ ការពិចារណាពិសេសនានាដូចជាការរងរបួស កម្រិតនៃហានិភ័យដែលគួរយល់ដឹងដោយ អត្តពលិក និងកម្រិតនៃការយកចិត្តទុកដាក់ និងការស៊ើបអង្កេត ដែលបានអនុវត្តដោយអត្តពលិក ទាក់ទងទៅនឹងអ្វីដែលគួរត្រូវបានគិតថាជាកម្រិតនៃហានិភ័យ។ ក្នុងការវាយតម្លៃកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតកាលៈទេសៈដែលត្រូវបានពិចារណាត្រូវតែជាក់លាក់ និងពាក់ព័ន្ធ ដើម្បីពន្យល់អត្តពលិក ឬបុគ្គលផ្សេងទៀតពីការអនុវត្តប្រាសចាកពីស្តង់ដារឥរិយាបថដែលបានរំពឹងទុក។ ដូច្នេះ ឧទាហរណ៍ ការពិតថា អត្តពលិកម្នាក់ នឹងបាត់បង់ឱកាសក្នុងការរកប្រាក់បានច្រើនក្នុងអំឡុងពេលនៃការព្យួរសិទ្ធិ ឬការពិតដែលថា អត្តពលិក នៅសល់ពេលខ្លីក្នុងអាជីព ឬពេលវេលានៃប្រតិទិនប្រកួត នឹងមិនមែនជាកត្តាពាក់ព័ន្ធដែលត្រូវពិចារណាក្នុងការបន្ធូរបន្ថយរយៈពេលនៃការព្យួរសិទ្ធិ តាមប្រការ 10.6.1 ឬ ប្រការ 10.6.2 នោះទេ។

***ទណ្ឌកម្មហិរញ្ញវត្ថុ៖*** សូមមើល ទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ា ខាងលើ។

***ក្នុងការប្រកួត៖*** រយៈពេលដែលគិតចាប់ពីម៉ោង 11:59 នាទីនៅថ្ងៃមុនការប្រកួត ដែល អត្តពលិក គ្រោងនឹងចូលរួម រហូតដល់ការបញ្ចប់ ការប្រកួតនោះ និងដំណើរការប្រមូល សំណាកទាក់ទងនឹងការប្រកួតនោះ ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីដែលថា ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អនុម័ត សម្រាប់កីឡាជាក់លាក់ណាមួយ និយមន័យជំនួស ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិផ្តល់នូវយុត្តិកម្មសមហេតុផលថា និយមន័យផ្សេងពីនោះមានភាពចាំបាច់សម្រាប់ការប្រកួតរបស់ខ្លួន ក្រោយពេលមានការអនុម័តបែបនោះពីទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោក និយមន័យជំនួសនឹងត្រូវបានអនុវត្តដោយ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗទាំងអស់សម្រាប់ការប្រកួតជាក់លាក់នោះ។

***កម្មវិធីអ្នកសង្កេតការណ៍ឯករាជ្យ៖*** ក្រុមអ្នកសង្កេតការណ៍ និង/ ឬសវនករក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោក ដែលសង្កេតការ និងផ្តល់ការណែនាំស្តីពី ដំណើរការត្រួតពិនិត្យសារធាតុដូប៉ា មុន ឬក្នុងព្រឹត្តិការណ៍ ជាក់លាក់ណាមួយ និងរាយការណ៍អំពីការសង្កេតរបស់ពួកគេដែលជាផ្នែកមួយនៃកម្មវិធីពិនិត្យតាមដានអនុលោមភាព របស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ។

***កីឡាឯកត្តបុគ្គល៖*** កីឡាណាមួយដែលមិនមែនជាកីឡាជាក្រុម។

***ល្បួរសិទ្ធិ៖*** សូមមើលទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ាខាងលើ។

***ឯករាជ្យភាពស្ថាប័ន៖*** ក្រុមប្រឹក្សាជំនុំជម្រះលើបណ្តឹងជំទាស់ត្រូវមានឯករាជ្យភាពពេញលេញផ្នែកស្ថាប័ន ពីអង្គការប្រឆាំងដូប៉ាដែលទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ា។ ដូច្នេះ ស្ថាប័នទាំងនេះមិនត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាល មិនត្រូវពាក់ព័ន្ធ ឬស្ថិតក្រោមគ្រប់គ្រងរបស់ អង្គការប្រឆាំងដូប៉ាដែល ទទួលខុសត្រូវលើ ការដោះស្រាយវិវាទដូប៉ាឡើយ។

***ព្រឹត្តិការណ៍កីឡាអន្តរជាតិ*** ៖ ជាព្រឹត្តិការណ៍កីឡា ឬការប្រកួតកីឡាណាមួយ ដែលគណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ សហព័ន្ធកីឡាអន្តរជាតិ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ ឬស្ថាប័នរៀបចំកីឡាអន្តរជាតិផ្សេងទៀតជាស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡានោះ ឬតែងតាំងមន្ត្រីបច្ចេកទេសសម្រាប់ ព្រឹត្តិការណ៍កីឡានោះ។

***អត្តពលិកកម្រិតអន្តរជាតិ៖*** អត្តពលិក ដែលចូលរួមប្រកួតកីឡានៅកម្រិតអន្តរជាតិ ដូចដែលបានកំណត់ដោយសហព័ន្ធកីឡាអន្តរជាតិនីមួយៗ ស្របតាម ស្តង់ដារអន្តរជាតិសម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត។ស្តង់ដារមួយដែលត្រូវបានអនុម័តដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីការគាំទ្រក្រមនេះ។ ការអនុលោមតាម ស្តង់ដារអន្តរជាតិ (មិនមែនស្តង់ដារ ឬការអនុវត្ត ឬនីតិវិធីជំនួសផ្សេងទៀត) គឺគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថានីតិវិធីដែលមានចែងក្នុង ស្តង់ដារអន្តរជាតិត្រូវបានអនុវត្តត្រឹមត្រូវ។ស្តង់ដារអន្តរជាតិ ត្រូវរាប់បញ្ចូលទាំង ឯកសារបច្ចេកទេស ដែលត្រូវបានចេញ ដោយអនុលោមតាមស្តង់ដារអន្តរជាតិនោះ ។

***ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ៖*** សមាគមប្រចាំទ្វីបនៃគណៈកម្មាធិការជាតិអូឡាំពិក និងអង្គការពហុកីឡាអន្តរជាតិដទៃទៀត ដែលមានតួនាទីជាស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡាប្រចាំទ្វីប តំបន់ ឬព្រឹត្តិការណ៍កីឡាអន្តរជាតិផ្សេងទៀត។

***សារធាតុបិទបាំង៖*** ជាសមាសធាតុ ក្រុមនៃសមាសធាតុ ឬកត្តាជីវសាស្ត្រដែលបង្ហាញពីការប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់។

***សារធាតុមេតាប៉ូលីស៖*** សារធាតុណាមួយដែលផលិតដោយដំណើរការផ្លាស់ប្តូរជីវសាស្ត្រ។

***កម្រិតនៃការរាយការណ៍អប្បបរមា៖*** កំហាប់ប៉ាន់ស្មាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាប៉ូលី ឬសារធាតុបិទបាំងនៅក្នុងសំណាក ក្រោមកម្រិតដែលមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោក មិនគួររាយការណ៍ថាសំណាកនោះ មានលទ្ធផលវិភាគវិជ្ជមានទេ។

***អនីតិជន៖*** ជាបុគ្គលណាម្នាក់ ដែលមិនទាន់ឈានដល់អាយុដប់ប្រាំបី (18) ឆ្នាំ។

***អង្គការជាតិប្រឆាំងដូប៉ា៖*** ជាអង្គភាពដែលត្រូវបានកំណត់ដោយប្រទេសនីមួយៗថា ជាស្ថាប័នមានសិទ្ធិអំណាច និងទំនួលខុសត្រូវចម្បងក្នុងការអនុម័ត និងអនុវត្តវិធានប្រឆាំងដូប៉ា ដឹកនាំការប្រមូលសំណាក ការដោះស្រាយវិវាទដូប៉ា និងការប្រព្រឹត្តទៅនូវសវនាការកម្រិតជាតិ។ ប្រសិនបើការកំណត់នេះមិនត្រូវបានធ្វើឡើងដោយអាជ្ញាធរសាធារណៈដែលមានសមត្ថកិច្ចទេ អង្គភាពនេះនឹងត្រូវជាគណៈកម្មាធិការជាតិអូឡាំពិករបស់ប្រទេស ឬស្ថាប័នដែលគណៈកម្មាធិការនេះចាត់តាំង។

***ព្រឹត្តិការណ៍កីឡាជាតិ*** ៖ ព្រឹត្តិការណ៍កីឡា ឬការប្រកួតណាមួយ ដែលពាក់ព័ន្ធនឹង អត្តពលិកកម្រិតអន្តរជាតិ ឬកម្រិតជាតិ

ដែលមិនមែនជា ព្រឹត្តិការណ៍កីឡាអន្តរជាតិ ។

***អត្តពលិកកម្រិតជាតិ៖*** អត្តពលិក ដែលចូលរួមប្រកួតកីឡានៅថ្នាក់ជាតិ ដូចដែលបានកំណត់ដោយ អង្គការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាជាតិនីមួយៗ ស្របតាមស្តង់ដាអន្តរជាតិសម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត។

***គណៈកម្មាធិការជាតិអូឡាំពិក៖*** អង្គការដែលទទួលស្គាល់ដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ។ ពាក្យថា គណៈកម្មាធិការជាតិអូឡាំពិក ក៏ត្រូវបញ្ចូលសហព័ន្ធកីឡាជាតិនៅក្នុងប្រទេសទាំងនោះ ដែលសហព័ន្ធកីឡាជាតិត្រូវអនុវត្តការទទួលខុសត្រូវធម្មតារបស់គណៈកម្មាធិការជាតិអូឡាំពិក ក្នុងកិច្ចការប្រឆាំងដូប៉ា។

***គ្មានកំហុស ឬការធ្វេសប្រហែស*** ៖ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលបាន បង្ហាញថា ខ្លួនមិនបានដឹង ឬសង្ស័យ ហើយក្នុងហេតុផលសមស្រប មិនអាចដឹង ឬសង្ស័យ ទោះដោយការប្រុងប្រយ័ត្នខ្ពស់បំផុតក៏ដោយ ថាខ្លួនបាន ប្រើប្រាស់ ឬត្រូវបានផ្តល់ឱ្យ សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ឬមិនបានដឹងថាបានបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា។ លើកលែងតែក្នុងករណី បុគ្គលដែលត្រូវបានការពារ ឬ អត្តពលិកកំសាន្ត ចំពោះការបំពានលើប្រការ 2.1 អត្តពលិក ក៏ត្រូវបង្ហាញផងដែរនូវរបៀបដែល សារធាតុហាមឃាត់ ចូលក្នុងប្រព័ន្ធរាងកាយរបស់អត្តពលិកនោះ។

***គ្មានកំហុសធ្ងន់ធ្ងរ ឬការធ្វេសប្រហែស៖*** អត្តពលិក ឬបុគ្គលផ្សេងទៀតដែលបាន បង្ហាញថា កំហុស ឬការធ្វេសប្រហែសនៅពេលពិនិត្យមើលជារួមនៃកាលៈទេសៈ ហើយពិចារណាលើលក្ខណៈវិនិច្ឆ័យសម្រាប់ភាពគ្មានកំហុសធ្ងន់ធ្ងរ ឬការធ្វេសប្រហែសនោះ មិនធ្ងន់ធ្ងរទាក់ទងទៅនឹងការបំពានវិធានប្រឆាំងដូប៉ា។ លើកលែងតែក្នុងករណីបុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកំសាន្ត ចំពោះការបំពានលើប្រការ 2.1 អត្តពលិកក៏ត្រូវបង្ហាញផងដែរនូវរបៀបដែលសារធាតុហាមឃាត់ចូលក្នុងប្រព័ន្ធរាងកាយរបស់អត្តពលិកនោះ។

***ឯករាជ្យភាពផ្នែកប្រតិបត្តិការ៖*** មានន័យថា (1) សមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិក សមាជិកគណៈកម្មការ ទីប្រឹក្សា និងមន្ត្រីនៃអង្គការប្រឆាំងដូប៉ាដែលមានទំនួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ា ឬស្ថាប័នបុត្រសម្ព័ន្ធរបស់ខ្លួន( ឧទាហរណ៍ ៖ សហព័ន្ធ ឬសហភាពដែលជាសមាជិក) ក៏ដូចជា បុគ្គលដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេត និងក្នុងការធ្វើបុរេវិនិច្ឆ័យលើបញ្ហានោះ មិនអាចត្រូវបានតែងតាំងជាសមាជិក និង/ ឬស្មៀន (ក្នុងករណីដែលស្មៀនបែបនេះពាក់ព័ន្ធនឹងដំណើរការពិចារណា និង/ ឬការព្រាងសេចក្តីសម្រេចណាមួយ) នៃក្រុមប្រឹក្សាជំនុំជម្រះរបស់ អង្គការប្រឆាំងដូប៉ា ការទទួលខុសត្រូវចំពោះ ការដោះស្រាយវិវាទដូប៉ា និង (2) ក្រុមប្រឹក្សាជំនុំជម្រះគឺជាស្ថាប័នដែលមានមូលដ្ឋានសមស្របក្នុងការដំណើរការសវនាការ និងការធ្វើសេចក្តីសម្រេចដោយគ្មានការជ្រៀតជ្រែកពីអង្គការប្រឆាំងដូប៉ា ឬភាគីទីបីណាមួយឡើយ។ គោលបំណងគឺដើម្បីធានាថាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះ ឬបុគ្គលនានាដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះមិនចូលរួមក្នុងការស៊ើបអង្កេត ឬការធ្វើសេចក្តីសម្រេចក្នុងការបន្តរឿងក្តីទេ។

***ក្រៅការប្រកួត៖*** រយៈពេលណាមួយដែលមិនមែននៅក្នុងការប្រកួត។

***អ្នកចូលរួម៖*** អត្តពលិក ឬអ្នកគាំពារអត្តពលិក។

***បុគ្គល៖*** ជារូបវន្តបុគ្គល ឬអង្គការណាមួយ ឬអង្គភាពផ្សេងទៀត។

***ការកាន់កាប់៖*** ការកាន់កាប់ជាក់ស្តែង និងជារូបវន្ត ឬការកាន់កាប់ជាក់ស្តែងតែមិនជារូបវន្ត (ដែលនឹងត្រូវបានរកឃើញតែក្នុងករណីដែលបុគ្គលនោះមានការគ្រប់គ្រងផ្តាច់មុខ ឬមានបំណងគ្រប់គ្រងលើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់

ឬបរិវេណដែលមានសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់) ក្នុងលក្ខខណ្ឌដែលថាប្រសិនបើបុគ្គលនោះមិនមានការគ្រប់គ្រងផ្ដាច់មុខលើធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ឬបរិវេណដែលមានសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់នោះទេ ការកាន់កាប់ជាក់ស្ដែងតែមិនជារូបវន្ត អាចត្រូវបានរកឃើញ លុះត្រាតែបុគ្គលនោះបាន ដឹងអំពីវត្តមាននៃសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ និងមានបំណងធ្វើការគ្រប់គ្រងលើវា។ ក្នុងលក្ខខណ្ឌដែលថា គ្មាការបំពានវិធានប្រឆាំងដូប៉ាណាមួយ ដែលផ្អែកលើតែការកាប់កាប់មួយមុខនោះទេ ប្រសិនបើ មុនពេលទទួលបានការជូនដំណឹងអំពីការប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាប្រភេទណាមួយ បុគ្គលនោះបានចាត់វិធានការជាក់ស្ដែងដែលបង្ហាញថា បុគ្គលនោះ មិនដែលមានបំណងកាន់កាប់ និងបានប្រកាសបោះបង់ការកាន់កាប់នោះច្បាស់លាស់ទៅអង្គការប្រឆាំងដូប៉ា ។ ទោះជាមានអ្វីផ្ទុយពីនិយមន័យនេះក៏ដោយការទិញ (រួមបញ្ចូលទាំងតាមមធ្យោបាយអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀត) នៃសារធាតុហាមឃាត់ ឬ វិធីសាស្ត្រហាមឃាត់ ត្រូវបានចាត់ទុកថាជាការកាន់កាប់របស់បុគ្គលដែលធ្វើការទិញនោះ។

***បញ្ជីហាមឃាត់ ៖*** បញ្ជីដែលសម្គាល់នូវសារធាតុហាមឃាត់ និង វិធីសាស្ត្រហាមឃាត់ ។

***វិធីសាស្ត្រហាមឃាត់៖*** វិធីសាស្ត្រណាមួយដែលត្រូវបានពិពណ៌នានៅក្នុងបញ្ជីហាមឃាត់ ។

***សារធាតុហាមឃាត់៖*** សារធាតុណាមួយ ឬប្រភេទណាមួយនៃសារធាតុដែលត្រូវបានពិពណ៌នានៅក្នុងបញ្ជីហាមឃាត់ ។

***បុគ្គលដែលត្រូវបានការពារ៖*** អត្តពលិក ឬរូបវន្តបុគ្គលផ្សេងទៀតដែលនៅពេលមានការបំពានវិធានប្រឆាំងការប្រើប្រាស់សារធាតុដូប៉ា៖ (i) មិនទាន់មានដល់អាយុ 16 (ដប់ប្រាំមួយ) ឆ្នាំ (ii) មិនទាន់មានដល់អាយុ 18 (ដប់ប្រាំបី) ឆ្នាំ និងមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីធ្វើតេស្តណាមួយ ហើយមិនដែលចូលរួមប្រកួតក្នុង ព្រឹត្តិការណ៍កីឡាអន្តរជាតិ នៅក្នុងប្រភេទកីឡាបើកចំហ ឬ (iii) សម្រាប់ហេតុផលផ្សេងក្រៅពីអាយុ ត្រូវបានកំណត់ថាខ្វះសមត្ថភាពផ្នែកច្បាប់ ក្រោមច្បាប់ជាតិជាធរមាន។

***សវនាការបណ្ដោះអាសន្ន៖*** សម្រាប់គោលបំណងនៃប្រការ 7.4.3 សវនាការបន្ទាន់ដែលធ្វើឡើងមុនពេលបើកសវនការក្រោមប្រការ 8 ដែលផ្ដល់ការ ជូនដំណឹងដល់អត្តពលិក និងឱកាសសម្រាប់ផ្ដល់ហេតុផល ទាំងក្នុងទំរង់ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

***ការព្យួរសិទ្ធិបណ្ដោះអាសន្ន៖*** សូមមើលទណ្ឌកម្មនៃការបំពានវិធានប្រឆាំងដូប៉ា ខាងលើ។

***ផ្សព្វផ្សាយជាសាធារណៈ៖*** សូមមើលទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ា ខាងលើ។

***អត្តពលិកកម្សាន្ត៖*** ជារូបវន្តបុគ្គលដែលត្រូវបានកំណត់ថាជារូបវន្តបុគ្គលដោយអង្គការប្រឆាំងដូប៉ាជាតិពាក់ព័ន្ធ ក្នុងលក្ខខណ្ឌដែលថាពាក្យនេះមិនត្រូវរាប់បញ្ចូល បុគ្គលណាម្នាក់ដែលក្នុងរយៈពេលប្រាំឆ្នាំ (5) មុនពេលបំពានវិធានប្រឆាំងដូប៉ានោះ គឺជា អត្តពលិកកម្រិតអន្តរជាតិ (ដូចដែលបានកំណត់ដោយសហព័ន្ធកីឡាអន្តរជាតិនីមួយៗ ស្របតាម ស្តង់ដារអន្តរជាតិ សម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត) ឬអត្តពលិកកម្រិតជាតិ (ដូចដែលបានកំណត់ដោយ អង្គការជាតិប្រឆាំងដូប៉ាជាតិ នីមួយៗ ស្របតាម ស្តង់ដារអន្តរជាតិ សម្រាប់ ការធ្វើតេស្ត និងការស៊ើបអង្កេត) មានតំណាងឱ្យប្រទេសណាមួយនៅក្នុង ព្រឹត្តិការណ៍អន្តរជាតិ នៅក្នុងប្រភេទបើកចំហរ ឬត្រូវបានរួមបញ្ចូលនៅក្នុង បញ្ជីឈ្មោះធ្វើតេស្ត ឬបញ្ជីព័ត៌មានកន្លែងណាផ្សេងទៀតដែលត្រូវបានថែរក្សាដោយសហព័ន្ធអន្តរជាតិ ឬ អង្គការជាតិប្រឆាំងដូប៉ា។

***អង្គការតំបន់ប្រឆាំងដូប៉ា*** ៖ អង្គភាពប្រចាំតំបន់ដែលកំណត់ដោយប្រទេសជាសមាជិកដើម្បីឱ្យសម្របសម្រួល និង

គ្រប់គ្រងតំបន់ជាក់លាក់នៃសិទ្ធិនៃកម្មវិធីប្រឆាំងដូប៉ាជាតិរបស់ពួកគេ ដែលអាចរាប់បញ្ចូលទាំងការអនុម័ត និងការអនុវត្តវិធានប្រឆាំងដូប៉ា ការធ្វើផែនការ និងការប្រមូល សំណាក ការគ្រប់គ្រងលទ្ធផលតេស្ត ការពិនិត្យឡើងវិញនៃការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ការធ្វើសវនាការ និងការអនុវត្តកម្មវិធីអប់រំ នៅថ្នាក់តំបន់។

*បញ្ជីឈ្មោះធ្វើតេស្ត៖* បញ្ជីឈ្មោះអត្តពលិកដែលមានអាទិភាពខ្ពស់បំផុត ត្រូវបាន បង្កើតឡើងដាច់ដោយឡែកនៅកម្រិតអន្តរជាតិដោយសហព័ន្ធកីឡាអន្តរជាតិ និងនៅថ្នាក់ជាតិដោយ អង្គការប្រឆាំងជាតិប្រឆាំងដូប៉ា ដែលជាកម្មវត្ថុនៃការធ្វើតេស្តក្នុងការប្រកួត និងក្រៅការប្រកួតជាក់លាក់ ដែលជាផ្នែកមួយនៃផែនការបែងចែកការធ្វើតេស្តរបស់សហព័ន្ធកីឡាអន្តរជាតិ ឬអង្គការប្រឆាំងដូប៉ា ដូច្នេះហើយចាំបាច់ត្រូវផ្តល់ព័ត៌មានអំពីទីសំចត ដូចដែលមានចែងក្នុងប្រការ 5.5 នៃក្រម និងស្តង់ដារអន្តរជាតិសម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត។

*ការដោះស្រាយវិវាទដូប៉ា៖* ដំណើរការដែលរួមបញ្ចូលទាំងរយៈពេលកំណត់ ចាប់ពីការជូនដំណឹងដូចមានចែងក្នុងប្រការ 5 នៃស្តង់ដារអន្តរជាតិ សម្រាប់ ការដោះស្រាយវិវាទដូប៉ា ឬក្នុងករណីជាក់លាក់មួយចំនួន (ឧទាហរណ៍៖ លទ្ធផលមិនធម្មតាប្រវត្តិជីវសាស្ត្រអត្តពលិក ការខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចត) ជំហានមុនការជូនដំណឹងបែបនេះ ដូចដែលមានចែងក្នុងប្រការ 5 នៃ ស្តង់ដារអន្តរជាតិសម្រាប់ការដោះស្រាយវិវាទដូប៉ា រហូតដល់ការចោទប្រកាន់ និងសេចក្តីសម្រេចចុងក្រោយលើករណីនោះ រួមទាំងការបញ្ចប់ដំណើរការសវនាការនៃរឿងក្តីដំបូង ឬបណ្តឹងជំទាស់ (ប្រសិនបើបណ្តឹងជំទាស់ត្រូវបានដាក់)។

*សំណាក ឬប៉ាន់៖* សម្ភារៈជីវៈសាស្ត្រណាមួយដែលត្រូវបានប្រមូលសម្រាប់គោលបំណងនៃការត្រួតពិនិត្យដូប៉ា។

*ស្ថាប័នហត្ថលេខី៖* អង្គភាពទាំងឡាយដែលទទួលយក ក្រមនេះ ហើយយល់ព្រមអនុវត្ត ក្រម នេះ ដូចមានចែងក្នុងប្រការ 23 នៃក្រមនេះ ។

*វិធីសាស្ត្រដែលបានបញ្ជាក់៖* សូមមើលប្រការ 4.2.2 ។

*សារធាតុជាក់លាក់៖* សូមមើលប្រការ 4.2.2 ។

*ការទទួលខុសត្រូវតឹងរ៉ឹង៖* វិធានដែលចែងថា នៅក្រោមប្រការ 2.1 និងប្រការ 2.2 វាមិនចាំបាច់ដែលថាចេតនា កំហុសការធ្វេសប្រហែស ឬការប្រើប្រាស់ដោយមានការយល់ដឹងរបស់អត្តពលិក ត្រូវបានបង្ហាញដោយអង្គការប្រឆាំងដូប៉ា ក្នុងគោលបំណងបង្កើតបទបំពានវិធានប្រឆាំងដូប៉ា។

*សារធាតុបំពាន៖* សូមមើលប្រការ 4.2.3 ។

*ជំនួយសំខាន់៖* សម្រាប់គោលបំណងនៃប្រការ 10.7.1 បុគ្គលដែលផ្តល់ ជំនួយសំខាន់ ត្រូវតែ៖ (1) បង្ហាញពេញលេញនៅក្នុងសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខា ឬការសម្ភាសន៍ដែលត្រូវបានថតទុក នូវរាល់ព័ត៌មានទាំងអស់ដែលគាត់មាន ទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា ឬដំណើរការផ្សេងទៀត ដូចមានចែងក្នុងប្រការ 10.7.1.1 និង (2) សហការពេញលេញជាមួយការស៊ើបអង្កេត និងការវិនិច្ឆ័យករណី ឬបញ្ហាណាមួយដែលពាក់ព័ន្ធនឹងព័ត៌មាននោះ រួមមានដូចជាការបង្ហាញសក្ខីកម្មនៅឯសវនាការ ប្រសិនបើមានការស្នើពី អង្គការប្រឆាំងដូប៉ា ឬក្រុមប្រឹក្សាជំនុំជម្រះ។ លើសពីនេះទៀត ព័ត៌មានដែលបានផ្តល់ត្រូវតែមានភាពអាចជឿទុកចិត្តបាន ហើយត្រូវតែមានផ្នែកសំខាន់នៃករណី ឬនីតិវិធីដែលត្រូវបានផ្តួចផ្តើម ឬបើគ្មានករណី ឬ ដំណើរការនីតិវិធីណាមួយដែលត្រូវបានផ្តួចផ្តើមឡើងទេ ត្រូវមានមូលដ្ឋានគ្រប់

គ្រាន់ដែលអាចនាំឱ្យមានករណី ឬដំណើរការនីតិវិធីករណី។

***ការធ្វើឱ្យខូចដំណើរការ៖*** ការប្រព្រឹត្តដោយចេតនាដែលធ្វើឱ្យខូចដល់ ដំណើរការត្រួតពិនិត្យសារធាតុដូប៉ា ប៉ុន្តែដែលនឹងមិនត្រូវបានរាប់បញ្ចូលក្នុងនិយមន័យនៃវិធីសាស្ត្រហាមឃាត់។ ការធ្វើឱ្យខូចដំណើរការ រួមបញ្ចូលទាំងការផ្តល់ ឬទទួលសំណូកដើម្បីអនុវត្ត ឬមិនអនុវត្តសកម្មភាពណាមួយ ការរារាំងដល់ការប្រមូលសំណាក ការធ្វើឱ្យប៉ះពាល់ ឬធ្វើឱ្យមិនអាចវិភាគបាននូវសំណាក ការក្លែងបន្លំឯកសារដែលបានបញ្ជូនទៅអង្គការប្រឆាំងដូប៉ា ឬគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ឬក្រុមប្រឹក្សាជំនុំជម្រះ ការផ្តល់សក្ខីកម្មមិនពិតពីសាក្សី ការប្រព្រឹត្តនូវការក្លែងបន្លំណាមួយលើ អង្គការប្រឆាំងដូប៉ា ឬក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីមានឥទ្ធិពលលើការគ្រប់គ្រងលទ្ធផលតេស្ត ឬការដាក់ទណ្ឌកម្ម និងការជ្រៀតជ្រែកដោយចេតនា ឬ ការប៉ុនប៉ងជ្រៀតជ្រែកណាមួយដែលពាក់ព័ន្ធនឹងផ្នែកណាមួយនៃការត្រួតពិនិត្យសារធាតុដូប៉ា។

***ការធ្វើតេស្តគោលដៅ៖*** ការជ្រើសរើសអត្តពលិកជាក់លាក់សម្រាប់ការធ្វើតេស្ត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចដែលមានចែងក្នុងស្តង់ដារអន្តរជាតិសម្រាប់ការធ្វើតេស្ត និងការស៊ើបអង្កេត។

***កីឡាជាក្រុម៖*** កីឡាមួយដែលការជំនួសកីឡាករត្រូវបានអនុញ្ញាតក្នុងពេលប្រកួត ។

***ឯកសារបច្ចេកទេស៖*** ឯកសារណាមួយដែលត្រូវបានទទួលយកទៅអនុវត្ត និងផ្សព្វផ្សាយដោយ ទីភ្នាក់ងារប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាពិភពលោកនៅពេលណាមួយ ដែលមានលក្ខខណ្ឌតម្រូវបច្ចេកទេសចាំបាច់លើប្រធានបទប្រឆាំងដូប៉ាជាក់លាក់ ដូចដែលមានចែងក្នុងស្តង់ដារអន្តរជាតិ។

***ការធ្វើតេស្ត៖*** ផ្នែកខ្លះនៃដំណើរការត្រួតពិនិត្យសារជាតុដូប៉ារួមមានផែនការបែងចែកការធ្វើតេស្ត ការប្រមូលសំណាក ការគ្រប់គ្រងសំណាក និងការដឹកជញ្ជូនសំណាកទៅមន្ទីរពិសោធន៍ជាដើម។

***ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល៖*** ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល អនុញ្ញាតឱ្យអត្តពលិក ដែលមានលក្ខខណ្ឌវេជ្ជសាស្ត្រជាក់លាក់ ប្រើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ប៉ុន្តែលុះត្រាតែលក្ខខណ្ឌ ដូចដែលមានចែងក្នុងប្រការ 4.4 និង ស្តង់ដារអន្តរជាតិ សម្រាប់ ការលើកលែងការប្រើព្យាបាល ត្រូវបានបំពេញប៉ុណ្ណោះ។

***ការជួញដូរ៖*** ការលក់ ការផ្តល់ឱ្យ ការដឹកជញ្ជូន ការផ្ញើ ការប្រគល់ ឬការចែកចាយ (ឬការកាន់កាប់សម្រាប់គោលបំណងបែបនោះ) នូវសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់(ទាំងតាមមធ្យោបាយផ្ទាល់ ឬតាមមធ្យោបាយអេឡិចត្រូនិ ឬមធ្យោបាយណាមួយផ្សេងទៀត) ដោយអត្តពលិក *អ្នកគាំពារអត្តពលិក* ឬបុគ្គលផ្សេងទៀត ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់អង្គភាពប្រឆាំងដូប៉ា ទៅឱ្យភាគីទីបីណាមួយ ក្នុងលក្ខខណ្ឌដែលថានិយមន័យនេះមិនត្រូវរាប់បញ្ចូលសកម្មភាពរបស់បុគ្គលិកវេជ្ជសាស្ត្រដែលប្រើប្រាស់សារធាតុហាមឃាត់ សម្រាប់គោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬយុត្តិកម្មផ្សេងទៀតដែលអាចទទួលយកបាន និងមិនរាប់បញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹង សារធាតុហាមឃាត់ ដែលមិនត្រូវបានហាមឃាត់នៅក្នុងការធ្វើតេស្តក្រៅការប្រកួតទេ លុះត្រាតែកាលៈទេសៈទាំងមូលបង្ហាញថា សារធាតុហាមឃាត់បែបនេះមិនត្រូវបានបម្រុងទុកសម្រាប់គោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬមានគោលបំណងដើម្បីបង្កើនសមត្ថភាពកីឡា។

***អនុសញ្ញាអន្តរជាតិរបស់អង្គការយូណេស្កូ៖*** អនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ាក្នុងវិស័យកីឡា ដែលត្រូវបានអនុម័តនៅក្នុងសម័យប្រជុំលើកទី 33 នៃសន្និសីទទូទៅរបស់អង្គការយូណេស្កូ នៅថ្ងៃទី 19 ខែតុលា ឆ្នាំ 2005 រួមទាំងវិសោធនកម្មណាមួយ និងទាំងអស់ដែលត្រូវបានអនុម័តដោយរដ្ឋភាគីនៃអនុសញ្ញានេះ និងសន្និសីទរបស់រដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិ

ប្រឆាំងដូប៉ាក្នុងវិស័យកីឡា។

***ការប្រើប្រាស់៖*** ការប្រើប្រាស់ ការអនុវត្ត ការលេបចូល ការចាក់បញ្ចូល ឬការស្រូបចូលដោយប្រើមធ្យោបាយណាមួយ នៃសារធាតុ ហាមឃាត់ ឬ វិធីសាស្ត្រហាមឃាត់ ។

***ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក៖*** ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

***កិច្ចព្រមព្រៀងរក្សាសិទ្ធិភាគី៖*** សម្រាប់គោលបំណងនៃប្រការ 10.7.1.1 និងប្រការ 10.8.2 កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាង អង្គការប្រឆាំងដូប៉ា និង អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលអនុញ្ញាតឱ្យ អត្តពលិក ឬបុគ្គលផ្សេងទៀតផ្តល់ព័ត៌មានដល់អង្គការប្រឆាំងដូប៉ា ក្នុងរយៈពេលកំណត់ច្បាស់លាស់ ជាមួយនឹងការយល់ដឹងថា ប្រសិនបើកិច្ចព្រមព្រៀងស្តីពីជំនួយសំខាន់ ឬកិច្ចព្រមព្រៀងដំណោះស្រាយរឿងក្តីមិនត្រូវបានបញ្ចប់ទេនោះ ព័ត៌មានដែលផ្តល់ដោយ អត្តពលិក ឬបុគ្គលផ្សេងទៀត នៅក្នុងបរិបទជាក់លាក់នេះ មិនអាចត្រូវបានប្រើប្រាស់ដោយ អង្គការប្រឆាំងដូប៉ា ប្រឆាំងនឹងអត្តពលិក ឬ បុគ្គលផ្សេងទៀតឡើយ នៅក្នុងការដោះស្រាយវិវាទដូប៉ា ណាមួយដែលស្ថិតក្រោម ក្រម នេះ ហើយព័ត៌មានដែលផ្តល់ដោយ អង្គការប្រឆាំងការប្រើប្រាស់សារជាតុដូប៉ា ក្នុងបរិបទជាក់លាក់នេះមិនអាចត្រូវបានប្រើដោយ អត្តពលិក ឬ បុគ្គលផ្សេងទៀតប្រឆាំងនឹង អង្គការប្រឆាំងដូប៉ា នៅក្នុងនីតិវិធី ការដោះស្រាយវិវាទដូប៉ា ណាមួយឡើយ នៅក្រោមក្រមនេះ ។ កិច្ចព្រមព្រៀងបែបនេះមិនត្រូវហាមឃាត់អង្គភាពប្រឆាំងដូប៉ា អត្តពលិក ឬបុគ្គលផ្សេងទៀតពី ការប្រើប្រាស់ព័ត៌មាន ឬភស្តុតាងណាមួយដែលប្រមូលបានពីប្រភពណាមួយ ក្រៅពីក្នុងកំឡុងពេលជាក់លាក់ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងឡើយ។

**និយមន័យជាក់លាក់ចំពោះប្រការ 24.1**

***ស្ថានទម្ងន់ទោស៖*** ពាក្យនេះរួមបញ្ចូលការប៉ុនប៉ងចេតនាដើម្បីចៀសវាង ឬធ្វើឱ្យអន្តរាយដល់ ក្រម ឬ ស្តង់ដារអន្តរជាតិ និង/ ឬធ្វើឱ្យខូចប្រព័ន្ធប្រឆាំងដូប៉ាការប៉ុនប៉ងបិទបាំងការមិនគោរពច្បាប់ ឬទម្រង់អាក្រក់ណាមួយផ្សេងទៀត ស្ថាប័នហត្ថលេខី នៅក្នុងសំណួរ; ការបដិសេធ ឬការបរាជ័យជាប់លាប់ដោយ ស្ថាប័នហត្ថលេខី ក្នុងការខិតខំប្រឹងប្រែងសមហេតុផលណាមួយដើម្បីកែតម្រូវការ មិនអនុលោមតាម ដែលត្រូវបានជូនដំណឹងដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ធ្វើបានម្តងទៀត; និងកត្តាផ្សេងទៀតដែលធ្វើឱ្យការមិនអនុលោមតាម របស់ស្ថាប័នហត្ថលេខីកាន់តែធ្ងន់ធ្ងរឡើង។

***ភាគីទីបីដែលមានការយល់ព្រម៖*** បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័នមិនមែនហត្ថលេខី អង្គការប្រឆាំងដូប៉ា និង/ ឬភាគីទីបីមួយ ឬច្រើនដែលត្រូវបានជ្រើសរើស ឬអនុម័តដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីត្រួតពិនិត្យ ឬការកាន់កាប់ ឬរ៉ាប់រងសកម្មភាពប្រឆាំងដូប៉ាមួយចំនួន ឬទាំងអស់របស់ស្ថាប័នហត្ថលេខីនេះ។ ជាជម្រើសចុងក្រោយ ប្រសិនបើគ្មានស្ថាប័នសមស្របផ្សេងទៀតនោះទេ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចអនុវត្តមុខងារនេះដោយខ្លួនឯង។

***សំខាន់៖*** តម្រូវការដែលត្រូវបានចាត់ទុកថាមាន សារៈសំខាន់ ចំពោះការប្រយុទ្ធប្រឆាំងនឹងសារជាតុហាមឃាត់នៅក្នុងកីឡា។ សូមមើលឧបសម្ព័ន្ធ ក បន្ថែមទៀតនៃ *ស្តង់ដារអន្តរជាតិ* សម្រាប់ការអនុលោមតាមក្រមដោយអ្នកហត្ថលេខី។

***ការផាកពិន័យ៖*** ការទូទាត់ដោយស្ថាប័នហត្ថលេខី លើចំនួនទឹកប្រាក់ដែលឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃកត្តាមិនអនុលោមតាមច្បាប់/ ស្ថានទម្ងន់ទោស រយៈពេលរបស់វា និងតម្រូវការដើម្បីរារាំងការប្រព្រឹត្តស្រដៀងគ្នានាពេលអនាគត ក្នុងករណីដែលមិនពាក់ព័ន្ធនឹងការមិនអនុលោមតាមលក្ខខណ្ឌតម្រូវណាមួយសំខាន់មួយ ការផាកពិន័យមិនត្រូវលើសពីទាបនៃ (ក) 10% នៃការចំណាយថវិកាប្រចាំឆ្នាំសរុបស្ថាប័នហត្ថលេខីរបស់; និង (ខ) 10 ម៉ឺនដុល្លារអាមេរិក វិចិត្រនេះនឹងត្រូវបានអនុ

វត្តដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក សកម្មភាពបន្ថែមទៀតដើម្បីផ្តល់ហិរញ្ញវត្ថុអនុលោមតាមច្បាប់ការត្រួតពិនិត្យក្រម និង/ឬការប្រឆាំងដូប៉ាអប់រំ និង/ឬស្រាវជ្រាវប្រឆាំងដូប៉ា។

***ទូទៅ៖*** តម្រូវការមួយដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ចំពោះការប្រយុទ្ធប្រឆាំងដូប៉ាក្នុងកីឡាប៉ុន្តែមិនធ្លាក់ចូលក្នុងប្រភេទ សំខាន់ ឬអាទិភាពខ្ពស់ឡើយ។ សូមមើលឧបសម្ព័ន្ធ ក បន្ថែមទៀតនៃ ស្តង់ដារអន្តរជាតិ សម្រាប់ការអនុលោមតាមក្រុមដោយស្ថាប័នហត្ថលេខី។

***អាទិភាពខ្ពស់៖*** តម្រូវការមួយដែលត្រូវបានគេចាត់ទុកថាមាន អាទិភាពខ្ពស់ ប៉ុន្តែមិន សំខាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងសារធាតុហាមឃាត់នៅក្នុងកីឡា។ សូមមើលឧបសម្ព័ន្ធ ក បន្ថែមទៀតនៃ ស្តង់ដារអន្តរជាតិ សម្រាប់ការអនុលោមតាម ក្រមដោយស្ថាប័នហត្ថលេខី។

***ការមិនអនុលោម៖*** ក្នុងករណីដែលស្ថាប័នហត្ថលេខីមួយដែលមិនអនុវត្តតាមក្រម និង/ ឬមួយ ឬស្តង់ដារអន្តរជាតិជាច្រើនទៀត និង/ ឬតម្រូវការណាមួយដែលបានកំណត់ដោយគណៈកម្មាធិការប្រតិបត្តិរបស់ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក នោះទេប៉ុន្តែឱកាសដែលបានផ្តល់ឱ្យក្នុងស្តង់ដារអន្តរជាតិសម្រាប់ក្រមការអនុលោមដោយស្ថាប័នហត្ថលេខីដើម្បីកែមិនមែនបាន -ភាពមិនស៊ីចង្វាក់គ្នា/ ការមិនអនុលោមតាមច្បាប់ មិនទាន់ផុតកំណត់នៅឡើយទេដូច្នេះ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មិនទាន់បានចោទប្រកាន់ជាផ្លូវការថា ស្ថាប័នហត្ថលេខី មិនគោរពតាម។

***ការចូលជាធរមានឡើងវិញ៖*** នៅពេលដែល ស្ថាប័នហត្ថលេខី មួយដែលត្រូវបានប្រកាសថាមិនអនុលោមតាម ក្រម និង/ ឬស្តង់ដារអន្តរជាតិ ត្រូវបានប្តេជ្ញាថានឹងកែតម្រូវការមិនអនុលោមតាមច្បាប់ និងបានបំពេញតាមល័ក្ខខ័ណ្ឌផ្សេងទៀតដែលបានកំណត់ស្របតាមប្រការ 11 នៃ ស្តង់ដារអន្តរជាតិ សម្រាប់លេខក្រមការអនុលោមស្ថាប័នហត្ថលេខីសម្រាប់ការឱ្យដោយការឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីនៃ ក្រម ស្ថាប័នហត្ថលេខីត្រាប់តាម (និងមានការធ្វើឱ្យដូចដើមនឹងត្រូវបានបកប្រែទៅតាម)។

***អ្នកតំណាង៖*** មន្ត្រីនាយកមន្ត្រីសមាជិកជាប់ឆ្នោតនិយោជិត និងសមាជិកគណៈកម្មាធិការនៃ ស្ថាប័នហត្ថលេខី ឬស្ថាប័នផ្សេងទៀតដែលមានបញ្ហាហើយផងដែរ (ក្នុងករណី ដែលអង្គការប្រឆាំងដូប៉ាជាតិ ឬ គណៈកម្មាធិការជាតិអូឡាំពិក ដើរតួជាអង្គការជាតិប្រឆាំងដូប៉ា) តំណាង រដ្ឋាភិបាលនៃប្រទេសនៃ អង្គការជាតិប្រឆាំងដូប៉ា ឬ គណៈកម្មាធិការជាតិអូឡាំពិក ។

***ការឃ្លាំមើលពិសេស៖*** ជាផ្នែកមួយនៃទណ្ឌកម្មដែលបានដាក់លើ ស្ថាប័នហត្ថលេខី ដែលមិនអនុលោម ក្នុងករណីដែលទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអនុវត្តប្រព័ន្ធត្រួតពិនិត្យជាក់លាក់ និងជាបន្ត ចំពោះសកម្មភាពប្រឆាំងដូប៉ារបស់ស្ថាប័នហត្ថលេខី មួយចំនួន ឬទាំងអស់ ដើម្បីធានាថា ស្ថាប័នហត្ថលេខី កំពុងអនុវត្តសកម្មភាពទាំងនោះប្រកបដោយអនុលោមភាព។

***ការត្រួតពិនិត្យ៖*** ដែលជាផ្នែកមួយនៃផលវិបាកដែលបានដាក់លើ ស្ថាប័នហត្ថលេខី ដែលមិនអនុលោមតាមច្បាប់ភាគីទីបីដែលបានអនុម័ត ត្រួតពិនិត្យ និងត្រួតពិនិត្យ សកម្មភាពប្រឆាំងដូប៉ារបស់ស្ថាប័នហត្ថលេខី ដែលដឹកនាំដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយចំណាយរបស់ស្ថាប័នហត្ថលេខី (ហើយការ ត្រួតពិនិត្យ នឹងត្រូវបកស្រាយតាម) ។ ក្នុងករណីដែល ស្ថាប័នហត្ថលេខី ត្រូវបានប្រកាសថាមិនអនុលោម និងមិនទាន់បញ្ចប់កិច្ចព្រមព្រៀង ត្រួតពិនិត្យ ជាមួយភាគីទីបីដែលបានអនុម័ត នោះ ស្ថាប័នហត្ថលេខី នឹងមិនអនុវត្តសកម្មភាពឯករាជ្យ ប្រឆាំងនឹងសារធាតុដូប៉ា ដោយឯករាជ្យនៅក្នុងតំបន់ដែល ភាគីទីបីដែលបានអនុម័តនោះ គឺដើម្បីត្រួតពិនិត្យ និងត្រួតពិនិត្យ ដោយគ្មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនរបស់ ទីភ្នាក់ងារប្រឆាំ*ងដូប៉ាពិភពលោក*

*ការកាន់កាប់៖* ដែលជាផ្នែកមួយនៃផលវិបាកដែលបានដាក់លើ ស្ថាប័នហត្ថលេខី ដែលមិនគោរពតាមភាគីទីបីដែលបានយល់ព្រម នឹងទទួលយក សកម្មភាពប្រឆាំងដូប៉ារបស់ស្ថាប័នហត្ថលេខី ទាំងអស់ ឬខ្លះតាមការណែនាំរបស់ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយចំណាយ របស់ស្ថាប័នហត្ថលេខី។ ក្នុងករណីដែលស្ថាប័នហត្ថលេខីមួយត្រូវបានប្រកាសថាជាការមិនគោរពតាម និងមិនបានបញ្ចប់កិច្ចព្រមព្រៀងទិញយកអាជីវកម្មមួយជាមួយនឹងភាគីទីបីបានអនុម័តនៅឡើយទេ ថាស្ថាប័នហត្ថលេខីមិនត្រូវអនុវត្តដាច់ដោយឡែកពីសកម្មភាពប្រឆាំងដូប៉ាណាមួយនៅក្នុងតំបន់បានថាភាគីទីបីបានអនុម័តនេះគឺដើម្បីយកជាងដោយគ្មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

WORLD ANTI-DOPING AGENCY

play true

wada-ama.org/code